# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

University Royale de Droit et des Sciences Economies

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ទម្រង់ និង អានុភាពនៃមតកសាសន៍

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ៖

និស្សិតឈ្មោះ លោក **យ៉ន ពិសិដ្ឋ**

លោក **វណ្ណ តុលា**

សាស្ត្រាចារ្យណែនាំ៖

លោក **ញឹក វុធ្ធី**


ថ្នាក់បរិញ្ញាបត្រ៖ **នីតិសាស្ត្រ**

ជំនាន់៖ ២២

ឆ្នាំសិក្សា៖ ២០១៨

ឆ្នាំសរសេរសារណា៖ ២០២២

# សេចក្តីថ្លែងអំណរគុណ

ក្នុងនាមក្រុមខ្ញុំបាទជាសិស្សនិស្សិតឆ្នាំសិក្សា ២០២១-២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយបានសម្រេចនូវការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ទៅលើប្រធានបទ **ទម្រង់ និង អានុភាពនៃមតកសាសន៍** បានបញ្ចប់ដោយជោគជ័យជាស្ថាពរ ។

ក្នុងន័យនេះ ខ្ញុំបាទ និង មិត្តរួមក្រុម សូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖

- មាតាបិតា ដែលលោកបានផ្តល់កំណើត ថែទាំ ថែមទាំងជួយផ្គត់ផ្គង់ ជ្រោមជ្រែង ឧបត្ថមទាំងសម្ភារៈ និងថវិកា ព្រមទាំងជំរុញលើកទឹកចិត្ត ឱ្យខ្ញុំបាទបានសិក្សារៀនសូត្រក្រេបជញ្ជក់យកចំណេះដឹង ដើម្បីក្លាយជាពលរដ្ឋល្អក្នុងការជួយដល់សង្គមឱ្យមានការរីកចម្រើន។
- មិត្តរួមក្រុម ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការសហការដើម្បីធ្វើការស្រាវជ្រាវយ៉ាងម៉ត់ចត់ទៅលើប្រធានបទមួយនេះហើយបានចូលរួមបញ្ចេញមតិ រួមទាំងបានផ្តល់ចំណេះដឹងអោយគ្នាទៅវិញទៅមកយ៉ាងជិតស្និតដោយមិនគិតពីការនឿយហត់ ទើបសម្រេចបានជាកម្រងឯកសារមួយនេះ ។
- លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំយកចិត្តទុកដាក់ក្នុងការបង្ហាត់បង្រៀន និង អប់រំទូន្មាន ដល់និស្សិតអោយមានចំណេះជំនាញយល់ដឹងទាំងទ្រឹស្តី និង ការអនុវត្តក្នុងគោលដៅដើម្បីអោយមានសមត្ថភាពប្រកបវិជ្ជាជីវផ្នែកច្បាប់ និង ចូលរួមជួយអភិវឌ្ឍសង្គមអោយប្រកបទៅដោយចីរភាព និង និរន្តរភាព។
- ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង និង សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំដឹកនាំ និង គ្រប់គ្រងក្នុងគោលបំណងបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីក្លាយជាសសរទ្រូងប្រទេស ។
- សាស្ត្រាចារ្យ **ញឹក ឌុធ្ធី** ដែលជាសាស្ត្រាចារ្យបង្រៀនមុខវិជ្ជា **នីតិឯកជន** និង ជាគ្រូដឹកនាំក្នុងការសរសេរសារណានេះផ្ទាល់ ដែលលោកបានយកចិត្តទុកដាក់ក្នុងផ្តល់ជាមតិយោបល់ កែលម្អទៅលើកម្រងឯកសារ ថែមទាំងបានជួយលើកទឹកចិត្ត និង ផ្តល់នូវដំបូន្មានល្អៗដល់ក្រុមខ្ញុំបាទ ។

ជាទីបញ្ចប់ ខ្ញុំបាទ និងមិត្តរួមក្រុម សូមប្រសិទ្ធពរជ័យ សិរីសួរស្តី វិបុលសុខ បវរមហាប្រសើរដល់លោកអ្នកមានគុណទាំងអស់ទទួលបានជោគជ័យគ្រប់ភារកិច្ច និង សុខភាពរឹងមាំទទួលទានគ្រប់ៗគ្នា ព្រមទាំងពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ការសិក្សាស្រាវជ្រាវ បូករួមទាំងការចងក្រងជាឯកសារបានផ្តល់នូវគុណតម្លៃដ៏សំខាន់សម្រាប់បម្រើប្រយោជន៍ដល់សង្គម និង ជាពិសេសដល់អ្នកសិក្សាជំនាន់ក្រោយ ដែលរាល់ការស្រាវជ្រាវសុទ្ធតែជា សមិទ្ធិផល, ស្នាដៃ និង ជាមូលដ្ឋានគ្រឹះសម្រាប់អ្នកអាន ក្នុងការពង្រីកចំណេះដឹង និងពង្រឹងនូវសមត្ថភាពរបស់ខ្លួន ។ ដោយយល់ឃើញដូច្នេះ ក្រោយពីបានសិក្សានូវមុខជំនាញនីតិសាស្ត្រអស់រយៈពេលជិត៤ឆ្នាំ ខ្ញុំបាទ និង មិត្តរួមក្រុមបានសហការគ្នាសម្រេចជ្រើសយកការសរសេរសារណាបញ្ចប់ការសិក្សា ដែលជាឱកាសដ៏ល្អសម្រាប់ខ្ញុំបាទ និង មិត្តរួមក្រុមក្នុងការបញ្ចេញនូវសមត្ថភាព និង ជាការរួមចំណែកចូលរួមពន្លឿនការអភិវឌ្ឍលើវិស័យអប់រំអោយមានភាពទូលំទូលាយ និង រីកចម្រើន ។ ពួកយើងបានយកចិត្តទុកដាក់ក្នុងសិក្សាស្រាវជ្រាវទៅលើនីតិឯកជន ហើយពួកយើងបានយល់ឃើញពីគុណតម្លៃនៃមតកសាសន៍ ដែលជាមូលហេតុញ៉ាំងអោយពួកយើងសម្រេចជ្រើសយកប្រធានបទដែលមានចំណងជើងជាខេមរភាសាថា "**ទម្រង់ និង អានុភាពនៃមតកសាសន៍**" ក្នុងការសរសេរជាសារណា សម្រាប់ទុកជាស្នាដៃ ហើយក៏ជាបទពិសោធន៍ក្នុងការចែករំលែកនូវចំណេះដឹងដល់អ្នកអាន និង ជាពិសេសគឺដល់សិស្សានុសិស្សដែលស្រលាញ់នូវមុខជំនាញនីតិសាស្ត្រអោយមាននូវពុទ្ធិយល់ដឹងទៅលើប្រធានបទមួយនេះ ។

ខ្ញុំបាទ និងមិត្តរួមក្រុមសង្ឃឹម និងជឿជាក់ថានៅក្នុងការស្រាវជ្រាវរបស់ក្រុមខ្ញុំបាទនេះទោះបីជាមានការខិតខំព្យាយាមពិនិត្យផ្ទៀងផ្ទាត់យ៉ាងណាក៏ដោយនៅតែមានការខ្វះខាតខុសឆ្គងខ្លះៗ ដោយអចេតនាជាមិនខាន។ បើពិតដូច្នេះខ្ញុំបាទសូមអភ័យទោសអំពីសំណាក់អស់លោក លោកស្រី និងមិត្តអ្នកអានទុកជាមុននូវរាល់កំហុសឆ្គងទាំងឡាយដែលអាចកើតមានដោយចេតនាក្តី ឬ អចេតនាក្តី និង សូមខន្តីអភ័យទោសដោយការគោរពយ៉ាងស្មោះស្ម័គ្រ ពីសំណាក់ក្រុមរបស់ខ្ញុំបាទ ។ ខ្ញុំបាទ និង មិត្តរួមក្រុមរីករាយ នឹងទទួលស្វាគមន៍នូវរាល់ការរិះគន់បែបស្ថាបនាក្នុងគោលបំណងកែលំអព្រមទាំងស្វាគមន៍ទទួលយកបន្ថែមនូវគំនិតល្អៗ ដើម្បីបំពេញការខ្វះចន្លោះលើខ្លឹមសារនៃសៀវភៅមួយនេះ។

ជាទីបញ្ចប់នេះ ក្រុមខ្ញុំបាទសូមអរគុណចំពោះការចំណាយពេលវេលាដ៏មានតម្លៃក្នុងការអានសមិទ្ធិផលស្នាដៃមួយនេះ និង សូមប្រសិទ្ធពរជ័យដល់មិត្តអ្នកអានទាំងអស់ ដែលជាក្រុមនិស្សិត, លោកគ្រូ អ្នកគ្រូ ក៏ដូចជាប្រជាពលរដ្ឋខ្មែរគ្រប់រូបឱ្យជួបប្រទះតែសំណាងល្អ សុខភាពល្អ និងទទួលបាននូវជោគជ័យនៅក្នុងជីវិតគ្រប់ភារកិច្ច។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........................................................ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃមតកសាសន៍**

**ផ្នែកទី១ ប្រវត្តិនៃមតកសាសន៍** ........................................................ ៤

**កថាភាគទី១ ការកកើតមតកសាសន៍** ........................................................ ៤

១. និយមន័យ ........................................................ ៥

២. អត្ថប្រយោជន៍ ........................................................ ៦

**កថាភាគទី២ ប្រវត្តិនៃមតកសាសន៍នៅកម្ពុជា** ........................................................ ៧

១. ការវិវត្តរបបមតកសាសន៍ក្នុងនីតិវិជ្ជមានកម្ពុជា ........................................................ ៧

២. ការវិវត្តន៍របបមតកសាសន៍កម្ពុជាបច្ចុប្បន្ន ........................................................ ៨

**ផ្នែកទី២ ទិដ្ឋភាពទូទៅនៃមត៌ក** ........................................................ ៩

**កថាភាគទី១ ប្រភេទនៃមត៌ក** ........................................................ ១០

**កថាភាគទី២ កម្មវត្ថុនៃមត៌ក** ........................................................ ១០

១. សិទ្ធិនៃកម្មសិទ្ធិ ........................................................ ១១

២. អាជ្ញាយុកាលលទ្ធកម្មនៃកម្មសិទ្ធិ ........................................................ ១២

៣. សិទ្ធិជួលអចិន្ត្រៃយ៍ ........................................................ ១៣

៤. សិទ្ធិលើបំណុល ........................................................ ១៣

៥. ការអនុប្បទានឋានៈក្នុងកិច្ចសន្យា ........................................................ ១៤

**ជំពូកទី២**

**ទម្រង់ និង ការតាក់តែងលិខិតមតកសាសន៍**

**ផ្នែកទី ១ ទម្រង់ និង ការតាក់តែងមតកសាសន៍តាមវិធីធម្មតា** ........................................................ ១៥

**កថាភាគទី ១ ទម្រង់នៃលិខិតមតកសាសន៍តាមវិធីធម្មតា** ........................................................ ១៦

១. ទម្រង់ជាលិខិតយថាភូត ........................................................ ១៦

២.  ទម្រង់ជាលិខិតឯកជន ........................................................ ១៧

៣. ទម្រង់ជាលិខិតសម្ងាត់ ......... ១៧

**កថាភាគទី ២ សមាសភាពចូលរួម** ......... ១៨

១. មតកជន ......... ១៨

២. សារការី ......... ១៩

៣. សាក្សី ......... ១៩

**កថាភាគទី ៣ ការតាក់តែងលិខិតមតកសាសន៍** ......... ២០

១. ការតាក់តែងមតកសាសន៍ជាលិខិតយថាភូត ......... ២៣

២. ការតាក់តែងមតកសាសន៍ជាលិខិតឯកជន ......... ២៤

៣. ការតាក់តែងមតកសាសន៍ជាលិខិតសម្ងាត់ ......... ២៥

**ផ្នែកទី ២ ទម្រង់ និង ការតាក់តែងមតកសាសន៍តាមវិធីពិសេស** ......... ២៦

**កថាភាគទី ១ ទម្រង់នៃមតកសាសន៍តាមវិធីពិសេស** ......... ២៦

១. មតកសាសន៍របស់ជនដែលជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ......... ២៦

២. មតកសាសន៍របស់ជនដែលត្រូវជាប់ឃុំ ......... ២៧

## ជំពូកទី៣

## អានុភាព និង ការអនុវត្តមតកសាសន៍

**ផ្នែកទី ១ ការបង្កើតអានុភាពមតកសាសន៍** ......... ២៩

**កថាភាគទី ១ ការបង្កើតអានុភាពមតកសាសន៍ដោយមរណភាពមតកជន** ......... ២៩

**កថាភាគទី ២ ការបង្កើតអានុភាពមតកសាសន៍នៃការប្រកាសបាត់ខ្លួន** ......... ៣០

១. លក្ខខណ្ឌនៃការប្រកាសបាត់ខ្លួន ......... ៣០

២. នីតិវិធីនៃការប្រកាសបាត់ខ្លួន ......... ៣០

៣. អានុភាពនៃការប្រកាសបាត់ខ្លួន ......... ៣១

**កថាភាគទី ៣ លក្ខខណ្ឌបង្អង់នៃមតកសាសន៍** ......... ៣២

**ផ្នែកទី ២ អានុភាពមតកសាសន៍** ......... ៣២

**កថាភាគទី ១ អានុភាពនៃការកំណត់ចំណែកមត៌ក** ......... ៣២

**កថាភាគទី ២ ការកំណត់ចំណែកមត៌កករណីសន្តតិជនទទួលមរណភាពជាអាទិ៍** ......... ៣៣

**កថាភាគទី ៣ អានុភាពចំពោះអាណាព្យាបាលទូទៅ** ......... ៣៤

**កថាភាគទី ៤ អច្ច័យទាន** ........ ៣៤
១. អច្ច័យទានត្រូវចាត់ទុកជាមោឃៈ ........ ៣៥
២. ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃអច្ច័យទាន ........ ៣៦
៣. អច្ច័យទានដែលភ្ជាប់ជាមួយសិទ្ធិរបស់តតិយជន ........ ៣៧
៤. ឧបាទេសកម្មលើវត្ថុ និងសិទ្ធិលើបំណុល ........ ៣៧
៥. អច្ច័យទានដែលភ្ជាប់បន្ទុក ........ ៣៨
៦. ការបោះបង់អច្ច័យទាន ........ ៣៨
**កថាភាគទី៥ អានុភាពមតកសាសន៍ និង ភាគបម្រុង** ........ ៣៩
**ផ្នែកទី ៣ ការយល់ព្រម និង បោះបង់សន្តតិកម្មរបស់សន្តតិជន** ........ ៤០
**កថាភាគទី ១ លក្ខខណ្ឌនៃការបង្ហាញឆន្ទៈយល់ព្រម និងបោះបង់មតកសាសន៍** ........ ៤០
១. អំឡុងពេលនៃការយល់ព្រម ឬ បោះបង់មតកសាសន៍ ........ ៤១
២. លក្ខខណ្ឌនៃការលុបចោលនូវការយល់ព្រម ឬ បោះបង់មតកសាសន៍ ........ ៤១
**កថាភាគទី ២ អានុភាពនៃការយល់ព្រម និង បោះបង់សន្តតិកម្ម** ........ ៤២
១. ការយល់ព្រមទាំងស្រុង ........ ៤២
២. យល់ព្រមដោយមានកម្រិត ........ ៤៣
៣. ការបោះបង់សន្តតិកម្ម ........ ៤៥
**ផ្នែកទី ៤ ការអនុវត្តមតកសាសន៍** ........ ៤៥
**កថាភាគទី ១ ការបញ្ជាក់មតកសាសន៍** ........ ៤៥
**កថាភាគទី២ ការអនុវត្តពិសេសនៃមតកសាសន៍យថាភូត** ........ ៤៦
**កថាភាគទី៣ អ្នកប្រតិបត្តិមតកសាសន៍** ........ ៤៧
១. មូលហេតុបង្កើតឱ្យមានអ្នកប្រតិបត្តិ ........ ៤៧
២. ការជ្រើសតាំងអ្នកប្រតិបត្តិ ........ ៤៧
៣. ការលាឈប់ និង ការបញ្ឈប់ តួនាទីអ្នកប្រតិបត្តិ ........ ៤៨
៤. ការកាន់កាប់មុខងារជាអ្នកប្រតិបត្តិ និង អានុភាព ........ ៤៨
៥. សិទ្ធិ និង តួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍ ........ ៤៩
៦. កាតព្វកិច្ចអ្នកប្រតិបត្តិ ........ ៥១

៧. បន្ទុកនៃមត៌ក........................................................................................................................ ៥១
**កថាភាគទី ៤ ការបញ្ចប់មតកសាសន៍** ...................................................................................... ៥១
**សេចក្តីសន្និដ្ឋាន**.............................................................................................................. ៥២
**អនុសាសន៍**...................................................................................................................... ៥៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

នៅក្នុងជីវភាពរស់នៅរបស់មនុស្សក្នុងពិភពលោកយើងនេះ ដើម្បីអាចផ្គត់ផ្គង់ការរស់នៅទៅបាន ពួកគេតែងតែខិតខំប្រឹងប្រែងស្វែងរកប្រាក់ចំណូល ឬ ទ្រព្យសម្បត្តិសម្រាប់ចំណាយទៅតាមតម្រូវការរស់នៅរបស់ពួកគេ ដោយឡែកមនុស្សម្នាក់ៗតែងជៀសមិនផុតពីវដ្តនៃជីវិតគឺ កើត, ចាស់, ឈឺ, ស្លាប់ ។ ដោយហេតុថាមនុស្សដែលបានទទួលមរណភាពហើយពុំអាចយកទ្រព្យសម្បត្តិតាមខ្លួន ឬ បង្ហាញឆន្ទៈចាត់ចែងមត៌កបាននោះទេ ជាហេតុនាំអោយទ្រព្យសម្បត្តិដែលនៅសេសសល់របស់មតកជននឹងគ្មានម្ចាស់គ្រប់គ្រង បើពុំមានវិធានការច្បាប់ ។ ដូចនេះទើបក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាយើង បានចែងកំណត់អំពីវិធីនៃការបែងចែកមត៌ករបស់មតកជន ដែលវិធីទាំងនោះមានដូចជា សន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមបណ្តាំ។ សន្តតិកម្មតាមច្បាប់ គឺសំដៅដល់ការបែងចែកចំណែកមត៌កដែលកំណត់ដោយច្បាប់ អោយជនដែលត្រូវបានច្បាប់សន្មតថាមានសិទ្ធិក្នុងការទទួលបានចំណែកមត៌កពោលគឺ "សន្តតិជន" ហើយសន្តតិជនដែលកំណត់ដោយច្បាប់នេះមានដូចជាសហព័ទ្ធ (គ្រប់ករណីទាំងអស់), សន្តតិកម្មលំដាប់ទី១ (កូនបង្កើត ឬ កូនស្មុំរបស់មតកជន), សន្តតិកម្មលំដាប់ទី២ (បុព្វញាតិ), សន្តតិកម្មលំដាប់ទី៣ (បងប្អូនបង្កើត) ។ សន្តតិកម្មតាមច្បាប់ ត្រូវបានគេប្រើ នៅពេលដែលមតកជន កាលនៅរស់ពុំបានបន្សល់ទុកការបង្ហាញឆន្ទៈក្នុងការចាត់ចែងមត៌ក ឬ លិខិតបណ្តាំអ្វីសោះ ។ រីឯសន្តតិកម្មតាមបណ្តាំ គឺសំដៅដល់ការបង្ហាញឆន្ទៈរបស់មតកជនកាលនៅរស់ដោយធ្វើមតកសាសន៍ក្នុងការកំណត់អំពី អ្នកដែលមានសិទ្ធិទទួលបានមត៌កពោលគឺ "សន្តតិជនឬអច្ច័យលាភី", វិធីនៃការចាត់ចែងមត៌ក, ការធ្វើវិភាគទាន, អ្នកប្រតិបត្តិមត៌ក, អំឡុងពេលចាប់អានុភាពនៃមត៌ក, ការទទួលស្គាល់កូន និង ការផ្តែផ្តាំនូវពាក្យពេចន៍ចុងក្រោយ។

ការយល់ដឹងទៅលើទម្រង់ និងអានុភាពនៃមតកសាសន៍ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ដែលអាចសម្រួលដល់ការរស់នៅក្នុងសង្គមដោយបានផ្តល់មធ្យោបាយ ដល់បុគ្គលគ្រប់រូបនូវវិធានការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនក្រោយពីទទួលមរណភាព ហើយថែមទាំងជួយបញ្ចៀសនូវរាល់វិវាទទាយាទក្នុងការចែកចំណែកមត៌កដែលខុសពីសន្តតិកម្មតាមច្បាប់។ ជាក់ស្តែងយើងឃើញជាញឹកញាប់ថា ការអនុវត្តសន្តតិកម្មតាមច្បាប់តែងមានការតតាំងគ្នានឹងគ្នានៅចំពោះមុខតុលាការទៅលើសិទ្ធិក្នុងការទាមទារនូវចំណែកមត៌ក ដែលបណ្តាលអោយគ្រួសារមានភាពរង្គោះរង្គើរបែកបាក់ និង បាត់បង់ភាពសុខដុមរមនាក្នុងក្រុមគ្រួសារ ។ ដោយឡែកមតកជន អាចធ្វើមតកសាសន៍ដោយសេរីប៉ុន្តែត្រូវស្របតាមទម្រង់ដែលច្បាប់បានកំណត់ ហើយទម្រង់នីមួយៗនឹងផ្តល់នូវភាពខុសៗគ្នាទៅតាមទម្រង់ ដែលភាពខុសគ្នានោះរួមមានដូចជា សុក្រឹតភាពនិងសុពលភាពនៃលិខិត និងអានុភាពនៃការអនុវត្តមតកសាសន៍ ។

កាលបើមតកជន ពុំបានយល់ដឹងច្បាស់ពីទម្រង់មតកសាសន៍ ហើយបានធ្វើនូវលិខិតបណ្តាំដែលមិនស្របតាមទម្រង់ដែលច្បាប់បានកំណត់នោះ លិខិតបណ្តាំនឹងត្រូវបានចាត់ទុកជាមោឃៈហើយក៏គ្មានអានុភាពក្នុងការអនុវត្តនោះដែរ ។ ដើម្បីអោយយល់ច្បាស់ទៅលើ ទម្រង់ និងអានុភាពនៃមតកសាសន៍យើងនឹងសិក្សាទៅលើក្រមរដ្ឋប្បវេណី ដែលជាច្បាប់សារធាតុនៃនីតិឯកជន បូករួមទាំងច្បាប់ដោយឡែកមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា ។

ដូច្នេះថាតើ មតកសាសន៍មានទម្រង់អ្វីខ្លះ ? តើអានុភាពនៃលិខិតទៅតាមទម្រង់នីមួយៗបានផ្តល់នូវសុពលភាព និង សារប្រយោជន៍ខុសៗគ្នាយ៉ាងដូចម្តេច ? តើមតកសាសន៍ចាប់ផ្តើមមានអានុភាពនៅពេលណា ? និងត្រូវបានអនុវត្តដោយរបៀបណា ?

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ "**ទម្រង់ និង អានុភាពមតកសាសន៍**" មានគោលបំណងរួមចំណែកក្នុងការចងក្រងនូវឯកសារដែលជាមូលដ្ឋានក្នុងការស្វែងយល់ដល់អ្នកសិក្សា និង ជាការលើកកម្ពស់បង្កើនអោយមាននូវវប្បធម៌នៃការសិក្សាស្រាវជ្រាវអោយមានភាពសម្បូរបែប ហើយក៏ជាការរួមចំណែកមួយដើម្បីអភិវឌ្ឍសង្គមជាតិអោយឆ្ពោះទៅរកភាពរុងរឿង និង ភាពរីកចម្រើនក៏ព្រោះតែបច្ចុប្បន្នភាពនេះ វិស័យអប់រំដើរតួរយ៉ាងសំខាន់សម្រាប់ប្រទេសដែលកំពុងអភិវឌ្ឍន៍ ក្នុងការអភិវឌ្ឍប្រទេសអោយប្រកបដោយចីរភាព និង និរន្តរភាព ។

ការចងក្រងសៀវភៅមួយនេះ មានគោលបំណងគ្របដណ្តប់ទៅលើវិស័យនីតិឯកជន ដែលមានវិសាលភាពក៏ដូចជាទំហំនៃការសិក្សាស្រាវជ្រាវទៅលើក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ រហូតមកដល់បច្ចុប្បន្ន ។ ការស្រាវជ្រាវមួយនេះផ្តោតសំខាន់ទៅលើទ្រឹស្តីនៃទម្រង់ និងការអនុវត្តមតកសាសន៍តែប៉ុណ្ណោះ ចំពោះសន្តតិកម្មតាមច្បាប់ និង ភាគបម្រុង ពួកយើងពុំបានសរសេរអោយស៊ីជម្រៅនោះទេ គ្រាន់តែបានលើកឡើងនូវចំណុចខ្លះៗដើម្បីសម្រួលដល់អ្នកអានក្នុងការស្វែងយល់ ។

ការយល់ដឹងទៅលើទម្រង់ និង អានុភាពនៃមតកសាសន៍នឹងផ្តល់នូវអត្ថប្រយោជន៍ អោយយើងមានសមត្ថភាពក្នុងការជ្រើសរើសយកទម្រង់ ឬ តាក់តែងមតកសាសន៍ដោយខ្លួនឯងដែលមានសុពលភាពមួយជាក់លាក់ស្របតាមវិធានច្បាប់ដែលអាចយកជាផ្លូវការណ៍ រួមទាំងអាចពង្រីកនូវការយល់ដឹងលើវិស័យច្បាប់ក្នុងការអភិវឌ្ឍចំណេះដឹងរបស់ខ្លួនសម្រាប់ថ្ងៃអនាគត។

តបតាមការលើកឡើងខាងលើនេះ យើងនឹងធ្វើការសិក្សាទៅលើច្បាប់សារធាតុ (ពោលគឺក្រមរដ្ឋប្បវេណី, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, សេចក្តីកំណត់ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា) បន្ទាប់មកសិក្សាទៅលើបទដ្ឋានគតិយុត្តិពាក់ព័ន្ធ (ដែលរួមមានដូចជានីតិវិធីរដ្ឋប្បវេណី, ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, ច្បាប់ភូមិបាល និង រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាជាដើម), រួចមកធ្វើការសិក្សា

ស្រាវជ្រាវទៅលើស្នាដៃរបស់លោកគ្រូអ្នកគ្រូ ថែមទាំងអត្ថបទរបស់សាស្ត្រាចារ្យបរទេស ដែលមាននៅក្នុងប្រព័ន្ធអ៊ីនធឺណែត ។ ក្រោយពីបានស្រាវជ្រាវនូវឯកសារទាំងហើយ យើងនឹងពិភាក្សាពិគ្រោះជាមួយមិត្តរួមក្រុម និងសុំយោបល់ពីសាស្ត្រាចារ្យណែនាំ។

ដើម្បីអោយស្រាយនូវចម្ងល់ និង អោយកាន់តែយល់ច្បាស់ទៅលើការលើកឡើងចោទសួរខាងលើ យើងនឹងសិក្សាទៅលើ ៖

**ជំពូកទី១ សញ្ញាណទូទៅនៃមតកសាសន៍**

ផ្នែកទី១ ប្រវត្តិនៃមតកសាសន៍

ផ្នែកទី២ ទិដ្ឋភាពទូទៅនៃមត៌ក

**ជំពូកទី២ ទម្រង់ និងការតាក់តែងលិខិតមតកសាសន៍**

ផ្នែកទី ១ ទម្រង់ និង ការតាក់តែងមតកសាសន៍តាមវិធីធម្មតា

ផ្នែកទី ២ ទម្រង់ និង ការតាក់តែងមតកសាសន៍តាមវិធីពិសេស

**ជំពូងទី៣ អានុភាព និង ការអនុត្តមតកសាសន៍**

ផ្នែកទី ១ ការបង្កើតអានុភាពមតកសាសន៍

ផ្នែកទី ២ អានុភាពមតកសាសន៍

ផ្នែកទី ៣ ការយល់ព្រម និង បោះបង់សន្តតិកម្មរបស់សន្តតិជន

# ជំពូកទី១
# សញ្ញាណទូទៅនៃមតកសាសន៍

# ជំពូកទី១
# សញ្ញាណទូទៅនៃមតកសាសន៍

ដើម្បីស្វែងយល់ពីសញ្ញាណទូទៅរបស់មតកសាសន៍ យើងត្រូវតែសយល់ដឹងពីវត្ថុបំណង ភាពចាំបាច់ និងអត្ថប្រយោជនរបស់វាជាមុនសិន ហើយយើងនឹងពិត្យមើលផងដែលពីប្រវត្តនៃការកកើតមតកសាសន៍ និងការវិវត្តនៃរបបសន្តតិកម្មតាមបណ្តាំនេះ ក្នុងបរិបទប្រទេសកម្ពុជាផងដែរ ។ ហេតុដូច្នេះនៅក្នុងជំពូកទី១ ស្តីពីសញ្ញាណទូទៅនៃមតកសាសន៍ យើងនឹងធ្វើការបែងចែកជាពីរផ្នែកសំខាន់ៗ ផ្នែកទី១ ប្រវត្តិនៃមតកសាសន៍ និងផ្នែកទី២ ការវិវត្តរបបមតកសាសន៍កម្ពុជាបច្ចុប្បន្ន ។

## ផ្នែកទី១ ប្រវត្តិនៃមតកសាសន៍

### កថាភាគទី១ ការកកើតមតកសាសន៍

ការបែងចែកមត៌ក គឺជាសកម្មភាពមួយដែលមានយូរលង់ណាស់មកហើយ ស្របពេលដែលមនុស្សលោកចាប់ផ្តើមស្គាល់ពីអ្វីទៅជាកម្មសិទ្ធិ ។ ប្រវត្តិនៃការបែងចែកមត៌កមានប្រភព និង ការវិវឌ្ឍន៍ខុសៗគ្នាទៅតាមតំបន់ដោយសារតែភាពខុសគ្នានៃ ច្បាប់, បរិបទនយោបាយ, វប្បធម៌, ប្រពៃណី ឬ ទំនាមទំលាប់ពីបុរាណ្យ ។

ដោយឡែកបើងាកមកមើលរបៀបរស់នៅរបស់ប្រជាជននៅក្នុងទីក្រុងអាថែន (Athens) ប្រទេសក្រិច (Greece) ជាង៣០០០ឆ្នាំមុន គ.ស គេឃើញមានច្បាប់បុរាណ្យមួយ បានកំណត់អំពីវិធីក្នុងការចាត់ចែងមត៌ករបស់មតកជន ដោយបានបញ្ញត្តថា រាល់ទ្រព្យសម្បត្តិរួមទាំងបំណុលទាំងអស់ របស់អ្នកដែលស្លាប់ ឬ មតកជន គឺគួរតែបានទៅលើញាតិខ្សែផ្ទាល់ ឬសាខាញាតិរបស់ពួកគេ ។[1] ហើយនៅក្នុងរាជកាលចន្លោះឆ្នាំ ៦៣៨ ដល់ ៥៥៨ មុនគ.ស លោក Solon ដែលជារដ្ឋបុរស និង ជាសមាជិកសភាធម្មនុញ្ញ បានធ្វើការវិសោធនកម្មច្បាប់ក្នុងគោលបំណងផ្តល់សិទ្ធិអោយប្រជាពលរដ្ឋ នៅទីក្រុងអាថែន (Athens) ដែលមានអាយុយ៉ាងតិច២០ឆ្នាំ មានសិទ្ធិធ្វើមតកសាសន៍ក្នុងការផ្ទេរទ្រព្យសម្បត្តិរបស់ខ្លួនបន្ត ។ មតកជនមានសេរីភាពក្នុងការធ្វើមតកសាសន៍ ប៉ុន្តែសេរីភាពទាំងនេះត្រូវបានកម្រិតដោយច្បាប់ដែលបានចែងកំណត់ថា ៖

- ប្រជាជនដែលមានសិទ្ធិក្នុងការធ្វើមតកសាសន៍រួមមាន ៖
  - ✓ ជាបុគ្គលដែលមិនមែនជាកូនកំព្រា (ករណីដែលជាកូនកំព្រា កាលបើទទួលមរណភាព នោះទ្រព្យសម្បត្តិទាំងអស់ត្រូវបានទៅលើឪពុកម្តាយចិញ្ចឹមរបស់ជននោះ) ។
  - ✓ ប្រសិនបើពួកគេមានកូនប្រុស ពួកគេមិនអាចធ្វើមតកសាសន៍បានទេ ព្រោះកូនប្រុសត្រូវបានផ្តល់សិទ្ធិអត្តិភាពពីរដ្ឋ ដោយទទួលបាននូវសិទ្ធិស្នងមត៌កទាំងស្រុង ។

[1] ទំព័រទី២ អត្ថបទ History of Wills របស់ លោក Richard Boaden

- ✓ ពួកគេគួរតែមានស្មារតីនឹងនរក្នុងការធ្វើមតកសាសន៍ និងមិនគួរធ្វើមតកសាសន៍កំឡុងពេលដែលមានបញ្ហាខ្សោយផ្នែកស្មារតីដោយសារជម្ងឺ ឬការវង្វេងដោយសារភាពជរា ។

នៅក្នុងសម័យកាលបុរាណក្រិចនេះ ជាធម្មតាមតកសាសន៍ត្រូវបានគេតាក់តែងឡើងដោយមានការចុះហត្ថលេខាឬស្នាមមេដៃរបស់គូភាគី ហើយមានការចូលរួមពីសាក្សីចំនួន២ ឬ ៣នាក់ និង ធ្វើការបោះត្រាហើយមានការពិនិត្យបញ្ជាក់ពីភាពត្រឹមត្រូវទៅលើសុក្រឹតភាពនៃលិខិត បន្ទាប់មកត្រូវប្រគល់អោយទៅអ្នកគ្រប់គ្រងទទួលភារៈកិច្ច ឬ អ្នកតំណាងក្នុងការរក្សាទុក ។[2]

**១. និយមន័យ**

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់សិទ្ធិអោយប្រជាពលរដ្ឋខ្មែរមានសិទ្ធិធ្វើជាម្ចាស់កម្មសិទ្ធិ និង សិទ្ធិក្នុងការចាត់ចែងទៅលើទ្រព្យសម្បត្តិរបស់ខ្លួន រួមទាំងត្រូវបានគាំពារដោយច្បាប់ថែមទៀតផង ។[3] មួយវិញទៀត នៅក្នុងក្រមរដ្ឋប្បវេណីក៏បានចែងអំពីគោលការណ៍ស្វ័យភាពបុគ្គលឯកជន ដែលមានអត្ថន័យ និងគោលបំណងក្នុងការគោរពនូវសេរីភាពនៃការបង្ហាញឆន្ទៈរបស់បុគ្គលទៅលើការប្រើប្រាស់សិទ្ធិរបស់ខ្លួន ក៏បូករួមទាំងសិទ្ធិក្នុងការធ្វើមតកសាសន៍ផងដែរ ។[4]

មតកសាសន៍ ត្រូវបានប្រជាជនខ្មែរទូទៅស្គាល់ថាជាបណ្តាំមត៌ក ដែលម្ចាស់បណ្តាំបានធ្វើការផ្តែផ្តាំចាត់ចែងដល់សាច់សារលោហិតមុនពេលដែលខ្លួនទទួលមរណភាព។

ពាក្យថា "មតកសាសន៍" មានន័យថា គឺជាបណ្តាំ ដែលបុគ្គលម្នាក់បានធ្វើឡើងជាទម្រង់ដែលកំណត់ដោយច្បាប់ ដើម្បីសម្តែងឆន្ទៈចុងក្រោយ អំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍ បន្ទាប់ពីមរណភាព ។[5]

មួយវិញទៀត "មតកសាសន៍" ក៏ត្រូវបានគេអោយនិយមន័យថា ជាការបង្ហាញឆន្ទៈឯកតោភាគីដោយពុំមានភាគីម្ខាងទៀត ដែលធ្វើឡើងដោយម្ចាស់បណ្តាំពាក់ព័ន្ធ និងចំណុចពិសេសស្តីពីទំនាក់ទំនងទ្រព្យសម្បត្តិរបស់ជននោះ ឬស្តីពីទំនាក់ទំនងឋានៈបុគ្គលក្នុងគោលបំណងបង្កើតអានុភាព នៅពេលដែលខ្លួនទទួលមរណភាព ហើយដែលបានធ្វើទៅតាមវិធីកំណត់ជាក់លាក់ ។[6]

---

[2] ទំព័រទី៣ អត្ថបទ History of Wills របស់ លោក Richard Boaden

[3] មាត្រា ៤៤ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[4] មាត្រា ៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[5] ទំព័រទី១៧ សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ ឆ្នាំ២០០៧

[6] ទំព័រទី៣៦ សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ ៦ ឆ្នាំ២០១២

**២. អត្ថប្រយោជន៍**

ការបែងចែងទ្រព្យសម្បត្តិ តាមមតកសាសន៍បានផ្តល់នូវសារប្រយោជន៍ជាច្រើន និងជួយកំណត់អំពីភាពច្បាស់លាស់ទៅលើចំណែកទ្រព្យសម្បត្តិដែលសន្តតិជន ឬអច្ច័យលាភីទទួលបាន ហើយសារប្រយោជន៍ទាំងអស់នេះរួមមានដូចជា ៖

ជួយបញ្ចៀសរាល់វិវាទក្នុងគ្រួសារ ឬ វិវាទទាយាទក្នុងការចែកចំណែកមត៌ក ក៏ព្រោះតែមតកសាសន៍ត្រូវបានធ្វើឡើងដោយឆន្ទៈរបស់មតកជនកាលនៅរស់ ដែលចែងច្បាស់នូវរាល់ចំណែកដែលទាយាទទទួលបាន ។ ដូចនេះការបែងចែកមត៌កត្រូវធ្វើស្របតាមមតកសាសន៍ ក្រោយពេលដែលមតកសាសន៍ចាប់ផ្តើមបង្កើតនូវអានុភាព ។

មតកសាសន៍ អាចចែងពីការកំណត់នូវបែងចែកមត៌កដែលផ្ទុយនឹងសន្តតិកម្មកំណត់ដោយច្បាប់បានក្នុងន័យនេះគឺគេអាចធ្វើអច្ច័យទាន តាមបំណងប្រាថ្នារបស់ខ្លួន ដោយផ្តល់ចំណែកមត៌កតិច ឬ ច្រើន និង អាចកំណត់ទៅលើលក្ខខណ្ឌក្នុងការអនុវត្តមតកសាសន៍, អ្នកកាន់កាប់ ឬ អ្នកប្រតិបត្តិបណ្តាំមត៌ក ប៉ុន្តែរាល់ការចាត់ចែងចំណែកមត៌កទាំងអស់នេះមិនអាចរំលោភលើភាគបម្រុងបាននោះទេ ។

មតកសាសន៍ អាចកំណត់អំពីការផ្តាច់មត៌កពីសន្តតិជនបាន ពោលគឺបុគ្គលនោះមិនត្រូវបានរាប់បញ្ចូលនៅក្នុងការបែងចែកចំណែកមត៌ក ហើយករណីនេះអាចកើតមានឡើងដោយសារតែ បុគ្គលដែលត្រូវបានកាត់ផ្តាច់នោះទទួលបាននូវផលប្រយោជន៍ពិសេស ឬ ទទួលបានចំណែកទ្រព្យសម្បត្តិរួចរាល់កាលដែលមតកជននៅរស់ មួយវិញទៀតក៏មានករណីមួយចំនួនដែលអាចមកពីការធ្វើបាបចំពោះមតកជន, ការប្រមាថយ៉ាងធ្ងន់ធ្ងរ, មិនយកចិត្តទុកដាក់ទៅលើមតកជននៅពេលដែលមតកជនមានជម្ងឺ, ត្រូវបានទទួលសាលក្រម ឬ សាលដីកាផ្តន្ទាទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត និង បានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឱ្យកត់សម្គាល់ជាអាទិ៍ ។[7]

មតកជន អាចប្រើប្រាស់សិទ្ធិក្នុងការទទួលស្គាល់កូន ដោយកំណត់នៅក្នុងមតកសាសន៍បាន ។ ការទទួលស្គាល់បែបនេះគឺក្នុងគោលបំណងកំណត់នូវបិតុភាពចំពោះ កូន ឬ ទារកនៅក្នុងគភ៌ ថែមទាំងដើម្បីផ្តល់សិទ្ធិអោយក្លាយជាទាយាទក្នុងការទទួលបាននូវចំណែកមត៌កផងដែរ ។[8] ក្រៅពីទ្រព្យសម្បត្តិ មតកជនក៏អាចធ្វើការចាត់ចែងនូវសិទ្ធិអំណាចមេបាចំពោះកូនដែលជាអនីតិជន ក្នុងគោលដៅកំណត់ចំពោះបុគ្គលដែលខ្លួនទុកចិត្តដើម្បីមើលថែទាំ និងថែរក្សាកូនដែលជាអនីតិជន ករណីដែលគ្មានអ្នកមានអំណាចអាណាព្យាបាលបន្ត ។[9]

---

[7] មាត្រា ១១៥១ និង១១៥២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[8] មាត្រា ៩៩៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[9] មាត្រា ១០៦៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

## កថាភាគទី២ ប្រវត្តិនៃមតកសាសន៍នៅកម្ពុជា

និយាយដោយឡែក នៅប្រទេសកម្ពុជាយើងក៏ជារដ្ឋដែលមានអរិយធម៌ចំណាស់មួយនៅអាស៊ីដែល ចំពោះការផ្ទេរមត៌កពីជំនាន់មួយទៅជំនាន់មួយ ជាទូទៅសង្គមកម្ពុជាច្រើនអនុវត្តទម្លាប់ជាលក្ខណៈប្រពៃណី ។ ជាក់ស្តែងទម្លាប់នេះយើងសង្កេតឃើញថានៅតែមានឥទ្ធិពលដល់សង្គមកម្ពុជាសព្វថ្ងៃ ទោះបីជាបច្ចុប្បន្នកម្ពុជា មាននូវបទដ្ឋានគតិយុត្តទំនើបដែលបញ្ញត្តនានាទាក់ទងនឹងរបបនៃការផ្ទេរមត៌ក ឬ សន្តតិកម្មក៏ដោយ ។ ហេតុនេះប្រជាជនកម្ពុជាមិនសូវជាមានទម្លាប់ក្នុងការរៀបចំបណ្តាំមត៌ក ឬ មតកសាសន៍ភាគច្រើននៅឡើយ ដែលពេលខ្លះវាបានបន្សល់ទុកនូវទំនាស់ផលប្រយោជន៍នានាដល់សន្តតិជនរបស់គាត់ ។ ជាក់ស្តែងទម្លាប់ដែលអាចចាត់ទុកថាជាលក្ខណៈប្រពៃណីរបស់សង្គមកម្ពុជាក្នុងការចាត់ចែងទ្រព្យសម្បត្តិរបស់ប្រជាជនកម្ពុជា នោះគឺច្រើនតែធ្វើការចែកទ្រព្យសម្បត្តិឱ្យកូនៗមុនពេលស្លាប់ ចំណែកទ្រព្យសម្បត្តិដែលនៅសល់ក្រោយពេលស្លាប់ ច្រើនតែមតកជនមានចេតនាទុកឱ្យកូនដែលនៅអំឡុងពេលនៅក្នុងបន្ទុកមិនទាន់រៀបអាពាហ៍ពិពាហ៍ ឬ កូនពៅដែលមានអាទិភាព ដែលបាននៅបីបាច់ថែរក្សាមតកជនមិនទាន់រៀបអាពាហ៍ពិពាហ៍ ឬ មិនបែកលំនៅឋានជាអាទិ៍ ។

### ១. ការវិវត្តរបបមតកសាសន៍ក្នុងនីតិវិជ្ជមានកម្ពុជា

ក្នុងការវិវត្តនៃរបបមតកសាសន៍ក្នុងនីតិវិជ្ជមានកម្ពុជា គឺមានបទដ្ឋានចំនួនពីរសំខាន់ដែលគ្រប់គ្រងលើសកម្មភាពនៃការផ្ទេរមត៌កពីមតកជន ទៅទាយាទគឺ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ១៩៦៧ និង ព្រះរាជក្រមលេខ ៩១០ ន.ស ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ ស្តីពី វិជ្ជាជីវៈសាការី ។

❖ <u>តាមរយៈក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ១៩៦៧</u>

ដូចបានបញ្ជាក់ការផ្ទេរមត៌ក ក្នុងសង្គមខ្មែរសម័យដើមរបស់ប្រជាជនកម្ពុជាមិនមានទម្រង់ច្បាស់លាស់នោះទេ ហើយវាក៏អាចខុសគ្នាទៅតាមទម្លាប់នៃតំបន់ដែរ ហើយការរៀបចំបណ្តាំទៀតសោត ភាគច្រើនគ្រាន់ជាការផ្តាំផ្ញើរដោយផ្ទាល់មាត់របស់មតកជនទៅសន្តតិជនរបស់គេជាការស្រេច ណាមួយវាបញ្ជាក់ពីភាពសុចរិត ភាពស្មោះត្រង់ ដឹងគុណទោស និង កម្រិតសីលធម៌របស់ប្រជាជនកម្ពុជាក្នុងសម័យដើម ដែលគោរពឆន្ទៈបុព្វការីក្នុងការបែងចែកទ្រព្យសម្បត្តិ ។ ប៉ុន្តែការរស់នៅតែងតែមានការវិវត្ត បញ្ហាសង្គមតែងមានការជះឥទ្ធិពលដល់ការរៀបចំសណ្តាប់ធ្នាប់សង្គម ហើយការរៀបចំសណ្តាប់ធ្នប់សង្គមគឺ ច្បាប់ ។ ហេតុដូច្នេះ យើងសង្កេតឃើញថា របបមតកសាសន៍របស់កម្ពុជា ក៏ចាប់ផ្តើមវិវត្តន៍ផងដែលជាពិសេសក្នុងសម័យអាណានិគមបារាំង ដែលនិយមប្រតិបត្តិបទដ្ឋាននីត្យានុកូលភាព ឬ ស៊ីវិលឡ ទើបរបបមតកសាសន៍ត្រូវបានបង្កើតឡើងជាក់ស្តែងតាមរយៈក្រមរដ្ឋប្បវេណីឆ្នាំ១៩៦៧ ដែលអាចចាត់ទុកថា ជានីតិវិជ្ជមានច្បាស់លាស់ ក្នុងការផ្តល់សិទ្ធិ

ឱ្យពលរដ្ឋកម្ពុជាអាចរៀបចំផ្ទេរនូវសិទ្ធិ និង កាតព្វកិច្ចរបស់ខ្លួនទៅឱ្យទាយាទប្រកបដោយអនុឡោមភាព តាមរយៈទម្រង់ច្បាស់លាស់ទទួលស្គាល់ដោយច្បាប់ ។

តាមរយៈក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ១៩៦៧ មានចែងយ៉ាងលម្អិតស្តីពីសន្តតិកម្ម ដោយបានបញ្ជាក់យ៉ាងច្បាស់ថា សន្តតិកម្មគឺជាការផ្ទេរនូវបេតិកភណ្ឌ នៃបុគ្គលណាម្នាក់ដែលស្លាប់ឱ្យទៅជនម្នាក់ ឬ ច្រើននាក់ ដែលហៅថា ទាយាទ ឬ សន្តតិជន ។ សន្តតិកម្ម ត្រូវបានផ្ទេរតាមច្បាប់ ឬ តាមឆន្ទៈរបស់ខ្មោច ។ សន្តតិកម្មដែលផ្ទេរតាមច្បាប់ហៅថា សន្តតិកម្មឥតបណ្តាំ ឯសន្តតិកម្មដែលផ្ទេរតាមឆន្ទៈខ្មោច ហៅថា សន្តតិកម្មមានបណ្តាំ ។[10] ចំណែកវិធីសាស្ត្រក៏ដូចជាទម្រង់នានា នៃនីតិវិធីក្នុងការចែកមត៌ក និង ការធ្វើបណ្តាំបានចែងយ៉ាងលម្អិត ក្នុងជំពូកទី៤ (សន្តតិកម្មមានបណ្តាំ) នៃមាតិកាទី៦ (អំពីសិទ្ធិ និង កាតព្វកិច្ចទាំងឡាយលើបេតិកភណ្ឌក្នុងគ្រួសារ) នៃគន្ថីទី១ (អំពីបុគ្គល) ។

❖ **<u>ព្រះរាជក្រមលេខ ៩១០ នស ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ ស្តីពី សាការី</u>**

តាមរយៈព្រះរាជក្រមលេខ ៩១០ ន.ស ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ បានចែងផ្តោតសំខាន់លើវិជ្ជាជីវៈសារការី ដែលជាមន្ត្រីសាធារណៈ ដែលតែងតាំងឡើងតាមព្រះរាជក្រឹត្យនៃរដ្ឋាភិបាលដោយសារការីមានតួនាទីទទួល និង ធ្វើតាមតម្រូវការ នូវលិខិតកិច្ចសន្យាដែលគូសសញ្ញាត្រូវធ្វើឱ្យមាន ឬ ចូលចិត្តឱ្យមានចរឹកជាពេញលក្ខណៈច្បាប់ ដែលតែងតែមានដល់លិខិតរបស់រាជការសាធារណៈ ។[11] តាមរយៈព្រះរាជក្រឹត្យដែលបានបន្ថែមមុខងារដល់វិជ្ជាជីវៈសារការីដែលមានសិទ្ធិធ្វើនូវលិខិតយថាភូត ដែលជាទូទៅជាលិខិតធ្វើឡើងដោយមន្ត្រីរាជការសាធារណៈ ហើយវាកាន់តែមានភាពងាយស្រួល និង ច្បាស់លាស់ក្នុងករណីដែលមតកសាសន៍ដូចមានចែងក្នុងក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ១៩៦៧ ត្រូវបានធ្វើឡើងដោយសារការី ព្រោះសារការីត្រូវបានចាត់ទុកថាជាមន្ត្រីជំនាញក្នុងការធ្វើលិខិតយថាភូត និង ទទួលបាននីតិសម្បទាជាមន្ត្រីសាធាណៈ តាមរយៈប្រតិភូកម្មអំណាចពីរដ្ឋក្នុងការតាក់តែង បញ្ជាក់ តម្កល់ និង អនុវត្តនូវលិខិតយថាភូតនានា ។

### ២. ការវិវត្តន៍របបមតកសាសន៍កម្ពុជាបច្ចុប្បន្ន

បច្ចុប្បន្នកម្ពុជាមានរបបស្តីពីសន្តតិកម្ម ដែលបញ្ញត្តដាក់លាក់ទាំងលក្ខណៈសារធាតុ លក្ខណៈទម្រង់ និង នីតិវិធីអនុវត្តយ៉ាងច្បាស់លាស់តាមរយៈក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ ដែលដាក់ឱ្យប្រើប្រាសជំនួសក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ១៩៦៧ ដែលចាត់ទុកថាជាការធ្វើបច្ចុប្បន្នភាពនៃសន្តតិកម្មស្របទៅតាមការវិវត្តន៍របស់សង្គម និង សាកលភាវូបនីយកម្ម ។ តាមរយៈក្រមរដ្ឋប្បវេណីកម្ពុជាបច្ចុប្បន្នបានបែងចែកប្រភេទនៃសន្តតិកម្ម

[10] មាត្រា ៤៨៦ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ១៩៦៧

[11] មាត្រា ១-១ ព្រះរាជក្រមលេខ ៩១០ នស ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤

មិនខុសអ្វីពីក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ១៩៦៧ នោះទេ គឺសន្តតិកម្មមានពីរប្រភេទ រួមមាន សន្តតិកម្មតាមបណ្តាំ និងសន្តតិម្មតាមច្បាប់ក្នុងករណីគ្មានបណ្តាំ ឬ បណ្តាំត្រូវជាចាត់ទុកជាមោឃៈជាអាទិ៍ ។[12]

និយាយដោយឡែកចំពោះ របបសន្តតិកម្មតាមរយៈបណ្តាំ ឬ មតកសាសន៍ ក្រមរដ្ឋប្បវេណីបានកំណត់ថាជាសកម្មភាពឯកតោភាគី ដែលត្រូវធ្វើតាមរយៈទម្រង់កំណត់ដោយច្បាប់គឺ ទម្រង់មតកសាសន៍ជាលិខិតឯកជន ទម្រង់មតកសាសន៍ដោយលិខិតសម្ងាត់ និង ទម្រង់មតកសាសន៍ជាលិខិតយថាភូត ។ ប៉ុន្តែដើម្បីឱ្យមតកសាសន៍នៃទម្រង់នានាដែលត្រូវបានបង្កើតអាចមានអានុភាពយកទៅអនុវត្តបាន លុះត្រាតែធ្វើឡើងដោយស្របតាមលក្ខខណ្ឌទម្រង់កំណត់ដោយច្បាប់ សមត្ថភាពបង្ហាញឆន្ទៈ សមត្ថភាពក្នុងការធ្វើសកម្មភាព ព្រមទាំងលក្ខខណ្ឌនានាក្នុងករណីពិសេសផងដែរ ។ តាមរយៈភាពសំបូរបែបនៃទម្រង់មតកសាសន៍នេះ វាបង្ហាញពីជម្រើសរបស់មតកជន ក្នុងការជ្រើសរើសយកការធ្វើបណ្តាំរបស់ខ្លួន ដែលសមស្របទៅនឹងស្ថានភាព ជីវភាព នឹងហេតុការណ៍ណាមួយ ។ នេះវាក៏បានបង្ហាញយ៉ាងច្បាស់ពីភាពជាក់លាក់ប្រកបដោយការបត់បែននៃរបបសន្តតិកម្ម តាមរយៈបណ្តាំបែបទំនើបរបស់កម្ពុជាផងដែរ ។

អ្វីដែលគួរឱ្យកត់សម្គាល់នៃអានុភាពមតកសាសន៍ នោះគឺមិនបានចងកាតព្វកិច្ចដាច់ខាតឱ្យទាយាទរបស់មតកជនត្រូវតែទទួលយកនូវសិទ្ធិ និង កាតព្វកិច្ចជុំវិញទ្រព្យសម្បត្តិមតកជននោះទេ ពោលគឺសន្តតិជន ឬ អច្ច័យលាភី ដែលទទួលផលប្រយោជន៍តាមរយៈបណ្តាំ អាចមានសិទ្ធិក្នុងការបដិសេធន៍ក្នុងការទទួលសន្តតិកម្មបាន ដែលនេះជាគោលការណ៍នៃសិទ្ធិស្វ័យភាពរបស់បុគ្គល ដែលជាមូលដ្ឋានគ្រឹះនៃក្រមរដ្ឋប្បវេណីរបស់កម្ពុជាបច្ចុប្បន្ន និង មានលក្ខណៈខុសគ្នាពីក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ១៩៦៧ ដែលបញ្ញត្តថាកាតព្វកិច្ចឱ្យសន្តតិជនដែលមានសិទ្ធិលើភាគីបម្រុង រួមមានប្រពន្ធ និង កូនរបស់មតកជនត្រូវទទួលខុសត្រូវជាកាតព្វកិច្ចនៃបំណុលរបស់មតកជន ។[13] ក្រៅពីលក្ខខណ្ឌនៃការបង្កើតមតកសាសន៍ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ ក៏បានបញ្ញត្តនូវនីតិវិធីនៃការអនុវត្ត ដើម្បីឱ្យសម្រេចនូវខ្លឹមសារនៃមតកសាសន៍ ចាប់ផ្តើមពីការបង្កើតអានុភាព រហូតដល់ការប្រតិបត្តិមតកសាសន៍ ។

## ផ្នែកទី២ និដ្ឋភាពទូទៅនៃមត៌ក

ទ្រព្យសម្បត្តិដែលបន្សល់ទុកដោយមតកជនក្រោយពេលខ្លួនទទួលមរណភាព ត្រូវបានគេហៅថាជាមត៌ក ។[14] រាល់មត៌កទាំងអស់ មិនមែនសុទ្ធតែផ្តល់ប្រយោជន៍ ដល់សន្តតិជន ឬ អច្ច័យលាភី ទាំងស្រុងនោះ

[12] មាត្រា ១១៨៥ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

[13] មាត្រា ៥៨៣ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ១៩៦៧

[14] ទំព័រ ១៧ សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ ឆ្នាំ២០០៧

ទេ ពេលខ្លះមត៌ក ក៏មានការភ្ជាប់កាតព្វកិច្ច ឬ បន្ទុកដែលបន្ថយនូវផលប្រយោជន៍ ឬ តម្លៃនៃមត៌កផងដែរ ។ ជាទូទៅយើងសង្កេតឃើញថា មតកជន ផ្តល់នូវមត៌តដល់ សន្តតិជន ឬ អច្ច័យលាភី តែងមានតម្លៃច្រើនជាង បន្ទុក ក៏ព្រោះតែកាលបើមតកសាសន៍ដែលមានបន្ទុកច្រើនជាងផលប្រយោជន៍នោះ សន្តតិជន ឬ អច្ច័យលាភី ប្រាកដជាបង្ហាញឆន្ទៈបោះបង់សន្តតិកម្មជាមិនខាន ។

ដើម្បីអោយយល់កាន់តែច្បាស់ថាអ្វីជាផលប្រយោជន៍ និង អ្វីជាបន្ទុក ដែលជាផ្នែកសំខាន់មួយនៅក្នុង មតកសាសន៍ យើងនឹងសិក្សាទៅលើ ប្រភេទនៃមត៌ក និង កម្មវត្ថុនៃមត៌ក ។

**កថាភាគទី១ ប្រភេទនៃមត៌ក**

នៅក្នុងជីវភាពរស់នៅត្រូវបានគេកត់សម្គាល់ថា ទ្រព្យសម្បត្តិ ឬ មត៌ក ដែលបានបន្សល់ដោយមតក ជនត្រូវបានញែកជាពីរប្រភេទ គឺ ទ្រព្យសកម្ម និង ទ្រព្យអកម្ម ។

❖ **ទ្រព្យសម្បត្តិ**

ទ្រព្យសកម្ម គឺជាទ្រព្យដែលអាចប្រើប្រាស់សម្រាប់ប្រតិបត្តិការអាជីវកម្ម ឬ អាចចំណាយទៅតាមតម្រូវ ការប្រចាំថ្ងៃ ហើយទ្រព្យសកម្មអាចមានលក្ខណៈជាកស្តែង ដូចជាលុយ, អាគារ, ដី, រថយន្ត, គ្រឿងសំណង់ និង ផ្ទះជាដើម ចំណែកទ្រព្យសកម្មម្យ៉ាងទៀត អាចមានលក្ខណៈជាអរូបី ដូចជាសិទ្ធិអ្នកនិពន្ធ, ប៉ាតង់ និង កម្មសិទ្ធិបញ្ញាជាដើម ។

❖ **ទ្រព្យអកម្ម**

ទ្រព្យអកម្ម ត្រូវបានគេស្គាល់ជាទូទៅថាបំណុល គឺជាទ្រព្យ ឬ កាតព្វកិច្ចដែលភាគីម្ខាងជំពាក់ទៅភាគី ម្ខាងទៀត ។ ទ្រព្យអកម្ម មានដូចជាប្រាក់កម្ចី, បំណុលធានាគារ, ការបញ្ចាំ និង បំណុលបង់ពន្ធជាដើម ។

មតកជន ពុំអាចធ្វើមតកសាសន៍បានឡើយបើ ទ្រព្យអកម្ម មានច្រើនជាងទ្រព្យសកម្មក៏ព្រោះតែមតកជន ប្រឈមនឹងការប្រកាសក្ស័យធន ដោយពុំមានមត៌កដែលជាធាតុសំខាន់ក្នុងការតាក់តែងមតកសាសន៍។

ករណីមានការបង្ហាញឆន្ទៈទទួលយកសន្តតិកម្ម ទៅលើទ្រព្យសកម្មរបស់មតកជន នោះសន្តតិជន ឬ អច្ច័យលាភីក៏ត្រូវទទួលនូវកាតព្វកិច្ចដែលមតកជនមានកាលនៅរស់ផងដែរ ពោលគឺទទួលរ៉ាប់រងក្នុងការសង បំណុលដែលមតកជនមាន ។

**កថាភាគទី២ កម្មវត្ថុនៃមត៌ក**

ទោះបីជាសេរីភាពក្នុងការធ្វើមតកសាសន៍ត្រូវបានគោរពក៏ពិតមែន ប៉ុន្តែមិនមែនរាល់សិទ្ធិទាំងអស់ដែល មតកជនមាន សុទ្ធតែអាចយកមកធ្វើជាកម្មវត្ថុនៃមត៌កបាននោះទេ សិទ្ធិដែលមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី និង ពុំអាចចាត់ចែងបាននោះមានដូចជា សេរភាព, ផលុភោគ និង សិទ្ធិប្រើប្រាស់អាស្រ័យនៅជាដើម សុទ្ធតែមិន

អាចចាត់ចែងបាន ដោយហេតុថាសិទ្ធិទាំងនេះភាគច្រើនត្រូវបានរលត់ទៅវិញដោយសារតែមូលហេតុនៃមរណភាពរបស់មតកជន និង ម្យ៉ាងទៀតគឺជាសិទ្ធិដែលមិនអាចធ្វើការបំបែកចេញពីវត្ថុអោយជាសិទ្ធិឯករាជ្យបាន ។

ដូចនេះសិទ្ធិដែលច្បាប់អនុញ្ញាតអោយមតកជន អាចធ្វើការចាត់ចែងតាមឆន្ទៈរបស់ខ្លួនបាន មានដូចជា ៖ សិទ្ធិកម្មសិទ្ធិ, អាជ្ញាយុកាលនៃលទ្ធកម្មនៃកម្មសិទ្ធិ, សិទ្ធិជួលអចិន្ត្រៃយ៍, សិទ្ធិលើបំណុល និង ការអនុប្បទានឋានៈក្នុងកិច្ចសន្យា ។

**១. សិទ្ធិនៃកម្មសិទ្ធិ**

កម្មសិទ្ធិ សំដៅទៅលើសិទ្ធិដែលកម្មសិទ្ធិករនោះអាចប្រើប្រាស់ អាស្រ័យផល និង ចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួន ដោយសេរីបាន នៅក្នុងទំហំដែលច្បាប់បានកម្រិត ។[15] វត្ថុដែលអាចយកមកធ្វើជាកម្មសិទ្ធិត្រូវបានបែងចែកជាពីរប្រភេទគឺ ចលនវត្ថុ និង អចលនវត្ថុ ។

❖ **<u>ចលនវត្ថុ</u>**

យោងតាមក្រមរដ្ឋប្បវេណីបានអោយនិយមន័យ ចលនវត្ថុសំដៅទៅលើវត្ថុក្រៅពីអចលនវត្ថុ ។[16] មួយវិញទៀតចលនវត្ថុ គឺ សំដៅទៅលើវត្ថុដែលអាចរំកិលបាន ឬ ផ្លាស់ប្តូរទីកន្លែងបានដូចជា របស់របរផ្ទាល់ខ្លួន ឬ ចលនទ្រព្យ ។ ឧទាហរណ៍ ៖ ថវិកា, ម៉ូតូ, រថយន្ត និង គ្រឿងអលង្ការជាអាទិ៍ ។

ដោយអនុលោមតាម មាត្រា ១៨៧ ដែលបានអនុញ្ញាតអោយកម្មសិទ្ធិលើចលនវត្ថុអាចធ្វើលទ្ធកម្មដោយសន្តតិកម្ម និយាយជារួមគឺ សន្តតិជន ឬ អច្ច័យលាភីអាចធ្វើលទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុតាមមតកសាសន៍របស់មតកជនបាន ។ សម្រាប់ករណីមតកសាសន៍ ដែលមានមត៌កជាចលនវត្ថុ គេសង្កេតឃើញថាមានភាពងាយស្រួលក្នុងការអនុវត្ត ដោយគ្រាន់តែធ្វើការចាត់ចែងតាមវិធីនៃការផ្ទេរការកាន់កាប់ដែលមានដូចជាការប្រគល់ជាក់ស្តែង, ការប្តូរលក្ខណៈនៃការកាន់កាប់, ការប្រគល់ដោយសង្ខេប និង ការផ្ទេរការកាន់ដោយបញ្ជា ។[17]

❖ **<u>អចលនវត្ថុ</u>**

អចលនវត្ថុ គឺសំដៅទៅលើដីធ្លី និង វត្ថុដែលជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជាសំណង់ ដំណាំ រុក្ខជាតិជាអាទិ៍ ។[18] យោងតាមច្បាប់ភូមិបាល អចលនវត្ថុបែងចែកជា បី ប្រភេទ គឺ អចលនវត្ថុតាំងពីកំណើត អចលនវត្ថុតាមការកំណត់របស់ច្បាប់ និង អចលនវត្ថុតាមភ័ព្វវាសនា ។[19]

---

[15] មាត្រា ១៣៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[16] មាត្រា ១២០-៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[17] មាត្រា ២២៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[18] មាត្រា ១២០-២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[19] មាត្រា ២ ច្បាប់ភូមិបាល ឆ្នាំ២០០១

អនុលោម មាត្រា ១៦០ នៃក្រមរដ្ឋប្បវេណី បានអនុញ្ញាតអោយកម្មសិទ្ធលើអចលនវត្ថុ អាចធ្វើលទ្ធកម្មដោយសន្តតិកម្មបាន ពោលគឺមតកជនមានសិទ្ធិក្នុងការចាត់ចែងដើម្បីអោយទាយាទរបស់ខ្លួនទទួលបាននូវកម្មសិទ្ធិតាមមតកសាសន៍បាន ។

ក្នុងការអនុវត្តជាក់ស្តែង គេសង្កេតឃើញថាការផ្ទេរកម្មសិទ្ធិលើអចលវត្ថុ ច្បាប់តម្រូវអោយមានការចុះបញ្ជី ដែលជាហេតុនាំអោយអ្នកប្រតិបត្តិមតកសាសន៍ មានការលំបាកក្នុងការចាត់ចែងមត៌កដែលតម្រូវឱ្យមានការស្នើសុំរូបមន្តអនុវត្តពីតុលាការ ករណីជាលិខិតឯកជន ឬ លិខិតសម្ងាត់ ជៀសជាងការចាត់ចែងមត៌កដែលជាចលនវត្ថុដោយគ្រាន់តែផ្ទេរការកាន់កាប់ប៉ុណ្ណោះ ។[20]

**២. អាជ្ញាយុកាលលទ្ធកម្មនៃកម្មសិទ្ធិ**

អាជ្ញាយុកាលលទ្ធកម្មនៃកម្មសិទ្ធិ គឺសំដៅដល់រយៈពេលនៃការបង្ហាញឆន្ទៈយកធ្វើជាកម្មសិទ្ធិរបស់ខ្លួនទៅលើចលនវត្ថុ ឬ អចលនវត្ថុ ។

កាលបើជនដែលបានកាន់កាប់អចលនវត្ថុ ដោយសន្តិវិធី និង ដឹងឮជាសាធារណៈដោយមានឆន្ទៈយកជាកម្មសិទ្ធិ ក្នុងអំឡុងពេល ២០ឆ្នាំ ត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុនោះ និង ក្នុងអំឡុងពេល ១០ឆ្នាំ កាលបើជននោះ សុចរិត និង គ្មានកំហុង នៅពេលដែលខ្លួនចាប់ផ្តើមកាន់កាប់ ។[21]

ករណីដែលមានការកាន់ទៅលើចលនវត្ថុ ដោយសន្តិវិធី និង ដឹងឮជាសាធារណៈ ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ក្នុងអំឡុងពេល ១០ឆ្នាំ ត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើចលនវត្ថុនោះ និង ក្នុងអំឡុងពេល ៥ឆ្នាំ កាលបើជននោះ សុចរិត និង គ្មានកំហុង នៅពេលដែលខ្លួនចាប់ផ្តើមកាន់កាប់ ។

នៅក្នុងការអនុវត្ត មានការជួបប្រទះនូវបញ្ហាមួយចំនួនដែល ការធ្វើលទ្ធកម្មនៃកម្មសិទ្ធិនោះ ត្រូវបានផ្ទេរបន្តអោយទៅ អ្នកកាន់កាប់បន្ត ដូចនេះមានសំណួរលេចឡើងថាអ្នកកាន់កាប់បន្តលើ ចលនវត្ថុ ឬ អចលនវត្ថុនោះមានសិទ្ធិក្នុងការបន្តអាជ្ញាយុកាលនៃលទ្ធកម្មអ្នកកាន់កាប់មុន ដែរឬទេ ?

ដោយអនុលោមតាមមាត្រា ២៣៥ នៃក្រមរដ្ឋប្បវេណី បានបញ្ញត្តផ្តល់សិទ្ធិអោយអ្នកកាន់កាប់បន្ត មានសិទ្ធិក្នុងការអះអាងតែការកាន់កាប់របស់ខ្លួនក៏បាន ឬ អាចអះអាងការកាន់កាប់របស់ខ្លួនជាមួយនឹងការកាន់កាប់របស់អ្នកកាន់កាប់មុនក៏បាន ។

ឧទាហរណ៍ A បានកាន់កាប់ដីរបស់អ្នកដទៃអស់រយៈពេល៥ឆ្នាំហើយក៏បានទទួលមរណភាព ។ A គឺជាជនសុចរិត និង គ្មានកំហុសនៅពេលចាប់ផ្តើមកាន់កាប់ ។ ក្រោយមក B ដែលជាសន្តតិជនរបស់ A បានបន្តរស់នៅលើដីនោះអស់រយៈពេល៥ឆ្នាំ ។ B គឺជាជនសុចរិត និង គ្មានកំហុសនៅពេលចាប់ផ្តើមកាន់កាប់ ។ តើ

[20] មាត្រា ១៣៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[21] មាត្រា ១៦២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

B អាចសម្រេចអាជ្ញាយុកាលនៃលទ្ធកម្មបានដែរឬទេ ? បើសិនជាករណីសន្តតិកម្មបានទទួលស្គាល់ការអនុវត្ត មាត្រា២៣៥នោះ B អាចអាចអះអាងការកាន់កាប់របស់ខ្លួនជាមួយនឹងការកាន់កាប់របស់អ្នកកាន់កាប់មុន ហើយ B សម្រេចអាជ្ញាយុកាលនៃលទ្ធកម្មដោយសារតែបានបន្តកាន់កាប់រយៈពេល៥ឆ្នាំដោយសុចរិត និង គ្មានកំហុសពេលចាប់ផ្តើមកាន់កាប់ ។

ដូច្នេះយើងឃើញថា អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិ ក៏អាចយកមកធ្វើជាកម្មវត្ថុនៃមតកសាសន៍សម្រាប់ជាផលប្រយោជន៍ ដល់ទាយាទបានដែរ ។

### ៣. សិទ្ធិជួលអចិន្ត្រៃយ៍

សិទ្ធិជួលអចិន្ត្រៃយ៍ គឺជាការជួលរយៈពេលវែងចាប់ពី ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ និង មិនអាចលើសពី ៥០ឆ្នាំ បានឡើយ ហើយប្រសិនបើមានការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ដែលមានអំឡុងពេលលើសពី ៥០ឆ្នាំ ត្រូវបន្ថយមកត្រឹម ៥០ឆ្នាំវិញ ករណីនេះសិទ្ធិជួលអចិន្ត្រៃយ៍អាចបន្តសាជាថ្មីបាន ប៉ុន្តែអំឡុងពេលនៃការជួលមិនអាចលើសពី ៥០ឆ្នាំ បានឡើយគិតចាប់ពីថ្ងៃដែលបានបន្តសាជាថ្មីនោះ ។[22] ការបង្កើតសិទ្ធិជួលអាចិន្ត្រៃយ៍ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ យ៉ាងណាមិញប្រសិនបើពុំបានធ្វើឡើងជាលាយលក្ខណ៍អក្សរនោះទេត្រូវចាត់ទុកថាជាភតិសន្យាដែលគ្មានកំណត់អំឡុងពេល ហើយអាចត្រូវបានបញ្ចប់ដោយភាគីម្ខាងនៅពេលណាក៏បានដោយការជូនដំណឹងផ្អែកលើការរំលាយកិច្ចសន្យា ។[23]

មតកជន មានសិទ្ធិក្នុងការធ្វើអនុប្បទាន ឬ អច្ច័យទានបន្ត ទៅលើសិទ្ធិជួលអចិន្ត្រៃយ៍ដល់ទាយាទរបស់ខ្លួនបាន ដោយហេតុថា សិទ្ធិជួលអចិន្ត្រៃយ៍ត្រូវបានច្បាប់អនុញ្ញាត ក្នុងការយកធ្វើជាកម្មវត្ថុនៃសន្តតិកម្មបាន ។[24]

### ៤. សិទ្ធិលើបំណុល

សិទ្ធិលើបំណុល អាចធ្វើការអនុប្បទានបាន លើកលែងតែករណីដែលសិទ្ធិនោះមានលក្ខណៈដែលមិនអាចអនុប្បទានបាន មានន័យថា ចំពោះសិទ្ធិលើបំណុលដែលជា សាច់ប្រាក់ ឬ ទ្រព្យសម្បត្តិផ្សេងៗដែលជាកម្មវត្ថុនៃសិទ្ធិ គឺសុទ្ធតែអាចធ្វើអនុប្បទានទៅអោយអនុប្បទានិកបាន លើកទ្បែងតែកម្មវត្ថុនោះមានលក្ខណៈដាច់ខាតដែលអាចប៉ះពាល់ផលប្រយោជន៍កូនបំណុល ។[25]

[22] មាត្រា ២៤៤ និង មាត្រា ២៤៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[23] មាត្រា ២៤៥-២ និង មាត្រា ៥៩៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[24] មាត្រា ២៥២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[25] មាត្រា ៥០១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

សិទ្ធិលើបំណុល ត្រូវបានផ្ទេរតាមការព្រមព្រៀងរវាងម្ចាស់បំណុល និង អនុប្បទានិកប៉ុណ្ណោះ ។[26] ដើម្បីអាចតតាំងនឹងតតិយជន ឬ កូនបំណុលបាន អនុប្បទានិកត្រូវធ្វើការជូនដំណឹងដោយលិខិតដែលមានកាលបរិច្ឆេទស្ថាពរ ។[27]

ក្នុងន័យនេះ មតកជន អាចតាក់តែងនូវខ្លឹមសារនៃមតកសាសន៍ របស់ខ្លួនក្នុងការចាត់ចែង ឬ អនុប្បទាននូវសិទ្ធិលើបំណុលដល់ទាយាទរបស់ខ្លួនបាន ។

**៥. ការអនុប្បទានឋានៈក្នុងកិច្ចសន្យា**

បុគ្គលដែលបានធ្វើកិច្ចសន្យាជាមួយនឹងបុគ្គលផ្សេងទៀត អាចធ្វើអនុប្បទានឋានៈរបស់ខ្លួនដែលមាននៅក្នុងកិច្ចសន្យានោះ ទៅឱ្យតតិយជនបាន ។ ពាក្យថា ឋានៈនៅក្នុងកិច្ចសន្យានេះ គឺសំដៅទៅលើឋានៈជាម្ចាស់បំណុល និង ឋានៈជាកូនបំណុល ។[28] ករណីដែលអនុប្បទាននៃកិច្ចសន្យានឹងធ្វើឱ្យភាគីម្ខាងទៀតនៃកិច្ចសន្យានោះខូចប្រយោជន៍ធ្ងន់ធ្ងរ បុគ្គលដែលមានបំណងធ្វើអនុប្បទានឋានៈក្នុងកិច្ចសន្យាត្រូវទទួលការយល់ព្រមអំពីអនុប្បទាននោះ ពីភាគីម្ខាងទៀតនៃកិច្ចសន្យានោះ ។ ក្នុងន័យនេះ ករណីដែលមតកជន មានទ្រព្យអកម្ម ឬ បំណុល នោះមតកជនអាចកំណត់ ផ្តល់ឋានៈដែលជាកូនបំណុលក្នុងការទទួលកាតព្វកិច្ច ដល់សន្តតិជន ឬ អច្ច័យលាភីបាន ។ ឧទាហរណ៍ **លោក ក** មានកូនតែ ២នាក់ គាត់បានធ្វើមតកសាសន៍ផ្តល់នូវទ្រព្យសម្បត្តិអោយ **កូនទី១** ទទួលបាន៤០% នៃមត៌កសរុប និង **កូនទី២** ទទួលបាន ៦០% នៃមត៌កសរុប ប៉ុន្តែ**កូនទី២** ត្រូវរ៉ាប់រងចាត់ចែងសងបំណុលដែលឪពុកជំពាក់ **លោកស្រី ខ** ។ កូនទី២ មានសិទ្ធិមិនទទួលយកមត៌កនេះបាន ។

---

[26] មាត្រា ៥០២-១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[27] មាត្រា ៥០៣-១ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[28] មាត្រា ៥០៣ សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០១០

# ជំពូកទី២

# ទម្រង់ និងការតាក់តែងលិខិតមតកសាសន៍

# ជំពូកទី២

# ទម្រង់ និង ការតាក់តែងលិខិតមតកសាសន៍

យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ទម្រង់នៃមតកសាសន៍ត្រូវបានចែកជាពីរប្រភេទ ដែលមានដូចជា ទម្រង់មតកសាសន៍តាមវិធីធម្មតា និង ទម្រង់មតកសាសន៍តាមវិធីពិសេស ។ មតកសាសន៍ដែលស្របទៅនឹងទម្រង់នីមួយៗមានសុពលភាពចំពោះទម្រង់នោះ ពោលគឺកម្រិតនៃការទទួលស្គាល់នូវភាពត្រឹមត្រូវ និង ភាពច្បាស់លាស់ មានដោយឡែកពីគ្នាទៅតាមទម្រង់ ហើយក្នុងនោះដែរ មតកសាសន៍តាមលិខិតយថាភូត គឺមានការទទួលស្គាល់ពីភាពត្រឹមត្រូវ និង ច្បាស់លាស់ជាងទម្រង់ផ្សេងៗដ៏ទៃទៀត ។ មតកសាសន៍ដែលធ្វើឡើងមិនត្រូវនឹងទម្រង់ទាំងពីរប្រភេទនេះ ពុំមានសុពលភាពក្នុងការអនុវត្តនោះទេនឹងត្រូវបានចាត់ទុកជាមោឃៈ។[29]

នៅក្នុងជំពូកទី២នេះ យើងនឹងសិក្សាទៅលើលក្ខខណ្ឌសារធាតុរួមទាំងលក្ខខណ្ឌទម្រង់ និង វិធីតាក់តែងមតកសាសន៍ ដែលមានដូចជា៖ ផ្នែកទី១ ទម្រង់ និងការតាក់តែងមតកសាសន៍តាមវិធីធម្មតា និង ផ្នែកទី២ ទម្រង់ និងការតាក់តែងមតកសាសន៍តាមវិធីពិសេស ។

## ផ្នែកទី ១ ទម្រង់ និង ការតាក់តែងមតកសាសន៍តាមវិធីធម្មតា

មតកសាសន៍តាមវិធីធម្មតា គឺជាមធ្យោបាយមួយសម្រាប់អោយមតកជនដែលស្ថិតនៅក្នុងស្ថានភាពប្រក្រតី(មិនស្ថិតក្នុងស្ថានភាពបន្ទាន់) ធ្វើការតាក់តែងនូវមតកសាសន៍ទៅតាមទម្រង់ដែលច្បាប់បានកំណត់ និងផ្តល់លទ្ធភាពដល់មតកជននូវជម្រើសក្នុងការរើសយកទម្រង់នៃលិខិតបណ្តាំ ដែលខ្លួនពេញចិត្តស្របតាមជីវភាព, សមត្ថភាពរបស់ខ្លួន និង កម្រិតនៃសុក្រឹតភាពលើលិខិតរបស់ខ្លួន ម្យ៉ាងទៀតនោះមតកជន មានពេលវេលាគ្រប់គ្រាន់ក្នុងការគិតពិចារណា និង កែតម្រូវទៅលើខ្លឹមសារនៃមតកសាសន៍ ចំណែកឯសុពលភាពនៃអានុភាពមតកសាសន៍មានភាពយូរអង្វែងជាង មតកសាសន៍តាមវិធីពិសេស ។

ក្នុងការអនុវត្តជាក់ស្តែង យើងឃើញថាទោះបីជាមានច្បាប់បានកំណត់ជាក់លាក់ទៅលើទម្រង់ និង របៀបនៃការតាក់តែងលិខិតបណ្តាំយ៉ាងណាក៏ដោយ ក៏យើងសង្កេតឃើញថាប្រជាជនខ្មែរ ភាគច្រើនតែធ្វើបណ្តាំដោយផ្ទាល់មាត់ដោយខ្លួនជឿជាក់ថា ទាយាទ ឬ កូនៗ នឹងគោរពតាមឱវាទរបស់ខ្លួនតែវិធីទាំងអស់នេះពុំត្រូវបានច្បាប់គាំពារនោះទេ ដូច្នេះដើម្បីឱ្យកាន់តែច្បាស់ទៅលើមតកសាសន៍តាមវិធីធម្មតា យើងនឹងសិក្សាទៅលើទម្រង់នៃលិខិតមតកសាសន៍តាមវិធីធម្មតា, សមាសភាពចូលរួម, ការតាក់តែងលិខិតមតកសាសន៍ ។

[29] មាត្រា ១១៧០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**កថាភាគទី ១ ទម្រង់នៃលិខិតមតកសាសន៍តាមវិធីធម្មតា**

ជម្រើសនៃទម្រង់របស់មតកជន នឹងផ្តល់អោយនូវភាពខុសគ្នាទៅលើនីតិវិធីក្នុងការតាក់តែងមតកសាសន៍ទៅតាមទម្រង់ ថែមទាំងសុពលភាពនៃលិខិតបណ្តាំផងដែរ ។

- ទម្រង់មតកសាសន៍តាមវិធីធម្មតាដែលត្រូវបានកំណត់ដោយច្បាប់រួមមានដូចជា ៖
  - ✓ ទម្រង់ជាលិខិតយថាភូត
  - ✓ ទម្រង់ជាលិខិតឯកជន
  - ✓ ទម្រង់ជាលិខិតសម្ងាត់ ។

**១. ទម្រង់ជាលិខិតយថាភូត**

លិខិតយថាភូត គឺជាលិខិតដែលតាក់តែងឡើងស្របតាមរូបមន្តច្បាប់ ដោយមន្ត្រីសាធារណៈ ដែលត្រូវបានអនុញ្ញាតក្នុងការប្រតិបត្តិនូវមុខងារទាំងនេះ ដោយក្នុងនោះក៏រាប់បញ្ចូលទាំងសារការីផងដែរ ។[30] លិខិតយថាភូត ត្រូវបានទទួលស្គាល់ថាជាឯកសារ និង ជាភស្តុតាងរឹងមាំ ហើយត្រូវបានគេជឿទុកចិត្ត ដូច្នេះក្នុងពេលដែលអនុវត្តទម្រង់ទាំងនេះ មិនតម្រូវអោយមានការពិនិត្យបញ្ជាក់ពីសុពលភាព ឬ ភាពត្រឹមត្រូវនោះទេ លើកលែងតែមានភស្តុតាងបញ្ជាក់ពីភាពសង្ស័យលើការក្លែងបន្លំដោយសារការី ។

មតកជនដែលជ្រើសយកមតកសាសន៍តាមទម្រង់លិខិតយថាភូត បានផ្តល់នូវគុណសម្បត្តិនិងគុណវិបត្តិដូចជា ៖

- <u>**គុណសម្បត្តិ**</u>
  - ✓ ខ្លឹមសារនៃបណ្តាំមានភាពច្បាស់លាស់
  - ✓ ងាយស្រួលសម្រាប់មតកជនដែលមិនចេះអក្សរ
  - ✓ មិនចាំបាច់មានការពិនិត្យបញ្ជាក់ក្នុងពេលអនុវត្តមតកសាសន៍ ។
- <u>**គុណវិបត្តិ**</u>
  - ✓ ចាំបាច់មានអន្តរាគមន៍ពីសារការី
  - ✓ សាក្សីដឹងឮអំពីខ្លឹមសារនៃមតកសាសន៍
  - ✓ ចំណាយថវិកា ។

[30] ទំព័រទី១៩ សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ ឆ្នាំ២០០៧

**២. ទម្រង់ជាលិខិតឯកជន**

លិខិតឯកជន គឺសំដៅដល់មតកសាសន៍ដែល ម្ចាស់បណ្តាំធ្វើការសរសេរនូវខ្លឹមសារបណ្តាំដោយខ្លួនឯង រួមទាំងការចុះថ្ងៃខែឆ្នាំ និងការចុះហត្ថលេខា ។ មតកជនដែលជ្រើសយកមតកសាសន៍តាមទម្រង់លិខិតឯកជនបានផ្តល់នូវគុណសម្បត្តិនិងគុណវិបត្តិដូចជា ៖

- **<u>គុណសម្បត្តិ</u>**
  - ✓ មិនអស់សោហ៊ុយ
  - ✓ អាចរក្សាការសម្ងាត់នៃលិខិតមតកសាសន៍ ។
- **<u>គុណវិបត្តិ</u>**
  - ✓ មិនសូវមានភាពត្រឹមត្រូវ
  - ✓ មានការលំបាកសម្រាប់មតកជនដែលមិនចេះអក្សរ
  - ✓ អាចមានការបាត់លិខិតបណ្តាំ ,មានការក្លែងលិខិត ឬមានការបន្លំ
  - ✓ ចាំបាច់ត្រូវឆ្លងកាត់ការត្រួតពិនិត្យបញ្ជាក់ដើម្បីអនុវត្តមតកសាសន៍ ។

**៣. ទម្រង់ជាលិខិតសម្ងាត់**

មតកសាសន៍ដោយលិខិតសម្ងាត់ គឺសំដៅដល់លិខិតបណ្តាំដែលធ្វើឡើងដោយមតកជន ឬ តតិយជនដែលជួយសម្រួលដល់ការសរសេរខ្លឹមសារនៃមតកសាសន៍ជំនួសមតកជន ដោយរក្សាជាសម្ងាត់ ដែលជួយការពារកុំអោយមានការលុបចោល ឬ ការកែប្រែដោយតតិយជន ។[31] ក្រោយពីការតាក់តែងលិខិតបណ្តាំរួច មតកជនត្រូវធ្វើការតម្កល់នៅមន្ទីរសារការី ដោយធ្វើសេចក្តីថ្លែងការណ៍ចំពោះមុខសារការី និង សាក្សី២នាក់ ។

មតកជនដែលជ្រើសយកមតកសាសន៍តាមទម្រង់លិខិតសម្ងាត់ បានផ្តល់នូវគុណសម្បត្តិនិងគុណវិបត្តិដូចជា ៖

- **<u>គុណសម្បត្តិ</u>**
  - ✓ មតកជនដែលមិនចេះអក្សរក៏អាចធ្វើបាន
  - ✓ ការពារការក្លែងបន្លំ
  - ✓ អាចរក្សាការសម្ងាត់នៃលិខិតមតកសាសន៍ ។
- **<u>គុណវិបត្តិ</u>**
  - ✓ តម្រូវអោយមានការអន្តរាគមន៍ពីសារការី
  - ✓ ចាំបាច់ត្រូវឆ្លងកាត់ការត្រួតពិនិត្យបញ្ជាក់ដើម្បីអនុវត្តមតកសាសន៍ ។

---

[31] មាត្រា ១១៧៥ សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០១០

### កថាភាគទី ២ សមាសភាពចូលរួម

សមាសភាពសំខាន់ៗ ដែលអាចមាន ឬ តម្រូវអោយមាន ក្នុងការតាក់តែងមតកសាសន៍មានដូចជា ៖ មតកជន, សារការី និង សាក្សី ។

**១. មតកជន**

នីតិជន ឬ អនីតិជនដែលទទួលបានអត្ថាធិនភាព សុទ្ធតែអាចអាចធ្វើមតកសាសន៍បាន ពោលគឺជាបុគ្គលមានសមត្ថភាពក្នុងការធ្វើសកម្មភាព ។ មួយវិញទៀតជននៅក្រោមហិតូបត្ថម្ភ ឬ ជនដែលនៅក្រោមអាណាព្យាបាលទូទៅ ក៏អាចធ្វើមតកសាសន៍បានដែរ ប៉ុន្តែដំណើរការនៃការតាក់តែងលិខិតមតកសាសន៍របស់ជនកម្រិតសមត្ថភាពទាំងនេះមានលក្ខខណ្ឌតម្រូវ ដែលក្នុងនោះរួមមានដូចជា ៖

- ✓ ចំពោះជនស្ថិតនៅក្រោមរបបហិតូបត្ថម្ភ ដែលត្រូវបានគេស្គាល់ថាជាជនដែលមានស្មារតីតិចតួចក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់ទៅលើសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកស្មារតី ប៉ុន្តែអាចធ្វើសកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃរបស់ខ្លួនបាន ដូច្នេះកំឡុងពេលនៃការតាក់តែងមតកសាសន៍ ច្បាប់តម្រូវអោយជននេះមានស្មារតីនឹងនរក្នុងការបង្ហាញនូវឆន្ទៈរបស់ខ្លួន ។[32]
- ✓ ចំពោះជនស្ថិតក្រោមរបបអាណាព្យាបាលទូទៅ ដែលជាជនស្ថិតក្រោមស្ថានភាពជានិរន្តរ៍, កង្វះនូវសមត្ថភាពយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់របស់ខ្លួន ដូច្នេះក្នុងការតាក់មតកសាសន៍របស់ជនស្ថិតក្រោមអាណាព្យាបាលទូទៅ ច្បាប់តម្រូវអោយជននេះត្រូវសះស្បើយ និង មានស្មារតីនឹងនរមួយរយៈពេលឡើងវិញនូវសមត្ថភាពនៃការយល់ដឹង និង វិនិច្ឆ័យសកម្មភាពរបស់ខ្លួន ហើយចាំបាច់ត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិតយ៉ាងតិច២នាក់ ។[33]

ដោយឡែកបុគ្គលដែលមិនអាចនិយាយបានក៏អាចបង្ហាញឆន្ទៈក្នុងការធ្វើបណ្តាំ ដែលស្របតាមទម្រង់លិខិតថាភូត និង ទម្រង់ជាលិខិតសម្ងាត់ដែរ ដោយមានជំនួយរបស់អ្នកបកប្រែក្នុងការធ្វើសេចក្តីថ្លែងការណ៍អំពីខ្លឹមសារនៃមតកសាសន៍ ឬ ធ្វើសេចក្តីថ្លែងការណ៍ថាលិខិតនោះជាលិខិតមតកសាសន៍ តាមការបកប្រែរបស់អ្នកបកប្រែ ឬ សរសេរដោយដៃខ្លួនផ្ទាល់នៅចំពោះមុខសារការី ។[34]

រីឯករណីដែលប្រជាជនខ្មែរ ដែលរស់នៅបរទេសមានសិទ្ធិក្នុងការធ្វើបណ្តាំចាត់ចែងនូវទ្រព្យសម្បត្តិរបស់ខ្លួនដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន ដោយធ្វើមតកសាសន៍តាមទម្រង់លិខិតយថាភូត និង

[32] មាត្រា ១១៦៨ សេចក្តីកំណត់ក្រមរដ្ឋប្បវេណី ភាគ៦ ឆ្នាំ២០១០

[33] មាត្រា ១១៦៨ សេចក្តីកំណត់ក្រមរដ្ឋប្បវេណី ភាគ៦ ឆ្នាំ២០១០

[34] មាត្រា ១១៧៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ទម្រង់លិខិតសម្ងាត់នៅចំពោះមុខសារការីបរទេស ។ ករណីជនជាតិខ្មែរដែលមិនចេះភាសាបរទេស អាចមក កុងស៊ុលកម្ពុជាដើម្បីធ្វើលិខិតមតកសាសន៍បាន ព្រោះថាច្បាប់បានកំណត់ផ្តល់សិទ្ធិអោយមន្ត្រីកុងស៊ុងអនុវត្ត មុខងាររបស់សារការី ។[35]

**២. សារការី**

សារការី ត្រូវបានស្គាល់ថាជាមន្ត្រីសាធារណៈ ដែលទទួលបាននូវប្រតិភូកម្មអំណាចពីរដ្ឋតាមរយៈការ តែងតាំងពីរាជរដ្ឋាភិបាលឱ្យបំពេញបេសកម្មផ្តល់យថាភូតភាពដល់រាល់កិច្ចសន្យា ឬ លិខិតគតិយុត្តទាំងឡាយ របស់បុគ្គលឯកជននៅក្នុងក្របខណ្ឌនៃមន្ទីរសារការីរបស់ខ្លួន និង មានតួនាទីក្នុងការតាក់តែងលិខិតយថាភូត, បញ្ជាក់អំពីលក្ខណៈពិតប្រាកដត្រឹមត្រូវ, ធានារ៉ាប់រងអំពីកាលបរិច្ឆេទ, តម្កល់រក្សាទុក និង ចេញសេចក្តីចម្លង លិខិតយថាភូតនៃលិខិតទាំងឡាយដែលត្រូវតែឱ្យបញ្ជាក់ ។[36]

នៅក្នុងដំណើរការតាក់តែងលិខិតយថាភូត សារការីមានកាតព្វកិច្ចក្នុងការប្រឹក្សា និង ផ្តល់យោបល់ ដល់មតកជនអំពីសិទ្ធិដែលខ្លួនមានដូចជា សិទ្ធិក្នុងការកំណត់ចំណែកមត៌ក, សិទ្ធិក្នុងការកាត់ផ្តាច់ចំណែកមត៌ក, សិទ្ធិទទួលស្គាល់កូន, សិទ្ធិជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍ និង សិទ្ធិក្នុងការផ្តល់អំណាចអាណាព្យាបាល បន្តរួមទាំងលទ្ធផលក្រោយការអនុវត្តលិខិតមតកសាសន៍ ។

សារការី មានកាតព្វកិច្ចរក្សាទុកនូវលិខិតមតកសាសន៍យ៉ាងហោចណាស់៤០ឆ្នាំ គិតពីកាលបរិច្ឆេទនៃ ឯកសារ ឬថ្ងៃបញ្ចប់សំណុំរឿង ។[37]

**៣. សាក្សី**

វត្តមានរបស់សាក្សី ពិតជាមានសារៈសំខាន់ណាស់នៅក្នុងការធ្វើមតកសាសន៍ ដូចនេះមិនមែនគ្រប់ បុគ្គលទាំងអស់សុទ្ធ តែអាចក្លាយជាសាក្សីនៅក្នុងការធ្វើមតកសាសន៍បាននោះទេ ព្រោះអាចមានការប៉ះពាល់ ដល់សុពលភាពនៃទម្រង់ ។

- សមត្ថភាពបុគ្គលដែលមិនអាចក្លាយជាសាក្សីក្នុងការចូលរួមធ្វើមតកសាសន៍ រួមមានដូចជា ៖
  - ✓ អនីតិជន
  - ✓ ជនដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី ហើយនឹងសហព័ទ្ធ និងញាតិខ្សែលោហិត ផ្ទាល់ របស់ជនទាំងនោះ

[35] មាត្រា១១៨១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[36] សិក្ខាសាលាស្តីពីវិជ្ជាជីវៈសារការីរបស់ សារការី នៅ សុជាតា ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២១

[37] មាត្រា១៤ ច្បាប់ស្តីពីបណ្ណាសារ ឆ្នាំ២០០៥

- ✓ បើសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ជាលិខិតយថាភូត ឬ ជាលិខិតសម្ងាត់ សហព័ទ្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី និង និយោជិត របស់សារការីនោះ ។[38]

មុននឹងបុគ្គលម្នាក់ អាចក្លាយជាសាក្សីក្នុងរឿងមតកសាសន៍ បុគ្គលនោះត្រូវធ្វើការអះអាងនៅចំពោះមុខសារការីថាខ្លួនមិនមានជាប់ពាក់ព័ន្ធជាញាតិលោហិតខ្សែផ្ទាល់នឹងម្ចាស់បណ្តាំ ហើយយល់ព្រមផ្តល់ចម្លើយជូនសមត្ថកិច្ចមន្ត្រីពាក់ព័ន្ធនៅពេលដែលមានការអនុវត្តខ្លឹមសារនៃលិខិតមតកសាសន៍ ក៏ព្រោះតែសាក្សីមានតួនាទីក្នុងការអះអាងដឹងឮពីភាពត្រឹមត្រូវ និង ពេញលេញទៅលើសកម្មភាព និង សមត្ថភាពរបស់ម្ចាស់បណ្តាំនៅក្នុងពេលតាក់តែងលិខិតមតកសាសន៍ ។

**កថាភាគទី ៣ ការតាក់តែងលិខិតមតកសាសន៍**

ដូចដែលបានលើកឡើងខាងលើការតាក់តែងលិខិតមតកសាសន៍ មាននីតិវិធីខុសគ្នាទៅតាមទម្រង់ដែល ភាពខុសគ្នានោះមានដូចជា ការអន្តរាគមន៍របស់សារការី, ការចូលរួមរបស់សាក្សី និង របៀបនៃការរក្សាទុក ឬ ការតម្កល់នៃលិខិតបណ្តាំ ។ យ៉ាងណាមិញ អត្ថន័យនៃខ្លឹមសារដែលមានចែងនៅក្នុងលិខិតមតកសាសន៍នោះពុំមានភាពខុសគ្នាក្រៅពី ឆន្ទៈរបស់មតកជននោះទេ ហើយការបង្ហាញឆន្ទៈនេះផងដែរ ច្បាប់ក៏បានកំណត់អោយមតកជន មានសិទ្ធិក្នុងការចែងខ្លឹមសារក្នុងមតកសាសន៍របស់ខ្លួនដែលរួមមានដូចជា ការផ្តាច់មត៌កពីសន្តតិជន, ការកំណត់នូវវិធីបែងចែកមត៌ក, ការអនុប្បទានទ្រព្យសម្បត្តិ, ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍, ការបង្កើតនីតិបុគ្គលមូលនិធិ, ការទទួលស្គាល់កូន, ការកំណត់អ្នកអាណាព្យាបាល និង ការផ្តែផ្តាំចុងក្រោយ ។

- ➢ <u>**ការផ្តាច់មត៌កពីសន្តតិជន**</u>

មតកជនមានសិទ្ធិក្នុងការកាត់ផ្តាច់មត៌កពីសន្តតិជន កាលបើសន្តតិជនបានធ្វើនូវសកម្មភាពដែលមិនគប្បីទៅលើមតកជន ។ នីតិវិធីនៃការកាត់ផ្តាច់អាចត្រូវបានធ្វើឡើងដោយម្ចាស់បណ្តាំ សរសេរក្នុងខ្លឹមសារនៃមតកសាសន៍អំពីការកាត់ផ្តាច់មត៌ក ពីសន្តតិជនដោយយោងនូវមូលហេតុដែលបានកំណត់ក្នុង មាត្រា ១១៥១ នៃក្រមរដ្ឋប្បវេណី ។ នៅពេលដែលមតកសាសន៍ចាប់ផ្តើមមានអានុភាពក្នុងការអនុវត្ត អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើការដាក់ពាក្យស្នើសុំកាត់ផ្តាច់មត៌កពីសន្តតិជនទៅតុលាការ ដើម្បីអោយតុលាការធ្វើការថ្លឹងថ្លែង និង វិនិច្ឆ័យនូវសកម្មភាពរបស់សន្តតិជនរួចធ្វើការសម្រេចសេចក្តី ។ សន្តតិជនដែលទទួលរងការកាត់ផ្តាច់អាច ធ្វើវិវាទទៅលើអត្ថិភាព ឬ នត្ថិភាពនៃការបង្ហាញនូវឆន្ទៈសុំផ្តាច់ ឬ មូលហេតុដែលជាអំណះអំណាងរបស់មតកជន ។ យ៉ាងណាមិញ ការកាត់ផ្តាច់នេះពុំមានអានុភាពឡើយ ប្រសិនបើមានការព្រមព្រៀងរវាងសហសន្តតិជនទាំង

[38] មាត្រា១១៧២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

អស់ព្រមព្រៀងគ្នាយល់ព្រមផ្តល់សិទ្ធិអោយ ជនដែលត្រូវកាត់ផ្តាច់មត៌កមានសិទ្ធិរួមចំណែកទទួលបានមត៌កវិញ ដូចនេះ អ្នកប្រតិបត្តិមតកសាសន៍ពុំចាំបាច់ដាក់ពាក្យសុំទៅតុលាការនោះទេ ក៏ព្រោះថាការព្រមព្រៀងនេះត្រូវបានចាត់ទុកដូចនឹងប្រទានកម្មនូវចំណែកដែលសហសន្តតិជនមាន អោយទៅជនដែលត្រូវកាត់ផ្តាច់មត៌ក ។[39]

➢ <u>**ការកំណត់នូវវិធីបែងចែកមត៌ក**</u>

មតកជន អាចកំណត់នូវវិធីបែងចែងមតកសាសន៍នូវចំណែកមត៌កដែលសន្តតិជនម្នាក់ទទួលបាន និង អាចប្រគល់សិទ្ធិតំណាងអាណត្តិអោយតតិយជនកំណត់វិធីក្នុងការកំណត់នេះ ។ ឧទាហរណ៍ លោក **ក** មាន កូន៣នាក់ ហើយគាត់បានធ្វើមតកសាន៍ដោយបានកំណត់អោយ**កូនទី១** ទទួលបានផ្ទះ ចំណែក**កូនទី២** ទទួលបានរថយន្ត និង**កូនទី៣**ទទួលបានភាគហ៊ុនក្រុមហ៊ុនជាដើម ។ មតកជនក៏អាចធ្វើការបង្អង់នូវអានុភាពក្នុងការអនុវត្តមតកសាសន៍ដោយហាមឃាត់មិនអោយបែងចែកនៅក្នុងអំឡុងពេលដែលមិនលើសពី៥ឆ្នាំ ។[40]

ដូចឧទាហរណ៍ដែលបានលើឡើងខាងលើ លោក **ក** អាចកំណត់នូវកាលបរិច្ឆេទនៃការចាប់ផ្តើមអនុវត្តមតសាសន៍ ក្រោយពីគាត់ទទួលមរណភាពដោយមិនលើសពី៥ឆ្នាំ ។

➢ <u>**ការអនុប្បទានទ្រព្យសម្បត្តិ**</u>

មតកជន មានសិទ្ធិក្នុងការធ្វើអនុប្បទាននូវទ្រព្យសម្បត្តិរបស់ខ្លួនដល់សន្តតិជន ឬ តតិយជនដែលមិនមែនជាសន្តតិជន នូវទ្រព្យសម្បត្តិមួយផ្នែក ឬ ទាំងអស់របស់ខ្លួនបានដោយមិនរំលោភលើភាគបម្រុង ។[41] ពាក្យថា "ភាគបម្រុង" ត្រង់ចំណុចនេះគឺសំដៅដល់ របបធានានូវចំណែកមត៌កដែលកំណត់ដោយច្បាប់ ចំពោះសន្តតិជនដែលមានសិទ្ធិក្នុងការទទួលភាគបម្រុង ។ កាលបើមតកជន បានចាត់ចែងនូវមត៌កដោយបំពាននូវភាគបម្រុងនោះ សន្តតិជនដែលមានសិទ្ធិក្នុងការទទួលភាគបម្រុង អាចធ្វើវិវាទដើម្បីបន្ថយនូវចំណែកមត៌កដែលទាយាទទទួលបាន ដើម្បីបង្គ្រប់ភាគបម្រុង ។

❖ **ចំណាំ៖**

ពាក្យថា "អនុប្បទាន" និង "អច្ច័យទាន" មានភាពខុសគ្នាត្រង់ចំណុចថា អនុប្បទាន ភាគច្រើនត្រូវបានគេប្រើនៅក្នុងការកំណត់នូវវិធីបែងចែកមត៌កដល់សន្តតិជន មានន័យថាកាលបើមតកជនបានធ្វើអនុប្បទានអោយសន្តតិជននូវមត៌កដែលមានតម្លៃតិចជាង សន្តតិកម្មតាមច្បាប់នោះសន្តតិជននៅតែមានសិទ្ធិទទួលបានចំណែកមត៌កដែលនៅសល់ ។ ឧទាហរណ៍៖ លោក **ក** មានទ្រព្យសម្បត្តិតម្លៃសរុប ៩០០,០០០ដុល្លា និង កូន ៣នាក់ ដោយលោក **ក** បានធ្វើមតកសាសន៍អនុប្បទានដល់**កូនទី១** ទទួលបានដី៣កន្លែងដែលមានតម្លៃ

[39] មាត្រា១១៥១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[40] មាត្រា១១៨៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[41] មាត្រា១១៨៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

៤០០,០០០ដុល្លា ហើយ**កូនទី២** ទទួលបានផ្ទះ១ខ្នងដែលមានតម្លៃ ២០០,០០០ដុល្លា ចំណែកឯ**កូនទី៣** ទទួលបានចលនវត្ថុដែលមានតម្លៃសរុប ២០០,០០០ដុល្លា ដូចនេះមត៌កដែលនៅសល់គឺ ១០០,០០០។ ដូច្នេះ មានសំនួរលេចឡើងថាមត៌កដែលនៅសល់ត្រូវបានទៅលើអ្នកណា ? ការកំណត់ចំណែកមត៌កខាងលើគឺជាការ កំណត់នូវវិធីបែងចែកមត៌កមិនមែនជាអច្ច័យទាននោះទេ ក៏ព្រោះតែកូនដែលទទួលបានមត៌កតិចជាងសន្តតិកម្ម តាមច្បាប់ សន្តតិជននេះនៅមានសិទ្ធិទទួលនូវចំណែកមត៌កដែលនៅសល់ ។ ដោយមើលទៅលើឧទាហរណ៍ ខាងលើ សន្តតិកម្មដែលកំណត់ដោយច្បាប់គឺកូនម្នាក់ៗមានសិទ្ធិទទួលបាន **១/៣** នៃមត៌កសរុបដែលត្រូវនឹង ចំនួន ៣០០,០០០ដុល្លា យ៉ាងណាមិញ**កូនទី១**ទទួលបានចំណែកលើស ដូច្នេះមិនអាចទទួលបានសន្តតិកម្ម ផ្សេង ឬ មត៌កដែលនៅសល់នោះទេ ដូចនេះមត៌កដែលនៅសេសសល់ត្រូវបានទៅលើ **កូនទី២** និង **កូនទី៣** ដែលម្នាក់ៗទទួលបាន ៥០,០០០ដុល្លា ។

ចំណែកឯ "អច្ច័យទាន" មានការលំបាកក្នុងការកំណត់ថាជាការបង្ហាញឆន្ទៈរបស់មតកជនជា ការ កំណត់វិធីក្នុងការបែងចែកមត៌ក ឬ ជាការធ្វើអច្ច័យទាន ចំពោះសន្តតិជន ដោយឡែក "អច្ច័យទាន" មានភាព ងាយស្រួលក្នុងកំណត់ចំពោះតតិយជន ក៏ព្រោះថាការប្រទានកម្មមត៌កអោយទៅ តតិយជនត្រូវបានសន្មតថា ជា "អច្ច័យទាន" រីឯការប្រទានកម្មមត៌កដល់សន្តតិជនត្រូវបានសន្មតថាជា "ការកំណត់នូវវិធីនៃការបែងចែកមត៌ក" កាលបើមតកជនមិនបានបង្ហាញនូវឆន្ទៈច្បាស់លាស់ ។[42] ដោយយោងឧទាហរណ៍ដូចខាងលើ កាលបើមតជន បានចែងកំណត់ក្នុងមតកសាសន៍ជាក់ច្បាស់ដោយអោយ **កូនទី២** មានសិទ្ធិទទួលបានផ្ទះតែ១ខ្នងដែលមាន តម្លៃ ២០០,០០០ដុល្លាប៉ុណ្ណោះ និង មិនមានសិទ្ធិទទួលបានមត៌កក្រៅពីនេះទេ នោះមត៌កដែលនៅសល់នឹង ត្រូវបានទៅលើ **កូនទី៣**ទាំងអស់ ។ ការបង្ហាញនូវឆន្ទៈបញ្ជាក់ច្បាស់លាស់នូវចំណែកមត៌កចំពោះសន្តតិជន ដែលអាចទទួលបានបែបនេះ ទើបជាការធ្វើអច្ច័យទាន ដែលធ្វើអោយសន្តតិជននោះទទួលបាននូវទ្រព្យសម្បត្តិ ជាក់លាក់ ។

- **<u>ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍</u>**

មតកជន អាចជ្រើសយកសហសន្តតិជនណាម្នាក់ ឬ ចាត់តាំងតតិយជនអោយក្លាយជាអ្នកប្រតិបត្តិ មតកសាសន៍បាន ។ ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍នេះ មិនមែនមានលក្ខណៈបង្ខំនោះទេ អ្នកដែល ត្រូវបានជ្រើសអោយក្លាយជាអ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិក្នុងការបដិសេធ ដោយធ្វើការជូនដំណឹងដល់ សន្តតិជនដោយគ្មានការយឺតយ៉ាវ ប៉ុន្តែកាលបើជននោះ បានបង្ហាញឆន្ទៈយល់ព្រមក្លាយជាអ្នកប្រតិបត្តិ មតកសាសន៍នោះ ដើម្បីលាឈប់ត្រូវមានការអនុញ្ញាតពីតុលាការ ។[43]

[42] មាត្រា១១៨៥-២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[43] មាត្រា១២១៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

- **វិភាគទានទ្រព្យសម្បត្តិដើម្បីបង្កើតនីតិបុគ្គលមូលនិធិ**

មតកជន អាចបង្ហាញឆន្ទៈដោយចែងកំណត់នៅក្នុងមតកសាសន៍ ដើម្បីវិភាគទាននូវទ្រព្យសម្បត្តិដើម្បីបង្កើតនូវនីតិបុគ្គលមូលនិធិ ក្នុងគោលបំណងបម្រើនូវផលប្រយោជន៍សាធារណៈ ដោយមិនយកកម្រៃតបស្នង ។[44]

- **ការទទួលស្គាល់កូន**

ការទទួលស្គាល់កូន អាចត្រូវបានធ្វើឡើងតាមមតកសាសន៍ ដោយអ្នកប្រតិបត្តិមតកសាសន៍ធ្វើការជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាន ។ ការទទួលស្គាល់កូន គឺសំដៅដល់ការបង្កើតនូវអានុភាពនៃបិតុភាព រវាងឪពុក និង កូន ហើយការទទួលស្គាល់នេះ មានអានុភាពប្រតិសកម្មតាំងពីកំណើតកូន ថែមទាំងអោយកូន ក្លាយជាសន្តតិជនម្នាក់ទៀតផង ។

- **ការកំណត់អ្នកអាណាព្យាបាល**

មតកសាសន៍ អាចចែងកំណត់អំពីជនដែលអាចទទួលបានអំណាចអាណាព្យាបាលបន្ត សម្រាប់អនីតិជនកាលបើគ្មានអាណាព្យាបាលទំនុបបម្រុងពោលគឺគ្មានទាំងឪពុក និងម្តាយ ។ ការកំណត់អ្នកអាណាព្យាបាល មិនមាននូវលក្ខណៈនៃការបង្ខំនោះទេ ជនដែលត្រូវបានជ្រើសតាំងនេះមានសិទ្ធិក្នុងការបដិសេធនៃការកំណត់នេះ ។[45]

- **ការផ្តែផ្តាំចុងក្រោយ**

ក្រៅពីនេះ មតកជនអាចធ្វើការផ្តែផ្តាំនូវពាក្យពេជច៍ចុងក្រោយដូចជាការផ្តល់ដំបូន្មាន, អប់រំ, ការផ្តល់យោបល់ ដើម្បីអោយមានភាពសុខដុមរមនាដល់ក្រុមគ្រួសារ និង អាចចែងអំពីករណីយកិច្ចដល់សន្តតិជនអោយគោរពតាម ។[46] កាលបើ សន្តតិជន ឬ អច្ច័យលាភី បង្ហាញឆន្ទៈយល់ព្រមទទួលមត៌កនេះ នោះសន្តតិជន ឬ អច្ច័យលាភី មានកាតព្វកិច្ចគោរពតាមការផ្តែផ្តាំរបស់មតកជន ។

**១. ការតាក់តែងមតកសាសន៍ជាលិខិតយថាភូត**

លិខិតយថាភូត ត្រូវធ្វើការតាក់តែងឡើងដោយស្របតាមទម្រង់ដែលច្បាប់បានកំណត់ដូចដែលបានចែងនៅក្នុងមាត្រា១១៧៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ដែលក្នុងទម្រង់នេះតម្រូវអោយមានដូចជា ៖

- ✓ ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច២ (ពីរ)នាក់ ។
- ✓ ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ ចំពោះសារការី ។

---

44 មាត្រា១១៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

45 មាត្រា១០៦៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

46 មាត្រា១១៨៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

- ✓ សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះ ជាលាយល័ក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និងសាក្សីនោះស្តាប់ ។
- ✓ បន្ទាប់ពីម្ចាស់បណ្តាំ និងសាក្សីបានទទួលស្គាល់ថាកំណត់ជាលាយលក្ខណ៍អក្សរនោះត្រឹមត្រូវហើយ ជននីមួយៗនោះត្រូវធ្វើអោយមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និង លំនៅដ្ឋាន ហើយត្រូវចុះហត្ថលេខារៀងៗខ្លួន ។ ប៉ុន្តែបើម្ចាស់បណ្តាំមិនអាចសរសេរអក្សរ ឬ មិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និងហត្ថលេខាដូចកំណត់ខាងលើនេះ ដោយសរសេរឈ្មោះ អាយុ និងលំនៅដ្ឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវមូលហេតុផងដែរ ។
- ✓ សារការីត្រូវសរសេរថ្ងៃខែឆ្នាំ ហើយចុះហត្ថលេខា ។

ក្នុងការតាក់តែងលិខិតយថាភូតអោយស្របតាមទម្រង់នេះ ត្រូវមានការសរសេរដូចជា៖

- ✓ បាវចនានៃព្រះរាជាណាចក្រកម្ពុជា គឺជាតិ,សាសនា,ព្រះមហាក្សត្រ ។
- ✓ ចំណងជើងនៃលិខិត ពោលគឺ ‶លិខិតមតកសាសន៍‶ ។
- ✓ បន្ទាប់មកសរសេរអំពីប្រវត្តិរូបភាគី(ម្ចាស់បណ្តាំ,អច្ច័យលាភី និង សាក្សី២រូប) ដែលមានដូចជា ឈ្មោះ, ភេទ, ជនជាតិ, សញ្ជាតិ, ថ្ងៃខែឆ្នាំកំណើត, ទីកន្លែងកំណើត, មុខរបប, នាមរបស់ម្តាយឪពុក, ស្ថានភាពគ្រួសារ, លេខអត្តសញ្ញាណប័ណ្ណ, លេខសៀវភៅគ្រួសារ និងទីលំនៅបច្ចុប្បន្ន ។
- ✓ រួចមកសរសេរឈ្មោះសារការី, នាមករណ៍ស្ថាប័ន, ប្រវត្តិរូប, លេខទូរស័ព្ទមន្ទីរ និងអ៊ីម៉ែល ។
- ✓ រួចហើយសរសេរអំពីខ្លឹមសារនៃបណ្តាំ ។
- ✓ បន្ទាប់មកសរសេរអំពីការអះអាងរបស់សាក្សីក្នុងគោលបំណងអះអាងទទួលស្គាល់អំពីសកម្មភាពរបស់មតកជននិងរួមទាំងខ្លឹមសារមតកសាសន៍ ។
- ✓ សរសេររៀបរាប់ពីការប្រព្រឹត្តទៅ និង ការរៀបចំលិខិតមតកសាសន៍ ។
- ✓ ជាចុងក្រោយបង្អស់គឺ មានការផ្តិតស្នាមមេដៃរបស់មតកជន នៅគ្រប់ទំព័រនៃលិខិតមតកសាសន៍ ចំណែកសាក្សី២រូបធ្វើការផ្តិតមេដៃនៅទំព័រក្រោយ រីឯសារការីធ្វើការពិនិត្យបញ្ជាប់រួចចុះកាលបរិច្ឆេទ, ចុះហត្ថលេខា និងបោះត្រា ។[47]

### ២. ការតាក់តែងមតកសាសន៍ជាលិខិតឯកជន

ការធ្វើមតកសាសន៍តាមលិខិតឯកជន មិនសូវមាននូវភាពស្មុគស្មាញនោះទេ ដោយគ្រាន់តែមតកជនធ្វើការសរសេរដោយខ្លួនឯងផ្ទាល់នូវឈ្មោះសាមីខ្លួន, ឈ្មោះទាយាទ, ខ្លឹមសារមតកសាសន៍រួចធ្វើការចុះថ្ងៃខែ

[47] សូមមើលឧបសម្ព័ន្ធទី៥

ឆ្នាំ និង ចុះហត្ថលេខាលើលិខិតបណ្ដាំ ។ ករណីដែលមតកជន សរសេរនូវខ្លឹមសារនៃមតកសាសន៍មានការកោសលុប ការបន្ថែម ឬការកែប្រែផ្សេងទៀត នោះមតកជនចាំបាច់ត្រូវសរសេរបន្ថែមនូវហេតុនៃការកែប្រែនោះ រួមទាំងចុះហត្ថលេខាផងដែរ បើពុំធ្វើដូចនេះខ្លឹមសារនៃការកែប្រែទាំងអស់នេះពុំមានអានុភាពឡើយ ។[48]

ច្បាប់បានកំណត់នូវលក្ខខណ្ឌដាច់ខាតដែលតម្រូវមតកជនធ្វើការសរសេរ នូវមតកសាសន៍របស់ខ្លួនដោយផ្ទាល់ដៃ ករណីបើមានមតកសាសន៍ដោយលិខិតឯកជន ដែលត្រូវបានធ្វើឡើងដោយការសរសេរជំនួយដោយអ្នកដទៃ ឬ សរសេរដោយប្រើប្រាស់ម៉ាស៊ីននឹងត្រូវបានចាត់ទុកជាមោឃៈ ក៏ព្រោះតែខ្លឹមសារនៃលិខិតឯកជន អាចត្រូវបានគេក្លែងបន្លំ ហើយមួយវិញទៀតក៏មានការលំបាកក្នុងការបញ្ជាក់ពីភាពត្រឹមត្រូវ ឬ សុក្រឹតភាពផងដែរ ដោយសារតែមតកជនមិនមានវត្តមាននៅពេលដែលលិខិតមតកសាសន៍ចាប់ផ្ដើមអនុវត្ត នោះគេមិនអាចអោយម្ចាស់បណ្ដាំធ្វើសេចក្ដីថ្លែងការណ៍បាននោះទេ ហេតុនេះការបញ្ជាក់ពីសុក្រឹតភាពនឹងអាចមានភាពខ្វះចន្លោះ ។ ជាទូទៅដើម្បីបញ្ជាក់ពីសុក្រឹតភាពនៃលិខិតឯកជន នោះគេនឹងធ្វើការផ្ទៀងមើលអក្សរ និងប្រៀបធៀបអក្សររបស់មតកជនដែលបានសរសេរក្នុងលិខិតផ្សេងៗកាលនៅរស់ ។[49]

- ការតាក់តែងមតកសាសន៍ដោយលិខិតឯកជនតម្រូវអោយមានដូចជា ៖
  - ✓ ប្រវត្តិរូបភាគី (ម្ចាស់បណ្ដាំ,ទាយាទ)
  - ✓ ខ្លឹមសារនៃបណ្ដាំ
  - ✓ ការចុះថ្ងៃខែឆ្នាំ និងហត្ថលេខា ។

### ៣. ការតាក់តែងមតកសាសន៍ជាលិខិតសម្ងាត់

មតកសាសន៍ដោយលិខិតសម្ងាត់ មានលក្ខណៈពិសេសជាងមតកសាសន៍ដោយលិខិតឯកជន ត្រង់ចំណុចដែលមតកសាសន៍ដោយលិខិតសម្ងាត់ អនុញ្ញាតអោយមានការជួយសរសេរជំនួសដោយតតិយជន និងអាចសរសេរដោយប្រើម៉ាស៊ីន ដែលផ្ដល់ភាពងាយស្រួលដល់មតកជនមិនចេះអក្សរ ថែមទាំងអាចរក្សាការសម្ងាត់នូវខ្លឹមសារនៃមតកសាសន៍ និង មិនមានការក្លែងបន្លំនូវអត្ថន័យនៃលិខិតបណ្ដាំក្នុងពេលអនុវត្ត ។

- នីតិវិធីក្នុងការតាក់តែងមតកសាសន៍ដោយលិខិតសម្ងាត់ត្រូវធ្វើឡើងតាមដំណាក់កាល ៖
  - ✓ ជាដំបូងម្ចាស់បណ្ដាំត្រូវចុះហត្ថលេខាលើលិខិតបណ្ដាំ ។
  - ✓ បន្ទាប់មកម្ចាស់បណ្ដាំត្រូវដាក់លិខិតនោះនៅក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬ សរសេរសញ្ញាសម្គាល់ ឬ មធ្យោបាយផ្សេងទៀតដែលអាចវិនិច្ឆ័យបានអំពីការបានបើកឬមិនបានបើកស្រោមលិខិតនោះ នៅមាត់ស្រោមលិខិតនោះ ។

[48] មាត្រា១១៧៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[49] មាត្រា១១៧៤ សេចក្ដីកំណត់ក្រមរដ្ឋប្បវេណី ឆ្នាំ២០១០

- ✓ ក្រោយមកម្ចាស់បណ្តាំត្រូវដាក់លិខិតដែលបានបិទជិតនោះ នៅចំពោះមុខសារការីម្នាក់ និង សាក្សី ២ (ពីរ)នាក់ និងធ្វើសេចក្តីថ្លែងការណ៍ថា លិខិតនេះជាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានជនក្រៅពីសាមីខ្លួនបានសរសេរ ត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីឈ្មោះ និង លំនៅឋានរបស់ជនដែលសរសេរនោះ ។
- ✓ ទីបញ្ចប់សារការីត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួនបានដាក់លិខិតនោះ និង សរសេរសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំ នៅលើលិខិតដែលបិទជិតនោះ ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ ជាមួយគ្នានឹងសាក្សី និង ម្ចាស់បណ្តាំ ។[50]

## ផ្នែកទី ២ ទម្រង់ និង ការតាក់តែងមតកសាសន៍តាមវិធីពិសេស

ជាក់ស្តែងការរស់នៅក្នុងសង្គម យើងអាចនឹងមានការជួបឧប្បត្តិហេតុកើតមានឡើងដោយចៃដន្យគ្រប់ពេលវេលា និងពុំមានការព្រៀងទុកជាមុនដែលអាចដាក់អោយយើងស្ថិតក្នុងស្ថានភាពបាត់បង់ជីវិត ។ ដោយយល់ឃើញអំពីហេតុកាណ៍នេះហើយបានជាច្បាប់ផ្តល់នូវវិធីក្នុងការតាក់តែងមតកសាសន៍តាមវិធីពិសេស ក្នុងគោលបំណងដើម្បីអោយមាននូវនីតិវិធីងាយស្រួល និង ភាពបត់បែនស្របតាមស្ថានភាពភ្លាមៗ(ករណីបន្ទាន់) ដល់មតកជនដែលទទួលរងគ្រោះថ្នាក់ ឬ អាចនឹងទទួលរងនូវគ្រោះថ្នាក់ ហើយបណ្តាលអោយបុគ្គលនោះបាត់បង់ជីវិត ឬ ធ្វើអោយប៉ះពាល់ដល់សមត្ថភាព ឬ ពេលវេលាគ្រប់គ្រាន់ ក្នុងការធ្វើមតកសាសន៍តាមវិធីធម្មតា ។

### កថាភាគទី ១ ទម្រង់នៃមតកសាសន៍តាមវិធីពិសេស

- ➢ ទម្រង់មតកសាសន៍តាមវិធីពិសេសដែលត្រូវបានកំណត់ដោយច្បាប់រួមមានដូចជា៖
  - ✓ មតកសាសន៍របស់ជនដែលជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ។
  - ✓ មតកសាសន៍របស់ជនដែលត្រូវជាប់ឃុំ។

### ១. មតកសាសន៍របស់ជនដែលជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត

កាលបើមានជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ដោយសារជម្ងឺ ឬ ហេតុផ្សេងទៀត មានបំណងចង់ធ្វើមតកសាសន៍ មតកសាសន៍នេះអាចធ្វើបានដោយតម្រូវឱ្យមានវត្តមានរបស់សាក្សីយ៉ាងតិច ៣នាក់ ហើយដោយប្រកាសខ្លឹមសារនៃមតកសាសន៍នោះ ដោយផ្ទាល់មាត់ ចំពោះជនម្នាក់ ក្នុងចំណោមសាក្សីនោះ ។ នៅក្នុងករណីនេះ ជនដែលទទួលការប្រកាសដោយផ្ទាល់មាត់នោះ ត្រូវសរសេរជាលាយល័ក្ខណ៍អក្សរ ហើយអានឱ្យសាក្សីស្តាប់ ឬ ឱ្យមើល ហើយនៅក្រោយពេលដែលសាក្សីនីមួយៗបានទទួលស្គាល់ថាការសរសេរនោះត្រឹមត្រូវហើយ សាក្សីនីមួយៗនោះត្រូវចុះហត្ថលេខាលើលិខិតនោះ ។[51]

---

[50] មាត្រា១១៧៥ សេចក្តីកំណត់ក្រមរដ្ឋប្បវេណី ឆ្នាំ២០១០

[51] មាត្រា១១៧៧-១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

- នីតិវិធីក្នុងការតាក់តែងមតកសាសន៍របស់ជនដែលជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិតត្រូវធ្វើឡើងតាមដំណាក់កាល ៖
  - ✓ ជាដំបូងត្រូវស្វែងរកសាក្សី៣នាក់ ។
  - ✓ បន្ទាប់មកមតកជនប្រកាសខ្លឹមសារនៃមតកសាសន៍នោះ ដោយផ្ទាល់មាត់ ។
  - ✓ សាក្សីម្នាក់ក្នុងចំណោម៣នាក់ជាអ្នកកត់ត្រានូវខ្លឹមសារនៃមតកសាសន៍ ។
  - ✓ សាក្សីនីមួយៗធ្វើការពិនិត្យបញ្ជាក់ និងចុះហត្ថលេខា ។

ទោះបីជាមតកសាសន៍ប្រភេទនេះ មានលក្ខណៈបន្ទាន់ក៏ដោយក៏សាក្សីតម្រូវអោយស្របតាមមាត្រា ១១៧២ នៃក្រមរដ្ឋប្បវេណីដែលចែងអំពីលក្ខខណ្ឌ និង សមាសភាពដែលអាចក្លាយជាសាក្សីផងដែរ ។

មតកសាសន៍របស់ជនដែលជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត នឹងលែងមានអានុភាពកាលបើសាក្សីណាម្នាក់ ឬ អ្នកពាក់ព័ន្ធនូវផលប្រយោជន៍ ពុំបានដាក់ពាក្យសុំទៅតុលាការនៅក្នុងកំឡុងរយៈពេល ១ខែ គិតចាប់ពីថ្ងៃដែលបានធ្វើមតកសាសន៍ ហើយពុំទទួលបានការបញ្ជាក់ពីតុលាការទេ ។ តុលាការ មិនអាចធ្វើការបញ្ជាក់មតកសាសន៍បានឡើយ ប្រសិនបើពុំមានជំនឿទុកចិត្តថាមតកសាសន៍នោះ ចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ ។

**២. មតកសាសន៍របស់ជនដែលត្រូវជាប់ឃុំ**

ជនដែលត្រូវជាប់ឃុំ អាចធ្វើមតកសាសន៍បានដោយមានការអន្តរាគមន៍ពីមន្ត្រីពាក់ព័ន្ធ។ ជនដែលត្រូវជាប់ឃុំនេះ ត្រូវបានច្បាប់កំណត់ដោយញែកជាពីរករណីមានដូចជា បុគ្គលដែលជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែក និង បុគ្គលដែលនៅក្នុងនាវា ឬ យន្តហោះ ។

ចំពោះបុគ្គលដែលជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែក ដោយសាលក្រម ឬសាសដីកា ឬដោយសារការចាត់ចែងផ្នែករដ្ឋបាល អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវអោយមានវត្តមានរបស់នគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ និង សាក្សី យ៉ាងតិច២នាក់។ ចំណែកឯបុគ្គលដែលនៅក្នុងនាវា ឬ យន្តហោះ អាចធ្វើលិខិតមតសាសន៍បានដោយត្រូវអោយមានវត្តមានរបស់មេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះម្នាក់ និង សាក្សីយ៉ាងតិចពីរនាក់ ។[52]

ដំណើរការតាក់តែងមតកសាសន៍នេះ ត្រូវអនុវត្តស្រដៀងគ្នានឹងដំណើរការតាក់តែងមតកសាសន៍ដោយលិខិតយថាភូតដែរ ដោយគ្រាន់តែលិខិតយថាភូតមានការអន្តរាគមន៍ពីសារការី ចំណែកមតកសាសន៍

[52] មាត្រា១១៧៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

របស់ជនដែលជាប់ឃុំមានអន្តរាគមន៍ពីមន្ត្រីពាក់ព័ន្ធ ប៉ុន្តែមតកសាសន៍របស់ជនដែលត្រូវជាប់ឃុំនេះ មិនមានសុពលភាពដូចលិខិតយថាភូតនោះទេ ។

- នីតិវិធីក្នុងការតាក់តែងមតកសាសន៍របស់ជនដែលត្រូវជាប់ឃុំត្រូវធ្វើឡើងតាមដំណាក់កាល ៖
  - ✓ ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច២ (ពីរ)នាក់ ។
  - ✓ ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ ចំពោះនគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ ករណីជាជនជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែក និង ចំពោះមេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះ ករណីជាជនជាប់ក្នុងនាវា ឬ យន្តហោះ។
  - ✓ មន្ត្រីពាក់ព័ន្ធត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះ ជាលាយលក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និងសាក្សីនោះស្តាប់ ។
  - ✓ បន្ទាប់ពីម្ចាស់បណ្តាំ និង សាក្សីបានទទួលស្គាល់ថាកំណត់ជាលាយល័ក្ខណ៍អក្សរនោះត្រឹមត្រូវហើយ ជននីមួយៗនោះត្រូវធ្វើអោយមានភាពច្បាស់លាស់នៅលើឯកសារអំពី ឈ្មោះ អាយុ និង លំនៅដ្ឋានហើយត្រូវចុះហត្ថលេខារៀងៗខ្លួន ។ ប៉ុន្តែបើម្ចាស់បណ្តាំមិនអាចសរសេរអក្សរ ឬ មិនអាចចុះហត្ថលេខាបានទេ មន្ត្រីពាក់ព័ន្ធអាចជំនួសការសរសេរ និង ហត្ថលេខាដូចកំណត់ខាងលើនេះ ដោយសរសេរឈ្មោះ អាយុ និង លំនៅដ្ឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវមូលហេតុផងដែរ។
  - ✓ មន្ត្រីពាក់ព័ន្ធត្រូវសរសេរថ្ងៃខែឆ្នាំ ហើយចុះហត្ថលេខា។

មតកសាសន៍របស់ជនដែលត្រូវជាប់ឃុំនឹងអស់សុពលភាព កាលបើម្ចាស់បណ្តាំបន្តនៅរស់ក្រោយអំឡុងពេល៦ខែ ដោយរាប់ចាប់ពីថ្ងៃដែលបានធ្វើលិខិតមតកសាសន៍នោះ ។ ច្បាប់បានកំណត់រយៈពេលអានុភាពនៃមតកសាសន៍ប្រភេទនេះ ក៏ព្រោះតែមតកសាសន៍តាមវិធីពិសេស មានគោលបំណងអនុវត្តតែក្នុងស្ថានភាពបន្ទាន់ប៉ុណ្ណោះ ដូច្នេះកាលបើម្ចាស់បណ្តាំមានវាសនារស់រានមានជីវិតក្រោយពីបានជួបគ្រោះថ្នាក់ មូលហេតុនេះម្ចាស់បណ្តាំគួរតែធ្វើមតកសាសន៍តាមវិធីធម្មតា ដែលផ្តល់នូវសុក្រឹតភាពជៀសជាងមតកសាសន៍តាមវិធីពិសេស ។

# ជំពូកទី៣

# អានុភាព និង ការអនុត្តមតកសាសន៍

# ជំពូកទី៣

# អានុភាព និង ការអនុវត្តមតកសាសន៍

នៅក្នុងជំពូកទី២ យើងបានលើកឡើងនូវលក្ខខណ្ឌ ទាំងលក្ខខណ្ឌសារធាតុ និង ទម្រង់ស្ដីពី មតកសាសន៍រួចមកហើយ ។ ដោយឡែក នៅក្នុងជំពូកទី៣ នេះយើងនឹងធ្វើការសិក្សាទៅលើ ផ្នែកទី១ ការបង្កើតអានុភាពមតកសាសន៍ , ផ្នែកទី២ អានុភាពមតកសាសន៍, ផ្នែកទី៣ ការយល់ព្រមនិងបោះបង់សន្តតិកម្ម និង ផ្នែកទី៤ ការប្រតិបត្តិមតកសាសន៍ ។

## ផ្នែកទី ១ ការបង្កើតអានុភាពមតកសាសន៍

ជាគោលការណ៍ មតកសាសន៍ ជាសកម្មភាពឯកតោភាគី របស់មតកជន ដែលសំដែងនូវឆន្ទៈជាមុន ដើម្បីចាត់ចែងនូវទ្រព្យសម្បត្តិ ឬ បំណុលរបស់ខ្លួន នៅពេលខ្លួននៅរស់ ដើម្បីយកទៅអនុវត្តនៅពេលដែលខ្លួនបានស្លាប់ ឬ ហេតុការណ៍ណាមួយដែលខ្លួនអវត្តមានដោយមិនអាចបញ្ជាក់ថាខ្លួននៅមានជីវិត ឬ គ្មានជីវិត ។ លើសពីនេះមតកជន ក៏អាចកំណត់ផងដែលពីលក្ខខណ្ឌនានា ដូចជា រយៈពេល ឬ ស្ថានភាពណាមួយ ដែលត្រូវបំពេញ ដើម្បីឱ្យមតកសាសន៍របស់ខ្លួនមានអានុភាពក្រោយពេលខ្លួនស្លាប់ ។ ដូច្នេះ មតកសាសន៍ នឹងបង្កើតអានុភាព តាមរយៈវិធានបីគឺ ការបង្កើតអានុភាពមតកសាសន៍ដោយមរណភាពមតកជន, ការបង្កើតអានុភាពមតកសាសន៍នៃការប្រកាសបាត់ខ្លួន និង លក្ខខណ្ឌបង្អង់អានុភាពនៃមតកសាសន៍ ។

### កថាភាគទី ១ ការបង្កើតអានុភាពមតកសាសន៍ដោយមរណភាពមតកជន

អនុលោមតាមមាត្រា ១១៩៤ នៃក្រមរដ្ឋប្បវេណីកថាខណ្ឌទី១ បញ្ញត្តិថា "មតកសាសន៍ ត្រូវបង្កើតអានុភាព ចាប់ពីពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព" ។ ដោយហេតុថា សន្តតិកម្ម គឺជាលិខិតបណ្ដាំ ដែលបុគ្គលម្នាក់បានធ្វើឡើងតាមទម្រង់ ដែលកំណត់ដោយច្បាប់ ដើម្បីសម្ដែងនូវឆន្ទៈចុងក្រោយ អំពីការបែងចែកទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍ បន្ទាប់ពីមរណភាព ឬ អាចនិយាយដោយងាយថា មតកសាសន៍ គឺ មតកជន បានបង្កើតឡើងដោយបង្ហាញនូវឆន្ទៈជាមុនក្នុងការចាត់ចែងនូវទ្រព្យរបស់ខ្លួន ដើម្បីយកទៅអនុវត្តនៅពេលម្ចាស់បណ្ដាំ ឬ មតកជនទទួលមរណភាព ដូច្នេះមរណភាពរបស់មតកជន គឺជាប្រធានដែលអាចធ្វើឱ្យមតកសាសន៍ចាប់ផ្ដើមមានអានុភាព ។

យ៉ាងណាមិញរបេបគិតយុត្តនៃសន្តតិកម្មនេះ វាបានឆ្លុះបញ្ចាំងពីការបាត់បង់នូវសិទ្ធិរបស់បុគ្គល ដូចមានចែងក្នុងមាត្រា ៨ បញ្ញត្តថា " រូបវន្តបុគ្គលម្នាក់ៗ មានសមត្ថភាពទទួលសិទ្ធិនៅពេលខ្លួនចាប់កំណើត ហើយបាត់បង់អស់នូវសមត្ថភាពទទួលសិទ្ធិនេះ នៅពេលទទួលមរណភាព" ។[53] អ្វីដែលសំខាន់គឺ នៅពេល

[53] មាត្រា ៨ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

សិទ្ធិបុគ្គលណាម្នាក់ត្រូវបានរលត់ដោយមរណភាព នោះដើម្បីរក្សានូវស្ថិរភាពគតិយុត្តជុំវិញ សិទ្ធិ និងកាតព្វកិច្ច ជាហេតុត្រូវចាត់ចែងឱ្យមានរបបនៃការស្នងសិទ្ធិ និង កាតព្វកិច្ចទាំងនោះ ។ ហេតុនេះការបង្កើតឡើងនូវរបបស្តីពីសន្តតិកម្ម វាជាការលើកតំកើនដល់សិទ្ធិបុគ្គលជុំវិញទ្រព្យសម្បត្តិរបស់ខ្លួន ទោះបីជាខ្លួនបានទទួលមរណភាពក្តី ។

**កថាភាគទី ២ ការបង្កើតអានុភាពមតកសាសន៍នៃការប្រកាសបាត់ខ្លួន**

ជាគោលការណ៍ទូទៅ មតកសាសន៍ បង្កើតអានុភាពនៅពេល ដែលមតកជនទទួលមរណភាព ប៉ុន្តែបើក្នុងស្ថានភាពមួយ ដែលមតកជន អវត្តមាន ឬ បានបាត់ខ្លួនដោយមិនដឹងមូលហេតុ តើវាអាចប៉ះពាល់យ៉ាងដូចម្តេចចំពោះ មតកសាសន៍ ? ហេតុនេះ ដើម្បីដោះស្រាយនូវបញ្ហាគតិយុត្តនេះ តាមរយៈក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ជារបបគតិយុត្តដែលបង្កើតឡើង ក្នុងការដោះស្រាយលើចំណោទបញ្ហានេះ ដូច្នេះដើម្បីយល់ពីខ្លឹមសារនៃរបបស្តីពីការប្រកាសបាត់ខ្លួន យើងនឹងលើកឡើងនូវ លក្ខខណ្ឌនៃការប្រកាសបាត់ខ្លួន ,នីតិវិធីនៃការប្រកាលបាត់ខ្លួន និងអានុភាពនៃការប្រកាសបាត់ខ្លួន ។

**១. លក្ខខណ្ឌនៃការប្រកាសបាត់ខ្លួន**

នៅពេលដែលបុគ្គលណាម្នាក់បានបាត់ខ្លួនទៅ ដែលធ្វើឱ្យបុគ្គលពាក់ព័ន្ធស្ថិតក្នុងស្ថានភាពមិនអាចដឹងថា បុគ្គលបាត់ខ្លួន ស្លាប់ ឬ ក៏នៅរស់ នោះគេអាចដាក់ពាក្យទៅតុលាការដើម្បីប្រកាសពីការបាត់ខ្លួនបានក្នុងលក្ខខណ្ឌចំនួនពីរ ដូចខាងក្រោម ៖

**លក្ខខណ្ឌទី១** ៖ ប្រសិនបើពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាពក្នុងអំឡុងពេល ០៥(ប្រាំ) ឆ្នាំ តុលាការអាចប្រកាសបានថា បុគ្គលនោះបានបាត់ខ្លួន តាមពាក្យស្នើសុំរបស់សហព័ទ្ធ អ្នកដែលត្រូវបានសន្មតជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា ឪពុកម្តាយ ឬ អ្នកផ្សេងទៀតដែលមានផលប្រយោជន៍តាមផ្លូវច្បាប់ ។

**លក្ខខណ្ឌទី២** ៖ ដូចលក្ខខណ្ឌទី១ខាងលើដែរ ប៉ុន្តែអំឡុងពេលកំណត់ត្រឹមរយៈពេល ១ (មួយ) ឆ្នាំ ក្នុងករណីបុគ្គលដែលចូលទៅតំបន់ដែលមានសង្គ្រាម បុគ្គលដែលមានវត្តមានក្នុងនាវាដែលបានលិច ឬ បុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងទៀតដែលអាចនាំឱ្យទទួលមរណភាព ហើយពុំមានដំណឹងច្បាស់លាស់ថាអ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាព ។[54]

**២. នីតិវិធីនៃការប្រកាសបាត់ខ្លួន**

នៅពេលដែលលក្ខខណ្ឌ ស្តីពីអំឡុងពេល និង ស្ថានភាពនៃការបាត់ខ្លួនដូចមានចែងក្នុងមាត្រា ៤១ នៃក្រមរដ្ឋប្បវេណី ត្រូវបានបំពេញ នោះ សហព័ទ្ធ, អ្នកដែលត្រូវបានសន្មតជាសន្តតិជន, អច្ច័យលាភី, អ្នកទទួល

[54] មាត្រា ៤១ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

ប្រាក់ធានារ៉ាប់រង, អ្នកមានសិទ្ធិអំណាចមេបា, ឪពុកម្តាយ ឬអ្នកផ្សេងទៀតដែលមានផលប្រយោជន៍ នៃអ្នកអវត្តមាន អាចដាក់ស្នើសុំ ទៅសាលាដំបូង នៃលំនៅឋានរបស់អ្នកអវត្តមានដើម្បីឱ្យតុលាការចេញដីកាសម្រេចស្តីពីការប្រកាសបាត់ខ្លួន ។ នៅពេលទទួលបានពាក្យសុំពីអ្នកដែលមានសិទ្ធិដាក់ពាក្យសុំ តុលាការត្រូវរៀបចំនីតិវិធីនានាតាមការចាំបាច់ ជាពិសេស នីតិវិធីនៃការដាស់តឿនជាសាធារណៈតាមរយៈវិធានដូចខាងក្រោម ៖

- ការដាស់តឿនជាសាធារណៈត្រូវធ្វើឡើងតាមវិធីផ្សព្វផ្សាយជាសាធារណៈ ។
- ការផ្សាយជាសាធារណៈ ត្រូវធ្វើឡើងដោយបិទប្រកាសនៅកន្លែងសម្រាប់បិទប្រកាសរបស់តុលាការ និងចុះផ្សាយនៅក្នុងប្រតិបត្តិរបស់ក្រសួងយុត្តិធម៌ ។
- ប្រសិនបើយល់ឃើញថាសមរម្យ តុលាការអាចធ្វើការផ្សាយជាសាធារណៈតាមការចុះផ្សាយនៅក្នុងសារព័ត៌មានប្រចាំថ្ងៃ ឬ តាមវិធីផ្សេងទៀតដែលយល់ឃើញថាសមរម្យបាន ។
- ការផ្សាយជាសាធារណៈត្រូវបញ្ជាក់អំពីចំណុចខាងក្រោម ៖
  - ✓ ឈ្មោះ និង អាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ។
  - ✓ ឈ្មោះ និង អាសយដ្ឋានចុងក្រោយដែលត្រូវបានដឹង និងថ្ងៃ ខែ ឆ្នាំ កំណើតរបស់អ្នកអវត្តមាន ។
  - ✓ កំណត់ថា អ្នកអវត្តមានត្រូវផ្តល់ព័ត៌មានអំពីការរស់នៅរបស់ខ្លួននៅមុនពេលចប់អំឡុងពេលនៃការដាស់តឿនជាសាធារណៈ ហើយបើមិនបានផ្តល់ព័ត៌មានមុនអំឡុងពេលនេះទេ អ្នកអវត្តមាននោះនឹងទទួលការប្រកាសអំពីការបាត់ខ្លួន ។
  - ✓ កំណត់ថា ជនដែលដឹងអំពីការរស់នៅ ឬ មរណភាពរបស់អ្នកអវត្តមាន ត្រូវផ្តល់ព័ត៌មាន នៅមុនពេលចប់អំឡុងពេលនៃការដាស់តឿនជាសាធារណៈ ។
  - ✓ ថ្ងៃចប់អំឡុងពេលនៃការដាស់តឿនជាសាធារណៈ ។
- អំឡុងពេលនៃការដាស់តឿនជាសាធារណៈ ត្រូវមានមិនតិចជាង ៦(ប្រាំមួយ) ខែ ។[55]

បន្ទាប់ពីលក្ខខណ្ឌក៏ដូចជានីតិវិធីសំខាន់នានា ដូចការរៀបរាប់ខាងលើត្រូវបានបំពេញ នោះតុលាការត្រូវចេញការប្រកាសបាត់ខ្លួន តាមរយៈដីការសម្រេច ។

### ៣. អានុភាពនៃការប្រកាសបាត់ខ្លួន

នៅពេលតុលាការបានចេញដីកាសម្រេច ស្តីពីការប្រកាសបាត់ខ្លួន និងបានចូលជាស្ថាពរ នោះនាំឱ្យបង្កើតអានុភាពពិសេសគឺ ជនដែលតុលាការត្រូវបានប្រកាស់បាត់ខ្លួនត្រូវចាត់ទុកថាជននោះបានទទួលមរណភាព។ អាស្រ័យដោយអានុភាព នៃការប្រកាសបាត់ខ្លួនរបស់ដីកាសម្រេចរបស់តុលាការត្រូវចាត់ទុកថា

[55] មាត្រា ៥៨ ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង ឆ្នាំ២០១០

បុគ្គលបាត់ខ្លួនបានទទួលមរណៈ ជាហេតុធ្វើឱ្យ មតកសាសន៍របស់ជនដែលបាត់ខ្លួននោះ ក៏ចាប់ផ្ដើមបង្កើតអានុភាព ពីពេលដែលសេចក្ដីសម្រេចពីការបាត់ខ្លួនចូលជាស្ថាពរ ។[56]

**កថាភាគទី ៣ លក្ខខណ្ឌបង្អង់នៃមតកសាសន៍**

ដូចមានចែងក្នុងមាត្រា ១១៩៤ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីបញ្ញត្តថា " នៅក្នុងករណីមតកសាសន៍ ភ្ជាប់ជាមួយលក្ខខណ្ឌបង្អង់ បើលក្ខខណ្ឌនោះត្រូវបានបំពេញនៅពេលម្ចាស់បណ្ដាំបានទទួលមរណភាព មតកសាសន៍នោះ ត្រូវមានអានុភាព ចាប់ពីពេលដែលលក្ខខណ្ឌនោះត្រូវបានបំពេញ" ។[57] តាមរយៈបញ្ញត្តនេះ វាជាការបង្ហាញឆន្ទៈរបស់មតកជន តាមរយៈបណ្ដាំរបស់ខ្លួន ដូច្នេះសន្តតិជន ឬ អច្ច័យលាភី មានករណីយកិច្ចត្រូវតែធានា និង អនុវត្តតាមលក្ខខណ្ឌបង្អង់នេះ ទើបខ្លួនអាចទទួលនូវសិទ្ធិសន្តតិកម្មតាមខ្លឹមសារនៃមតកសាសន៍បាន ។

ឧទាហរណ៍ថា៖ មតកជន A សរសេរបណ្ដាំផ្ដល់ដីមួយកន្លែង ទៅឱ្យកូនប្រុសទី៣ របស់ខ្លួនមុនពេលស្លាប់ ។ ប៉ុន្តែដោយគាត់យល់ថា ខ្លាចពេលដែលគាត់ស្លាប់ទៅ**កូនប្រុសទី៣** របស់គាត់ នៅមានអាយុតិច និងគំនិតនៅក្មេងខ្ចីនឹងលក់ដីដែលជាកម្មវត្ថុនៃមតកសាសន៍យកប្រាក់ទៅចាយវាយអស់ នាំឱ្យគាត់បានចែងពីលក្ខខណ្ឌបង្អង់ថា **កូនប្រុសទី៣**នឹងទទួលបានដីនោះ នៅពេលគេមានអាយុ ២៥ ឆ្នាំ ។ នេះជាលក្ខខណ្ឌបង្អង់ លុះត្រាតែកូនប្រុសទី៣ របស់គាត់មានអាយុ ២៥ឆ្នាំ ទើបគាត់អាចទទួលបានដីនោះបាន ។

**ផ្នែកទី ២ អានុភាពមតកសាសន៍**

បន្ទាប់ពីមតកជនបានទទួលមរណភាព ឬ មានការប្រកាសបាត់ខ្លួនពីតុលាការ ឬ លក្ខខណ្ឌបង្អង់នៃមតកសាសន៍ ដែលជាប្រធានទើបអានុភាពនៃមតកសាសន៍ត្រូវបានចាប់ផ្ដើម ។ ដូច្នេះ នៅពេលមតកសាសន៍ត្រូវបង្កើតអានុភាព តើវានឹងមានអានុភាពយ៉ាងដូចម៉េច ? ជាទូទៅ មតកសាសន៍ គឺមានខ្លឹមសារផ្ទេរនូវសិទ្ធិ និងកាតព្វកិច្ចទៅឱ្យ អ្នកស្នង ហេតុនេះក្នុងការសិក្សាពីអានុភាពរបស់វា យើងនឹងផ្ដោតសំខាន់ទៅលើអានុភាពប្រាំ គឺ អានុភាពនៃការកំណត់ចំណែកមត៌ក, អានុភាពនៃការកំណត់ចំណែកមត៌កករណីសន្តតិជនទទួលមរណភាព , អានុភាពចំពោះអាណាព្យាបាលទូទៅ, អានុភាពនៃអច្ច័យទាន និង អានុភាពមតកសាសន៍និងភាគបម្រុង ។

**កថាភាគទី ១ អានុភាពនៃការកំណត់ចំណែកមត៌ក**

ក្នុងករណីដែល មតកជន បានកំណត់ពីចំណែក ព្រមទាំងវិធីសាស្ត្រក្នុងការកំណត់ចំណែក ទៅលើទ្រព្យសម្បត្តិជាក់លាក់ មួយ ឬ ច្រើន ទៅឱ្យសន្តតិជនម្នាក់ ឬ ច្រើននាក់ តាមរយៈមតកសាសន៍ នោះអានុភាពនៃការកំណត់លើទ្រព្យសម្បត្តិជាក់លាក់នោះ នឹងត្រូវធ្លាក់ទៅសន្តតិជនដែលនឹងត្រូវទទួលនូវទ្រព្យសម្បត្តិនោះ

[56] មាត្រា ៤៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[57] មាត្រា ១១៩៤-២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ដោយស្វ័យប្រវត្តិព្រមគ្នានឹងពេលមតកសាសន៍នោះបង្កើតអានុភាព ឬ នៅពេលលក្ខខណ្ឌបង្អង់ត្រូវបានបំពេញ។[58] អានុភាពនេះ វាបានទទួលស្គាល់នូវអាទិភាពចម្បងនៃការអនុវត្តមតកសាសន៍ ដែលបានចងជាកាតព្វកិច្ច ឱ្យអ្នកប្រតិបត្តិមតកសាសន៍ ឬ តុលាការចេញនូវសេចក្តីសម្រេចទទួលស្គាល់នូវចំណែក និង វិធីនៃការចាត់ចែង ដែលមានស្រាប់ក្នុងមតកសាសន៍ ។ ហេតុនេះនៅពេលប្រតិបត្តិ អ្នកប្រតិបត្តិត្រូវផ្តល់អាទិភាពជាងគេនូវចំណែកដែលបានកំណត់ជាក់លាក់ទាំងនេះ ហើយក្នុងករណីនេះផងដែរ វាក៏ផ្តល់ភាពងាយស្រួលដល់ការចាត់ចែងសន្តតិកម្ម ឬ អនុវត្តសន្តតិកម្ម ក្នុងទំហំនៃទ្រព្យសម្បត្តិដែលបានចាត់ចែង និង វិធានបែងចែករបស់មតកជន ។

**កថាភាគទី ២ ការកំណត់ចំណែកមត៌កករណីសន្តតិជនទទួលមរណភាពជាអាទិ៍**

ក្នុងលក្ខខណ្ឌនៃសន្តតិកម្ម ដែលមតកជនបានកំណត់នូវចំណែកលើទ្រព្យសម្បត្តិជាក់លាក់របស់ខ្លួនព្រមទាំងវិធីនៃការបែងចែងផងនោះ ក្នុងករណីដែលសន្តតិជនដែលត្រូវបានកំណត់ស្ថិតក្នុងស្ថានភាពមិនអាចបង្កើតអានុភាព ដោយហេតុថា សន្តតិជននោះបានទទួលមរណភាពមុនមតកជន ឬ សន្តតិជនក្លាយជាអភព្វបុគ្គល ឬ សន្តតិជននោះត្រូវបានមតកជនកាត់កាល បើសិនមកតជនមិនបានបង្ហាញឆន្ទៈផ្សេងពីនោះទេ សិទ្ធិរបស់សន្តតិជនទាំងនោះគឺត្រូវផ្ទេរដោយស្វ័យប្រវត្តិទៅ សន្តតិជនជំនួសរបស់ពួកគេ ដែលត្រូវជាចៅ ឬ ចៅទួតរបស់មតកជន ។[59]

ឧទាហរណ៍ថា ៖ មតកជន A បានធ្វើបណ្តាំមត៌ក លើដីមួយកន្លែង ទៅឱ្យកូនប្រុសពីរនាក់ គឺ B និង C ដោយកំណត់ទទួលបានម្នាក់ ៥០% នៃដីនោះ ។ ប៉ុន្តែជាអកុសល B បានស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ដោយបានបន្សល់ទុកកូនម្នាក់ D មួយឆ្នាំមុនពេលមតកជនទទួលមរណភាព ។ ដោយហេតុថា មតកជនមិនបានកែប្រែខ្លឹមសារនៃមតកសាសន៍នោះទេ វាក៏មានន័យថា មតកជន A មានបំណងចង់ប្រគល់ចំណែករបស់ B ទៅកូនរបស់ B ដែល ហេតុនេះ ចំណែករបស់ B ត្រូវធ្លាក់ទៅ D ដោយស្វ័យប្រវត្តិ ។

ប៉ុន្តែជាអញ្ញត្រកម្ម ស្តីពីសន្តតិកម្មជំនួស បានកំណត់ថា បុគ្គលដែលអាចកំណត់យកជាសន្តតិកម្មជំនួសបាន លុះត្រាតែបុគ្គលនោះជាបច្ឆាញាតិផ្ទាល់របស់សន្តតិជននោះប៉ុណ្ណោះ ។[60] ហេតុនេះក្នុងករណីដែលសន្តតិជន B ខាងលើមិនមានបច្ឆាញាតិទេ នោះចាត់ទុកថា មិនមានសន្តតិកម្មជំនួស នោះមតកសាសន៍ត្រង់ការកំណត់ចែកទ្រព្យសម្បត្តិនេះ មិនអាចមានអានុភាពឡើយ ។ ក្នុងករណីនេះបញ្ញត្តស្តីពីការបោះបង់សន្តតិកម្មគឺត្រូវយកមកអនុវត្ត មានន័យថាសន្តតិកម្មមិនមានអានុភាពតាំងពីដំបូង ។

---

[58] មាត្រា ១១៩៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[59] មាត្រា ១១៩៦ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧ និងមាត្រា ១១៩៦ សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០១០

[60] មាត្រា ១១៩៧-១-២ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

ឧទាហរណ៍ ៖ ក្នុងឧទហរណ៍ខាងលើ បើសិន B ពុំមានបច្ចាញាតិនោះទេ នោះចំណែករបស់គាត់គឺពុំមានអានុភាពឡើយ ឬ និយាយដោយងាយយល់ ចំណែករបស់ B ចាត់ទុកថាមិនទាន់មានបណ្ដាំឡើយ អាចធ្វើជាកម្មវត្ថុ នៃសន្តតិកម្មតាមច្បាប់បាន។

**កថាភាគទី ៣ អានុភាពចំពោះអាណាព្យាបាលទូទៅ**

ទោះបីជាមាត្រា ១១៧៦ នៃក្រមរដ្ឋប្បវេណីបានទទួលស្គាល់សិទ្ធិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ក្នុងការធ្វើមតកសាសន៍ ក៏ពិតមែន ប៉ុន្តែដោយហេតុថា ជននៅក្រោមអាណាព្យាបាលទូទៅត្រូវបានចាត់ទុកថាជាជនត្រូវបានកម្រិតសមត្ថភាព ដែលស្ថិតនៅក្នុងស្ថានភាពជានិរន្ត ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ជាហេតុធ្វើឱ្យការយល់ដឹងរបស់គាត់អាចមានការប្រែប្រួល ។ មូលហេតុទាំងនេះហើយទើបក្រមរដ្ឋប្បវេណីបានបញ្ញត្ត ក្នុងករណីជនដែលនៅក្រោមអាណាព្យាបាលទូទៅ បានធ្វើមតកសាសន៍ ដែលជាផលប្រយោជន៍ដល់អ្នកអាណាព្យាបាល ឬ សហព័ទ្ធ ឬ បច្ចាញាតិផ្ទាល់របស់អ្នកអាណាព្យាបាលនោះ នៅមុនពេលបញ្ចប់ការគណនានូវចំណូលចំណាយក្នុងកិច្ចការអាណាព្យាបាល មតកសាសន៍នោះត្រូវចាត់ទុកជាមោឃៈ លើកលែងតែ អ្នកអាណាព្យាបាលនោះ គឺជាសហព័ទ្ធ ឬ ជាបច្ចាញាតិ ឬ ជាបងប្អូនបង្កើត របស់ជននៅក្រោមអាណាព្យាបាលទូទៅ ។[61] បញ្ញត្តនេះចែងក្នុងអត្ថន័យបង្ការនូវការឆ្លៀតឱកាសដោយហេតុថា អ្នកអាណាព្យាបាលគឺជាអ្នកមើលការខុសត្រូវ និង ជួយសម្រួលដល់ការរស់នៅរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ទាំងរូបកាយ និង ទ្រព្យសម្បត្តិ ហើយមានការប្រាស្រ័យទាក់ទងយ៉ាងជិតស្និតជាមួយជននៅក្រោមអាណាព្យាបាល ដែលអាចផ្តល់លទ្ធភាពឱ្យអ្នកអាណាព្យាបាលប្រើឧបាយកលផ្សេងៗ ដើម្បីបញ្ចុះបញ្ចូលឱ្យមតកជន ធ្វើនូវមតកសាសន៍ដោយផ្តល់ផលប្រយោជន៍ដល់ខ្លួន ប្រពន្ធ ឬ កូនចៅរបស់ខ្លួន ។ ប៉ុន្តែបើសិនជា អ្នកអាណាព្យាបាល ត្រូវជាសហព័ទ្ធ ជាកូន ឬ ជាបងប្អូនបង្កើតជាមួយជននៅក្រោមអាណាព្យាបាលទូទៅនោះ ច្បាប់ទទួលស្គាល់ដោយហេតុថា ក្រុមបុគ្គលទាំងនេះ បានមើលថែរក្សាបីបាច់ជននៅក្រោមអាណាព្យាបាលទូទៅដោយមិនមែនដើម្បីតែប្រយោជន៍ និង ហានិភ័យក្នុងការប្រើប្រាស់ឧបាយកលទុច្ចរិតដើម្បីឱ្យ មតកជនធ្វើមតកសាសន៍ត្រូវបានកាត់បន្ថយ ។

**កថាភាគទី ៤ អច្ឆ័យទាន**

អច្ឆ័យទាន គឺជាប្រទានកម្មដែលម្ចាស់បណ្ដាំធ្វើទៅឱ្យមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិជាក់លាក់របស់ខ្លួនតាមរយៈមតកសាសន៍។[62] អច្ឆ័យទានមានពីរប្រភេទ គឺ ប្រទានកម្មដែលម្ចាស់បណ្ដាំធ្វើទៅឱ្យមនុស្សម្នាក់ ឬច្រើននាក់ នូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែកដែលកំណត់ទៅតាមភាគ ហៅថា អច្ឆ័យទាន

[61] មាត្រា ១១៩៧ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

[62] លេខ ១៧៧ សន្ទានុក្រមផ្នែករដ្ឋប្បវេណី ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

សកល និង ប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ ទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់ ដោយមតកសាសន៍ត្រូវបានហៅថា អច្ច័យទានមានកំណត់។[63]

ដោយហេតុថាមតកជន អាចផ្តល់នូវទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈអច្ច័យទាន ទៅឱ្យបុគ្គលម្នាក់ ឬ ច្រើននាក់ ក្លាយជាអច្ច័យលាភី ដើម្បីទទួលនូវទ្រព្យសម្បត្តិទាំងនោះ តាមរយៈមតកសាសន៍ ។ ដូច្នេះ ក្នុងករណីដែលមតកសាសន៍ មានចែងពីផ្នែកនៃអច្ច័យទាន នោះអច្ច័យទានគឺជាផ្នែកមួយនៃមតកសាសន៍ដែរ ប៉ុន្តែគ្រាន់តែថា ផលប្រយោជន៍របស់អច្ច័យលាភី គឺមានដោយពឹងផ្អែកទាំងស្រុងទៅលើខ្លឹមសារដែលមានចែងទុកដោយមតកសាសន៍ប៉ុណ្ណោះ។

ឧទាហរណ៍ ៖ មតកជន A បានធ្វើមតកសាសន៍ដោយបានផ្តល់ រថយន្ត ទៅឱ្យកូនប្រុស B និង ដី ឱ្យទៅកូនស្រី C និងធ្វើអច្ច័យទាន ប្រាក់ក្នុងកុងធនាគារ ឱ្យអច្ច័យលាភីត្រូវជាក្មួយស្រី D ។ ក្នុងករណីមតកសាសន៍មិនមានអានុភាព ចំពោះ C និង សន្តតិជនជំនួសរបស់ C ទេ ចំណែកឯ C ចាត់ទុកថាមិនមានអានុភាពតាំងពីដំបូង ហើយបើសិន A គ្មានសន្តតិជនណាផ្សេងទៀតទេ នោះ B ក្លាយជាសន្តតិជនតែមួយគត់ ដែលត្រូវទទួលបានចំណែករបស់ C ចំពោះ D ដែលជាអច្ច័យលាភីត្រូវទទួលតែចំណែកដែលមតកជនផ្តល់ឱ្យដដែរ ។

ក្នុងករណីដែលមតកសាសន៍ មានចែងអំពីអច្ច័យទាននោះ អច្ច័យទានក៏ជាផ្នែកមួយនៃមតកសាសន៍ ដែលហេតុនេះវានឹងមានរបបគតិយុត្តមួយចំនួន ស្តីពីអច្ច័យទាន តាមរយៈ អច្ច័យទានត្រូវចាត់ទុកជាមោឃៈ, ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃអច្ច័យទាន, អច្ច័យទានដែលភ្ជាប់ជាមួយសិទ្ធិរបស់តតិយជន, ឧបាទេសកម្មលើវត្ថុ និងសិទ្ធិលើបំណុល, អច្ច័យទានដែលភ្ជាប់បន្ទុក និង ការបោះបង់អច្ច័យទាន ។

**១. អច្ច័យទានត្រូវចាត់ទុកជាមោឃៈ**

លក្ខខណ្ឌដែលអាចចាត់ទុកថាអច្ច័យទានក្លាយជាមោឃៈ រួមមាន ៖

- ✓ មរណភាពរបស់អច្ច័យលាភី មុនមតកជន ឬ មរណភាពរបស់អច្ច័យលាភី មុនលក្ខខណ្ឌបង្អង់ត្រូវបានបំពេញ ។
- ✓ ដោយអច្ច័យលាភីក្លាយជាអភព្វបុគ្គល ។
- ✓ ការបោះបង់សន្តតិកម្មរបស់អច្ច័យលាភី ជាអាទិ៍ ។

លក្ខខណ្ឌទាំងនេះ មានអានុភាពចាត់ទុកថា អច្ច័យទានមិនត្រូវមានអានុភាពតាំងពីដំបូង ឬ អច្ច័យទាននោះត្រូវចាត់ទុកជាមោឃៈ ហើយសិទ្ធិ និង កាតព្វកិច្ចនានាដែលកំណត់ដោយអច្ច័យទាននឹងក្លាយជាកម្មវត្ថុនៃសន្តតិកម្មជាប្រយោជន៍សម្រាប់សន្តតិជនទាំងអស់ ដោយមិនអនុវត្តនូវរបបនៃសន្តតិជនជំនួសបានឡើយ ។

[63] មាត្រា ១១៩៩ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

តែទោះបីជាយ៉ាងណាច្បាប់ទទួលស្គាល់ និង គោរពសិទ្ធិនៃការបង្ហាញឆន្ទៈ ក្នុងករណីដែលមតកជនបានបង្ហាញឆន្ទៈបង្ការទុកជាមុន នូវចំណែកនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃអច្ច័យទាន បើសិនអច្ច័យទានត្រូវចាត់ទុកជាមោឃៈបាន ។ ក៏ប៉ុន្តែបើ អច្ច័យទាននោះ មតកជនបានធ្វើចំពោះ សន្តតិជន ឬ អច្ច័យលាភី ត្រូវបានកំណត់ថា ជាសន្តតិជន នោះកម្មវត្ថុនៃអច្ច័យទាននោះ អាចអនុវត្តរបបសន្តតិកម្មជំនួសបាន ។[64]

ឧទាហរណ៍ ១ ៖ ករណីមតកជន A បានធ្វើអច្ច័យទានទ្រព្យសម្បត្តិ ដីមួយកន្លែងទៅឱ្យ អច្ច័យលាភី B នឹងបានកំណត់លក្ខខណ្ឌបង្អង់ថា ក្រោយពី B មានអាយុ ២០ឆ្នាំ ទើបអាចធ្វើលទ្ធកម្មលើដីនោះបាន ។ ក្នុងរណីនេះ បើ B ទទួលមរណៈ មុនមតកជន ឬ មុនគាត់អាយុ ២០ឆ្នាំ នោះអច្ច័យទាននោះមិនមានអានុភាពនោះទេ ឬ អច្ច័យទានត្រូវបានចាត់ទុកជាមោឃៈ ហើយដីនោះនឹងក្លាយជាកម្មវត្ថុនៃសន្តតិកម្មដោយគ្មានបណ្តាំ ។

ប៉ុន្តែបើ មតកជនចែងបង្ការទុកជាមុនថា បើអច្ច័យទានមិនមានអានុភាពដោយសារមរណភាពអច្ច័យលាភី ឬ លក្ខខណ្ឌបង្អង់មិនត្រូវបានបំពេញ នោះត្រូវធ្វើអច្ច័យទានដែលមានអត្ថន័យដដែរនោះ ទៅឱ្យសន្តតិជនរបស់អច្ច័យលាភីនោះ ត្រូវគោរពតាមឆន្ទៈពិសេសនេះ ។

ឧទាហរណ៍២ ៖ ក្នុងលក្ខខណ្ឌដូចនឹងឧទារណ៍ទី១ ក្នុងករណីដែល អច្ច័យលាភីត្រូវបានសន្មតថាជាសន្តតិជននោះទោះបីជា មតកជនមិនបានបង្ហាញឆន្ទៈពិសេសផ្សេងក៏ដោយ ក៏អាចអនុវត្តរបបសន្តតិកម្មជំនួសបានដែរពោលគឺ បច្ឆាញាតិរបស់អច្ច័យលាភីដែលសន្មតថាជាសន្តតិជន អាចទទួលនូវសិទ្ធិ និង ករណីយកិច្ចបន្តបាន ។[65]

**២. ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃអច្ច័យទាន**

ជាគោលការណ៍ អច្ច័យទាន មានអានុភាពតែលើទ្រព្យសម្បត្តិដែលចាត់ទុកថាជាមត៌ករបស់មតកជនតែប៉ុណ្ណោះ ឬនិយាយងាយយល់ វត្ថុ ឬ សិទ្ធិនានា អាចយកមកធ្វើជាកម្មវត្ថុនៃអច្ច័យទានបាន លុះត្រាតែមតកជនបានធ្វើលទ្ធកម្មនូវវត្ថុ ឬ សិទ្ធិទាំងនោះមុនពេលមតកជននោះទទួលមរណភាព ឬ សន្តតិកម្មបង្កើតអានុភាព។[66] នេះគឺជាបញ្ញត្តជាក់លាក់មួយដើម្បីឱ្យមតកជនអាចផ្តល់មត៌ករបស់ខ្លួនទៅឱ្យអច្ច័យលាភីបាន តែក្នុងករណីដែលទ្រព្យសម្បត្តិនោះជារបស់ខ្លួន មុនពេលខ្លួនទទួលមរណភាពប៉ុណ្ណោះ ហើយវានឹងមិនអាចធ្វើបានឡើយចំពោះទ្រព្យសម្បត្តិដែលនឹងអាចកើតមាននៅពេលអនាគតនោះទេ ព្រោះវាមិនបានបង្ហាញភាពជាក់លាក់ណាមួយថាទ្រព្យនោះវានឹងកើតឡើងយ៉ាងពិតប្រាកដឡើយ ។ ដូច្នេះវាជាការកម្រិតសិទ្ធិមួយនៃរបបអច្ច័យទានដើម្បីបង្ការនូវវិបត្តិគតិយុត្តដែលអាចកើតមានឡើង ព្រោះថាបើមិនដូច្នេះទេវាអាចនឹងបណ្តាលឱ្យមតកជន ឬ សន្តតិជនផ្ទាល់ ក្លាយជាកូនបំណុលរបស់ អច្ច័យលាភីជាយថាហេតុ។

[64] មាត្រា ១១៨៥, មាត្រា ១១៩៦ និងមាត្រា ១២០០ ក្រមរដ្ឋប្បវេណី ២០០៧

[65] មាត្រា ១១៨៥ សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ២០១០

[66] មាត្រា ១២០៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ឧទាហរណ៍ ៖ មតកជន A មានមតក៌តម្លៃ ២០០០ដុល្លារ ហើយបានចែងក្នុងមតកសាសន៍ថា នឹងទិញដី មួយកន្លែងតម្លៃ ៥០០០ដុល្លារ ទៅឱ្យស្រីកំណាន់ចិត្ត B ។ ក្នុងករណីនេះ ឃើញថា ដី ដែលមតកជន A ថាទិញនោះគឺមិនទាន់បានទិញនៅឡើយ ។ ដូច្នេះ ដីដែលជាកម្មវត្ថុនៃ អច្ច័យទាន គឺមិនមានអានុភាពឡើយ ហេតុនេះ សន្តតិជនមិនចាំបាច់ទទួលបន្ទុកកាត់ចំណែកមត៌ក ឬ ចំណាយប្រាក់របស់ខ្លួនដើម្បីទទួលបន្ទុកចំពោះ B ឡើយ។[67]

**៣. អច្ច័យទានដែលភ្ជាប់ជាមួយសិទ្ធិរបស់តតិយជន**

បើសិនវត្ថុ ដែលជាកម្មវត្ថុនៃអច្ច័យទាន ដោយភ្ជាប់ជាមួយសិទ្ធិរបស់តតិយជន នៅពេលមតកសាសន៍បង្កើតអានុភាព នោះអច្ច័យលាភីមិនអាចទាមទាររំលត់សិទ្ធិ ឬ ករណីយកិច្ចនានាពាក់ព័ន្ធនឹងវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទានឡើយ នេះមានន័យថា អត្ថិភាពនៃសិទ្ធិ និងករណីយកិច្ចដែលមតកជនបានបង្កើត ឬជាភាគីនៃការបង្កើត នឹងនៅតែបន្តអានុភាពដល់ការបញ្ចប់នូវសកម្មភាពនោះ។ ជាក់ស្តែងការកំណត់បែបនេះ គឺមានស្មារតីការពារផលប្រយោជន៍របស់តតិយជន ដែលមានចំណងគតិយុត្តដោយផ្ទាល់ជាមួយមតកជន បើមិនដូច្នេះទេពួកគេនឹងរងការខាតបង់យ៉ាងធ្ងន់ធ្ងរដែលមិនអាចប៉ាន់ស្មានបាន ដូចជា សកម្មភាពធានាកាតព្វកិច្ច ឬ ភតិសន្យាជាអាទិ៍ ។[68]

ឧទាហរណ៍៖ នៅពេលមានជីវិត មតកជន A បានជួលដី ទៅឱ្យ B ក្រោមរបបជួលអចិន្ត្រៃយ៍ ។ មួយឆ្នាំក្រោយមក A បានស្លាប់ ហើយបានបន្សល់ទុកនូវមតកសាសន៍ដែលមានខ្លឹមសារ ធ្វើអច្ច័យទានដីជួលនោះទៅឱ្យអច្ច័យលាភី C ។ ដោយយោងលើមាត្រា ១២០៨ នៃក្រមរដ្ឋប្បវេណី នោះអានុភាពនៃអច្ច័យទាន មិនអាចរំលត់នូវសិទ្ធិរបស់តតិយជន B បាននោះទេ ជាហេតុកិច្ចសន្យាជួលអចិន្ត្រៃយ៍នៅតែមានអត្ថិភាព ។

**៤. ឧបាទេសកម្មលើវត្ថុ និងសិទ្ធិលើបំណុល**

ក្នុងករណីដែលមតកជន មានសិទ្ធិទាមទារវត្ថុ ឬ សិទ្ធិលើបំណុល ឬ នឹងធ្វើលទ្ធលម្មលើវត្ថុដែលជាកម្មវត្ថុនៃការជាប់គ្នា, លាយគ្នា, ឬច្របល់គ្នានឹងវត្ថុផ្សេងទៀត ទោះបីជាសិទ្ធិនោះ ជាកម្មវត្ថុនៃកម្មសិទ្ធិរបស់មតកជន ឬ កម្មសិទ្ធិអវិភាគក៏ដោយ ក៏អាចយកមកធ្វើជាកម្មវត្ថុនៃអច្ច័យទានបានដែល ហើយអច្ច័យលាភីមានសិទ្ធិធ្វើលទ្ធកម្មនូវសិទ្ធិទាំងអស់នោះ ។[69]

ឧទាហរណ៍ ៖ មតកជន A បានឱ្យប្រាក់ B ខ្ចី និង  បានយកមាស ២តំណឹង ទៅផ្សំជាមួយប្រាក់ និង ផ្លាកទីន ២តម្លឹងរបស់ C ដើម្បីផលិតជាលោហៈធាតុមួយផ្សេងទៀត បន្ទាប់មក A បានចែងក្នុងមតកសាសន៍ថា សិទ្ធិលើ

[67] មាត្រា ១២០៧ សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០១០

[68] មាត្រា ១២០៨ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧ និងមាត្រា ១២០៨ សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០១០

[69] មាត្រា ១២០៩ និងមាត្រា ១២១០ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

បំណុលលើ B និងសិទ្ធិធ្វើលទ្ធកម្មលើវត្ថុលាយជាមួយ C ត្រូវប្រគល់ទៅអោយអច្ច័យលាភី D ។ ដូច្នេះ D មានសិទ្ធិលើបំណុលលើ B និងអាចធ្វើលទ្ធកម្មលើវត្ថុលាយគ្នាជាមួយ C ក្នុងកម្រិតនៃសិទ្ធិរបស់ A ។

**៥. អច្ច័យទានដែលភ្ជាប់បន្ទុក**

ជាគោលការណ៍អច្ច័យទានគឺ ប្រទានកម្មនូវទ្រព្យសម្បត្តិ ពោលគឺសិទ្ធិ ឬ ផលប្រយោជន៍ ឬ ទ្រព្យសកម្ម ដល់អច្ច័យលាភី។ ប៉ុន្តែមតកជន ក៏អាចចែងពីករណីយកិច្ចរបស់អច្ច័យលាភីបានដែលហៅថា អច្ច័យទានភ្ជាប់បន្ទុក តែទោះបីយ៉ាងនេះក្តីដើម្បីរក្សាខ្លឹមសារជាប្រយោជន៍នៃអច្ច័យទាន ទើបច្បាប់បញ្ញត្តការពារការទទួលខុសត្រូវលើ អច្ច័យទានភ្ជាប់បន្ទុកនេះ ដោយកំណត់បន្ទុកនោះ មិនអោយលើសពីតម្លៃនៃទ្រព្យ ឬ សិទ្ធិដែលអច្ច័យលាភីទទួលតាមរយៈមតកសាសន៍ឡើយ ឬ ក្នុងករណីបន្ទុកនោះមានទទ្ងន់ ឬ តម្លៃខ្ពស់ជាង តម្លៃនៃទ្រព្យដែលអច្ច័យលាភីទទួល នោះបន្ទុកដែលលើស គឺគ្មានអានុភាព ឱ្យអច្ច័យលាភីទទួលកាតព្វកិច្ចឡើយ លើកលែងតែអច្ច័យលាភីទទួលដោយការស្ម័គ្រចិត្ត ដោយគ្មានវិការៈនៃការបង្ហាញឆន្ទៈ។[70] លើសពីនេះក្នុងករណីដែលត្រូវកាត់បន្ថយតម្លៃកម្មវត្ថុនៃអច្ច័យទាន ដើម្បីបង្រ្គប់ភាគបម្រុងនោះ នាំឱ្យបន្ទុកនៃអច្ច័យទាននោះត្រូវកាត់ទៅតាមសមាមាត្រនៃការកាត់នោះដែល ។

ឧទាហរណ៍ ៖ មតកជន A បានធ្វើអច្ច័យទាន ដី មួយកន្លែងទំហំ ១០០០០ម៉ែត្រការ៉េ ដល់ B តែតម្រូវឱ្យ B ឱ្យចំណែកដីនោះ ២០% ទៅឱ្យ C ស្មើនឹង ២០០០ម៉ែត្រការ៉េ ។ ដោយសារមានការទាមទារភាគបម្រុង នាំឱ្យត្រូវកាត់យក ដី ២០% ពី B ដើម្បីបង្រ្គប់ភាគបម្រុងនោះ ដូច្នេះ ការកាត់តម្លៃ ២០%នៃភាគបម្រុង មានអានុភាពបន្ថយបន្ទុកអច្ច័យទាន ២០% ដែល ដូច្នេះ B អាចប្រគល់ដីឱ្យ C តែ ១៦០០០ម៉ែត្រការ៉េ ជាការស្រេច ។

**៦. ការបោះបង់អច្ច័យទាន**

ទោះបីជាទូទៅអច្ច័យទានបានផ្តល់ផលប្រយោជន៍ដល់ អច្ច័យលាភីយ៉ាងណាក្តី ក៏ក្រមរដ្ឋប្បវេណីគោរពសិទ្ធិសម្រេចរបស់ បុគ្គល ដែលអាចអនុញ្ញាតឱ្យអច្ច័យលាភី បោះបង់នូវសិទ្ធិ និង ករណីយកិច្ចរបស់ខ្លួនដែលមាននៅក្នុងមតកសាសន៍បាន ។ ចំពោះករណីអច្ច័យទានមានកំណត់ អច្ច័យលាភី អាចបង្ហាញឆន្ទៈបោះបង់ពេលណាក៏បាន ប៉ុន្តែចំពោះ អច្ច័យទានសាកល តម្រូវឱ្យអច្ច័យលាភីដាក់ពាក្យស្តីពីការបោះបង់សន្តតិកម្មទៅតុលការ សាលាដំបូងនៃទីកន្លែងចាប់ផ្តើមសន្តតិកម្ម ដើម្បីចេញដីកាសម្រេច ។ លើសពីនេះក្នុងករណីកម្មវត្ថុនៃអច្ច័យទានមានជាប់ពាក់ព័ន្ធនឹងផលប្រយោជន៍របស់តតិយជន នោះតតិជននោះ អាចធ្វើការដាស់តឿនដល់អច្ច័យលាភី ឱ្យបង្ហាញការយល់ព្រម ឬ បោះបង់អច្ច័យទានបាន ដោយកំណត់ពេលសមរម្យ

[70] មាត្រា ១២១១ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

ក្នុងករណីអច្ច័យលាភី មិនព្រមបង្ហាញឆន្ទៈក្នុងអំពេលកំណត់នេះទេ នោះចាត់ទុកថា អច្ច័យលាភីទទួលស្គាល់អច្ច័យទាននោះ ។[71]

**កថាភាគទី៥ អានុភាពមតកសាសន៍ និង ភាគបម្រុង**

ភាគបម្រុង គឺជារបបធានាមួយភាគនៃចំណែកមត៌កដែលកំណត់ដោយច្បាប់ ។ ត្បិតតែច្បាប់ទទួលស្គាល់ និង អនុញ្ញាតឱ្យមតកជនអាចចាត់ចែងនូវទ្រព្យសម្បត្តិរបស់ខ្លួនដោយសេរីតាមរយៈមតកសាសន៍ក៏ដោយ ប៉ុន្តែចំពោះមួយផ្នែកនៃទ្រព្យសម្បត្តិត្រូវបានច្បាប់ហាមឃាត់មិនឱ្យមតកជនក្នុងការធ្វើការចាត់ចែងនោះទេ នោះគឺភាគបម្រុង ហើយការធ្វើមតកសាសន៍ដែលបំពានលើសិទ្ធិអ្នកទទួលភាគបម្រុងនោះ អ្នកមានសិទ្ធិទទួលភាគបម្រុង មានសិទ្ធិក្នុងការទាមទារឱ្យកាត់ចំណែកនៃមតកសាសន៍ដើម្បីបំពេញភាគបម្រុងបាន ។ បើយើងនិយាយដោយសង្ខេបវត្ថុបំណងនៃរបបភាគបម្រុង គឺបង្កើតឡើងដើម្បីធានា សិទ្ធិរបស់សន្តតិជនលើទ្រព្យសម្បត្តិរបស់មកជន ករណីមតកជនមិនបានបែងចែងទៅឱ្យខ្លួន ឬ ដោយហេតុការណ៍ណាមួយ ដែលមតកជនពុំបានបែងចែកដោយគ្មានចេតនាជាអាទិ៍ ។ ភាគបម្រុងនេះនឹងយកមកអនុវត្តតែក្នុងករណីដែលមានអ្នកត្រូវទទួលភាគបម្រុងប៉ុណ្ណោះ ក្នុងករណីគ្មានបុគ្គលណាផ្សេង មានសិទ្ធិលើភាគបម្រុងទេ នោះនឹងត្រូវអនុវត្តតាមខ្លឹមសារនៃមតកសាសន៍ទាំងស្រុង ។

ក្នុងករណីមតកសាសន៍ បានបំពានលើភាគបម្រុង ហើយអ្នកមានសិទ្ធិទាមទារ អាចទាមទារឱ្យដកយកនូវតម្លៃនៃទ្រព្យសម្បត្តិនៃមតកសាសន៍ ដើម្បីបំពេញភាគបម្រុងរបស់ខ្លួនបាន ។ អ្នកដែលមានសិទ្ធិទាមទារនូវភាគបម្រុងរួមមាន ៖

- បច្ឆាញាតិផ្ទាល់ ឬ ឪពុកម្តាយ ឬ ជីដូនជីតា និងសហព័ទ្ធរបស់មតកជន ដែលក្នុងនោះត្រូវបានកំណត់ថា៖
  - ✓ ១ ភាគ ៣ (មួយភាគបី) នៃទ្រព្យសម្បត្តិរបស់មតកជនក្នុងករណីមានតែសន្តតិជនជាឪពុកម្តាយ ឬ ជីដូន ជីតា ប៉ុណ្ណោះ ។
  - ✓ ១ ភាគ ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីផ្សេង ។[72]

ចំពោះទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង គឺត្រូវគណនាដោយយកទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម បូកតម្លៃផលប្រយោជន៍ពិសេស បូកនឹងតម្លៃប្រទានកម្ម និង ដកនូវចំនួនប្រាក់សរុបនៃកាតព្វកិច្ច ។[73]

---

[71] មាត្រា ១២០១ មាត្រា ១២០២ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧ និង មាត្រា ២ និង ចំនុច ១៤ ឧបសម្ព័ន្ធផ្នែកទី៥ ច្បាប់ស្តីពី រឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង ឆ្នាំ២០១០

[72] មាត្រា ១២៣០-១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[73] មាត្រា ១២៣១-១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ឧទាហរណ៍ ៖ មតកជន A មានកូនចំនួន ៣ នាក់ គឺ B , C , D និងប្រពន្ធ E នៅពេលចាប់ផ្តើមសន្តតិកម្ម A មានទ្រព្យ១០,០០០ ដុល្លារ B បានទទួលផលប្រយោជន៍ពិសេសនៃអាពាហ៍ពិពាហ៍ ចំនួន ១,០០០ ដុល្លារ ហើយ A បានធ្វើប្រទានកម្មតាមរយៈបណ្តាំទៅឱ្យស្រីកំណាត់ចិត្តចំនួន ៥,០០០ ដុល្លារ ហើយ A ក៏បានជំពាក់ប្រាក់ F ចំនួន ៣,០០០ ដុល្លារ ផងដែរ ។

ដូចនេះ ការគណនាភាគបម្រុង គឺ ទ្រព្យសម្បត្តិពេលចាប់ផ្តើមសន្តតិកម្ម + តម្លៃផលប្រយោជន៍ពិសេស + តម្លៃនៃប្រទានកម្ម + កាតព្វកិច្ច = តម្លៃនៃទ្រព្យសម្បត្តិទាំងអស់ = ១០០០០+១០០០+៥០០០-៣០០០= ១៣០០០ ដោយហេតុថា សន្តតិជនគឺ កូន និងប្រពន្ធ មានចំនួន ៤នាក់ ហេតុនេះដោយអនុឡោមតាមមាត្រា ១២៣០ នាំឱ្យភាគបម្រុងស្មើ ១៣០០០ / ២ / ៤ = ១៦២៥ ដុល្លារ ។

សរុបសេចក្តីមកតាមរយៈឧទាហរណ៍ខាងលើ ក្នុងករណីសន្តតិជនណាម្នាក់មិនមានចំណែកដែលកំណត់ក្នុងមតកសាសន៍នោះទេ អាចទាមទារភាគបម្រុងរបស់ខ្លួនបាន ដោយត្រូវសម្រួលដកចេញពីតម្លៃមតកសាសន៍តាមលំដាប់ដែលកំណត់ដោយច្បាប់ ។

## ផ្នែកទី ៣ ការយល់ព្រម និង បោះបង់សន្តតិកម្មរបស់សន្តតិជន

សន្តតិកម្មកម្មតាមបណ្តាំ គឺជាសកម្មភាពឯកតោភាគី របស់មតកជនបង្ហាញឆន្ទៈចាត់ចែងនូវទ្រព្យសម្បត្តិរបស់ខ្លួនជាមុនពេលមានជីវិត ដើម្បីអនុវត្តនៅពេលខ្លួនទទួលមរណភាព ដូច្នេះវាមិនមែនជាសកម្មភាពទ្វេភាគី ដូចជាសកម្មភាពកិច្ចសន្យា ដែលមានអានុភាពចាប់បង្ខំឱ្យគោរព និងអនុវត្តតាម លើភាគីម្ខាងទៀតនៃកិច្ចសន្យាអញ្ចឹមញ្ចឹងឡើយ។ ហេតុនេះទើបច្បាប់ផ្តល់សិទ្ធិឱ្យសន្តតិជន ឬអច្ច័យលាភី អាចបង្ហាញឆន្ទៈថា ទទួលយក ឬ បោះបង់ សន្តតិកម្មនោះបានទោះជាសិទ្ធិ ឬ កាតព្វកិច្ចក៏ដោយ។ នេះជាផ្នែកមួយដែលបង្ហាញថាក្រមរដ្ឋប្បវេណីបានគោរពនូវគោលការណ៍ស្វ័យភាពបុគ្គលក្នុងការទទួលយក ឬ បោះបង់នូវសកម្មភាពរបស់មតកជនមកលើខ្លួន ព្រោះដើម្បីការពារនូវសេចក្តីថ្លៃថ្នូរ និង ស្ថិរភាពសេដ្ឋកិច្ចរបស់សន្តតិជន។ ហើយការបង្ហាញឆន្ទៈនេះ យើងនឹងបែងចែកជាពីរកថាភាគសំខាន់ៗ គឺ កថាភាគទី ១ លក្ខខណ្ឌនៃការបង្ហាញឆន្ទៈយល់ព្រម និងបោះបង់មតកសាសន៍ និង កថាភាគទី ២ អានុភាពនៃការយល់ព្រម និង បោះបង់សន្តតិកម្ម ។

### កថាភាគទី ១ លក្ខខណ្ឌនៃការបង្ហាញឆន្ទៈយល់ព្រម និងបោះបង់មតកសាសន៍

ការបង្ហាញឆន្ទៈយល់ព្រម និងបោះបង់មតកសាសន៍ ត្រូវអនុវត្តតាមលក្ខខណ្ឌមួយចំនួនដែលត្រូវគោរព និង ជាការទុកពេលវេលាសមរម្យដើម្បីឱ្យសន្តតិជនពិចារណា និង ស្រាវជ្រាវ ពីផលប្រយោជន៍ និង បន្ទុកនានាដែលអាចធ្លាក់មកលើខ្លួន មុនសម្រេចថាយល់ព្រមទទួល ឬ បោះបង់មតកសាសន៍ចំពោះខ្លួន ហើយរបបនេះក៏បញ្ញត្តពីស្ថានភាពខ្លះដែលផ្តល់សិទ្ធិឱ្យសន្តតិជនធ្វើការលុបចោលនូវការយល់ព្រម ឬ បោះបង់មតកសាសន៍នេះវិញបានដែរ ។ ហេតុនេះចំពោះលក្ខខណ្ឌទូទៅនៃការបង្ហាញឆន្ទៈ ការយល់ព្រម និង បោះបង់មតកសាសន៍នេះ

យើងនឹងលើកយកគោលការណ៍សំខាន់ រួមមាន ១. អំឡុងពេលនៃការយល់ព្រម ឬ បោះបង់មតកសាសន៍ ២. លក្ខខណ្ឌនៃការលុបចោលនូវការយល់ព្រម ឬ បោះបង់មតកសាសន៍ និង ៣. ការបោះបង់សន្តតិកម្ម ។

**១. អំឡុងពេលនៃការយល់ព្រម ឬ បោះបង់មតកសាសន៍**

សន្តតិជន មានពេល ៣(បី) ខែ គិតចាប់ពីពេលដែលខ្លួនបានដឹងថា សន្តតិកម្មបានបង្កើតអានុភាពចំពោះខ្លួនបានចាប់ផ្ដើម ប៉ុន្តែបើមានភាពចាំបាច់ ដូចជាត្រូវការសិក្សាពីប្រភេទ ប្រភព ទីកន្លែង សិទ្ធិ ឬ បន្ទុក ជាអាទិ៍នៃមតកសាសន៍ដែលនឹងមានចំពោះខ្លួន សន្តតិជនអាចស្នើសុំពន្យារពេលបាន ដោយដាក់ពាក្យសុំទៅតុលាការ ។ លើសពីនេះក្នុងករណីអំឡុងពេលដែលបានកំណត់នេះ សន្តតិជនបានទទួលមរណភាព ដោយពុំទាន់បានបង្ហាញឆន្ទៈថា យល់ព្រម ឬបោះបង់សន្តតិកម្មនេះទេ រយៈពេល ៣(បី) នោះ ត្រូវគិតពីពេលដែលសន្តតិជនជំនួសបានដឹងថា សន្តតិកម្មមានចំពោះខ្លួន ។[74]

ដោយឡែក ករណីសន្តតិជន ជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេល ៣ (បី) ខែ ត្រូវគណនាដោយគិតពីពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់បានដឹងថា សន្តតិកម្មមានចំពោះអនីតិជន ឬ ជននៅក្រោអាណាព្យាបាលទូទៅនោះ បានចាប់ផ្តើម ។[75]

ទោះបីជាមានការកំណត់ពីអំឡុងពេលដើម្បីបង្ហាញឆន្ទៈក្នុងការយល់ព្រម ឬ បោះបង់មតកសាសន៍បានកន្លងផុតទៅក៏ដោយ បើសិនជាការទទួលយកមតកសាសន៍ បន្ទាប់មកលេចឡើងនូវបន្ទុក ឬ អត្ថិភាពនៃកាតព្វកិច្ចថ្មី បានកើតឡើង ដោយសន្តតិជន ពុំអាចដឹងបានក្នុងលក្ខណៈនៃជីវភាពទូទៅរបស់មតកជន នោះ អំឡុងពេល ០៣ (បី) ខែ ដែលត្រូវកំណត់ ត្រូវគិតពីពេលដែលសន្តតិជនបានដឹងពីហេតុ បន្ទុក ឬ អត្ថិភាពនៃកាតព្វកិច្ចថ្មីនោះកើតមានឡើង ។[76]

**២. លក្ខខណ្ឌនៃការលុបចោលនូវការយល់ព្រម ឬ បោះបង់មតកសាសន៍**

ការបង្ហាញឆន្ទៈទទួលយក ឬ បោះបង់មតកសាសន៍ គឺមិនអាចលុបចោលវិញបានឡើយ ទោះបីជាការបង្ហាញឆន្ទៈនោះស្ថិតក្នុងអំឡុងពេល ៣(បី) ដែលបានកំណត់ក្នុងមាត្រា ១២៤៨ នៃក្រមរដ្ឋប្បវេណីក៏ដោយ ព្រោះការបង្ហាញឆន្ទៈរួចមកហើយ វាអាចបណ្តាលឱ្យប៉ះពាល់ដល់ផលប្រយោជន៍ភាគីពាក់ព័ន្ធ ដោយហេតុនានា នៃសកម្មភាពប្រតិបត្តិនៃមតកសាសន៍បានដំណើរការ ឬ មានវិបាកស្មុគស្មាញដល់ការរៀបចំឡើងវិញនៃការអនុវត្តមតកសាសន៍ជាអាទិ៍ ។ ប៉ុន្តែបើសិនការបង្ហាញឆន្ទៈក្នុងការទទួលយក ឬ បោះបង់ មតកសាសន៍នោះកើតឡើងក្នុងស្ថានភាពនៃវិការៈនៃការបង្ហាញឆន្ទៈ ដូចជា ការភាន់ច្រឡំ ការឆបោក ការគំរាមកំហែង ជាអាទិ៍

---

[74] មាត្រា ១២៤៨ និង មាត្រា ១២៤៩ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

[75] មាត្រា ១២៥១ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

[76] មាត្រា ១២៥១-១ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

នោះអាចធ្វើការលុបចោលនូវការយល់ព្រមទទួល ឬ បោះបង់ មតកសាសន៍នោះបាន ។ ប៉ុន្តែ សន្តតិជនត្រូវអនុវត្តសិទ្ធិលុបចោល ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីដឹងថាខ្លួនអាចផ្តល់សច្ចានុមតិបាន និង មិនអាចអនុវត្តសិទ្ធិលុបចោលបានឡើយបើសកម្មភាពនៃការយល់ព្រមទទួល ឬ បោះបង់មតកសាសន៍នោះ លើសពី ៥(ប្រាំ)ឆ្នាំ កន្លងផុតទៅហើយនោះ ។[77]

ឧទាហរណ៍ ៖ ប្រសិនបើ សន្តតិជន A បានបោះបង់ចោល នូវមតកសាសន៍ ដែលផ្តល់ឱ្យខ្លួនជាដី តម្លៃ២០០០០ ដុល្លារ តែត្រូវទទួលបន្ទុកសងប្រាក់ទៅ ម្ចាស់បំណុល B ៣០០០ ដុល្លារ ។ ប៉ុន្តែដោយហេតុថា អំឡុងពេលសន្តតិកម្មមានអានុភាពចំពោះគាត់ និង ក្នុងអំឡុងពេលតម្រូវឱ្យមានការបង្ហាញឆន្ទៈឱ្យ A ទទួលស្គាល់ ឬ បោះបង់ចោល មតកសាសន៍ ស្របពេលគាត់ជាប់បំពេញកិច្ចការនៅក្រៅប្រទេស ហើយ A ត្រូវបានសន្តតិជន B ឆបោកថា ដីនោះតម្លៃតែ ២០០០ដុល្លារ ទេទើប A សម្រេចបោះបង់មតកសាសន៍នោះតែម្តង ។ ហេតុនេះ ក្នុងរយៈ ៦ខែ គិតចាប់ពីគិតអាចផ្តល់សច្ចានុមតិបាន ឬចាប់ពីពេលដឹងថាខ្លួនមានសិទ្ធិលុបចោល A អាចលុបចោលនូវការ បោះបង់មកតសាសន៍នោះបាន ដោយការបង្ហាញឆន្ទៈមានវិការៈ។

## កថាភាគទី ២ អានុភាពនៃការយល់ព្រម និង បោះបង់សន្តតិកម្ម

### ១. ការយល់ព្រមទាំងស្រុង

ការយល់ព្រមទាំងស្រុង គឺសំដៅលើការយល់ព្រមបន្តនូវសិទ្ធិ និង កាតព្វកិច្ច ទាំងស្រុង ដោយគ្មានកម្រិតរបស់សន្តតិជន ជុំវិញមត៌កដែលមតកជនធ្វើចំពោះសន្តតិជន ។ ក្នុងន័យនេះ ករណីដែលមតកសាសន៍ធ្វើសម្រាប់សន្តតិជននូវចំណែកទ្រព្យសម្បត្តិ និង បន្ទុកដែលជាកាតព្វកិច្ចនោះ ទៅឱ្យសន្តតិជនម្នាក់ ឬ ច្រើននាក់ ក្នុងករណីសន្តតិជនបានទទួលយល់ព្រមទាំងស្រុងនូវមតកសាសន៍ចំពោះខ្លួននោះ សន្តតិជនត្រូវទទួលទាំងស្រុងដោយមិនគិតពីតម្លៃ ឬ ទម្ងន់បន្ទុក រវាងសិទ្ធិ និង កាតព្វកិច្ចនោះឡើយ មានន័យថា ទោះបីជាទ្រព្យសម្បត្តិដែលផ្តល់ឱ្យដោយមតកសាសន៍ មានតម្លៃតិចជាងតម្លៃនៃកាតព្វកិច្ចនោះក្តី ។[78]

ឧទាហរណ៍ ៖ មតកជន A បានផ្តល់ផ្ទះដែលខ្លួនធ្លាប់រស់នៅជុំគ្រួសារតម្លៃ ៥០០០ ដុល្លារ ទៅឱ្យកូនប្រុសម្នាក់ B ប៉ុន្តែ B ត្រូវសងបំណុលទៅឱ្យម្ចាស់បំណុលរបស់ A ចំនួន ១០០០០ ដុល្លារ ។ ទោះបីជាផ្ទះមានតម្លៃតិចជាង បំណុលពាក់កណ្តាលក្តី B យល់ព្រមដោយខ្លួនគិតថា ផ្ទះនោះមានអនុស្សាវរីយ៍ខ្លាំងចំពោះគាត់ដោយមិនគិតពីបន្ទុក ។

លើសពីនេះការយល់ព្រមទាំងស្រុងលើអានុភាពមតកសាសន៍ គឺត្រូវបានបែងចែកជាពីរគឺ ការយល់ព្រមទាំងស្រុងដោយការបង្ហាញឆន្ទៈ និង ការយល់ព្រមទាំងស្រុងកំណត់ដោយច្បាប់ ។

[77] មាត្រា ១២៥២-១ និង មាត្រា ១២៥២-២ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

[78] មាត្រា ១២៥៤ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧ និង មាត្រា ១២៥៤ សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០១០

➢ **ការយល់ព្រមទាំងស្រុងដោយការបង្ហាញឆន្ទៈ**

នៅពេលដែលសន្តតិជន បានដឹងពីការចាប់ផ្តើមនៃអានុភាពសន្តតិកម្មសម្រាប់ខ្លួន អំឡុងពេលកំណត់ ៣ (បី) ខែ ឬ លើសក្នុងករណីស្នើសុំទៅតុលាការ ដូចមានចែងក្នុងមាត្រា ១២៤៨ នៃក្រមរដ្ឋប្បវេណី ហើយអំឡុងពេលនោះសន្តតិជនអាចបង្ហាញឆន្ទៈក្នុងការទទួលយកសន្តតិកម្មនោះបាន ។

➢ **ការយល់ព្រមទាំងស្រុងកំណត់ដោយច្បាប់**

ផ្ទុយពីការយល់ព្រមទាំងស្រុងដោយការបង្ហាញឆន្ទៈ ករណីដែលសន្តតិកម្មបានបំពេញ ឬ មិនបានបំពេញនូវសកម្មភាពដូចខាងក្រោមច្បាប់បានបញ្ញត្តថា សន្តតិជនបានយល់ព្រមទទួលទាំងស្រុងនូវមតកសាសន៍នោះគឺ៖

- ✓ បើសន្តតិជនបានចាត់ចែងមត៌កនោះ ទាំងអស់ ឬ មួយភាគ ប៉ុន្តែបញ្ញត្តនេះមិនអនុវត្តឡើយក្នុងករណីចំពោះសកម្មភាពរក្សារ និង សកម្មភាពត្រឹមតែជាការគ្រប់គ្រង ឬ ការចាត់ចែងដោយការភាន់ច្រឡំដែលមិនអាចដឹងពី អត្ថិភាពពិតប្រាកដនៃកាតព្វកិច្ច ដូចមានចែងក្នុងមាត្រា ១២៥១ ។
- ✓ បើសន្តតិជនមិនបានយល់ព្រមដោយមានកម្រិត ឬ បោះបង់ នៅក្នុងអំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ ។
- ✓ ទោះបីជាសន្តតិជនបានយល់ព្រមដោយមានកម្រិត ឬ បោះបង់ ក៏ដោយបើសន្តតិជន បានលាក់មត៌កទាំងអស់ ឬ មួយភាគ ឬ បានប្រើប្រាស់មត៌កនោះដើម្បីខ្លួន ប៉ុន្តែករណីនេះសកម្មភាពរបស់សន្តតិជនលំដាប់មុនមិនមានអានុភាពចំពោះសន្តតិជនលំដាប់ក្រោយដោយសារការបោះបង់សន្តតិកម្មឡើយ ។

**២. យល់ព្រមដោយមានកម្រិត**

ការយល់ព្រមដោយមានកម្រិតមានគោលបំណង ការពារសន្តតិជនពីការទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់មតកជន ដោយអានុភាពនៃការទទួលមត៌ក ។ ផ្ទុយពីការទទួលយកទាំងស្រុង របបទទួលយល់ព្រមមានកម្រិតអាចឱ្យសន្តតិជន បម្រុងទុកនូវសំណងកាតព្វកិច្ច ឬ អច្ច័យទានរបស់មតកជន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម តែប៉ុណ្ណោះ ។[79] ទាក់ទងនឹងរបបនៃការយល់ព្រមដោយមានកម្រិតនេះ យើងសិក្សាលើ នីតិវិធីនៃការស្នើសុំការយល់ព្រមដោយមានកម្រិត និង អានុភាពនៃការយល់ព្រមដោយមានកម្រិត ។

➢ **នីតិវិធីនៃការស្នើសុំការយល់ព្រមដោយមានកម្រិត**

ដើម្បីបង្កើតសិទ្ធិពេញលេញតាមច្បាប់លើ សន្តតិជន ឬ សហសន្តតិជនទាំងអស់ក្នុងករណីមានសន្តតិជនច្រើននាក់នៃមត៌ក ដែលចង់ទទួលបានការយល់ព្រមដោយមានកម្រិតលើមតកសាសន៍របស់ខ្លួន ត្រូវ

[79] ទំព័រទី១០១ សៀវភៅសេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគទី៣ ឆ្នាំ២០១៧

ដាក់ពាក្យស្នើសុំអំពី ការយល់ព្រមដោយមានកម្រិត ដោយរួមជាមួយនឹងបញ្ជីសារពើភ័ណ្ឌ ទៅតុលាការសាលាដំបូង នៃទីកន្លែងចាប់ផ្តើមសន្តតិកម្ម នៅអំឡុងពេល ៣ (ខែ) ចាប់ពីសន្តតិជនបានដឹងពីការចាប់ផ្តើមបង្កើតអានុភាពមតកសាសន៍ចំពោះខ្លួន ។ ប្រសិនបើតុលាការ យល់ឃើញថាពាក្យស្នើសុំអំពីការយល់ព្រមដោយមានកម្រិត មានភាពត្រឹមត្រូវ តុលាការនឹងចេញដីកាសម្រេច ដើម្បីទទួលយកពាក្យស្នើសុំនោះ ។[80]

➢ **<u>អានុភាពនៃការយល់ព្រមដោយមានកម្រិត</u>**

នៅពេលដែលតុលាការបានចេញនូវសេចក្តីសម្រេច ទទួលស្គាល់ការទទួលខុសត្រូវដោយមានកម្រិតរបស់សន្តតិជន នោះម្ចាស់បំណុលរបស់មតកជន មិនអាចទាមទារឱ្យសន្តតិជនទទួលខុសត្រូវទាំងស្រុង ឬទាមទារជម្រះបញ្ជី ដោយប្រើទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជនទទួលខុសត្រូវ ដោយមានកម្រិតនោះទេ ទោះបីជាតម្លៃនៃមត៌កដែលសន្តតិជនទទួលយកមិនគ្រប់គ្រាន់ សំរាប់សងបំណុលចំពោះម្ចាស់បំណុលក៏ដោយ ។[81]

ប៉ុន្តែ អានុភាពនៃការយល់ព្រមដោយមានកម្រិត គឺការពារតែសន្តតិជនសុចរិត ប៉ុណ្ណោះ ។ ក្នុងករណីដែលសន្តតិជន បានធ្វើសកម្មភាពដោយទុច្ចរិត ដូចជា មិនសរសេរទ្រព្យសម្បត្តិទាំងអស់ ឬ មួយភាគទៅក្នុងបញ្ជីសារពើភ័ណ្ឌ ឬ បានចាត់ចែងភាគណាមួយនៃទ្រព្យសម្បត្តិ ឬ លាក់ ឬ ប្រើប្រាស់ភាគណាមួយនៃទ្រព្យជាប្រយោជន៍ផ្ទាល់ខ្លួន នោះសន្តតិជនរូបនោះត្រូវបានច្បាប់សន្មតថា បានយល់ព្រមទទួលទាំងស្រុងនៃមតកសាសន៍ចំពោះខ្លួន ។[82]

ឧទាហរណ៍ ៖ តាមរយៈមតកសាសន៍ បានផ្តល់ឱ្យសន្តតិជន A ទទួលបានដីមួយកន្លែង មានតម្លៃ ១០០០០ ដុល្លារ ប៉ុន្តែ ត្រូវសងបំណុលទៅឱ្យម្ចាស់បំណុល B ។ ដោយមិនដឹងថាចំនួនទឹកប្រាក់ត្រូវសងលើម្ចាស់បំណុល B មានចំនួនប៉ុន្មាន នាំឱ្យ A ដាក់ពាក្យទៅតុលាការស្នើសុំសេចក្តីសម្រេចអំពី ការទទួលយកដោយមានកម្រិត ប៉ុន្តែក្នុងបញ្ជីរគាត់បានដាក់ថ្លៃលក់ដី តែចំនួន ៥០០០ ដុល្លារ ដោយសារគាត់យកទៅចាយអស់ ៥០០០ដុល្លារ បាត់ទៅហើយ។ ក្នុងករណីនេះ ទោះបីជាសិទ្ធិលើបំណុលរបស់ B មានតម្លៃ លើសពី ១០០០០ ក៏ដោយ ក៏ B អាចទាមទារបំណុលទាំងអស់ពី A បានដែរ ព្រោះ A ត្រូវបានសន្មតថា បានទទួលទាំងស្រុងនូវមតកសាសន៍ចំពោះខ្លួន។

[80] មាត្រា ១២៤៨, មាត្រា ១២១២៥៦, មាត្រា ១២៥៧ ក្រមរដ្ឋប្បវេណី ២០០៧ និង មាត្រា៣-២ ច្បាប់ស្តីពី នីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

[81] ទំព័រទី ១០៣ នៃសៀវភៅសេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគទី៣ ឆ្នាំ២០១៧

[82] មាត្រា ១២៥៥-១-ក ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ៣. ការបោះបង់សន្តតិកម្ម

បុគ្គលដែលមានបំណងបោះបង់សន្តតិកម្ម ឬ មតកសាសន៍ ត្រូវដាក់ពាក្យស្នើសុំទៅតុលការ លើកលែងអច្ច័យលាភីមានកំណត់ ។ ការបោះបង់សន្តតិកម្ម មានអានុភាពប្រតិសកម្មដោយចាត់ទុកថា សន្តតិកម្មនោះគ្មានអានុភាពតាំងពីដំបូងនូវចំណែកនៃការបោះបង់នោះ មានន័យថា បើសន្តតិជន និង អច្ច័យលាភីដែលជាប្រធាននៃមតកសាសន៍បានបោះបង់មតកសាសន៍ទាំងអស់គ្នា នោះស្មើនឹងគ្មានមតកសាសន៍ ឬ មតកសាសន៍គ្មានអានុភាពទាំងស្រុង ។ ប៉ុន្តែ បើសន្តតិជនណាម្នាក់បានបោះបង់សន្តតិកម្មនោះចាត់ទុកថា មិនមានអានុភាពលើចំណែកនៃការបោះបង់នោះ ឬ មកសាសន៍គ្មានអានុភាពដោយផ្នែក ។[83]

## ផ្នែកទី ៤ ការអនុវត្តមតកសាសន៍

វត្ថុបំណង នៃការអនុវត្តមតកសាសន៍ គឺជាការចាត់ចែងដែលចាំបាច់ ដើម្បីសម្រេចនូវខ្លឹមសារនៃមតកសាសន៍នោះ ក្រោយពេលដែលអានុភាពនៃមតកសាសន៍នោះ បានកើតឡើង ។ ត្បិតក្នុងការអនុវត្តមតកសាសន៍មិនមាននីតិវិធីច្បាស់លាស់យ៉ាងណាក្តី ដើម្បីមតកសាសន៍នោះអាចអនុវត្តបានត្រូវបំពេញលក្ខខណ្ឌចំបាច់រួមមាន ការបញ្ជាក់មតកសាសន៍, អ្នកប្រតិបត្តិមតកសាសន៍ និង ការបញ្ចប់មតកសាសន៍ ។

### កថាភាគទី ១ ការបញ្ជាក់មតកសាសន៍

នៅពេលដែលលក្ខខណ្ឌនៃការបង្កើតអានុភាពនៃមតកសាសន៍ តាមរយៈមរណភាពរបស់មតកជន ឬ តាមរយៈការប្រកាសបាត់ខ្លួនមតកជនជាផ្លូវការពីតុលាការ នោះ អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ឬ ក្នុងករណីគ្មានអ្នកថែរក្សាគ្រប់គ្រងមតកសាសន៍ នោះសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ដែលបានរកឃើញលិខិតមតកសាសន៍នោះ ត្រូវដាក់ពាក្យសុំបញ្ជាក់លិខិតនោះ ដោយភ្ជាប់លិខិតមតកសាសន៍ទៅតុលាការ ដោយគ្មានការយឺតយ៉ាវ ក្រោយពីខ្លួនបានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម លើកលែងលិខិតបណ្តាំដែលបានធ្វើជាទម្រង់លិខិតយថាភូត ។[84]

ដោយហេតុថា លិខិតមតកសាសន៍ មាន ៣(បី) ទម្រង់ គឺ មតកសាសន៍ដោយលិខិតឯកជន ដោយលិខិតសម្ងាត់ និង ដោយលិខិតយថាភូត ដូច្នេះតាមរយៈ មាត្រា ១២១៣ កថាខណ្ឌទី១ និង កថាខណ្ឌទី២ លិខិតដែលត្រូវឆ្លងកាត់ការបញ្ជាក់ជាចាំបាច់ពីតុលាការ គឺ មតកសាសន៍ដោយលិខិតឯកជន និង មតកសាសន៍ដោយលិខិតសម្ងាត់ ។ ចំពោះនីតិវិធីនៃការបញ្ជាក់សុពលភាពនេះ គឺអ្នកដែលដាក់ពាក្យសុំបញ្ជាក់មតកសាសន៍ ត្រូវធ្វើឡើងយ៉ាងឆាប់រហ័សទៅតុលាការ សាលាដំបូងនៃទីកន្លែងចាប់ផ្តើមសន្តតិកម្ម ហើយ

[83] មត្រា ១២០១-១, មាត្រា១២៦០ និងមាត្រា ១២៦១ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

[84] មាត្រា ១២១៣ ក្រមរដ្ឋប្បវេណី ២០០៧

តុលាការនឹងចេញនូវការបញ្ជាក់មតកសាសន៍តាមរយៈដីកាសម្រេច ។[85] មូលហេតុចាំបាច់ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃ មតកសាសន៍ជាលិខិតឯកជន ឬ លិខិតសម្ងាត់គឺ មានវត្ថុបំណងសំខាន់ ដើម្បីបញ្ជាក់ភាពត្រឹមត្រូវនៃឆន្ទៈរបស់មតកជន ជៀសវាងការក្លែងបន្លំ និង ដើម្បីឱ្យសន្តតិជន និង ភាគីពាក់ព័ន្ធនឹងផលប្រយោជន៍ដោយអានុភាពនៃមតកសាសន៍នោះ ទទួលស្គាល់ ឬ ធ្វើការតវ៉ានានាដែលអាចកើតមានជាយថាហេតុ ។ ដោយឡែកចំពោះ មតកសាសន៍ដោយលិខិតយថាភូត ដែលតាក់តែង ឬ ផ្តល់យថាភាព ដោយសារការី ច្បាប់មិនតម្រូវឱ្យដាក់ពាក្យស្នើសុំបញ្ជាក់ពីសុពលភាពនោះទេ ដោយហេតុថា សារការី គឺទទួលបានអំណាចតាមរយៈប្រតិភូកម្មអំណាចពីរដ្ឋ និង បំពេញមុខងាររបស់ខ្លួនក្នុងនាមជាមន្ត្រីសាធារណៈ ដែលមានមុខងារធ្វើលិខិតយថាភូតបញ្ជាក់ពីលក្ខណៈពិតប្រាកដត្រឹមត្រូវ ធានារ៉ាប់រងអំពីកាលបរិច្ឆេទតម្កល់ រក្សាទុក និង ចេញសេចក្តីចម្លងយថាភូត នៃលិខិតទាំងឡាយដែលត្រូវតែឱ្យមានការបញ្ជាក់ ។[86] មូលហេតុដូច្នេះហើយទើបមានការទទួលស្គាល់ភាពច្បាស់លាស់របស់មតកសាសន៍ ដែលធ្វើឡើងដោយសារការីដែលជាអ្នកជំនាញផ្នែកច្បាប់ ក្លាយជាលិខិតយថាភូតដែលអាចជឿជាក់ពីភាពច្បាស់លាស់ ដោយមិនចាំបាច់ក្នុងការបញ្ជាក់ពីតុលាការ ហើយអាចយកទៅអនុវត្តបានដោយពេញលេញតាមច្បាប់ ។[87]

**កថាភាគទី២ ការអនុវត្តពិសេសនៃមតកសាសន៍យថាភូត**

ដោយឡែកមតកសាសន៍ដោយលិខិតថាភូត ដែលតាក់តែងឡើងដោយសារការី មានអានុភាពអនុវត្តបានដោយពុំចាំបាច់ឆ្លងកាត់នីតិវិធីបញ្ជាក់ពីតុលាការឡើយ ។[88] ដោយហេតុថា សារការី គឺជាមន្ត្រីសាធារណៈដែលមានមុខងារធ្វើលិខិតយថាភូតបញ្ជាក់ពីលក្ខណៈពិតប្រាកដត្រឹមត្រូវ ធានារ៉ាប់រងអំពីកាលបរិច្ឆេទតម្កល់ រក្សាទុក និង ចេញសេចក្តីចម្លងយថាភូតនៃលិខិតទាំងឡាយដែលត្រូវតែឱ្យមានការបញ្ជាក់ ។ លើសពីនេះតាមរយៈក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៣៥០ (លិខិតអនុវត្ត) កថាខណ្ឌទី២ ចំណុច ច មាត្រា ៣៥៤ (ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្តល់រូបមន្តអនុវត្ត) កថាខណ្ឌទី២ បានបង្ហាញថាក្នុងករណីដែល មតកសាសន៍ជាលិខិតយថាភូតធ្វើឡើងដោយសារការី គឺអាចយកទៅអនុវត្តបាន ព្រោះ សារការី ជាអ្នកតាក់តែងមតកសាសន៍យថាភូត ជាអ្នករក្សាទុក និង សេចសេចក្តីចម្លងមតកសាសន៍យថាភូតសម្រាប់អនុវត្ត និង ចេញរូបមន្តដែលអាចអនុវត្តដោយបង្ខំបាន ។[89]

85 មាត្រា ៣-២, មាត្រា ៤ និង ឧបសម្ព័ន្ធផ្នែកទី៥ ចំនុចទី៥ ច្បាប់ស្តីពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ២០១០
86 លេខ ១៥៤ សន្ធានក្រមក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧
87 មាត្រា ១២១៣ សេចក្តីកំណត់មាត្រានីមួយៗចំពោះក្រមរដ្ឋប្បវេណី ភាគី ៦ ឆ្នាំ២០១០
88 ១២១៣-១-២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
89 សូមមើលឧបសម្ព័ន្ធទី ៥ ទី៦ និង ទី៧

ទោះបីជាច្បាប់មិនបានកំណត់ច្បាស់លាស់ថា មតកសាសន៍ដោយលិខិតយថាភូតគឺ សារការី ជាអ្នកចេញនូវរូបមន្តអនុវត្ត និង មានអានុភាពអនុវត្តដោយបង្ខំ តាមខ្លឹមសារនៃមតកសាសន៍យថាភូតក៏ដោយ ប៉ុន្តែដោយយោងលើបទបញ្ញត្តិខាងលើ ព្រមទាំងសារៈសំខាន់នៃតួនាទីរបស់សារការី និង ការអនុវត្តជាក់ស្តែងកន្លងមកគឺបានបញ្ជាក់ទាំងលក្ខណៈគតិយុត្ត និង ជាលក្ខណៈយុត្តិសាស្ត្រ បានឆ្លុះបញ្ចាំងឱ្យឃើញថា មតកសាសន៍ដោយលិខិតយថាភូតដែលតាក់តែងដោយសារការី រក្សាទុកដោយសារការី ហើយសារការីជាអ្នកចេញសេចក្តីចម្លងយថាភូត និង រូបមន្តអនុវត្ត ដែលអាចអនុវត្តដោយបង្ខំស្របតាមខ្លឹមសារនៃមតកសាសន៍ ។

ឧទាហរណ៍ ៖ មតកជន A បានធ្វើមតកសាសន៍ដោយលិខិតយថាភូតធ្វើឡើងដោយសារការី B ដោយមានខ្លឹមសារផ្តល់ដីមួយកន្លែងទៅឱ្យកូនប្រុស C និង ផ្ទះល្វែងមួយកន្លែងទៅឱ្យកូនស្រី D ។ នៅពេលមតកសាសន៍ចាប់ផ្តើមមានអានុភាពដោយមរណភាពរបស់ A នោះសារការីអាចហៅភាគីពាក់ព័ន្ធដើម្បីប្រកាសបណ្តាំ និង អាចចេញសេចក្តីចម្លងយថាភូត និង រូបមន្តអនុវត្តឱ្យសន្តតិជននោះ ហើយសេចក្តីចម្លងយថាភូត និង រូបមន្តអនុវត្តអាចអានុវត្តដោយបង្ខំដើម្បីឱ្យស្ថាប័នសុរិយោដីចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយប្តូរពីមតកជន មកសន្តតិជនបាន ។

### កថាភាគទី៣ អ្នកប្រតិបត្តិមតកសាសន៍

របបនៃអ្នកប្រតិបត្តិបង្កើតឡើង ដើម្បីសម្រួលដល់ការអនុវត្តមតកសាសន៍ប្រកបដោយភាពត្រឹមត្រូវការជឿទុកចិត្ត កាត់បន្ថយការរាំងស្ទះនានា ក្នុងកិច្ចដំណើរការអនុវត្តមតកសាសន៍ ធ្វើយ៉ាងណាឱ្យសម្រេចនូវខ្លឹមសារនៃមតកសាសន៍ ។ ហេតុនេះយើងនឹងលើកឡើងនូវចំនុចសំខាន់ៗទាក់ទងនឹងការអនុវត្តមតកសាសន៍នូវ មូលហេតុចាំបាច់ឱ្យមានអ្នកប្រតិបត្តិ, ការជ្រើសតាំងអ្នកប្រតិបត្តិ, ការលាឈប់ និង ការបញ្ឈប់ពីតួនាទីអ្នកប្រតិបត្តិ, ការកាន់កាប់មុខងារជាអ្នកប្រតិបត្តិ និង អានុភាព, សិទ្ធិនិងតួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍, កាតព្វកិច្ចអ្នកប្រតិបត្តិមតកសាសន៍ និង បន្ទុកនៃមត៌ក ។

#### ១. មូលហេតុបង្កើតឱ្យមានអ្នកប្រតិបត្តិ

មូលហេតុចម្បងដែលច្បាប់បង្កើតរបបនៃអ្នកប្រតិបត្តិនេះឡើង គឺដើម្បីឱ្យបុគ្គល ឬ ក្រុមបុគ្គល ជាអ្នកដែលនឹងក្លាយជាអ្នកប្រតិបត្តិ អនុវត្តឱ្យបានសម្រេចនូវខ្លឹមសារនៃមតកសាសន៍ ។ ហេតុនេះនៅពេលខ្លួនក្លាយជាអ្នកប្រតិបត្តិមតកសាសន៍ហើយនោះ ត្រូវតែអនុវត្ត សិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនស្របតាមច្បាប់ និង ឆន្ទៈរបស់មតកជន ដើម្បីសម្រេចឱ្យបានទាំងស្រុងនូវខ្លឹមសារមតកសាសន៍ ធានាតម្លាភាព ជម្លោះនឹងជៀសវាងបញ្ហារាំងស្ទះនានាដែលបង្កឡើងដោយភាគីពាក់ព័ន្ធ ។

#### ២. ការជ្រើសតាំងអ្នកប្រតិបត្តិ

បុគ្គល ដែលអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍ បានតាមរបៀបពីរយ៉ាង គឺ តាមរយៈការកំណត់ក្នុងមតកសាសន៍ និង តាមរយៈការជ្រើសតាំងពីតុលាការ ។

- ✓ ការកំណត់អ្នកប្រតិបត្តិតាមរយៈមតកសាសន៍ គឺកើតចេញពីឆន្ទៈរបស់ម្ចាស់បណ្ដាំដែលកំណត់ជាមុននូវអ្នកប្រតិបត្តិជាក់លាក់តែម្ដង ឬ មតកជនបានកំណត់អ្នកតំណាងដោយអាណត្តិរបស់ខ្លួន ដើម្បីជ្រើសតាំងអ្នកប្រតិបត្តិជំនួសខ្លួន ។
- ✓ ក្នុងករណីដែលមតកសាសន៍មិនបានកំណត់អំពីសមាសភាពអ្នកតំណាងដោយអាណត្តិ ឬ អ្នកប្រតិបត្តិនោះទេ ឬ អ្នកតំណាងដោយអាណត្តិ ឬ អ្នកប្រតិបត្តិលាលែងពីមុខងារ នោះសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ អាចស្នើសុំទៅតុលាការដើម្បីចាត់តាំងអ្នកប្រតិបត្តិបាន ។[90]

ទោះបីជាមតកសាសន៍បានកំណត់ពីសមាសភាពអ្នកប្រតិបត្តិ ឬ ផ្ដល់សិទ្ធិឱ្យតតិយជនជាអ្នកតំណាងដោយអាណត្តិរបស់ខ្លួនមានសិទ្ធិជ្រើសរើសអ្នកប្រតិបត្តិក៏ដោយ ច្បាប់មិនអនុញ្ញាតឱ្យក្រុមបុគ្គលមួយចំនួនមិនអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍បានដែល ព្រោះមានការបារម្ភពីសមត្ថភាព និង ភាពទុកចិត្តក្នុងការអនុវត្តមតកសាសន៍ ដោយបុគ្គលទាំងនោះមានជាអាទិ៍ អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភ និង ជនក្ស័យធន ។[91]

### ៣. ការលាឈប់ និង ការបញ្ឈប់ តួនាទីអ្នកប្រតិបត្តិ

អ្នកប្រតិបត្តិអាចលាឈប់ពីតួនាទីរបស់ខ្លួនបានក្នុងករណីខ្លួនមានមូលហេតុត្រឹមត្រូវ ដែលមិនអាច ឬ ពិបាកបំពេញនូវកិច្ចការអាណត្តិក្នុងនាមជាអ្នកប្រតិបត្តិមតកសាសន៍បាន ដោយដាក់ពាក្យស្នើសុំលាឈប់ទៅតុលាការសាលាដំបូងនៃទីកន្លែងចាប់ផ្ដើមសន្តតិកម្មបាន ។ នៅក្នុងពាក្យសុំលាឈប់នេះ អ្នកប្រតិបត្តិត្រូវតែបញ្ជាក់ភាពចាំបាច់របស់ខ្លួនដែលមិនអាចបំពេញកិច្ចការប្រតិបត្តិបានយ៉ាងជាក់ច្បាស់ ដូចជា បញ្ហាសុខភាព ការជាប់ទៅបំពេញបេសកកម្មក្នុងរយៈពេលវែងនៅក្រៅប្រទេស ឬ មូលហេតុចូលកាន់តំណែង ឬ កិច្ចការផ្សេងដែលធ្វើឱ្យមានការមមាញឹកជាអាទិ៍ ។ម្យ៉ាងវិញទៀតក្នុងករណីដែលអ្នកប្រតិបត្តិបានធ្វេសប្រហែល ខ្ជីខ្ជា ក្នុងការបំពេញភារកិច្ច ឬ មានភាពខ្ជិលច្រអូសក្នុងការបំពេញកិច្ចការរបស់ខ្លួន នោះសន្តតិកម្ម ឬ អច្ច័យលាភី ឬ អ្នកពាក់ព័ន្ធផលប្រយោជន៍នៃមតកសាសន៍អាចដាក់ពាក្យទៅតុលាការដើម្បីបញ្ឈប់តួនាទីអ្នកប្រតិបត្តិនោះ ។[92]

### ៤. ការកាន់កាប់មុខងារជាអ្នកប្រតិបត្តិ និង អានុភាព

នៅពេលអ្នកប្រតិបត្តិមតកសាសន៍ យល់ព្រមទទួលតួនាទីក្នុងនាមជាអ្នកប្រតិបត្តិមតកសាសន៍ នោះអ្នកប្រតិបត្តិត្រូវចូលកាន់មុខងារ និង ចាប់ផ្ដើមអនុវត្តមុខងារខ្លួនភ្លាមៗ ។ ក្នុងករណីដែលមតកសាសន៍ត្រូវបានកំណត់សមាសភាពអ្នកប្រតិបត្តិ ឬ តតិយជនតំណាងដោយអាណត្តិ មិនបានអនុវត្តតួនាទីរបស់ខ្លួន សន្តតិជន

[90] មាត្រា ១២១៤, មាត្រា ១២១៨ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

[91] មាត្រា ១២១៧ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

[92] មាត្រា ១២២៧ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ និង មាត្រា ១២២៧ សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០១០

ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍នៃមតកសាសន៍អាចធ្វើការដាស់តឿនទៅអ្នកប្រតិបត្តិ ឬ តតិយជនតំណាងដោយអាណត្តិបាន ក្នុងករណីមិនឆ្លើយតបស្មើនឹងបដិសេធទទួលតួនាទីជាអ្នកប្រតិបត្តិ ឬ អ្នកតំណាងដោយអាណត្តិ ។ ហើយនៅពេលមានអ្នកប្រតិបត្តិ នោះសន្តតិជនពុំអាចចាត់ចែងមត៌ក ឬ សកម្មភាពផ្សេងៗដែលនាំឱ្យរារាំងដល់ការប្រតិបត្តិមតកសាសន៍ឡើយ និង ក្នុងករណីសន្តតិជន ធ្វើការចាត់ចែងនូវសកម្មភាពអនុវត្តមតកសាសន៍ នោះសកម្មភាពទាំងនោះ គឺគ្មានអានុភាពឡើយ ។[93]

### ៥. សិទ្ធិ និង តួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍

ក្នុងនាមជាអ្នកប្រតិបត្តិមតកសាសន៍ អាចបំពេញតួនាទី និង មុខងាររបស់ខ្លួនដោយឯករាជ្យ មិនចំណុះទៅនឹងភាគីណាមួយ ឬ អ្នកពាក់ព័ន្ធផលប្រយោជន៍ណាមួយឡើយក្រៅតែខ្លឹមសារនៃមតកសាសន៍ ដូច្នេះគ្មានភាគីណាមួយ រួមទាំងសន្តតិជនផងមិនអាចបង្គាប់បញ្ជាឱ្យអ្នកប្រតិបត្តិអនុវត្តនូវសេចក្តីសម្រេចស្របតាមគំនិតរបស់ខ្លួនឡើយ ព្រោះអ្នកប្រតិបត្តិបំពេញមុខងារក្នុងនាមម្ចាស់បណ្តាំ ស្របតាមស្មារតីរបស់មតកសាសន៍ប៉ុណ្ណោះ ។ ផ្ទុយទៅវិញ សកម្មភាពរបស់អ្នកប្រតិបត្តិត្រូវមានអានុភាពដោយផ្ទាល់ចំពោះសន្តតិជន ។[94] មូលហេតុដែលច្បាប់ផ្តល់សិទ្ធិអំណាចឯករាជ្យមុខងារដល់អ្នកប្រតិបត្តិ គឺដើម្បីកុំឱ្យអ្នកពាក់ព័ន្ធផលប្រយោជន៍ធ្វើសកម្មភាពរារាំងនានាជាយថាហេតុដល់ការអនុវត្តមតកសាសន៍ ។

អ្នកអនុវត្តមតកសាសន៍ត្រូវអនុវត្តតួនាទី សិទ្ធិ និង មុខងាររបស់ខ្លួនក្នុងនាមជាអ្នកតំណាងអាណត្តិរបស់មតកជន ដើម្បីប្រយោជន៍សន្តតិជន ព្រោះសន្តតិជន ឬ អច្ច័យលាភីគឺជាប្រធាននៃសន្តតិកម្ម ដែលជាហេតុសកម្មភាពរបស់អ្នកប្រតិបត្តិមានអានុភាពលើសន្តតិជន និង អច្ច័យលាភី ។ តួនាទី សិទ្ធិ និង មុខងារសំខាន់ៗ របស់អ្នកប្រតិបត្តិមតកសាសន៍រួមមាន ៖

- ✓ **តួនាទីគ្រប់គ្រង** ៖ ក្នុងករណីមតកសាសន៍មានអ្នកប្រតិបត្តិ នោះអ្នកប្រតិបត្តិត្រូវជាអ្នកគ្រប់គ្រងមត៌ក ប៉ុន្តែអ្នកប្រតិបត្តិអាចមានភារកិច្ចគ្រប់គ្រងតែលើទ្រព្យសម្បត្តិ ដែលបានកំណត់ក្នុងមតកសាសន៍ប៉ុណ្ណោះ ពោលគឺទ្រព្យសម្បត្តិរបស់មតកជនដែលមិនបានចែងក្នុងមតកសាសន៍នោះទេ អ្នកប្រតិបត្តិពុំមានភារកិច្ចក្នុងការគ្រប់គ្រង ឬ កាន់កាប់ឡើយ ។[95]

  ឧទាហរណ៍៖ មតកជនមានរថយន្តចំនួន ២០គ្រឿង ប៉ុន្តែនៅក្នុងមតកសាសន៍គាត់បានចែកឱ្យ កូន៣នាក់របស់គាត់ ដោយម្នាក់ៗ ទទួលបានរថយន្តចំនួន ៤ គ្រឿង ដូច្នេះ អ្នកប្រតិបត្តិអាចធ្វើការកាន់កាប់ និង គ្រប់គ្រងរថយន្តតែ ១២គ្រឿង ដែលជាកម្មវត្ថុនៃមតកសាសន៍ដើម្បីអនុវត្តតាមខ្លឹមសារប៉ុណ្ណោះ ។

---

[93] មាត្រា ១២១៥, មាត្រា ១២១៦ និងមាត្រា ១២២១ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

[94] មាត្រា ១២២០ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

[95] មាត្រា ១២៦៣ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

- ✓ **តួនាទីរៀបចំបញ្ជីសារពើភ័ណ្ឌ** ៖ នៅពេលចូលកាន់តួនាទីជាអ្នកអនុវត្តមតកសាសន៍ អ្នកអនុវត្តត្រូវរៀបចំនូវបញ្ជីសារពើភ័ណ្ឌ ។ បញ្ជីសារពើភ័ណ្ឌសំដៅលើបញ្ជីដែលមានរាយនូវទ្រព្យសម្បត្តិទាំងអស់ដោយផ្អែកលើការកំណត់ក្នុងមតកសាសន៍ ដោយអនុញ្ញាតផងដែលក្នុងករណីសន្តតិជន ចង់ចូលរួមនៅពេលធ្វើបញ្ជីសារពើភ័ណ្ឌ ។ បន្ទាប់ពីរៀបចំបញ្ជីសារពើភ័ណ្ឌរួចហើយ អ្នកប្រតិបត្តិមតកសាសន៍ត្រូវប្រគល់បញ្ជីនោះទៅឱ្យសន្តតិជនយ៉ាងឆាប់រហ័ស ។
- ✓ **ត្រួតពិនិត្យពីឋានៈបុគ្គល** ៖ អ្នកប្រតិបត្តិមិនត្រឹមតែមានតួនាទីពិនិត្យ ស្រាវជ្រាវតែទៅលើទ្រព្យសម្បត្តិនោះទេ អ្នកប្រតិបត្តិក៏ត្រូវពិនិត្យផងដែល ទៅលើអត្ថិភាពនៃសិទ្ធិរបស់សន្តតិជន ឬ អច្ច័យលាភី ។ ក្នុងករណីនេះ អ្នកប្រតិបត្តិត្រូវផ្ទៀងផ្ទាត់ទៅលើខ្លឹមសារនៃសន្តតិកម្មទាក់ទងនឹងឋានៈបុគ្គលជាក់ស្តែង ។ ក្នុងការពិនិត្យនេះ ករណីដែលមតកសាសន៍បានបញ្ញត្តពីការផ្តាច់មត៌ក ឬ ការលុបចោលការផ្តាច់មត៌ក ឬ មតកសាសន៍មានចែងអំពីការទទួលស្គាល់កូន ឬ មានការបោះបង់មតកសាសន៍ជាអាទិ៍ អ្នកប្រតិបត្តិត្រូវធ្វើបណ្តឹងនានាទៅស្ថាប័នមានសមត្ថកិច្ច ដើម្បីប្រាកដថាអ្នកទទួលអានុភាពនៃមតកសាសន៍ត្រូវតែជាអ្នកមានសិទ្ធិ និង មានលក្ខណៈសម្បត្តិត្រឹមត្រូវតាមច្បាប់ និង មតកសាសន៍ ។
- ✓ **ការបែងចែកចំណែក** ៖ ក្នុងករណីវិធីនៃការបែងចែកត្រូវបានកំណត់ដោយមតកសាសន៍ នោះអ្នកអនុវត្តត្រូវអនុវត្តតាមបណ្តាំនោះ តែបើមិនដូច្នេះទេ អ្នកប្រតិបត្តិមានសិទ្ធិធ្វើការបែងចែកទៅតាមសមាមាត្រនៃតម្លៃ ឬ សម្របសម្រួលរវាងសន្តតិជន ឬ អច្ច័យលាភី ដែលទទួលជាភាគលើវត្ថុតែមួយ ដោយការជ្រើសឱ្យសន្តតិជនណាមួយធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុនោះ ដោយបង់តម្លៃទៅឱ្យចំណែកសន្តតិជនផ្សេង ឬ អាចលក់ដោយយកប្រាក់មកបែងចែងតាមចំណែកជាអាទិ៍ ។[96]
- ✓ **ការចាត់ចែង ឬ ការប្រគល់** ៖ វាជាកិច្ចការរបស់អ្នកប្រតិបត្តិដើម្បីបញ្ចប់កិច្ចការរបស់ខ្លួនក្នុងការប្រគល់នូវមត៌កដែលខ្លួនបានគ្រប់គ្រង និង រៀបចំចាត់ចែងប្រគល់ទៅឱ្យសន្តតិជន ឬ អច្ច័យលាភីនូវទ្រព្យសម្បត្តិ ព្រមទាំងកាតព្វកិច្ចនានាដែលកំណត់ដោយបណ្តាំ ។ ជាក់ស្តែងក្នុងករណីជាអចលនវត្ថុ អ្នកប្រតិបត្តិត្រូវរៀបចំចាត់ចែងតាមនីតិវិធីដោយស្នើសុំផ្ទេរកម្មសិទ្ធិតាមរយៈការចុះបញ្ជី តាមនីតិវិធីច្បាប់ ឬ ករណីជាចលនវត្ថុ ត្រូវប្រគល់វត្ថុនោះតាមរយៈការប្រគល់ជាក់ស្តែងដូចជា ការដកប្រាក់ក្នុងធនាគារ ឱ្យសន្តតិជនជាដើម ។

[96] មាត្រា ១២៦៦, មាត្រា ១២៦៧ និង មាត្រា១២៧១ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

**៦. ភាតព្វកិច្ចអ្នកប្រតិបត្តិ**

អ្នកប្រតិបត្តិមតកសាសន៍ មានករណីយកិច្ចចាត់ចែងកិច្ចការអាណត្តិ ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។ ក្នុងករណីអ្នកប្រតិបត្តិ អនុវត្តករណីយកិច្ចខ្ជីខ្ជា ខ្វះការប្រុងប្រយ័ត្ន ដែលបណ្តាលឱ្យខូចខាតប្រយោជន៍ដោយមិនសមរម្យចំពោះ អ្នកពាក់ព័ន្ធផលប្រយោជន៍នានានៃមតកសាសន៍ នោះអ្នកពាក់ព័ន្ធផលប្រយោជន៍នោះអាចទាមទារសំណងនៃការខូចខាតពីអ្នកប្រតិបត្តិបាន ។[97]

ចំពោះការបំពេញតួនាទីទាំងអស់របស់ខ្លួន អ្នកប្រតិបត្តិត្រូវបំពេញដោយខ្លួនឯងផ្ទាល់ ដោយមិនអាចអនុញ្ញាតឱ្យតតិយជនណា ឬ តែងតាំងតតិយជនណាមកបំពេញកិច្ចការប្រតិបត្តិជំនួសខ្លួនឡើយ លើកលែងតែមានការកំណត់អនុញ្ញាតដោយមតកសាសន៍ ។ ក្នុងករណីអ្នកប្រតិបត្តិតែងតាំងតតិយជនឱ្យបំពេញតួនាទីជំនួសខ្លួន ឬ ជួយកិច្ចការប្រតិបត្តិរបស់ខ្លួន ស្របតាមមតកសាសន៍ នោះអ្នកប្រតិបត្តិត្រូវត្រួតពិនិត្យលើតតិយជនដែលត្រូវបានតែងតាំងនោះ ចំពោះ សន្តតិជន និង អច្ច័យលាភី ដោយធានាថា ការបំពេញកិច្ចការជំនួសនិងមិនបង្កឱ្យមានការខូចខាតដល់ផលប្រយោជន៍ណាមួយនៃការប្រតិបត្តិនោះទេ ។ ផ្ទុយទៅវិញក្នុងករណីអ្នកប្រតិបត្តិធ្វើការតែងតាំងតតិយជនឱ្យបំពេញកិច្ចការប្រតិបត្តិដោយចិត្តឯង បើសិនបណ្តាលឱ្យខូចខាតនូវផលប្រយោជន៍ណាមួយដល់សន្តតិជន ឬ អច្ច័យលាភី នោះអ្នកប្រតិបត្តិត្រូវទទួលខុសត្រូវសងនូវការខូចខាតទាំងនោះ ។

**៧. បន្ទុកនៃមត៌ក**

រាល់សកម្មភាពទាំងអស់នូវការចំណាយចាំបាច់ក្នុងការអនុវត្ត ដើម្បីសម្រេចនូវខ្លឹមសារនៃមតសាសន៍ជាបន្ទុកលើមត៌ក ដូចជាការចំណាយចាំបាច់ក្នុងការគ្រប់គ្រង ថែរក្សាមត៌ក ឬ អនុវត្តនីតិវិធីបញ្ជាក់មតកសាសន៍ជាអាទិ៍ ។ លើសពីនេះ អ្នកអនុវត្តអាចទទួលបានប្រាក់កម្រៃនៃការបំពេញតួនាទីរបស់ខ្លួនតាមការកំណត់ជាមុនក្នុងមតកសាសន៍ ឬ ក្នុងករណីបណ្តាំមិនបានកំណត់ជាមុននូវសោហ៊ុយសំរាប់អ្នកប្រតិបត្តិ ក៏អ្នកប្រតិបត្តិអាចទាមទារឱ្យតុលាការកំណត់ពីសោហ៊ុយនេះបានដែល ហើយធ្វើការកាត់លើតម្លៃនៃមត៌កតែម្តង ។[98]

**កថាភាគទី ៤ ការបញ្ចប់មតកសាសន៍**

ក្នុងករណីគ្មានវិវាទណាមួយកើតឡើងនោះទេ ការបញ្ចប់មតកសាសន៍ នៅពេលដែលការអនុវត្តមតកសាសន៍ត្រូវបានបញ្ចប់ ឬ ការសម្រេចខ្លឹមសារនៃមតកសាសន៍នោះ ឬ យើងអាចនិយាយដោយងាយយល់ថានៅពេលដែលអ្នកប្រតិបត្តិបញ្ចប់តួនាទីដោយបានបែងចែកចំណែកដោយបានផ្ទេរសិទ្ធិ និង កាតព្វកិច្ច ទៅឱ្យសន្តតិជន ឬ អច្ច័យលាភីចប់សព្វគ្រប់ ហើយសន្តតិជន និង អច្ច័យលាភី នៃមតកសាសន៍ទាំងអស់បានធ្វើលទ្ធកម្មនូវសិទ្ធិ និងកាតព្វកិច្ច ជុំវិញមត៌កចប់សព្វគ្រប់ ។

---

[97] មាត្រា ៦៤០ និងមាត្រា ១២២៩ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

[98] មាត្រា ១២២៦ និងមាត្រា ១២២៨ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានបញ្ចប់ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី **ទម្រង់ និង អានុភាពមតកសាសន៍** ក្រុមខ្ញុំបាទយល់ឃើញថាបេបគតិយុត្តនានាស្តីពីសន្តតិកម្មដោយមតកសាសន៍ វាជាផ្នែកសំខាន់មួយនៃនីតិឯកជនដោយបានអនុញ្ញាតឱ្យមានការរៀបចំចាត់ចែងនូវសិទ្ធិ និង កាតព្វកិច្ចជុំវិញទ្រព្យសម្បត្តិរបស់មតកជន ទៅឱ្យទាយាទរបស់ពួកគេដោយគោរពតាមឆន្ទៈរបស់មតកជនដែលជាម្ចាស់សិទ្ធិ និង កាតព្វកិច្ចទាំងនោះ។ ហើយក៏បញ្ជាក់ដែលថា របបស្តីពីសន្តតិកម្មវាមានសារៈសំខាន់ណាស់ ក្នុងទំនាក់ទំនងនៃនីតិឯកជនជាពិសេសកម្មភាពជំនួញ ឬ សកម្មភាពអាជីវកម្មនានារបស់បុគ្គលដែលបានស្លាប់ទៅអំឡុងពេលសិទ្ធិ និង កាតព្វកិច្ចរបស់គាត់នៅតែបន្តមានអត្ថិភាពនៅឡើយ ។ ដូច្នេះបើសិនមិនមានរបបគតិយុត្តដើម្បីបន្តអត្ថិភាពនៃសិទ្ធិ និង កាតព្វកិច្ចរបស់អ្នកដែលទទួលមរណភាពនោះទេ វានឹងបង្កឱ្យមានអស្ថិរភាពគតិយុត្ត អាចធ្វើឱ្យភាគីនានា ដែលមានចំណងគតិយុត្តជាមួយអ្នកស្លាប់ស្ថិតក្នុងស្ថានភាពដែលមិនច្បាស់លាស់ជាអចិន្ត្រៃយ៍ ដែលវានឹងអាចបង្កផលវិបាកដល់សង្គមទាំងមូលជាក់ជាមិនខាន ។

តាមរយៈការសិក្សានេះផងដែលដើម្បីអាចឱ្យបុគ្គលម្នាក់ៗ មានលទ្ធភាពក្នុងការចាត់ចែងទ្រព្យសម្បត្តិរបស់ពួកគេ ឱ្យទៅទាយាទដែលជាសន្តតិជន ឬ តតិយជនដែលហៅថា អច្ច័យលាភី តាមរយៈមតកសាសន៍ ឬ បណ្តាំមត៌កទៅបាន លុះត្រាតែមតកជនខ្លួនឯងផ្ទាល់ជាអ្នកផ្តួចផ្តើមក្នុងការធ្វើលិខិតបណ្តាំ ឬ មតកសាសន៍ដើម្បីកំណត់ពីឆន្ទៈក្នុងការចាត់ចែងនោះ ។ ទោះបីជាយ៉ាងណាក្តីការតាក់តែងនូវលិខិតមតកសាសន៍មានទម្រង់ជាច្រើន ទាំងទម្រង់ធម្មតារួមមាន ទម្រង់មតកសាសន៍ដោយលិខិតយថាភូត ទម្រង់មតកសាសន៍ដោយលិខិតឯកជន ទម្រង់មតកសាសន៍ដោយលិខិតសម្ងាត់ និង ទម្រង់មតកសាសន៍ពិសេស ដែលផ្តល់លទ្ធភាពឱ្យមតកជន ដែលស្ថិតក្នុងស្ថានភាពទាក់ទងនឹងសមត្ថភាព ឬ ស្ថានភាពអាសន្នណាមួយអាចធ្វើមតកសាសន៍បាន រួមមានមតកសាសន៍របស់ជនស្ថិតដែលជួបគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត និង មតកសាសន៍របស់ជនដែលត្រូវជាប់ឃុំជាអាទិ៍ ។ ប៉ុន្តែតាមរបបស្តីពីមតកសាសន៍នេះ បានកំណត់ពីនីតិវិធីនានាដើម្បីអនុវត្តទៅតាមទម្រង់ច្បាស់លាស់នីមួយៗរបស់វា មិនដូច្នេះទេវានឹងប៉ះពាល់ដល់សុពលភាពមតកសាសន៍ជាក់ជាមិនខាន ហេតុនេះត្រូវមានរបបគតិយុត្តមួយច្បាស់លាស់ដើម្បីគ្រប់គ្រងសកម្មភាពទាំងនេះ ។ ជាក់ស្តែងរបបសន្តតិកម្មនេះ បង្កើតឡើងដើម្បីធ្វើនិយ័តកម្ម និង ស្វយ័តកម្ម ក្នុងការធានា ដោះស្រាយ បង្ការនូវវិបត្តិទាំងនេះដែលអាចកើតមានជាយថាហេតុ ។

ក្រៅពីចំណេះដឹងក្នុងការបង្កើតមតកសាសន៍ទៅតាមទម្រង់ ដើម្បីឱ្យមានសុពលភាពអនុវត្តតាមផ្លូវច្បាប់ ប្រធានបទនេះ ក៏ផ្តោតសំខាន់ខ្លាំងដែលនៃអានុភាពរបស់វា និង នីតិវិធីនៃការអនុវត្ត ចាប់តាំងពីការបង្កើតអានុភាព ការអនុវត្ត និង បញ្ចប់ ។ បន្ទាប់ពីមតកសាសន៍ត្រូវបង្កើតអានុភាពតាមរយៈ មរណភាពនៃមតកជន ឬ អានុភាពនៃការប្រកាសបាត់ខ្លួន និង បំពេញនូវលក្ខខណ្ឌបង្អង់ក្នុងករណីមានកំណត់ក្នុងមតកសាសន៍ នោះមតកសាសន៍នឹងត្រូវចាប់ផ្តើមមានអានុភាពអនុវត្ត ។ ការអនុវត្តមតកសាសន៍គឺផ្តោតសំខាន់ទៅលើការសម្រេចឱ្យបាននូវខ្លឹមសារនៃមតកសាសន៍ ដោយអាចមានការចាត់តាំងអ្នកប្រតិបត្តិដើម្បីអនុវត្តមតកសាសន៍ ហើយអ្នកប្រតិបត្តិត្រូវបំពេញកិច្ចការអនុវត្តមតកសាសន៍ដោយឈរលើមូលដ្ឋាននៃខ្លឹមសារមតកសាសន៍ និង ច្បាប់ធ្វើយ៉ាងណាឱ្យសម្រេចនូវខ្លឹមសារមតកសាសន៍ដែលជាបណ្តាំរបស់មតកជន។ ដោយហេតុថា មតកសាសន៍វាជាសកម្មភាពឯកតោភាគី ដែលមតកជនធ្វើឡើងដើម្បីទាយាទរបស់ខ្លួន ដូច្នេះដើម្បីគោរពលើគោលការណ៍នៃស្វ័យភាពបុគ្គល មតកសាសន៍មិនចងកាតព្វកិច្ចឱ្យសន្តតិជន ឬ អច្ច័យលាភីត្រូវតែទទួលយក និង អនុវត្តតាមខ្លឹមសារនៃមតកសាសន៍នោះទេ ជាហេតុរបបស្តីពីសន្តតិកម្មក៏កំណត់ផងដែរ នូវសិទ្ធិរបស់សន្តតិជន ឬ អច្ច័យលាភី ក្នុងការបោះបង់ចោលនូវមតកសាសន៍ ។ ជាចុងក្រោយក្នុងករណីអ្នកប្រតិបត្តិបានអនុវត្តតួនាទីរបស់ខ្លួនចប់សព្វគ្រប់ហើយ ដោយការចាត់ចែងនូវសិទ្ធិ និង កាតព្វកិច្ចនានាជុំវិញទ្រព្យសម្បត្តិរបស់មតកជន ដូចជាការធ្វើសកម្មភាពនានាដើម្បីឱ្យសន្តតិជន អច្ច័យលាភី ឬ អ្នកពាក់ព័ន្ធនានាអាចធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិរបស់មតកជនជាអាទិ៍ ។ នៅពេលដែលខ្លឹមសាររបស់មតកសាសន៍ត្រូវបានបំពេញចប់សព្វគ្រប់ និង គ្មានការជំទាស់ពីភាគីពាក់ព័ន្ធ នោះត្រូវបានសន្មតថាការអនុវត្តមតកសាសន៍ត្រូវបានបញ្ចប់។

សរុបសេចក្តីមក ប្រធានបទស្តីពីទម្រង់ និងអានុភាពមតកសាសន៍ ពិតជាមានសារៈសំខាន់ណាស់ក្នុងការរក្សាតុល្យភាព និង ស្ថិរភាព ក្នុងការបន្តនូវសិទ្ធិ និង កាតកិច្ចពីមតកជន ទៅទាយាទ ប្រកបដោយអនុឡោមភាព និង ប្រសិទ្ធិភាពតាមនីតិវិធីនៃច្បាប់ ។

# អនុសាសន៍

# អនុសាសន៍

តាមរយៈការសិក្សាស្រាវជ្រាវលម្អិតស្តីពីប្រធានបទ **ទម្រង់ និង អានុភាពនៃមតកសាសន៍** រួចមកក្រុមខ្ញុំបាទយល់ឃើញថា ត្បិតតែរបបគតិយុត្តស្តីពី សន្តតិកម្មតាមរយៈមតកសាសន៍បានផ្តល់ផលប្រយោជន៍ ដោយសម្រួលដល់ការផ្ទេរនូវសិទ្ធិ និង កាតព្វកិច្ចពីមតកជន ទៅទាយាទរបស់គេ និង អ្នកពាក់ព័ន្ធនានាពិតមែនក៏ដោយ ប៉ុន្តែចំពោះនីតិវិធីក្នុងការកំណត់ ចាប់តាំងពីការកំណត់ក្នុងនីតិវិធីទម្រង់ ខ្លឹមសារច្បាប់ រហូតដល់នីតិវិធីអនុវត្តមតកសាសន៍ នៅមានភាពស្មុគស្មាញ ភាពមិនច្បាស់លាស់ជាច្រើន ទាំងខ្លឹមសារ និង នីតិវិធី ។ ជាក់ស្តែងឧបមាថា មតកសាសន៍ដោយលិខិតឯកជន និង លិខិតសង្ងាត់ នៅពេលមានបង្កើតអានុភាពដោយមរណភាពនៃមតកជន ភាគីពាក់ព័ន្ធដែលដឹងពីមូលហេតុនៃមតកសាសន៍ ត្រូវដាក់ពាក្យបញ្ជាក់ទៅតុលាការ តែតាមរយៈសេចក្តីកំណត់ក្រមរដ្ឋប្បវេណី បានបញ្ជាក់ថា ការបញ្ជាក់នេះមិនមែនមានន័យថា ជាការបញ្ជាក់សុពលភាពនោះទេ វាគ្រាន់តែនីតិវិធីនៃការបើកបណ្តាំមត៌កប៉ុណ្ណោះ ។ បន្ទាប់ពីបើកបណ្តាំមត៌ក ត្រូវទទួលស្គាល់ ឬ ចាត់តាំងអ្នកអនុវត្តដើម្បីអនុវត្តខ្លឹមសារមតកសាសន៍ ដូច្នេះអ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិអនុវត្តតួនាទីរបស់ខ្លួនដើម្បីសម្រេចខ្លឹមសារមតកសាសន៍ ។ ប៉ុន្តែទាក់ទាងនឹងការអនុវត្តកាតព្វកិច្ចរបស់អ្នកអនុវត្តមតកសាសន៍មានអានុភាពកម្រិតណា នោះគឺនៅមានភាពមិនច្បាស់លាស់នោះទេ ព្រោះនៅពេលដែលអ្នកប្រតិបត្តិរៀបចំឯកសារផ្សេងៗដូចជាបញ្ជីសារពើភ័ណ្ឌ ឯកសារដើម្បីសម្រួលដល់ការធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិដល់សន្តតិជនអច្ច័យទាន និងភាគីពាក់ព័ន្ធ ច្បាប់មិនបានតម្រូវដាក់ច្បាស់ ឱ្យដាក់កិច្ចការទាំងនោះទៅតុលាការដើម្បីចេញនៅសេចក្តីសម្រេច ឬ បញ្ជាក់សុពលភាពនោះទេ ។ ក្នុងលក្ខខណ្ឌនេះតើសកម្មភាពរបស់អ្នកប្រតិបត្តិអាចអនុវត្តបានដែរ ឬ យ៉ាងណា បើនីតិវិធីក្នុងការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ តម្រូវឱ្យមានរូបមន្តអនុវត្តពីតុលាការ ។ លើសពីនេះទៅទៀតការផ្សព្វផ្សាយស្តីពី របបគតិយុត្តស្តីពីសន្តតិកម្មតាមបណ្តាំ ដល់ប្រជាពលរដ្ឋជាទូទៅនៅមានកម្រិត ។ ទាំងនេះប្រហែលជាមូលហេតុចម្បងៗ ដែលធ្វើឱ្យអ្នកប្រកបវិជ្ជាជីវៈច្បាប់ដូចជាមេធាវីជាអាទិ៍ មិនសូវជាចាប់អារម្មណ៍ក្នុងការផ្តល់យោបល់ដល់អតិថិជនរបស់ខ្លួនក្នុងការធ្វើមតកសាសន៍តាមរយៈលិខិតឯកជន ឬ លិខិតសម្ងាត់ ព្រោះថាបើធ្វើហើយមិនដឹងថាយកទៅអនុវត្តមានសុពលភាព ឬ ក៏យ៉ាងណា និង មានការលំបាកក្នុងការអនុវត្ត ដែលជាហេតុយើងកម្រឃើញណាស់មានការដាក់ពាក្យទៅតុលាការ ទាក់ទងនឹងការអនុវត្តមតកសាសន៍ដោយលិខិតឯកជន ឬ លិខិសម្ងាត់ ពោលគឺច្រើនលើសលប់តែសន្តតិកម្មតាមច្បាប់ ឬ អាចនិយាយបានថារបបសន្តតិកម្មតាមបណ្តាំ វាមិនទាន់ពេញនិយម ឬ មិនមែនជាតម្រូវការចាំបាច់ដោយសារស្ថានភាពទម្លាប់រស់នៅ ឬដោយសារកម្រិតជីវភាព និង ចំណេះដឹងរបស់ប្រជាពលរដ្ឋខ្មែរនៅមានកម្រិត ។ ទោះបីជាយ៉ាងណាបន្ទាប់ពីបានសិក្សាពីប្រធានបទខាងលើរួចមក យើងខ្ញុំស្នើសុំផ្តល់ជាអនុសាសន៍មួយចំនួន

ដែលជាការចូលរួមចំណែក ជាយោបល់ដើម្បីឱ្យរបបស្តីពីសន្តតិកម្មតាមមតកសាសន៍ ទទួលបានការចាប់អារម្មណ៍ពីអ្នកសិក្សាផ្នែកច្បាប់ អ្នកប្រកបវិជ្ជាជីវៈ ច្បាប់ និង ប្រជាពលរដ្ឋជាទូទៅដើម្បីត្រិះរិះពិចារណាបន្ថែមដើម្បីវឌ្ឍនភាព ដែលអនុសាសន៍ទាំងនោះរួមមាន ៖

- ✓ **ករណីមតកសាសន៍ដោយលិខិតឯកជន ឬ លិខិតសម្ងាត់** ៖ ដោយហេតុថា ទម្រង់លិខិតទាំងនេះ មតកជនអាចធ្វើបានដោយខ្លួនឯងផ្ទាល់ ជាហេតុដែលការតាក់តែងរបស់គាត់អាចមិនបានគោរពតាមខ្លឹមសារច្បាប់ ឬ ទម្រង់នោះទេ ដោយមូលហេតុនៃចំណេះដឹង ។ ដូច្នេះវាអាចមានការបំពានលើភាគបម្រុងជាអាទិ៍ ដូច្នេះតាមយោបល់របស់ខ្ញុំបាទ យើងគួរពិនិត្យលទ្ធភាពបង្កើតបទដ្ឋានគតិយុត្តដែលអាចផ្តល់ភាពងាយស្រួលដល់មតកជន ដូចជាការកំណត់នូវតម្លៃទ្រព្យសម្បត្តិជាក់លាក់ ដែលអាចធ្វើការបង្ហាញឆន្ទៈដោយសេរីរបស់មតកជន ដោយមិនចាំបាច់អនុវត្តភាគបម្រុងជាដើម ដោយហេតុថា ទ្រព្យសម្បត្តិមានតម្លៃតិចតួចជាដើម ។
- ✓ **ទាក់ទងនឹងនីតិវិធីអនុវត្តមតកសាសន៍** ៖ ចំពោះសកម្មភាពរបស់អ្នកអនុវត្តមតកសាសន៍ នៅពេលកំណត់ពីការបែងចែងចំណែកតាមខ្លឹមសារនៃមតកសាសន៍រួចរាល់ គួរកំណត់យ៉ាងជាក់លាក់ថា ត្រូវស្នើសុំដីកាសម្រេច និងរូបមន្តអនុវត្តពីតុលាការ លើខ្លឹមសារទាំងស្រុងតែម្តង ។
- ✓ **សមត្ថភាពរបស់អ្នកអនុវត្ត** ៖ វាជាការព្រួយបារម្ភពីសមត្ថភាពរបស់អ្នកអនុវត្ត ព្រោះបើពិនិត្យតាមខ្លឹមសារច្បាប់ឃើញថា អ្នកប្រតិបត្តិត្រូវតែជាបុគ្គលដែលមានសមត្ថភាពគ្រប់គ្រាន់ ព្រោះបើមិនដូច្នេះទេ ពិតជាមានភាពរាំងស្ទះ ដល់ការអនុវត្តមតកសាសន៍នោះជាក់ជាមិនខាន ។ ដូច្នេះត្បិតតែ ច្បាប់គោរពនូវឆន្ទៈរបស់មតកជនក្នុងការជឿជាក់លើបុគ្គលណាម្នាក់ដើម្បីអនុវត្តបណ្តាំរបស់ខ្លួនក្តី ក៏ច្បាប់គួរតែកំណត់បុគ្គល ឬ ក្រុមបុគ្គល ឬ នីតិបុគ្គលដែលអាចបំពេញកិច្ចការនោះមានប្រសិទ្ធភាពខ្ពស់ ។ ឧទាហរណ៍ថា ទោះបីជាលិខិតមតកសាសន៍មានទម្រង់ប្រភេទណាក៏ដោយ ក៏អ្នកដែលអាចក្លាយជាអ្នកអនុវត្តមតកសាសន៍បានត្រូវតែជាសារការី ឬ បុគ្គលដែលទទួលបាននីតិសម្បទាជាអ្នកប្រតិបត្តិជាដើម ។
- ✓ **មតកសាសន៍ដោយលិខិតយថាភូត** ៖ ដោយហេតុថា មានតែសារការីប៉ុណ្ណោះដែលទទួលបានសិទ្ធិពីរដ្ឋ និង ច្បាប់ ក្នុងការតាក់តែងមតកសាសន៍ជាលិខិតយថាភូត និង មានសិទ្ធិចេញនូវរូបមន្តអនុវត្ត ដោយមិនចាំបាច់ឆ្លងកាត់ការបញ្ជាក់ ឬ នីតិវិធីនានាតាមផ្លូវតុលាការ ព្រោះច្បាប់បានសន្មតថា សារការីជាមន្ត្រីវិជ្ជាជីវៈជំនាញផ្នែកច្បាប់ ដូច្នេះមតកសាសន៍ដោយលិខិតយថាភូតអាចអនុវត្តបាន ។ ដោយហេតុថា មតកសាសន៍ដោយលិខិតយថាភូត មានភាពច្បាស់លាស់ និង ងាយស្រួសក្នុងការអនុវត្តជាងទម្រង់មតកសាសន៍នានា ដូច្នេះដើម្បីភាពងាយស្រួល និង បង្វែរការចាប់អារម្មណ៍អតិថិជន ក៏ដូចជាសាធារណៈ

ជនជាទូទៅមកទទួលសេវាកម្មធ្វើលិខិតមតកសាសន៍ប្រភេទនេះ នោះគួរតែកំណត់នូវតម្លៃសេវាកម្មជាក់លាក់មានលក្ខណៈទូទៅ ដូចជាសេវាសាធារណៈ ដើម្បីធានាតម្លាភាព និង គណនីភាព ។ ហើយនៅពេលមតកសាសន៍ដោយលិខិតយថាភូតមានការពេញនិយម នោះវានឹងកាត់បន្ថយនូវបញ្ហាស្មុគស្មាញនៃនីតិវិធី ធានាភាពច្បាស់លាស់ក្នុងការអនុវត្ត និង សម្រួលបន្ទុការកកស្ទះរឿងក្តីក្នុងស្ថាប័នតុលាការបានមួយអន្លើ ដោយសារបញ្ហារឿងក្តីសន្តតិកម្មតាមច្បាប់ជាអតិបរមាជាក់ជាមិនខាន ។

# ឯកសារយោង

# ឯកសារយោង

## ❖ ច្បាប់នានា

- ✓ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ។
- ✓ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ។
- ✓ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ ។
- ✓ ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០ ។
- ✓ ច្បាប់ភូមិបាល ឆ្នាំ២០០១ ។
- ✓ ច្បាប់ស្តីពីបណ្ណសារ ២០០៥ ។

## ❖ ឯកសារផ្សេងៗ

- ✓ ព្រះរាជក្រមលេខ ៩១០ ន.ស ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ ។
- ✓ ក្រមរដ្ឋប្បវេណីនៃព្រះរាជណាចក្រកម្ពុជា ឆ្នាំ១៩៦៧ ។
- ✓ សេចក្តីកំណត់មាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០១០ ។
- ✓ សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ឆ្នាំ២០១២ ។
- ✓ សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ ឆ្នាំ២០០៧ ។
- ✓ សិក្ខាសាលាស្តីពីវិជ្ជាជីវៈសារការីរបស់ សារការី នៅ សុជាតា ថ្ងៃ៣១ ខែកក្កដា ឆ្នាំ២០២១ ។
- ✓ អត្ថបទ History of Wills របស់ លោក Richard Boaden ។

## ❖ គេហទំព័រ

- ✓ https://www.youtube.com/watch?v=XKQfXGs63NI
- ✓ https://trustandwill.com/learn/history-of-last-will-and-testament

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១
# ក្រមរដ្ឋប្បវេណីដែលទាក់ទងនឹង
# មតកសាសន៍

ពិចារណាទៅលើពេល វិធី និង កម្រិតនៃវិភាគទាននោះ ចំនួនទឹកប្រាក់នៃមត៌ក និង ស្ថានភាពទាំងអស់ផ្សេងទៀត ។

៣-ភាគនៃវិភាគទាន មិនអាចឱ្យលើសពីចំនួនទឹកប្រាក់ដែលបានដកចេញនូវតម្លៃនៃអច្ច័យទាន និង តម្លៃនៃទ្រព្យសម្បត្តិ ដែលមតកជនបានកំណត់ថាជាចំណែកមត៌ករបស់សហសន្តតិជន ឬ ជាវិធីបែងចែកមត៌ក ពីចំនួនតម្លៃនៃមត៌ក ដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្មឡើយ ។

៤-ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាចធ្វើបានក្នុងករណីដែលមានពាក្យសុំ ដោយយោងតាមកថាខណ្ឌទី ១ នៃមាត្រា ១២៧០ (ការបែងចែកដោយតុលាការ) ឬ មានពាក្យបណ្តឹង ដោយយោងតាមមាត្រា ១២៧៤ (ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក) ។

**មាត្រា ១១៦៧.-** ទំនាក់ទំនងជាមួយនឹងតតិយជន

ការសម្រួលចំណែកមត៌កដែលយោងតាមបញ្ញត្តិនៃផ្នែកទី ៣ (ការសម្រួលចំណែកមត៌ក) នេះ មិនអាចយកមកអះអាងនឹងតតិយជនបានឡើយ បើមិនមានល័ក្ខខ័ណ្ឌតតាំងចំពោះលទ្ធផលនៃការបែងចែកមត៌ក ដោយផ្អែកលើការសម្រួលនោះទេ ។

## ជំពូកទី ៣
## សន្តតិកម្មតាមមតកសាសន៍

### ផ្នែកទី ១
### សមត្ថភាពក្នុងការធ្វើមតកសាសន៍

**មាត្រា ១១៦៨.-** បុគ្គលដែលអាចធ្វើមតកសាសន៍បាន

១-បុគ្គលដែលជានីតិជន និង អនីតិជនដែលបានអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬ អំណាចមេបា អាចធ្វើមតកសាសន៍បាន ។

២-បញ្ញត្តិនៃមាត្រា ២៦ (សិទ្ធិលុបចោលសកម្មភាព) និង មាត្រា ៣០ (សិទ្ធិលុប

ចោលសកម្មភាព) នៃក្រមនេះ មិនត្រូវយកមកអនុវត្តចំពោះមតកសាសន៍ឡើយ ។

**មាត្រា ១១៦៩.–** សមត្ថភាពនាពេលធ្វើមតកសាសន៍

១-ម្ចាស់បណ្តាំ ត្រូវមានសមត្ថភាព នៅពេលធ្វើមតកសាសន៍ ។

២-បុគ្គលដែលអះអាងអំពីការខ្វះសមត្ថភាពរបស់ម្ចាស់បណ្តាំ ត្រូវបញ្ជាក់ភស្តុតាងអំពីហេតុនោះ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបានកំណត់នៅក្នុងមាត្រា ១១៧៦ (មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

## ផ្នែកទី ២
## ទម្រង់នៃមតកសាសន៍

**មាត្រា ១១៧០.–** ភាពចាំបាច់នៃទម្រង់មតកសាសន៍

១-មតកសាសន៍ ពុំអាចធ្វើបានឡើយ បើពុំផ្អែកតាមទម្រង់ដែលបានកំណត់ក្នុងក្រមនេះទេ ។

២-មតកសាសន៍ដែលធ្វើមិនត្រូវនឹងទម្រង់ណាមួយក្នុងបញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកជាមោឃៈ ។ ប៉ុន្តែ មតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ ត្រូវចាត់ទុកថាមានសុពលភាព លុះត្រាតែមតកសាសន៍នោះ មិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលបានធ្វើដោយម្ចាស់បណ្តាំដូចគ្នានេះ ។ នៅក្នុងករណីដែលមតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ មានចំនួនច្រើន ហើយបើមតកសាសន៍ទាំងនេះ ផ្ទុយនឹងគ្នា អានុភាពនៃមតកសាសន៍ទាំងនោះត្រូវកាត់បន្ថយគ្នាទៅវិញទៅមក ។

**មាត្រា ១១៧១.–** សុពលភាពនៃទម្រង់

មតកសាសន៍ដែលត្រូវនឹងទម្រង់ណាមួយដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវចាត់ទុកថាមានសុពលភាពចំពោះទម្រង់ ។

**មាត្រា ១១៧២.–** បុគ្គលដែលមិនអាចក្លាយជាសាក្សី ជាអាទិ៍

បុគ្គលដែលកំណត់ដូចខាងក្រោមនេះ មិនអាចធ្វើជាសាក្សី ឬ ជាអ្នកសង្កេតការណ៍នៅពេលធ្វើមតកសាសន៍បានឡើយ :

ក-អនីតិជន ឬ ជននៅក្រោមអាណាព្យាបាលធម្មតា ។

ខ-ជនដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី ហើយនិងសហព័ទ្ធ និង ញាតិលោហិតខ្សែផ្ទាល់ របស់ជនទាំងនោះ ។

គ-បើសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ជាលិខិតយថាភូត ឬ ជាលិខិតមតកសាសន៍សម្ងាត់ សហព័ទ្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី និង និយោជិត របស់សារការីនោះ ។

**មាត្រា ១១៧៣.–** មតកសាសន៍ដោយលិខិតយថាភូត

១-មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំ នៅចំពោះមុខសារការី តាមទម្រង់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ ។

២-មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ :

ក-ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច ២ (ពីរ) នាក់ ។

ខ-ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ ចំពោះសារការី ។

គ-សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះ ជាលាយល័ក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និង សាក្សីនោះស្តាប់ ។

ឃ-បន្ទាប់ពីម្ចាស់បណ្តាំ និង សាក្សី បានទទួលស្គាល់ថាកំណត់ជាលាយល័ក្ខណ៍អក្សរនោះត្រឹមត្រូវហើយ ជននីមួយៗនោះត្រូវធ្វើឱ្យមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និង លំនៅឋាន ហើយ ត្រូវចុះហត្ថលេខា រៀងៗខ្លួន ។ ប៉ុន្តែ បើម្ចាស់បណ្តាំ មិនអាចសរសេរអក្សរ ឬ មិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និង ហត្ថលេខាដូចកំណត់ខាងលើនេះ ដោយសរសេរឈ្មោះ អាយុ និង លំនៅឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវហេតុនោះផង ។

ង-សារការីត្រូវសរសេរថ្ងៃខែឆ្នាំ ហើយត្រូវចុះហត្ថលេខា ។

**មាត្រា ១១៧៤.–** មតកសាសន៍ដោយលិខិតឯកជន

១-មតកសាសន៍ដោយលិខិតឯកជន ត្រូវធ្វើឡើង ដោយម្ចាស់បណ្តាំសរសេរពាក្យទាំងអស់ និង ចុះថ្ងៃខែឆ្នាំ ដោយខ្លួនឯង ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ ។ មតក-សាសន៍ដោយលិខិតឯកជនដែលត្រូវបានសរសេរជំនួសដោយអ្នកដទៃ ឬ ដែលត្រូវបានសរសេរដោយប្រើម៉ាស៊ីនដូចជាអង្គុលីលេខ ជាអាទិ៍ នឹងត្រូវចាត់ទុកជាមោឃៈ ។

២-ការបន្ថែម ការលុប ឬ ការកែប្រែផ្សេងទៀត នៅក្នុងមតកសាសន៍ដោយលិខិតឯកជន ពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំមិនបានបង្ហាញនូវកន្លែង ហើយសរសេរបន្ថែមនូវហេតុនៃការកែប្រែនោះ ជាពិសេសបើមិនបានចុះហត្ថលេខាទេ ។

**មាត្រា ១១៧៥.–** មតកសាសន៍ដោយលិខិតសម្ងាត់

មតកសាសន៍ដោយលិខិតសម្ងាត់ ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ :

ក-ម្ចាស់បណ្តាំត្រូវចុះហត្ថលេខាលើលិខិតនោះ ។

ខ-ម្ចាស់បណ្តាំត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬ សរសេរសញ្ញាសំគាល់ ឬ មធ្យោបាយផ្សេងទៀតដែលអាចវិនិច្ឆ័យបានអំពីការបានបើក ឬ មិនបានបើកស្រោមលិខិតនោះ នៅមាត់ស្រោមលិខិតនោះ ។

គ-ម្ចាស់បណ្តាំត្រូវដាក់លិខិតដែលបានបិទជិតនោះ នៅចំពោះមុខសារការីម្នាក់ និង សាក្សី ២ (ពីរ) នាក់ និង ធ្វើសេចក្តីថ្លែងការណ៍ថា លិខិតនេះជាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានជនក្រៅពីសាមីខ្លួនបានសរសេរ ត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីឈ្មោះ និង លំនៅឋានរបស់ជនដែលបានសរសេរនោះ ។

ឃ-សារការីត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួនបានដាក់លិខិតនោះ និង សរសេរសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំ នៅលើលិខិតដែលបិទជិតនោះ ហើយត្រូវចុះហត្ថ-លេខាលើលិខិតនោះ ជាមួយគ្នានឹងសាក្សី និង ម្ចាស់បណ្តាំ ។

**មាត្រា ១១៧៦.–** មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ

១-ដើម្បីធ្វើមតកសាសន៍ នៅពេលដែលជននៅក្រោមអាណាព្យាបាលទូទៅ បានសះស្បើយមួយរយៈឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិត យ៉ាងតិច ២ (ពីរ) នាក់ ។

២-វេជ្ជបណ្ឌិតដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ ត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិតមតកសាសន៍នោះថា នៅពេលដែលម្ចាស់បណ្ដាំបានធ្វើមតកសាសន៍នោះ ម្ចាស់បណ្ដាំពុំបានស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិស្មារតីទេ ហើយត្រូវចុះហត្ថលេខាដោយបញ្ជាក់ថា ខ្លួនជាវេជ្ជបណ្ឌិតផងដែរ ។

**មាត្រា ១១៧៧.–** មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត

១-ប្រសិនបើជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ដោយសារជម្ងឺ ឬ ហេតុផ្សេងទៀត មានបំណងចង់ធ្វើមតកសាសន៍ មតកសាសន៍នេះអាចធ្វើបានដោយតម្រូវឱ្យមានវត្តមានរបស់សាក្សីយ៉ាងតិច ៣ (បី) នាក់ ហើយដោយប្រកាសខ្លឹមសារនៃមតកសាសន៍នោះ ដោយផ្ទាល់មាត់ ចំពោះជនម្នាក់ ក្នុងចំណោមសាក្សីនោះ ។ នៅក្នុងករណីនេះ ជនដែលបានទទួលការប្រកាសដោយផ្ទាល់មាត់នោះ ត្រូវសរសេរជាលាយល័ក្ខណ៍អក្សរ ហើយអានឱ្យសាក្សីស្ដាប់ ឬ ឱ្យមើល ហើយនៅក្រោយពេលដែលសាក្សីនីមួយៗបានទទួលស្គាល់ថាការសរសេរនោះត្រឹមត្រូវហើយ សាក្សីនីមួយៗនោះ ត្រូវចុះហត្ថលេខាលើលិខិតនោះ ។

២-មតកសាសន៍ដែលបានធ្វើតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ បើសាក្សីណាម្នាក់ ឬ បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ពុំបានដាក់ពាក្យសុំទៅតុលាការ នៅក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានធ្វើមតកសាសន៍នោះ ហើយពុំបានទទួលការបញ្ជាក់ទេ ។

៣-តុលាការមិនអាចធ្វើការបញ្ជាក់មតកសាសន៍បានឡើយ ប្រសិនបើពុំមានជំនឿ

ទុកចិត្តថាមតកសាសន៍នោះ ចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ ។

**មាត្រា ១១៧៨.-** មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង ជាអាទិ៍

១-បុគ្គលដែលជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែក ដោយសាលក្រម ឬ សាលដីកា ឬ ដោយសារការចាត់ចែងផ្នែករដ្ឋបាល អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឱ្យមានវត្តមានរបស់នគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ និង សាក្សី យ៉ាងតិច ២ (ពីរ) នាក់ ។

២-បុគ្គលដែលនៅក្នុងនាវា ឬ យន្តហោះ អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឱ្យមានវត្តមានមេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះម្នាក់ និង សាក្សីយ៉ាងតិច ២ (ពីរ) នាក់ ។

៣-នៅពេលធ្វើមតកសាសន៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ ដោយផ្ទាល់មាត់ ចំពោះនគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះបាន ។

៤-បញ្ញត្តិពីចំណុច ខ ដល់ចំណុច ង កថាខណ្ឌទី ២ នៃមាត្រា ១១៧៣ (មតក-សាសន៍ដោយលិខិតយថាភូត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។ ក្នុងករណីនេះ ពាក្យ សារការីត្រូវបានបកស្រាយថាជា នគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះ ។

៥-មតកសាសន៍ដែលត្រូវបានធ្វើឡើង ដោយយោងតាមបញ្ញត្តិពីកថាខណ្ឌទី ១ ដល់កថាខណ្ឌទី ៤ ខាងលើនេះ ពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំបន្តនៅរស់ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលម្ចាស់បណ្តាំនោះ បែរជាអាចធ្វើមតកសាសន៍បាន តាមទម្រង់ណាមួយដែលបានកំណត់ចាប់ពីមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) ដល់មាត្រា ១១៧៥ (មតកសាសន៍ដោយលិខិតសម្ងាត់) នៃក្រមនេះក្រោយពេលខ្លួនត្រូវបានដោះលែងពីមន្ទីរឃុំឃាំង ឬ ចុះពីនាវា ឬ យន្តហោះ ។

**មាត្រា ១១៧៩.–** ការធ្វើមតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ជាអាទិ៍

១-នៅក្នុងករណីដែលបុគ្គលមិនអាចនិយាយបាន ធ្វើមតកសាសន៍តាមទម្រង់ដែលបានកំណត់នៅក្នុងមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) មាត្រា ១១៧៥ (មតកសាសន៍ដោយលិខិតសម្ងាត់) មាត្រា ១១៧៧ (មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត) នៃក្រមនេះ ម្ចាស់បណ្តាំនោះអាចជំនួសការប្រាប់បាន ដោយធ្វើសេចក្តីថ្លែងការណ៍អំពីខ្លឹមសារនៃមតកសាសន៍ ឬ សេចក្តីថ្លែងការណ៍ថាលិខិតនោះជាលិខិតមតកសាសន៍ តាមការបកប្រែរបស់អ្នកបកប្រែ ឬ សរសេរដោយដៃខ្លួនផ្ទាល់ នៅចំពោះមុខសារការី ឬ សាក្សី ។

២-ក្នុងករណីដែលសារការី ឬ បុគ្គលផ្សេងទៀតដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវអានឱ្យម្ចាស់បណ្តាំ ឬ សាក្សី ស្តាប់នូវអត្ថន័យនៃមតកសាសន៍ ក្រោយពេលបានសរសេរជាលាយល័ក្ខណ៍អក្សរនូវខ្លឹមសារនៃមតកសាសន៍នោះ បើម្ចាស់បណ្តាំ និង សាក្សីនោះ បែរជាមនុស្សថ្លង់មិនអាចស្តាប់បានទេ សារការី ឬ បុគ្គលផ្សេងទៀតដែលត្រូវបានកំណត់នៅក្នុងក្រមនេះ អាចជំនួសការអានឱ្យស្តាប់បាន ដោយប្រាប់អំពីអត្ថន័យដែលខ្លួនបានសរសេរនោះ តាមការបកប្រែរបស់អ្នកបកប្រែ ទៅម្ចាស់បណ្តាំ ឬ សាក្សីនោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ សារការី ឬ បុគ្គលផ្សេងទៀតដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវសរសេរអំពីហេតុនោះចូលទៅក្នុងលិខិតនោះ ។

**មាត្រា ១១៨០.–** ការសរសេរនាមត្រកូល និង នាមខ្លួន និង ការផ្តិតម្រាមដៃ ជំនួសឱ្យការចុះហត្ថលេខា

ក្នុងករណីដែលសារការី និង សាក្សី ត្រូវចុះហត្ថលេខា សារការី និង សាក្សីគ្រាន់តែសរសេរនាមត្រកូល និង នាមខ្លួន និង ផ្តិតម្រាមដៃ ជាការគ្រប់គ្រាន់ហើយ ។

**មាត្រា ១១៨១.–** បទប្បញ្ញត្តិពិសេសចំពោះមតកសាសន៍របស់ជនជាតិខ្មែរដែលរស់នៅបរទេស

បើជនជាតិខ្មែរមានបំណងចង់ធ្វើមតកសាសន៍ដោយលិខិតយថាភូត ឬ លិខិត

សម្ងាត់ នៅកន្លែងដែលមានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅ កុងស៊ុលនោះត្រូវអនុវត្តមុខនាទីរបស់សារការី ។

## ផ្នែកទី ៣
## ចំណុចនៃមតកសាសន៍

**មាត្រា ១១៨២.–** ការកំណត់ចំណែកមត៌ក

១-មតកជនអាចកំណត់ចំណែកមត៌ករបស់សហសន្តតិជនតាមមតកសាសន៍ ឬ អាចបង្ហាញឆន្ទៈផ្ទុយពីបញ្ញត្តិនៃមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) នៃក្រមនេះ ស្ដីពីចំណែកមត៌ករបស់បុគ្គលដែលបានទទួលផលប្រយោជន៍ពិសេសបាន ។ ប៉ុន្ដែ ការកំណត់ចំណែកមត៌កដែលបំពានភាគបម្រុង ត្រូវអនុលោមតាមបញ្ញត្តិស្ដីពីភាគបម្រុង ។

២-បើមតកជនបានកំណត់ចំណែកមត៌ក ចំពោះសន្តតិជនតែម្នាក់ ឬ ច្រើននាក់ក្នុងចំណោមសហសន្តតិជនទាំងអស់ ចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវកំណត់ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ៣ (ការសម្រួលចំណែកមត៌ក) ជំពូកទី ២ ។

**មាត្រា ១១៨៣.–** ការកំណត់នូវវិធីបែងចែកដោយមតកសាសន៍ ជាអាទិ៍

មតកជន អាចកំណត់នូវវិធីបែងចែកតាមមតកសាសន៍ ឬ អាចប្រគល់អាណត្តិឱ្យតតិយជនកំណត់វិធីនោះ ឬ អាចហាមឃាត់មិនឱ្យបែងចែកនៅក្នុងអំឡុងពេលដែលមិនលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្ដើមសន្តតិកម្មនោះ បាន ។

**មាត្រា ១១៨៤.–** អនុប្បទានទ្រព្យសម្បត្តិ

ម្ចាស់បណ្ដាំអាចធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែក ឬ អាចធ្វើប្រទានកម្មដោយមតកសាសន៍ តាមវិធីដែលបានកំណត់នៅក្នុងមាត្រា ១១៩៩ (និយមន័យនៃអច្ច័យទាន) នៃក្រមនេះបាន នៅក្នុងល័ក្ខខ័ណ្ឌដែលអនុលោមតាមបញ្ញត្តិស្ដីពីភាគបម្រុង ។

**មាត្រា ១១៨៥.–** អនុប្បទានទ្រព្យសម្បត្តិចំពោះសន្តតិជន

១-បើមតកជនបានធ្វើមតកសាសន៍ដែលមានអត្ថន័យជាការធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬ ច្រើន ឱ្យទៅសហសន្តតិជនតែម្នាក់ ឬ ច្រើននាក់ មតក-សាសន៍នោះត្រូវបានសន្មតថាបានកំណត់នូវវិធីបែងចែកមត៌ក លើកលែងតែនៅក្នុងករណីដែលមតកសាសន៍នោះមានអត្ថន័យជាអច្ច័យទានយ៉ាងច្បាស់លាស់ ដូចជាអច្ច័យទានដែលភ្ជាប់ជាមួយនឹងបន្ទុក ជាអាទិ៍ ហើយបើតម្លៃនៃទ្រព្យសម្បត្តិដែលបានកំណត់នោះ មានចំនួនលើសពីចំណែកមត៌ករបស់សន្តតិជន នោះត្រូវសន្មតថាបានកំណត់ចំណែកមត៌កផងដែរ ។

២-ក្នុងករណីដែលមតកជនបានធ្វើមតកសាសន៍ ចំពោះទ្រព្យសម្បត្តិតែមួយភាគនៅក្នុងចំណោមមត៌ក បើតម្លៃនៃទ្រព្យសម្បត្តិនោះ មានចំនួនតិចជាងចំណែកមត៌ក ដែលសន្តតិជននោះត្រូវទទួល លុះត្រាតែពុំមានការបង្ហាញឆន្ទៈផ្សេងទៀតនៅក្នុងមតកសាសន៍នោះ ត្រូវសន្មតថាបានកំណត់ត្រឹមតែវិធីបែងចែកមត៌កដែលត្រូវធ្លាក់ទៅលើសន្តតិជននោះតែប៉ុណ្ណោះ ។

**មាត្រា ១១៨៦.–** ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍

ម្ចាស់បណ្តាំអាចកំណត់អ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬ ច្រើននាក់ ឬ អាចប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិនោះ តាមមតកសាសន៍បាន ។

**មាត្រា ១១៨៧.–** ចំណុចផ្សេងៗ

ក្រៅពីធ្វើមតកសាសន៍តាមចំណុចដែលបានកំណត់នៅក្នុងក្រមនេះ ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ដោយផ្តល់ដំបូន្មាន ឬ យោបល់ ដើម្បីឱ្យមានភាពសុខដុមរមនាដល់ក្រុមគ្រួសារ និង ចំណុចផ្សេងៗទៀតបាន ។ នៅក្នុងករណីនេះ សន្តតិជន ជាអាទិ៍ ត្រូវគោរពទៅតាមមតកសាសន៍នោះ ។

## ផ្នែកទី ៤
## ការលុបចោលនូវមតកសាសន៍

**មាត្រា ១១៨៨.–** ពេល និង ទម្រង់នៃការលុបចោលនូវមតកសាសន៍

ម្ចាស់បណ្តាំអាចលុបចោលនូវមតកសាសន៍ មួយភាគ ឬ ទាំងមូល នៅពេលណាក៏បាន ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ៤ (ការលុបចោលនូវមតកសាសន៍) នេះ ។

**មាត្រា ១១៨៩.–** ការលុបចោលដោយទម្រង់នៃមតកសាសន៍

១-ម្ចាស់បណ្តាំអាចលុបចោលនូវមតកសាសន៍ មួយភាគ ឬ ទាំងមូលបាន តាមទម្រង់នៃមតកសាសន៍ ។

២-បើមតកសាសន៍ដែលបានធ្វើក្រោយនេះ មានភាពផ្ទុយនឹងមតកសាសន៍ដែលបានធ្វើមុន ត្រូវចាត់ទុកថា មតកសាសន៍ដែលបានធ្វើក្រោយនោះ បានលុបចោលមតកសាសន៍ដែលបានធ្វើមុន ចំពោះផ្នែកដែលផ្ទុយគ្នានោះ ។

**មាត្រា ១១៩០.–** ការលុបចោលមតកសាសន៍ ដោយការចាត់ចែងនាពេលនៅរស់

បើម្ចាស់បណ្តាំបានធ្វើអនុប្បទាន ឬ បានធ្វើសកម្មភាពផ្សេងទៀត ចំពោះវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍ នាពេលនៅរស់ ត្រូវចាត់ទុកថា ម្ចាស់បណ្តាំបានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលផ្ទុយនឹងអនុប្បទាន ឬ សកម្មភាពផ្សេងនោះ ។

**មាត្រា ១១៩១.–** ការលុបចោលដោយការបដិសេធលិខិតមតកសាសន៍ ជាអាទិ៍

បើម្ចាស់បណ្តាំបានបំផ្លាញច្បាប់ដើមនៃមតកសាសន៍ ដោយចេតនា ត្រូវចាត់ទុកថា បានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលត្រូវបានបំផ្លាញនោះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បណ្តាំបានបំផ្លាញវត្ថុ ដែលជាកម្មវត្ថុនៃមតកសាសន៍ ដោយចេតនា ។

**មាត្រា ១១៩២.–** ការបោះបង់សិទ្ធិលុបចោលមតកសាសន៍

ម្ចាស់បណ្តាំមិនអាចបោះបង់សិទ្ធិលុបចោលមតកសាសន៍ បានឡើយ ។

**មាត្រា ១១៩៣.–** ការលុបចោលអច្ច័យទានដែលភ្ជាប់បន្ទុក

បើអច្ច័យលាភីពុំបានអនុវត្តករណីយកិច្ចដែលម្ចាស់បណ្ដាំបានតម្រូវឱ្យអច្ច័យលាភីនោះទទួលបន្ទុកជាថ្នូរនឹងអច្ច័យទានទេ អ្នកប្រតិបត្តិមតកសាសន៍ ឬ បើគ្មានអ្នកប្រតិបត្តិមតកសាសន៍នោះទេ សន្តតិជនអាចដាស់តឿនឱ្យអច្ច័យលាភីនោះ អនុវត្តករណីយកិច្ចនោះ ដោយកំណត់អំឡុងពេលសមរម្យ ហើយប្រសិនបើអច្ច័យលាភីនោះ មិនបានអនុវត្តករណីយកិច្ច នៅក្នុងអំឡុងពេលនោះទេ អ្នកប្រតិបត្តិមតកសាសន៍ ឬ សន្តតិជននោះ អាចទាមទារទៅតុលាការ ឱ្យលុបចោលអច្ច័យទាននោះបាន ។

## ផ្នែកទី ៥
## អានុភាពនៃមតកសាសន៍

**មាត្រា ១១៩៤.–** ពេលដែលមតកសាសន៍បង្កើតអានុភាព

១-មតកសាសន៍ ត្រូវបង្កើតអានុភាព ចាប់ពីពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព ។

២-នៅក្នុងករណីដែលមតកសាសន៍ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញនៅក្រោយពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព មតកសាសន៍នោះ ត្រូវមានអានុភាព ចាប់ពីពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ។

**មាត្រា ១១៩៥.–** អានុភាពនៃការកំណត់ចំណែកមត៌ក ជាអាទិ៍

១-បើមតកជនបានកំណត់ចំណែកមត៌ក ឬ វិធីបែងចែកមត៌ក ដោយធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬ ច្រើន ឱ្យចំពោះសន្តតិជនតែម្នាក់ ឬ ច្រើននាក់ ដោយមតកសាសន៍ ទ្រព្យសម្បត្តិជាក់លាក់នោះ ត្រូវធ្លាក់ទៅសន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះ ដោយស្វ័យប្រវត្តិ ព្រមគ្នានឹងពេលមតកសាសន៍នោះបង្កើតអានុភាព ។

២-នៅក្នុងករណីដែលមតកសាសន៍ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញនៅក្រោយពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព ទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ទុកថា ត្រូវបានធ្លាក់ទៅ

សន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះ ដោយប្រតិសកម្ម គិតចាប់តាំងពីពេលដែលមតកជននោះ បានទទួលមរណភាព ។

**មាត្រា ១១៩៦.–** មរណភាពនៃជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍

១-នៅក្នុងករណីដែលមតកជនបានកំណត់ចំណែកមត៌ករបស់សន្តតិជន ឬ វិធីនៃការបែងចែកមត៌ក ដោយមតកសាសន៍ បើជនដែលត្រូវបានសន្មតថាជាសន្តតិជន បានទទួលមរណភាព នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) នៃក្រមនេះ ឬ ដោយការកាត់កាល់សន្តតិជន ការកំណត់នោះត្រូវបានចាត់ទុកថា បានធ្វើចំពោះអ្នកទទួលសន្តតិកម្មជំនួសរបស់ជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើគ្មានអ្នកទទួលសន្តតិកម្មជំនួសជនដែលត្រូវបានសន្មតថាជាសន្តតិជននោះទេ ការកំណត់ចំពោះជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ពុំត្រូវបង្កើតអានុភាពឡើយ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសន្តតិជនបានបោះបង់សន្តតិកម្ម ។

៣-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះក៏ដោយ បើមតកជនបានបង្ហាញឆន្ទៈផ្សេង ក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១១៩៧.–** ការកម្រិតនូវមតកសាសន៍ ចំពោះអ្នកអាណាព្យាបាល ជាអាទិ៍

១-បើជនដែលនៅក្រោមអាណាព្យាបាលទូទៅ បានធ្វើមតកសាសន៍ ដែលជាផលប្រយោជន៍ដល់អ្នកអាណាព្យាបាល ឬ សហព័ទ្ធ ឬ បច្ឆាញាតិផ្ទាល់របស់អ្នកអាណាព្យាបាលនោះ នៅមុនពេលបញ្ចប់ការគណនានូវចំណូលចំណាយក្នុងកិច្ចការអាណាព្យាបាល មតក-សាសន៍នោះត្រូវចាត់ទុកជាមោឃៈ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលញាតិលោហិតផ្ទាល់ សហព័ទ្ធ ឬ បងប្អូនបង្កើត ជាអ្នកអាណាព្យាបាលទូទៅ ។

សន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះ ដោយប្រតិសកម្ម គិតចាប់តាំងពីពេលដែលមតកជននោះ បានទទួលមរណភាព ។

**មាត្រា ១១៩៦.–** មរណភាពនៃជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍

១-នៅក្នុងករណីដែលមតកជនបានកំណត់ចំណែកមត៌ករបស់សន្តតិជន ឬ វិធីនៃការបែងចែកមត៌ក ដោយមតកសាសន៍ បើជនដែលត្រូវបានសន្មតថាជាសន្តតិជន បានទទួលមរណភាព នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) នៃក្រមនេះ ឬ ដោយការកាត់កាល់សន្តតិជន ការកំណត់នោះត្រូវបានចាត់ទុកថា បានធ្វើចំពោះអ្នកទទួលសន្តតិកម្មជំនួសរបស់ជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើគ្មានអ្នកទទួលសន្តតិកម្មជំនួសជនដែលត្រូវបានសន្មតថាជាសន្តតិជននោះទេ ការកំណត់ចំពោះជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ពុំត្រូវបង្កើតអានុភាពឡើយ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសន្តតិជនបានបោះបង់សន្តតិកម្ម ។

៣-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះក៏ដោយ បើមតកជនបានបង្ហាញឆន្ទៈផ្សេង ក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១១៩៧.–** ការកម្រិតនូវមតកសាសន៍ ចំពោះអ្នកអាណាព្យាបាល ជាអាទិ៍

១-បើជនដែលនៅក្រោមអាណាព្យាបាលទូទៅ បានធ្វើមតកសាសន៍ ដែលជាផលប្រយោជន៍ដល់អ្នកអាណាព្យាបាល ឬ សហព័ទ្ធ ឬ បច្ឆាញាតិផ្ទាល់របស់អ្នកអាណាព្យាបាលនោះ នៅមុនពេលបញ្ចប់ការគណនានូវចំណូលចំណាយក្នុងកិច្ចការអាណាព្យាបាល មតក-សាសន៍នោះត្រូវចាត់ទុកជាមោឃៈ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលញាតិលោហិតផ្ទាល់ សហព័ទ្ធ ឬ បងប្អូនបង្កើត ជាអ្នកអាណាព្យាបាលទូទៅ ។

**មាត្រា ១១៩៨.–** សិទ្ធិទទួលទ្រព្យសម្បត្តិ ក្នុងករណីដែលអច្ច័យទានមោឃៈ ជាអាទិ៍

បើអច្ច័យទានពុំបានបង្កើតអានុភាព ដោយសារអច្ច័យលាភីជាអភ័ព្វបុគ្គល ឬ ទទួលមរណភាព ឬ ដោយសារហេតុផ្សេងទៀត ឬ បើពុំបានបង្កើតអានុភាពដោយសារការបោះបង់ ទ្រព្យដែលអច្ច័យលាភីត្រូវទទួលនោះ ត្រូវធ្លាក់ទៅសន្តតិជនរបស់មតកជន ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

## ផ្នែកទី ៦
## អច្ច័យទាន

**មាត្រា ១១៩៩.–** និយមន័យនៃអច្ច័យទាន

អច្ច័យទានសកល គឺជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់ នូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែកដែលកំណត់ទៅតាមភាគ រីឯអច្ច័យទានមានកំណត់ គឺជាប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ ទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់ ដោយមតកសាសន៍ ។

**មាត្រា ១២០០.–** មរណភាពរបស់អច្ច័យលាភី

១-អច្ច័យទាន ពុំបង្កើតអានុភាពឡើយ បើអច្ច័យលាភីបានទទួលមរណភាព នៅមុន ឬ ក្នុងពេលដែលម្ចាស់បណ្តាំទទួលមរណភាព ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអច្ច័យទានភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ហើយអច្ច័យលាភីបានទទួលមរណភាព នៅមុនពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

៣-ក្នុងករណីដែលសន្តតិជនដែលត្រូវបានសន្មត ជាអច្ច័យលាភី បញ្ញត្តិនៃកថា-ខណ្ឌទី ១ ខាងលើនេះ មិនរារាំងចំពោះការយកបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ១១៩៦ (មរណភាពនៃជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍) នៃក្រមនេះ មកអនុវត្តឡើយ ។

**មាត្រា ១២០១.–** ការបោះបង់អច្ច័យទាន

១-នៅក្រោយពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព អច្ច័យលាភីអាចបោះបង់អច្ច័យទាន នៅពេលណាក៏បាន ។ ប៉ុន្តែ ចំពោះការបោះបង់អច្ច័យទានសកល ត្រូវអនុលោមតាមបញ្ញត្តិស្ដីពីការបោះបង់សន្តតិកម្ម ។

២-ការបោះបង់អច្ច័យទាន ត្រូវមានអានុភាពប្រតិសកម្ម ចាប់ពីពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព ។

**មាត្រា ១២០២.–** ការដាស់តឿនរបស់ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍

បុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធទៅនឹងអច្ច័យទាន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាស់តឿនឱ្យអច្ច័យលាភីទទួលស្គាល់ ឬ បោះបង់អច្ច័យទានបានដោយកំណត់អំឡុងពេលសមរម្យ ។ បើអច្ច័យលាភីមិនបានបង្ហាញឆន្ទៈ ចំពោះបុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធទៅនឹងអច្ច័យទាន នៅក្នុងអំឡុងពេលដែលបានកំណត់នោះទេ ត្រូវចាត់ទុកថា អច្ច័យលាភីបានទទួលស្គាល់អច្ច័យទាននោះ ។

**មាត្រា ១២០៣.–** ការបោះបង់ ឬ ការទទួលស្គាល់ ដោយសន្តតិជនរបស់អច្ច័យលាភី

បើអច្ច័យលាភីបានទទួលមរណភាព ដោយមិនបានទទួលស្គាល់ ឬ បោះបង់អច្ច័យទានទេ សន្តតិជនរបស់អច្ច័យលាភីនោះ អាចទទួលស្គាល់ ឬ បោះបង់អច្ច័យទានបាន ត្រឹមទំហំនៃសិទ្ធិលើសន្តតិកម្មរបស់ខ្លួន ។ ប៉ុន្តែ បើម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១២០៤.–** ការលុបចោលនូវការទទួលស្គាល់ ឬ ការបោះបង់

១-ការទទួលស្គាល់ ឬ ការបោះបង់អច្ច័យទាន ពុំអាចលុបចោលវិញបានទេ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៥២ (ការលុបចោលការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការទទួលស្គាល់ និង ការបោះបង់អច្ច័យទាននេះ ។

**មាត្រា ១២០៥.–** ការទទួលស្គាល់ ឬ បោះបង់ ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន

១-ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន បើបានបោះបង់សន្តតិកម្ម បុគ្គលនោះត្រូវបានចាត់ទុកថាបានបោះបង់អច្ច័យទានផងដែរ ។ អច្ច័យលាភីនោះ មិនអាចទទួលស្គាល់អច្ច័យទាន ដោយបោះបង់សន្តតិកម្មបានឡើយ ។

២-ទោះបីបានទទួលស្គាល់សន្តតិកម្មហើយក៏ដោយ ក៏អច្ច័យលាភីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចបោះបង់អច្ច័យទានមានកំណត់ បានដែរ ។

**មាត្រា ១២០៦.–** សិទ្ធិទទួលផលរបស់អច្ច័យលាភី

អច្ច័យលាភីអាចទទួលផល ចាប់តាំងពីពេលដែលខ្លួនអាចទាមទារឱ្យអនុវត្តអច្ច័យ-ទានបាន ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១២០៧.–** អច្ច័យទាននៃសិទ្ធិដែលមិនស្ថិតនៅក្នុងមត៌ក

អច្ច័យទាន ពុំមានអានុភាពឡើយ បើសិទ្ធិដែលជាកម្មវត្ថុនៃអច្ច័យទាននោះ ពុំស្ថិតនៅក្នុងមត៌ក នៅពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ។

**មាត្រា ១២០៨.–** អច្ច័យទាននៃវត្ថុ ឬ សិទ្ធិដែលភ្ជាប់ជាមួយនឹងសិទ្ធិរបស់តតិយជន

បើវត្ថុ ឬ សិទ្ធិ ដែលជាកម្មវត្ថុនៃអច្ច័យទាន ជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន នៅពេលដែលម្ចាស់បណ្តាំទទួលមរណភាព អច្ច័យលាភីមិនអាចទាមទារឱ្យរំលត់សិទ្ធិនោះចំពោះជនដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទានបានឡើយ ។

**មាត្រា ១២០៩.–** ឧបាទេសកម្មលើវត្ថុ

១-បើម្ចាស់បណ្តាំមានសិទ្ធិទាមទារប្រាក់សំណង ចំពោះតតិយជន ដោយការបាត់បង់ ឬ កែបន្លំវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាន ឬ បាត់បង់ការកាន់កាប់វត្ថុនោះ ត្រូវសន្មតថាបានយកសិទ្ធិនោះ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

២-ក្នុងករណីដែលវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាន មានភាពជាប់គ្នា លាយគ្នា ឬ

ច្របល់គ្នានឹងវត្ថុផ្សេងទៀត បើម្ចាស់បណ្ដាំបានក្លាយជាកម្មសិទ្ធិករតែឯង ឬ ជាម្ចាស់កម្មសិទ្ធិអវិភាគនៃវត្ថុដែលបានផ្សំ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១៨៦ (ការជាប់គ្នារវាងចលនវត្ថុ និង អចលនវត្ថុ) ឬ មាត្រា ១៩៨ (ការជាប់គ្នា ការលាយច្របល់គ្នានៃចលនវត្ថុ) នៃក្រមនេះ ត្រូវសន្មតថា ម្ចាស់បណ្ដាំបានយកកម្មសិទ្ធិទាំងអស់ ឬ កម្មសិទ្ធិអវិភាគនោះ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

**មាត្រា ១២១០.–** ឧបាទេសកម្មលើវត្ថុ នៃអច្ច័យទាននៃសិទ្ធិលើបំណុល

១-ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវបានយកមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន បើម្ចាស់បណ្ដាំបានទទួលសំណង ហើយបើវត្ថុដែលបានទទួលនោះ នៅតែមានក្នុងមត៌ក ត្រូវសន្មតថាបានយកវត្ថុនោះមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

២-ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ត្រូវសន្មតថាបានយកប្រាក់ និង ប្រាក់បញ្ញើ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ត្រឹមកម្រិតនៃប្រាក់ដែលមាននៅក្នុងមត៌ក និង ប្រាក់ដែលបានបញ្ចូលក្នុងប្រាក់បញ្ញើ ក្រោយពីបានសង ។

**មាត្រា ១២១១.–** ការទទួលខុសត្រូវរបស់អច្ច័យលាភី នៅក្នុងអច្ច័យទានភ្ជាប់បន្ទុក

១-ជនដែលបានទទួលអច្ច័យទានភ្ជាប់បន្ទុក ត្រូវទទួលខុសត្រូវក្នុងការអនុវត្តករណីយកិច្ចដែលខ្លួនទទួលបន្ទុក ត្រឹមតែកម្រិតដែលមិនលើសពីតម្លៃនៃកម្មវត្ថុនៃអច្ច័យទាននោះប៉ុណ្ណោះ ។

២-បើតម្លៃនៃកម្មវត្ថុនៃអច្ច័យទានភ្ជាប់បន្ទុក បានចុះថយ ដោយសារការទទួលស្គាល់សន្តតិកម្មដោយមានកម្រិត ឬ ដោយសារការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង អច្ច័យលាភីត្រូវរួចផុតពីករណីយកិច្ចដែលខ្លួនត្រូវទទួលបន្ទុក តាមសមាមាត្រនៃភាគដែលចុះថយនោះ ។ ប៉ុន្តែ បើម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១២១២.–** សិទ្ធិ និង ករណីយកិច្ចរបស់អច្ច័យលាភីសកល

១-អច្ច័យលាភីសកល មានសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងសន្តតិជន ។

២-បើមត៌កទាំងអស់ត្រូវបានផ្ញើអច្ច័យទានសកលឱ្យទៅបុគ្គលផ្សេងដែលមិនមែនជាសន្តតិជន សន្តតិជនត្រូវបានចាត់ទុកថា មិនបានទទួលសន្តតិកម្ម លើកលែងតែសិទ្ធិលើភាគបម្រុង ។

## ផ្នែកទី ៧
## ការប្រតិបត្តិមតកសាសន៍

**មាត្រា ១២១៣.–** ការពិនិត្យបញ្ជាក់ និង ការបើកលិខិតមតកសាសន៍

១-អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ត្រូវដាក់ពាក្យសុំការបញ្ជាក់លិខិតនោះ ដោយភ្ជាប់លិខិតមតកសាសន៍នោះ ជូនទៅតុលាការ ដោយគ្មានការយឺតយ៉ាវ ក្រោយពីខ្លួនបានដឹងអំពីការចាប់ផ្ដើមសន្តតិកម្ម ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលគ្មានអ្នកថែរក្សាគ្រប់គ្រង ក្រោយពេលដែលសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀត បានរកឃើញលិខិតមតកសាសន៍នោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះមតកសាសន៍ដែលបានធ្វើដោយលិខិតយថាភូត ។

៣-លិខិតមតកសាសន៍ដែលបិទដោយប្រថាប់ត្រា អាចបើកបានតែនៅតុលាការ ដោយមានវត្តមានរបស់អ្នកសង្កេតការណ៍ជាសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ឬ អ្នកតំណាងរបស់ជននោះ ។

៤-បុគ្គលដែលបានបើកលិខិតមតកសាសន៍ នៅក្រៅតុលាការ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ នឹងត្រូវពិន័យស៊ីវិលជាប្រាក់ មិនលើសពី ១.០០០.០០០ (មួយលាន) រៀល ។

៥-ចំពោះលិខិតមតកសាសន៍ ទោះបីជាបានបើកនៅក្រៅតុលាការ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ក៏ដោយ មិនត្រូវបាត់បង់អានុភាព ដោយសារតែមូលហេតុនោះឡើយ ។

**មាត្រា ១២១៤.–** ការកំណត់អ្នកប្រតិបត្តិមតកសាសន៍

១-បើម្ចាស់បណ្ដាំបានប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិមតកសាសន៍តាមមតកសាសន៍ ជនដែលបានទទួលអាណត្តិ ត្រូវកំណត់អ្នកប្រតិបត្តិមតកសាសន៍ ហើយត្រូវជូនដំណឹងនោះទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

២-បើជនដែលបានទទួលអាណត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មានបំណងលាឈប់ពីអាណត្តិនោះ ជននោះត្រូវជូនដំណឹងអំពីហេតុនោះ ទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

**មាត្រា ១២១៥.–** ការកាន់មុខងាររបស់អ្នកប្រតិបត្តិមតកសាសន៍

បើអ្នកប្រតិបត្តិមតកសាសន៍ បានយល់ព្រមកាន់មុខងារហើយ អ្នកប្រតិបត្តិមតក-សាសន៍នោះ ត្រូវអនុវត្តភារកិច្ចនោះ ភ្លាមៗ ។

**មាត្រា ១២១៦.–** ការដាស់តឿនឱ្យអ្នកប្រតិបត្តិមតកសាសន៍កាន់មុខងារ

១-សន្តតិជន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀត អាចកំណត់អំឡុងពេលសមរម្យ ហើយដាស់តឿន ចំពោះជនដែលត្រូវបានកំណត់ជាអ្នកប្រតិបត្តិមតក-សាសន៍ ឱ្យឆ្លើយបញ្ជាក់ច្បាស់ក្នុងអំឡុងពេលនោះ អំពីការយល់ព្រម ឬ មិនយល់ព្រមកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍បាន ។ បើអ្នកប្រតិបត្តិមតកសាសន៍ មិនបានឆ្លើយបញ្ជាក់ច្បាស់ ក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា បានលាឈប់ពីការងារនោះ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលតតិយជន ដែលត្រូវបានប្រគល់អាណត្តិឱ្យកំណត់អ្នកប្រតិបត្តិមតកសាសន៍ ពុំបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ ឱ្យបានឆាប់រហ័ស ។ ក្នុងករណីនេះ បើតតិយជននោះមិនបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ នៅក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា បានលាឈប់ពីអាណត្តិនោះ ។

**មាត្រា ១២១៧.–** បុគ្គលដែលមិនអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍

ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិត្ថបត្ថម្ភ អនីតិជន និង ជន

ធនក្ស័យ ពុំអាចធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បានឡើយ ។

**មាត្រា ១២១៨.–** ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍

បើគ្មានអ្នកប្រតិបត្តិមតកសាសន៍ទេ ឬ បើបាត់បង់អ្នកប្រតិបត្តិមតកសាសន៍ តុលាការអាចជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍បាន តាមការទាមទាររបស់សន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ។

**មាត្រា ១២១៩.–** ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ

១-អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ហើយប្រគល់បញ្ជីសារពើភ័ណ្ឌនោះទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

២-សន្តតិជន អាចមានវត្តមាន នៅពេលដែលអ្នកប្រតិបត្តិមតកសាសន៍ ធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិបាន ។

**មាត្រា ១២២០.–** សិទ្ធិអំណាច មុខនាទី នៃអ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិ និង ករណីយកិច្ចក្នុងការគ្រប់គ្រងមត៌ក និង ធ្វើនូវរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ ដើម្បីប្រតិបត្តិមតកសាសន៍ ។

**មាត្រា ១២២១.–** ការបាត់បង់នូវសិទ្ធិចាត់ចែងរបស់សន្តតិជន

១-បើមានអ្នកប្រតិបត្តិមតកសាសន៍ សន្តតិជនពុំអាចចាត់ចែងមត៌ក ឬ ធ្វើសកម្មភាពផ្សេងទៀតដែលនាំឱ្យរារាំងដល់ការប្រតិបត្តិមតកសាសន៍បានឡើយ ។

២-ការចាត់ចែងដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ ។

**មាត្រា ១២២២.–** ការប្រតិបត្តិមតកសាសន៍ ចំពោះទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់

ក្នុងករណីមតកសាសន៍ទាក់ទងនឹងទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់ បញ្ញត្តិចាប់ពីមាត្រា ១២១៩ (ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ) រហូតដល់មាត្រា ១២២១

(ការបាត់បង់នូវសិទ្ធិចាត់ចែងរបស់សន្តតិជន) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះតែទៅលើទ្រព្យសម្បត្តិនោះប៉ុណ្ណោះ ។

**មាត្រា ១២២៣.–** ឋានៈនៃអ្នកប្រតិបត្តិមតកសាសន៍

១-អ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើសកម្មភាព នៅក្នុងនាមជាអ្នកប្រតិបត្តិមតក-សាសន៍ ចំពោះមតិកដែលខ្លួនត្រូវប្រតិបត្តិ ។

២-សកម្មភាពដែលអ្នកប្រតិបត្តិមតកសាសន៍បានធ្វើជាមុខនាទី ត្រូវមានអានុភាពផ្ទាល់ ចំពោះសន្តតិជន ។

**មាត្រា ១២២៤.–** សិទ្ធិជ្រើសតាំងបន្តរបស់អ្នកប្រតិបត្តិមតកសាសន៍

១-បើគ្មានមូលហេតុដែលពុំអាចជៀសវាងបានទេ អ្នកប្រតិបត្តិមតកសាសន៍ ពុំអាចឱ្យតតិយជនអនុវត្តភារកិច្ចរបស់ខ្លួនបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេង នៅក្នុងមតកសាសន៍ ។

២-ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍ បានឱ្យតតិយជនអនុវត្តភារកិច្ចរបស់ខ្លួន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកប្រតិបត្តិមតកសាសន៍នោះត្រូវទទួលខុសត្រូវក្នុងការជ្រើសតាំង និង ការត្រួតពិនិត្យជននោះ ចំពោះអច្ច័យលាភី និង សន្តតិជន ។ បើអ្នកប្រតិបត្តិមតកសាសន៍ បានឱ្យតតិយជនអនុវត្តភារកិច្ចនោះ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសងសំណងនៃការខូចខាត ដែលកើតឡើងដោយសារហេតុនោះ ចំពោះអច្ច័យលាភី និង សន្តតិជន ។

**មាត្រា ១២២៥.–** សហអ្នកប្រតិបត្តិមតកសាសន៍

១-ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍មានច្រើននាក់ ការអនុវត្តភារកិច្ចនោះត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្តាល ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ អ្នកប្រតិបត្តិមតក-សាសន៍នីមួយៗ អាចធ្វើសកម្មភាពរក្សាទុកបាន ។

**មាត្រា ១២២៦.–** កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍

១-អ្នកប្រតិបត្តិមតកសាសន៍ អាចទទួលកម្រៃដែលបានកំណត់នៅក្នុងមតកសាសន៍បាន ។

២-ក្នុងករណីដែលមតកសាសន៍ពុំបានកំណត់កម្រៃទេ តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៃកម្រៃនោះ តាមពាក្យសុំរបស់អ្នកប្រតិបត្តិមតកសាសន៍ បើយល់ឃើញថាសមរម្យក្នុងការបង់កម្រៃ ដោយពិចារណាទៅលើស្ថានភាពនៃមត៌ក ទំនាក់ទំនងរវាងម្ចាស់បណ្តាំ និង អ្នកប្រតិបត្តិមតកសាសន៍ និង ស្ថានភាពផ្សេងទៀត ។

**មាត្រា ១២២៧.–** ការលាឈប់ និង ការបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍

១-បើមានមូលហេតុត្រឹមត្រូវ អ្នកប្រតិបត្តិមតកសាសន៍ អាចលាឈប់ពីភារកិច្ចបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

២-បើអ្នកប្រតិបត្តិមតកសាសន៍ បានធ្វេសប្រហែសក្នុងភារកិច្ច ឬ បើមានមូលហេតុត្រឹមត្រូវផ្សេងទៀត អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាក់ពាក្យសុំទៅតុលាការឱ្យបញ្ឈប់ជននោះបាន ។

**មាត្រា ១២២៨.–** សោហ៊ុយនៃការប្រតិបត្តិមតកសាសន៍

សោហ៊ុយដែលទាក់ទងទៅនឹងការប្រតិបត្តិមតកសាសន៍ ត្រូវជាបន្ទុកនៃមត៌ក ។ ប៉ុន្តែ មិនអាចបន្ថយភាគបម្រុង ដោយសារបន្ទុកនេះឡើយ ។

**មាត្រា ១២២៩.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីអាណត្តិ

បញ្ញត្តិស្តីពីអាណត្តិ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះមុខនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍ លើកលែងតែមានភាពផ្ទុយនឹងលក្ខណៈនៃតួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍នោះ ។

**មាត្រា ១២៤៧.-** ករណីជាសហសន្តតិជន

ការរលត់ដោយអាជ្ញាយុកាល នៃសិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងរបស់សន្តតិជនណាម្នាក់ ឬ ការបោះបង់ភាគបម្រុងដោយសហសន្តតិជនណាម្នាក់ ពុំមានឥទ្ធិពលទៅលើភាគបម្រុងរបស់សហសន្តតិជនផ្សេងទៀតទេ ។

## ជំពូកទី ៥
## ការយល់ព្រម និង ការបោះបង់សន្តតិកម្ម

### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១២៤៨.-** អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់

១-សន្តតិជន ត្រូវធ្វើការយល់ព្រម ឬ ការបោះបង់សន្តតិកម្ម ទាំងស្រុង ឬ ដោយកម្រិត នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួន បានចាប់ផ្តើម ។ ប៉ុន្តែ អំឡុងពេលនេះ អាចពន្យារទៀតបាន តាមពាក្យសុំរបស់សន្តតិ-ជនទៅតុលាការ ។

២-សន្តតិជន អាចធ្វើការស្រាវជ្រាវមត៌កបាន នៅមុនពេលធ្វើការយល់ព្រម ឬ ការបោះបង់ ។

**មាត្រា ១២៤៩.-** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនទទួលមរណភាព

បើសន្តតិជនបានទទួលមរណភាព នៅមុនពេលធ្វើការយល់ព្រម ឬ ការបោះបង់ អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជនរបស់ជននោះ បានដឹងថា សន្តតិកម្មចំពោះខ្លួន បានចាប់ផ្តើម ។

**មាត្រា ១២៥០.-** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនជាអនីតិជន ជាអាទិ៍

បើសន្តតិជន ជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេល

ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់នោះ បានដឹងថា សន្តតិកម្មចំពោះជនដែលជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅនោះ បានចាប់ផ្តើម ។

**មាត្រា ១២៥១.–** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនមិនដឹងអំពីអត្ថិភាពនៃកាតព្វកិច្ច

១-ក្នុងករណីដែលមតកជនមានកាតព្វកិច្ចដែលមានចំនួនទឹកប្រាក់ច្រើន ហើយមិនអាចយកមត៌កទៅសងឱ្យគ្រប់ចំនួនបានទេ បើសន្តតិជនមិនអាចដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ តាមស្ថានភាពនៃជីវភាពរបស់មតកជន ស្ថានភាពនៃទ្រព្យសម្បត្តិរបស់មតកជន ឬ ស្ថានភាពផ្សេងៗទៀត អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជនបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសន្តតិជនបានចាត់ចែងមត៌កដើម្បីសងកាតព្វកិច្ចផ្សេង ដែលត្រូវបានទទួលតាមរយៈសន្តតិកម្ម នៅមុនពេលបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះ បញ្ញត្តិនៃចំណុច ក មាត្រា ១២៥៥ (ការយល់ព្រមទាំងស្រុងតាមច្បាប់) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ។

**មាត្រា ១២៥២.–** ការលុបចោលការយល់ព្រម ឬ ការបោះបង់

១-ការយល់ព្រម និង ការបោះបង់សន្តតិកម្ម មិនអាចលុបចោលបានឡើយ ទោះជានៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ក៏ដោយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងចំពោះការលុបចោលនូវការយល់ព្រម ឬ បោះបង់សន្តតិកម្ម ដោយយកមូលហេតុមានវិការៈក្នុងការបង្ហាញឆន្ទៈឡើយ ។ ប៉ុន្តែ សិទ្ធិលុបចោលនេះ ត្រូវរលត់ បើពុំបានអនុវត្ត នៅក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ

គិតចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិបាន ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលពុំបានអនុវត្តសិទ្ធិលុបចោលនៅក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្តើមធ្វើសន្តតិកម្ម ។

៣-បុគ្គលដែលមានបំណងចង់លុបចោល ការយល់ព្រមដោយកម្រិត ឬ ការបោះបង់ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវដាក់ពាក្យសុំលុបចោលនោះ ទៅតុលាការ ។

**មាត្រា ១២៥៣.–** ការហាមឃាត់មិនឱ្យធ្វើបណ្តឹងចំពោះសន្តតិជន នៅមុនការយល់ព្រម

សិទ្ធិទាមទារចំពោះបេតិកភ័ណ្ឌ ពុំអាចយកមកអះអាងក្នុងបណ្តឹងចំពោះសន្តតិជន នៅមុនពេលយល់ព្រមលើសន្តតិកម្មបានឡើយ ។

## ផ្នែកទី ២
## ការយល់ព្រម

**មាត្រា ១២៥៤.–** ការយល់ព្រមទាំងស្រុង

បើសន្តតិជនបានយល់ព្រមទាំងស្រុង ត្រូវទទួលបន្តដោយគ្មានកម្រិត នូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជននោះ ។

**មាត្រា ១២៥៥.–** ការយល់ព្រមទាំងស្រុងតាមច្បាប់

ក្នុងករណីដែលកំណត់ដូចខាងក្រោមនេះ ត្រូវចាត់ទុកថា សន្តតិជនបានយល់ព្រមទាំងស្រុងតាមច្បាប់ :

ក-បើសន្តតិជនបានចាត់ចែងមតិកនោះ ទាំងអស់ ឬ មួយភាគ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះសកម្មភាពរក្សា និង សកម្មភាពត្រឹមតែជាការគ្រប់គ្រង ។

ខ-បើសន្តតិជនមិនបានយល់ព្រមដោយកម្រិត ឬ បោះបង់ នៅក្នុងអំឡុងពេល

ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ។

គ-ទោះបីជាសន្តតិជនបានយល់ព្រមដោយកម្រិត ឬ បោះបង់ ក៏ដោយ បើសន្តតិជនបានលាក់មត៌កទាំងអស់ ឬ មួយភាគ ឬ បានប្រើប្រាស់មត៌កនោះដើម្បីខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ នៅក្រោយពេលដែលជនដែលបានក្លាយជាសន្តតិជនដោយសារការបោះបង់របស់សន្តតិជនលំដាប់មុនបានយល់ព្រម ។

**មាត្រា ១២៥៦.–** ការយល់ព្រមដោយមានកម្រិត

១-សន្តតិជនអាចយល់ព្រម ដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និង អច្ច័យទានរបស់មតកជនបាន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម តែប៉ុណ្ណោះ ។

២-បើសន្តតិជនមានច្រើននាក់ ការយល់ព្រមដោយកម្រិតនេះ អាចធ្វើបាន លុះត្រាតែសហសន្តតិជននោះ បានធ្វើដោយរួមគ្នាទាំងអស់ ។

**មាត្រា ១២៥៧.–** វិធីនៃការយល់ព្រមដោយកម្រិត

សន្តតិជនដែលមានបំណងចង់យល់ព្រមដោយកម្រិត ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ ហើយត្រូវដាក់ពាក្យសុំអំពីការយល់ព្រមដោយកម្រិតនោះ ទៅតុលាការ នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ។

**មាត្រា ១២៥៨.–** អានុភាពនៃការយល់ព្រមដោយកម្រិត

១-ក្នុងករណីដែលសន្តតិជនបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតក-ជន ពុំអាចតាមទាមទារឱ្យសន្តតិជនទទួលខុសត្រូវ ចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជននោះ បានឡើយ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ សិទ្ធិ និង កាតព្វកិច្ចរបស់សន្តតិជនដែលមានចំពោះមតកជននោះ ត្រូវចាត់ទុកថាមិនបានរលត់ដោយល្បាកុល-

ភាពឡើយ ។

**មាត្រា ១២៥៩.–** ករណីដែលហេតុនៃការយល់ព្រមតាមច្បាប់ កើតឡើង ក្រោយការយល់ព្រមដោយកម្រិត

១-ក្នុងករណីដែលជនដែលបានធ្វើសន្តតិកម្មតែម្នាក់ឯង បានយល់ព្រមដោយកម្រិត បើសន្តតិជននោះមិនបានសរសេរទ្រព្យសម្បត្តិទាំងអស់ ឬ មួយភាគ នៅក្នុងបញ្ជីសារពើភ័ណ្ឌ ដោយទុច្ចរិត ឬ បើមានហេតុដែលបានកំណត់នៅក្នុងចំណុច ក ឬ គ នៃមាត្រា ១២៥៥ (ការយល់ព្រមទាំងស្រុងតាមច្បាប់) នៃក្រមនេះ កើតឡើងចំពោះសន្តតិជននោះ ត្រូវចាត់ទុកថា សន្តតិជននោះបានយល់ព្រមទាំងស្រុង ហើយសេចក្តីថ្លែងការណ៍នៃការយល់ព្រមដោយកម្រិត មិនបង្កើតអានុភាព តាំងពីដំបូងមក ។

២-បើមានមូលហេតុដូចកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះសហសន្តតិជនម្នាក់ ឬ ច្រើននាក់ ដែលបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជនអាចអនុវត្តសិទ្ធិរបស់ខ្លួនទៅលើសហសន្តតិជនម្នាក់ ឬ ច្រើននាក់នោះ ចំពោះចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល ដែលពុំអាចទទួលការសងដោយមត៌ក តាមចំណែកមត៌កនីមួយៗនោះបាន ។

## ផ្នែកទី ៣
## ការបោះបង់

**មាត្រា ១២៦០.–** ការបោះបង់សន្តតិកម្ម

បុគ្គលដែលមានបំណងបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំការបោះបង់សន្តតិកម្មនោះ ទៅតុលាការ ។

**មាត្រា ១២៦១.–** អានុភាពនៃការបោះបង់

បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូងមក ។

# ជំពូកទី ៦
# ការគ្រប់គ្រង និង ការបែងចែកមត៌ក

## ផ្នែកទី ១
## ការគ្រប់គ្រងមត៌ក

**មាត្រា ១២៦២.–** ការរក្សាទុក និង ការគ្រប់គ្រងមត៌ក

១-សន្តតិជនដែលកាន់កាប់មត៌ក នៅពេលមតកជនបានទទួលមរណភាព ត្រូវរក្សាទុក និង គ្រប់គ្រងមត៌កនោះ រហូតដល់ពេលធ្វើការបែងចែកមត៌ក ។ ប៉ុន្តែ ការរក្សាទុក និង ការគ្រប់គ្រងនេះ ត្រូវអនុលោមតាមបញ្ញត្តិនៃមាត្រា ១២៦៣ (ការរក្សាទុកដោយអ្នកប្រតិបត្តិមតកសាសន៍) ខាងក្រោមនេះ ។

២-ទោះបីជានៅមុនពេលយល់ព្រម ឬ បោះបង់សន្តតិកម្មក៏ដោយ សន្តតិជនត្រូវគ្រប់គ្រងមត៌កនោះ ដោយប្រុងប្រយ័ត្ន ដូចគ្នានឹងទ្រព្យសម្បត្តិផ្ទាល់ខ្លួនផងដែរ ។ ទោះបីជានៅក្រោយពេលបោះបង់សន្តតិកម្មក៏ដោយ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ រហូតដល់ពេលបុគ្គលដែលបានក្លាយជាសន្តតិជន ដោយសារការបោះបង់នោះ អាចចាប់ផ្ដើមធ្វើការគ្រប់គ្រងមត៌កនោះបាន ។

**មាត្រា ១២៦៣.–** ការរក្សាទុកដោយអ្នកប្រតិបត្តិមតកសាសន៍

បើបានកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍ហើយ អ្នកប្រតិបត្តិមតកសាសន៍នោះ ត្រូវធ្វើការគ្រប់គ្រងមត៌ក ។ ប៉ុន្តែ ប្រសិនបើមតកសាសន៍ទាក់ទងនឹងទ្រព្យសម្បត្តិដែលមានកំណត់ ត្រូវគ្រប់គ្រងតែទ្រព្យសម្បត្តិនោះប៉ុណ្ណោះ ។

**មាត្រា ១២៦៤.–** អ្នកគ្រប់គ្រងមត៌កជាបណ្ដោះអាសន្ន

១-បើគ្មានអ្នកប្រតិបត្តិមតកសាសន៍ គ្រប់គ្រងមត៌កទាំងមូលទេ សន្តតិជន អច្ច័យលាភី ឬ ម្ចាស់បំណុលរបស់មតកជន អាចដាក់ពាក្យសុំទៅតុលាការ ឱ្យធ្វើការជ្រើសតាំងអ្នកគ្រប់គ្រងមត៌កជាបណ្ដោះអាសន្នបាន រហូតដល់ពេលធ្វើការបែងចែកមត៌ក ។

២-ទោះបីជាមានបញ្ញត្តិនៃមាត្រា ១២៥៣ (ការហាមឃាត់មិនឱ្យធ្វើបណ្ដឹងចំពោះសន្តតិជន នៅមុនការយល់ព្រម) នៃក្រមនេះ ក៏ដោយ អ្នកគ្រប់គ្រងជាបណ្ដោះអាសន្នដែលត្រូវបានជ្រើសតាំងដោយបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ គឺជាអ្នកទទួលបន្ទុកក្នុងបណ្ដឹងនោះ ចំពោះសិទ្ធិទាមទារដែលទាក់ទងនឹងមត៌ក នៅក្នុងនាមជាអ្នកទទួលបន្ទុកក្នុងបណ្ដឹងរបស់សន្តតិជននៃមតកជន ដោយបញ្ជាក់ឈ្មោះមតកជននោះផង រហូតដល់ពេលដែលសន្តតិជនយល់ព្រមទទួលសន្តតិកម្មនោះ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ នៃមាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកគ្រប់គ្រងជាបណ្ដោះអាសន្ន ។

**មាត្រា ១២៦៥.–** សោហ៊ុយដែលទាក់ទងទៅនឹងមត៌ក

សោហ៊ុយដែលទាក់ទងទៅនឹងមត៌ក ត្រូវចំណាយចេញពីក្នុងទ្រព្យសម្បត្តិនោះ ។ ប៉ុន្តែ សោហ៊ុយដែលកើតចេញពីកំហុសរបស់សន្តតិជន គឺជាបន្ទុករបស់សន្តតិជននោះ ។

## ផ្នែកទី ២
## ការបែងចែកមត៌ក

**មាត្រា ១២៦៦.–** ការពិភាក្សាបែងចែកមត៌ក

១-សហសន្តតិជនអាចចាប់ផ្ដើមពិភាក្សាបែងចែកមត៌ក នៅពេលណាក៏បាន បើអំឡុងពេល ១ (មួយ) ខែ បានកន្លងផុត ក្រោយពីការចាប់ផ្ដើមសន្តតិកម្ម ។ ប៉ុន្តែ ចំពោះការផ្លាស់ប្ដូរឈ្មោះម្ចាស់សិទ្ធិលើមត៌ក ដោយសារលទ្ធផលនៃការបែងចែកមត៌ក ត្រូវអនុលោមតាមបញ្ញត្តិនៃមាត្រា ១២៧៧ (ការហាមឃាត់មិនឱ្យផ្លាស់ប្ដូរឈ្មោះម្ចាស់សិទ្ធិ) នៃក្រមនេះ ឬ ចំពោះករណីដែលមតកជនហាមឃាត់ការបែងចែកមត៌កតាមមតកសាសន៍ ការបែងចែកមត៌កពុំអាចធ្វើបានឡើយ នៅក្នុងអំឡុងពេលដែលហាមឃាត់នោះ ។

២-ដើម្បីផ្ទេរសិទ្ធិចំពោះវត្ថុតាមការបែងចែកមត៌ក ការបែងចែកត្រូវធ្វើជាលាយល័ក្ខណ៍អក្សរទៅតាមទម្រង់នីមួយៗ ដែលចាំបាច់នៅក្នុងការផ្ទេរសិទ្ធិនោះ ។

**មាត្រា ១២៦៧.–** មូលដ្ឋាននៃការបែងចែក

១-បើពុំបានកំណត់វិធីបែងចែកនៅក្នុងមតកសាសន៍ទេ ការបែងចែកមត៌កនេះ ត្រូវធ្វើដោយពិចារណាទៅលើប្រភេទ និង លក្ខណៈនៃវត្ថុ ឬ សិទ្ធិដែលមាននៅក្នុងមត៌ក ឬ អាយុ មុខរបរ ស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត ស្ថានភាពជីវភាព របស់សហសន្តតិជននីមួយៗ និង ស្ថានភាពផ្សេងទៀត ។

២-ក្នុងករណីដែលការបែងចែកបណ្ដាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់តម្លៃ បើយល់ឃើញថាសមរម្យ សហសន្តតិជនអាចឱ្យសហសន្តតិជនណាម្នាក់ ធ្វើលទ្ធកម្មទ្រព្យសម្បត្តិនោះបាន ដោយដាក់ល័ក្ខខ័ណ្ឌឱ្យបង់ប្រាក់សម្រួល ចំពោះសហសន្តតិជនផ្សេងទៀត តាមការពិភាក្សា ។

**មាត្រា ១២៦៨.–** សិទ្ធិអាទិភាពរបស់សហព័ទ្ធ

ក្នុងករណីដែលសហព័ទ្ធក្លាយជាសន្តតិជន បើមានទ្រព្យសម្បត្តិដែលទទួលបានជាកម្មសិទ្ធិអវិភាគជាមួយនឹងមតកជន ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ នៅក្នុងការបែងចែកមត៌ក សហព័ទ្ធនេះមានអាទិភាពជាងសហសន្តតិជនផ្សេងទៀត ក្នុងការទទួលយកចំណែកកម្មសិទ្ធិអវិភាគដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ រហូតដល់គ្រប់ចំនួននៃចំណែកមត៌កនោះ ។

**មាត្រា ១២៦៩.–** សំណងនៃកាតព្វកិច្ចរបស់មតកជន ជាអាទិ៍

បើមតកជនមានកាតព្វកិច្ច សហសន្តតិជនត្រូវបែងចែកមត៌ក ដោយពិចារណាពីការណ៍ថា ខ្លួនត្រូវសងកាតព្វកិច្ចនោះ និង មិនអាចប្តូរភាគបន្ទុកនៃកាតព្វកិច្ចនោះ ដោយគ្មានការយល់ព្រមពីសំណាក់ម្ចាស់បំណុលឡើយ ។

**មាត្រា ១២៧០.–** ការបែងចែកដោយតុលាការ

១-បើការពិភាក្សារវាងសហសន្តតិជន ចំពោះការបែងចែកមត៌ក ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ សហសន្តតិជនណាម្នាក់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យធ្វើការបែងចែកមត៌កនោះបាន ។

២-ក្នុងការបែងចែកមត៌ក ក្រៅពីបញ្ញត្តិចាប់ពីមាត្រា ១២៦៧ (មូលដ្ឋាននៃការបែងចែក) រហូតដល់មាត្រា ១២៦៩ (សំណងនៃកាតព្វកិច្ចរបស់មតកជន ជាអាទិ៍) ខាងលើនេះ តុលាការត្រូវធ្វើការពិចារណានូវទំនៀមទម្លាប់នៅក្នុងតំបន់នោះ និង មតិលើសពីពាក់កណ្តាលរបស់សហសន្តតិជន ។

**មាត្រា ១២៧១.–** ការប្តូរជាប្រាក់ដោយការលក់

ចំពោះទ្រព្យសម្បត្តិដែលមិនអាចទទួលការព្រមព្រៀងអំពីការបែងចែក ឬ អំពីបុគ្គលដែលត្រូវទទួល រវាងសហសន្តតិជនទេ តុលាការអាចលក់ ហើយធ្វើការបែងចែកប្រាក់ដែលបានមកពីការលក់នោះបាន ។

**មាត្រា ១២៧២.–** ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្ម ដោយផ្អែកលើការចាត់ចែងទ្រព្យសម្បត្តិ នៅមុនពេលបែងចែក ជាអាទិ៍

ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្ម ដោយការសងជំនួសការបាត់បង់ ការខូចខាត ឬការបំពានយកកម្មវត្ថុមត៌ក ឬ តាមកិច្ចសន្យាដែលយកមត៌កជាកម្មវត្ថុ ដោយផ្អែកលើសិទ្ធិដែលស្ថិតនៅក្នុងមត៌កនោះ ត្រូវស្ថិតនៅក្នុងមត៌ក ។

**មាត្រា ១២៧៣.–** អានុភាពនៃការបែងចែក

១-ការបែងចែកមត៌ក មានអានុភាពប្រតិសកម្ម គិតចាប់ពីពេលដែលបានចាប់ផ្តើមសន្តតិកម្ម ។ ប៉ុន្តែ ការបែងចែកនេះ ពុំអាចបំពានសិទ្ធិរបស់តតិយជនដែលបានចុះបញ្ជី ឬបានទទួលល័ក្ខខ័ណ្ឌតតាំងបានឡើយ ។

២-សហសន្តតិជននីមួយៗ ត្រូវទទួលយកលិខិតបញ្ជាក់សិទ្ធិដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិដែលខ្លួនបានធ្វើលទ្ធកម្ម ។

**មាត្រា ១២៧៤.–** ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក

ក្នុងករណីដែលជនដែលបានក្លាយជាសន្តតិជន ដោយសារជននោះត្រូវបានទទួលស្គាល់ ក្រោយពេលមតកជនបានទទួលមរណភាព មានបំណងទាមទារឱ្យបែងចែកមត៌ក

បើសហសន្តតិជនផ្សេងទៀតបានបែងចែកមត៌ក ឬ បានធ្វើការចាត់ចែងផ្សេងទៀតចំពោះមត៌ក ជននោះមានសិទ្ធិទាមទារឱ្យសងដោយតម្លៃតែប៉ុណ្ណោះ ។

**មាត្រា ១២៧៥.–** ល័ក្ខខ័ណ្ឌតតាំង ជាអាទិ៍ នៃការបែងចែកសិទ្ធិលើបំណុល

១-នៅក្នុងការបែងចែកមត៌ក ក្នុងករណីដែលបានបែងចែកសិទ្ធិលើបំណុលដែលមតកជនមាន ទៅតាមភាគក្រៅពីចំណែកមត៌កដែលកំណត់ដោយច្បាប់ បើសហសន្តតិ-ជនទាំងអស់មិនបានជូនដំណឹងពីការបែងចែកនោះ ឬ បើការបែងចែកមត៌កនោះ ត្រូវបានធ្វើដោយលិខិតយថាភូត តែមិនបានបង្ហាញលិខិតនោះ ឬ ប្រគល់លិខិតចម្លងនោះទៅឱ្យកូនបំណុលទេ ពុំអាចតតាំងជាមួយកូនបំណុលបានឡើយ ។

២-កូនបំណុលនៃមតកជន ដែលបានសងសំណងតាមចំណែកមត៌កដែលកំណត់ដោយច្បាប់ ចំពោះសហសន្តតិជន នៅមុនពេលបានទទួលដំណឹង ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចតតាំងចំពោះសហសន្តតិជនដែលបានធ្វើលទ្ធកម្មសិទ្ធិលើបំណុល តាមការបែងចែកមត៌កនោះបាន ។

**មាត្រា ១២៧៦.–** ការទទួលខុសត្រូវក្នុងការធានា របស់សហសន្តតិជន

សហសន្តតិជនម្នាក់ៗ ត្រូវមានបន្ទុកទទួលខុសត្រូវក្នុងការធានា ទៅតាមសមាមាត្រនៃចំណែកមត៌កនោះ ដូចជាអ្នកលក់ដែរ ចំពោះសហសន្តតិជនដទៃទៀត ។

## ផ្នែកទី ៣
## ការសម្រួលខាងម្ចាស់បំណុល

**មាត្រា ១២៧៧.–** ការហាមឃាត់មិនឱ្យផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិ

សន្តតិជន និង អ្នកគ្រប់គ្រងមត៌ក មិនអាចផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិលើមត៌កទៅឱ្យសន្តតិជន ឬ អច្ច័យលាភី បានឡើយ រហូតដល់ពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ បានកន្លងហួស ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ

ចំពោះករណីដែលផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិលើមតិក តាមភាពចាំបាច់ដើម្បីសងកាតព្វកិច្ចរបស់មតកជន ។

**មាត្រា ១២៧៨.-** ម្ចាស់បំណុលរបស់មតកជន

ម្ចាស់បំណុលនៃមតកជនពុំអាចអនុវត្តសិទ្ធិរបស់ខ្លួន ចំពោះទ្រព្យសម្បត្តិផ្ទាល់របស់សន្តតិជនបានឡើយ រហូតដល់ពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ បានកន្លងហួស ។

**មាត្រា ១២៧៩.-** ម្ចាស់បំណុលរបស់សន្តតិជន

ម្ចាស់បំណុលរបស់សន្តតិជន មិនអាចអនុវត្តសិទ្ធិរបស់ខ្លួន ចំពោះមតិកបានឡើយ រហូតដល់ពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ បានកន្លងហួស ។

## ផ្នែកទី ៤
## ការជម្រះ ជាអាទិ៍ នៅក្នុងករណីដែលមានការយល់ព្រមដោយកម្រិត

**មាត្រា ១២៨០.-** ការគ្រប់គ្រងមតិកនៅក្រោយពេលយល់ព្រមដោយកម្រិត

អ្នកយល់ព្រមដោយកម្រិត ត្រូវបន្តការគ្រប់គ្រងមតិក ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

**មាត្រា ១២៨១.-** ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន

១-អ្នកយល់ព្រមដោយកម្រិត ត្រូវជូនដំណឹងជាសាធាណៈ នៅក្នុងអំឡុងពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានយល់ព្រមដោយកម្រិតហើយ ចំពោះម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភីទាំងអស់ អំពីការណ៍ដែលខ្លួនបានយល់ព្រមដោយកម្រិត និង ការណ៍ដែលម្ចាស់បំណុល និង អច្ច័យលាភីទាំងនោះ ត្រូវស្នើសុំអំពីការទាមទារនៅក្នុងអំឡុងពេលដែលកំណត់ ។ ប៉ុន្តែ អំឡុងពេលនេះ មិនត្រូវឱ្យតិចជាង ២ (ពីរ) ខែ ឡើយ ។

២-នៅក្នុងការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកយល់ព្រមដោយកម្រិត ត្រូវសរសេរបន្ថែមថា បើម្ចាស់បំណុលមិនបានស្នើសុំនៅក្នុងអំឡុងពេលកំណត់នោះទេ សិទ្ធិលើបំណុលនោះនឹងត្រូវដកចេញពីការជម្រះ ។ ប៉ុន្តែ អ្នកយល់ព្រមដោយកម្រិតនេះ មិនអាចដកម្ចាស់បំណុលដែលខ្លួនបានដឹងចេញបានឡើយ ។

៣-អ្នកយល់ព្រមដោយកម្រិត ត្រូវដាស់តឿនដោយឡែកៗ ចំពោះម្ចាស់បំណុលដែលខ្លួនបានដឹងឱ្យធ្វើការស្នើសុំ ។

**មាត្រា ១២៨២.-** សិទ្ធិបដិសេធការសងនៅក្នុងអំឡុងពេលដាស់តឿន

នៅមុនពេលផុតអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) ខាងលើនេះ អ្នកយល់ព្រមដោយកម្រិត អាចបដិសេធការសង ចំពោះម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភីបាន ។

**មាត្រា ១២៨៣.-** ការសងតាមការចែកចំណែក

ក្រោយពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) ខាងលើនេះ បានកន្លងហួស អ្នកយល់ព្រមដោយកម្រិត ត្រូវយកមត៌កនោះមកសងឱ្យម្ចាស់បំណុលដែលបានស្នើសុំនៅក្នុងអំឡុងពេលនោះ និង ម្ចាស់បំណុលផ្សេងទៀតដែលខ្លួនបានដឹង ទៅតាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនីមួយៗនោះ ។ ប៉ុន្តែ ការសងនេះ ពុំអាចបំពានសិទ្ធិរបស់ម្ចាស់បំណុលដែលមានសិទ្ធិអាទិភាពបានឡើយ ។

**មាត្រា ១២៨៤.-** ការសងកាតព្វកិច្ច ជាអាទិ៍ នៅមុនពេលកំណត់

១-ទោះបីជាសិទ្ធិលើបំណុលមិនទាន់ដល់ពេលកំណត់សងក៏ដោយ អ្នកយល់ព្រមដោយកម្រិត ត្រូវសងដោយយោងតាមបញ្ញត្តិនៃមាត្រា ១២៨៣ (ការសងតាមការចែក

ចំណែក) ខាងលើនេះ ។

២-ចំពោះសិទ្ធិលើបំណុលដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬ សិទ្ធិលើបំណុលដែលអំឡុងពេលបន្តអត្ថិភាពមិនពិតប្រាកដ អ្នកយល់ព្រមដោយកម្រិតត្រូវសងសិទ្ធិលើបំណុលនោះដោយយោងតាមការវាយតម្លៃរបស់អ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការ ។

**មាត្រា ១២៨៥.–** ការសងចំពោះអច្ច័យលាភី

អ្នកយល់ព្រមដោយកម្រិត មិនអាចសងទៅឱ្យអច្ច័យលាភីបានឡើយ បើមិនទាន់បានសងចំពោះម្ចាស់បំណុលនីមួយៗ តាមបញ្ញត្តិនៃមាត្រា ១២៨៣ (ការសងតាមការចែកចំណែក) និង មាត្រា ១២៨៤ (ការសងកាតព្វកិច្ច ជាអាទិ៍ នៅមុនពេលកំណត់) ខាងលើនេះ ។

**មាត្រា ១២៨៦.–** ការប្តូរមត៌កជាប្រាក់

១-ប្រសិនបើចាំបាច់ត្រូវលក់មត៌កដើម្បីសង ដោយយោងតាមបញ្ញត្តិចាប់ពីមាត្រា ១២៨៣ (ការសងតាមការចែកចំណែក) រហូតដល់មាត្រា ១២៨៥ (ការសងចំពោះអច្ច័យលាភី) ខាងលើនេះ អ្នកយល់ព្រមដោយកម្រិត ត្រូវលក់មត៌កនោះ តាមវិធីលក់ដោយបង្ខំ ឬ លក់ក្នុងតម្លៃខ្ពស់ជាងការវាយតម្លៃរបស់អ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការ ។

២-អ្នកយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជន ឬ អច្ច័យលាភី អាចក្លាយជាអ្នកទិញដោយផ្ទាល់ខ្លួន នៅក្នុងការលក់ដោយបង្ខំ ឬ ការលក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

**មាត្រា ១២៨៧.–** ការទទួលខុសត្រូវក្នុងការសងមិនត្រឹមត្រូវ

១-ប្រសិនបើអ្នកយល់ព្រមដោយកម្រិតមានការធ្វេសប្រហែស ក្នុងការជូនដំណឹងជាសាធារណៈ ឬ ការដាស់តឿនដែលបានកំណត់នៅក្នុងមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) នៃក្រមនេះ ឬ បើពុំអាចសងទៅឱ្យម្ចាស់បំណុល ឬ អច្ច័យលាភីដទៃទៀត ដោយសារបានសងទៅឱ្យម្ចាស់បំណុល ឬ អច្ច័យលាភីណាផ្សេង

នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈដែលបានកំណត់ នៅក្នុងកថាខណ្ឌទី ១ នៃមាត្រាដដែលនេះទេ អ្នកយល់ព្រមដោយកម្រិតនោះ ត្រូវសង សំណងការខូចខាតដែលកើតឡើងដោយសារហេតុនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងការទាមទារសំណងការខូចខាត របស់ម្ចាស់បំណុល ឬ អច្ច័យលាភីដទៃ ចំពោះម្ចាស់បំណុល ឬ អច្ច័យលាភីដែលបាន ទទួលការសង ដោយដឹងអំពីភាពមិនត្រឹមត្រូវនៃការសងនោះ ។

**មាត្រា ១២៨៨.–** ករណីដែលពុំបានស្នើសុំ

ម្ចាស់បំណុល និង អច្ច័យលាភី ដែលពុំបានស្នើសុំនៅក្នុងអំឡុងពេលដែលបាន កំណត់នៅក្នុងការជូនដំណឹងជាសាធារណៈ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃ មាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) នៃក្រមនេះ ហើយដែល អ្នកយល់ព្រមដោយកម្រិតពុំអាចដឹងបាន អាចអនុវត្តសិទ្ធិរបស់ខ្លួនបាន ត្រឹមតែចំពោះ ទ្រព្យសម្បត្តិដែលនៅសេសសល់ប៉ុណ្ណោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះជនដែលមានសិទ្ធិប្រាតិភោគលើវត្ថុ ឬ សិទ្ធិដែលបានកំណត់ជាក់លាក់ក្នុងចំណោម មត៌ក ។

**មាត្រា ១២៨៩.–** ករណីដែលមានសន្តតិជនច្រើននាក់

១-នៅក្នុងករណីដែលមានសន្តតិជនច្រើននាក់ បើមានការយល់ព្រមដោយកម្រិត តុលាការត្រូវជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក ពីក្នុងចំណោមសន្តតិជនទាំងនោះ ។

២-អ្នកគ្រប់គ្រង ត្រូវបំពេញរាល់សកម្មភាពចាំបាច់ក្នុងការគ្រប់គ្រងមត៌ក និង សង កាតព្វកិច្ច ដើម្បីខ្លួនឯងផ្ទាល់ និង ជំនួសសហសន្តតិជនដទៃទៀត ។

៣-បញ្ញត្តិចាប់ពីមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) រហូតដល់មាត្រា ១២៨៨ (ករណីដែលពុំបានស្នើសុំ) ខាងលើនេះ ត្រូវយកមកអនុវត្តដូច គ្នាផងដែរ ចំពោះអ្នកគ្រប់គ្រង ។ ប៉ុន្តែ អំឡុងពេលដែលត្រូវជូនដំណឹងជាសាធារណៈ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) នៃក្រមនេះ មានចំនួន ១០ (ដប់) ថ្ងៃ បន្ទាប់ពីបានជ្រើសតាំងអ្នក

គ្រប់គ្រង ។

## ជំពូកទី ៧
## នត្ថិភាពនៃសន្តតិជន

**មាត្រា ១២៩០.-** នីតិបុគ្គលមត៌ក

ប្រសិនបើពុំច្បាស់ថាមានសន្តតិជនទេ មត៌កនោះត្រូវក្លាយជានីតិបុគ្គល ។

**មាត្រា ១២៩១.-** ការជ្រើសតាំងអ្នកគ្រប់គ្រង

១-ក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ១២៩០ (នីតិបុគ្គលមត៌ក) ខាងលើនេះ តុលាការត្រូវជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក តាមពាក្យសុំរបស់បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋាន ចុងក្រោយរបស់មតកជន ឬ តំណាងអយ្យការ ។

២-បើបានជ្រើសតាំងអ្នកគ្រប់គ្រងមត៌កហើយ តុលាការត្រូវធ្វើការជូនដំណឹងជាសាធារណៈអំពីការណ៍នោះ ដោយគ្មានការយឺតយ៉ាវ ។

**មាត្រា ១២៩២.-** សិទ្ធិ និង កាតព្វកិច្ចរបស់អ្នកគ្រប់គ្រង

១-អ្នកគ្រប់គ្រង ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌដែលទាក់ទងទៅនឹងមត៌ក ដោយគ្មានការយឺតយ៉ាវ ។

២-អ្នកគ្រប់គ្រង ត្រូវថែរក្សា និង គ្រប់គ្រងមត៌ក ។ បើមានការចាំបាច់ដើម្បីថែរក្សា និង គ្រប់គ្រងមត៌កនោះ អ្នកគ្រប់គ្រងអាចប្តូរមត៌កជាប្រាក់ ឬ អាចចាត់ចែងមត៌កនោះបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

៣-បើមានការទាមទារពីម្ចាស់បំណុលរបស់មតកជន ឬ អច្ច័យលាភី អ្នកគ្រប់គ្រងត្រូវរាយការណ៍អំពីស្ថានភាពនៃមត៌កទៅឱ្យជននោះ ។

៤-អ្នកគ្រប់គ្រងត្រូវអនុវត្តតាមចំណុចនីមួយៗ ដែលបានកំណត់ក្នុងបញ្ញត្តិចាប់ពីមាត្រា ១២៨២ (សិទ្ធិបដិសេធការសងនៅក្នុងអំឡុងពេលដាស់តឿន) រហូតដល់មាត្រា

១២៨៨ (ករណីដែលពុំបានស្នើសុំ) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៩៦ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍) ខាងក្រោមនេះ ។

៥-តាមការបង្គាប់របស់តុលាការ អ្នកគ្រប់គ្រង ត្រូវស្រាវជ្រាវអង្គហេតុ ហើយត្រូវធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនោះទៅតុលាការ ។

**មាត្រា ១២៩៣.–** កម្រៃសម្រាប់ អ្នកគ្រប់គ្រង

តុលាការអាចផ្តល់កម្រៃសមរម្យ ចេញពីក្នុងចំណោមមត៌ក ឱ្យទៅអ្នកគ្រប់គ្រងបាន ដោយគិតពិចារណាទៅលើស្ថានភាពនៃមត៌ក និង ស្ថានភាពផ្សេងទៀត ។

**មាត្រា ១២៩៤.–** ករណីដែលដឹងច្បាស់អំពីសន្តតិជន

ប្រសិនបើដឹងច្បាស់ថាមានសន្តតិជន នីតិបុគ្គលមត៌កត្រូវចាត់ទុកថាពុំមានអត្ថិភាពតាំងពីដំបូង ។ ប៉ុន្តែ បញ្ញត្តិនេះពុំរារាំងអានុភាពនៃសកម្មភាពដែលអ្នកគ្រប់គ្រងបានធ្វើហើយ នៅក្នុងទំហំនៃសិទ្ធិអំណាចរបស់ខ្លួនឡើយ ។

**មាត្រា ១២៩៥.–** ពេលរលត់សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រង

១-សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រង ត្រូវរលត់ នៅពេលដែលសន្តតិជនបានយល់ព្រមទទួលសន្តតិកម្ម ។

២-បើសន្តតិជនបានយល់ព្រមទទួលសន្តតិកម្មហើយ អ្នកគ្រប់គ្រងត្រូវគណនាអំពីការគ្រប់គ្រងនោះ ចំពោះសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

**មាត្រា ១២៩៦.–** ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍

១-បើពុំបានដឹងច្បាស់អំពីអត្ថិភាពនៃសន្តតិជន នៅក្នុងអំឡុងពេល ២ (ពីរ) ខែ បន្ទាប់ពីបានធ្វើការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ១២៩១ (ការជ្រើសតាំងអ្នកគ្រប់គ្រង) នៃក្រមនេះទេ អ្នកគ្រប់គ្រង ត្រូវជូនដំណឹងជាសាធារណៈ ដោយគ្មានការយឺតយ៉ាវ ចំពោះម្ចាស់បំណុលរបស់មតកជន និង អច្ច័យ-

លាភីទាំងអស់ អំពីការណ៍ដែលម្ចាស់បំណុល និង អច្ច័យលាភីទាំងនោះ ត្រូវស្នើសុំអំពីការទាមទារក្នុងអំឡុងពេលដែលកំណត់ ។ ប៉ុន្តែ អំឡុងពេលនេះ មិនត្រូវឱ្យតិចជាង ២ (ពីរ) ខែ ឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) និង បញ្ញត្តិចាប់ពីមាត្រា ១២៨២ (សិទ្ធិបដិសេធការសងនៅក្នុងអំឡុងពេលដាស់តឿន) រហូតដល់មាត្រា ១២៨៨ (ករណីដែលពុំបានស្នើសុំ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។ ប៉ុន្តែ អ្នកគ្រប់គ្រង ពុំអាចក្លាយជាអ្នកទិញនៅក្នុងការលក់ដោយបង្ខំ ឬ ការលក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨៦ (ការប្តូរមត៌កជាប្រាក់) នៃក្រមនេះ ដែលត្រូវបានយកមកអនុវត្តដូចគ្នា បានឡើយ ។

**មាត្រា ១២៩៧.-** ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន

១-ក្រោយពីអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៩៦ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍) ខាងលើនេះ បានកន្លងហួស ប្រសិនបើនៅតែមិនទាន់ដឹងច្បាស់ថាមានសន្តតិជននៅឡើយ តាមពាក្យសុំរបស់អ្នកគ្រប់គ្រង ឬ តំណាងអយ្យការ តុលាការត្រូវធ្វើការជូនដំណឹងជាសាធារណៈថា ប្រសិនបើមានសន្តតិជន សន្តតិជននោះត្រូវធ្វើការស្នើសុំអំពីការណ៍នោះ នៅក្នុងអំឡុងពេលដែលកំណត់ ។ ប៉ុន្តែ អំឡុងពេលនេះ មិនត្រូវឱ្យតិចជាង ៦ (ប្រាំមួយ) ខែ ឡើយ ។

២-បើប៉ាន់ប្រមាណឃើញថាគ្មានសេសសល់មត៌កទេ អ្នកគ្រប់គ្រង ឬ តំណាងអយ្យការ មិនអាចធ្វើការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះឡើយ ។

**មាត្រា ១២៩៨.-** ការដកហូតសិទ្ធិតាមការជូនដំណឹងជាសាធារណៈ

បើគ្មានការស្នើសុំថា ខ្លួនជាសន្តតិជន នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងបញ្ញត្តិនៃមាត្រា ១២៩៧ (ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន) ខាងលើនេះទេ សន្តតិជន ព្រមទាំងម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភី ដែលអ្នកគ្រប់គ្រងមិន

អាចដឹងបាន ពុំអាចអនុវត្តសិទ្ធិបានឡើយ ។

**មាត្រា ១២៩៩.–** ការចែកមត៌កឱ្យទៅជនដែលមាននិស្ស័យពិសេស

១-នៅក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ១២៩៨ (ការដកហូតសិទ្ធិតាមការជូនដំណឹងជាសាធារណៈ) ខាងលើនេះ បើយល់ឃើញថាសមរម្យ តុលាការអាចចែកមួយផ្នែកនៃមត៌កដែលនៅសេសសល់ក្រោយការជម្រះ ទៅឱ្យជនដែលមានជីវភាពជាមួយគ្នានឹងមតកជន ជនដែលបានខិតខំមើលថែទាំព្យាបាលមតកជន និង ជនដែលមាននិស្ស័យពិសេសផ្សេងទៀត តាមពាក្យសុំរបស់ជននោះ ។ ប៉ុន្តែ ចំនួនសរុបនៃតម្លៃទ្រព្យដែលត្រូវចែកទៅឱ្យ នោះ មិនត្រូវលើសពីចំនួនពាក់កណ្ដាលនៃមត៌កដែលនៅសេសសល់នោះទេ ។

២-ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើនៅក្នុងអំឡុងពេល ៣ (បី) ខែ ក្រោយពីអំឡុងពេលដែលបានកំណត់នៅក្នុងមាត្រា ១២៩៧ (ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន) ខាងលើនេះ បានកន្លងហួស ដោយបញ្ជាក់អំពីហេតុនៃនិស្ស័យពិសេសនោះឱ្យបានច្បាស់លាស់ ។

៣-ក្នុងការចែកទ្រព្យដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចស្រាវជ្រាវអំពីអង្គហេតុបាន ។ បើនៅក្នុងការស្រាវជ្រាវនេះ តុលាការអាចសួរយោបល់របស់មេឃុំ ឬ ចៅសង្កាត់បាន ។

**មាត្រា ១៣០០.–** មត៌កដែលធ្លាក់ទៅជាទ្រព្យរដ្ឋ

មត៌កដែលមិនត្រូវបានចាត់ចែង តាមបញ្ញត្តិនៃមាត្រា ១២៩៩ (ការចែកមត៌កឱ្យទៅជនដែលមាននិស្ស័យពិសេស) ខាងលើនេះ ត្រូវធ្លាក់ទៅជាទ្រព្យរដ្ឋ ។ ក្នុងករណីនេះ អ្នកគ្រប់គ្រងត្រូវគណនាអំពីការគ្រប់គ្រងនោះ ហើយដាក់ជូនទៅតុលាការ ដោយគ្មានការយឺតយ៉ាវ ។

# ជំពូកទី ៨
# ការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម

**មាត្រា ១៣០១.-** គោលបំណងនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម

សន្តតិជនដែលត្រូវបានដកហូតសិទ្ធិសន្តតិកម្ម អាចទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ដើម្បីទទួលបដិទាននៃមត៌កទាំងអស់ ឬ មួយភាគ បាន ។

**មាត្រា ១៣០២.-** អត្ថន័យនៃការទាមទារឱ្យធ្វើបដិទាននូវសន្តតិកម្ម

១-សន្តតិជនអាចទាមទារចំពោះជនដែលបានទទួលមត៌ក តាមសិទ្ធិសន្តតិកម្មដែលពុំត្រូវបានទៅជននោះ ឱ្យប្រគល់មកវិញ នូវទ្រព្យដែលបានទទួលនោះ ។

២-ទ្រព្យដែលភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម បានទទួល តាមកិច្ចសន្យាដែលយកមត៌កធ្វើជាកម្មវត្ថុ ក៏ត្រូវក្លាយជាកម្មវត្ថុនៃការទាមទារឱ្យធ្វើបដិទាននូវសន្តតិកម្មផងដែរ ។

**មាត្រា ១៣០៣.-** ខ្លឹមសារនៃករណីយកិច្ចប្រគល់វិញ

១-ភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ត្រូវប្រគល់មត៌កមកឱ្យសន្តតិជនដែលបានទាមទារវិញ ។ បើភាគីម្ខាងទៀតសុចរិត ជននោះមានសិទ្ធិរក្សាទុកនូវផល និង ការប្រាក់ដែលបានទទួល សិទ្ធិទាមទារឱ្យសងវិញនូវសោហ៊ុយដែលបានបង្កើនតម្លៃចំពោះទ្រព្យនោះ ហើយមានសិទ្ធិទាមទារសំណងចំពោះកាតព្វកិច្ចដែលត្រូវបានទទួលតាមរយៈសន្តតិកម្ម ដែលបានសងរួចហើយនោះ ។

២-បើភាគីម្ខាងទៀតទុច្ចរិត ជននោះមានកាតព្វកិច្ចត្រូវប្រគល់វិញនូវផល និង ការប្រាក់ដែលបានទទួល ហើយមិនត្រឹមតែគ្មានសិទ្ធិទាមទារសំណងចំពោះកាតព្វកិច្ចដែលត្រូវបានទទួលតាមរយៈសន្តតិកម្មដែលបានសងនោះទេ ថែមទាំងគ្មានសិទ្ធិទាមទារឱ្យសងវិញនូវសោហ៊ុយដែលបានបង្កើនតម្លៃចំពោះទ្រព្យនោះផង ។

**មាត្រា ១៣០៤.-** អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យធ្វើបដិទានសន្តតិកម្ម

អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យធ្វើបដិទានសន្តតិកម្ម នៅក្នុងករណីដែលមត៌កត្រូវបានផ្ទេរទៅភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម តាមមតកសាសន៍ ឬ ការបែងចែកមត៌ក មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលនោះ រីឯក្នុងករណីដែលជនតែម្នាក់បានទទួលសន្តតិកម្មក្នុងនាមជាសន្តតិជន មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃដែលមតកជនបានទទួលមរណភាព ។

# ឧបសម្ព័ន្ធទី២

# ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី

# ដែលមិនមែនជាបណ្តឹង

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៥ | ចំណុចលើកឡើងខាងក្រោមនេះ ក្នុងចំណោមចំណុចដែលបានកំណត់នៅក្នុងគន្ថីទី៨ នៃក្រមរដ្ឋប្បវេណី | |
| | ១ ការកំណត់អ្នកទទួលបន្តនូវសិទ្ធិដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ មាត្រា១១៤៧ (ការទទួលបន្តនូវមត៌ក) ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី៣ នៃកថាខណ្ឌដដែលនោះ | តុលាការនៃលំនៅឋានរបស់មតកជន ឬកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ២ ការផ្តាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជន និងការលុបចោលនូវការផ្តាច់មត៌កនោះ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១១៥១ (ការផ្តាច់មត៌កពីសន្តតិជន) មាត្រា១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍) និងមាត្រា១១៥៤ (ការលុបចោលនូវការផ្តាច់មត៌កពីសន្តតិជន) | តុលាការនៃលំនៅឋានរបស់មតកជន ឬកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ៣ ការបញ្ជាក់មតកសាសន៍ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា១១៧៧ (មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម ឬលំនៅឋានរបស់ម្ចាស់បណ្តាំ |
| | ៤ ការលុបចោលអច្ច័យទាន ដោយយោងតាមបញ្ញត្តិនៃមាត្រា ១១៩៣ (ការលុបចោលអច្ច័យទានដែលភ្ជាប់បន្ទុក) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ៥ ការពិនិត្យបញ្ជាក់លិខិតមតកសាសន៍ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១២១៣ (ការពិនិត្យបញ្ជាក់ និងការបើកលិខិតមតកសាសន៍) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ៦ ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ ដោយយោងតាមបញ្ញត្តិនៃមាត្រា១២១៨ (ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ៧ ការផ្តល់កម្រៃចំពោះអ្នកប្រតិបត្តិមតកសាសន៍ ដោយយោងតាមបញ្ញត្តិ នៃកថាខណ្ឌទី២ មាត្រា១២២៦ (កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ៨ ការអនុញ្ញាតឱ្យលាឈប់ពីអ្នកប្រតិបត្តិមតកសាសន៍ និងការបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍ ដោយយោងតាមបញ្ញត្តិនៃមាត្រា១២២៧ (ការលាឈប់ និងការបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ៩ ការជ្រើសតាំងអ្នកវាយតម្លៃ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១២៣១ (ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១០ ការអនុញ្ញាតឱ្យបោះបង់ភាគបម្រុង ដោយយោងតាមបញ្ញត្តិនៃមាត្រា ១២៤៦ (ការបោះបង់ភាគបម្រុង) | តុលាការនៃលំនៅឋានរបស់មតកជន |
| | ១១ ការពន្យារអំឡុងពេលនៃការយល់ព្រម ឬការបោះបង់សន្តតិកម្ម ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី២ កថាខណ្ឌទី១ មាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬការបោះបង់) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៥ | ១២ ការទទួលពាក្យសុំលុបចោលការយល់ព្រមដោយមានកម្រិត ឬការបោះបង់សន្តតិកម្ម ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៣ មាត្រា ១២៥២ (ការលុបចោលការយល់ព្រម ឬការបោះបង់) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១៣ ការទទួលពាក្យសុំយល់ព្រមសន្តតិកម្មដោយមានកម្រិត ដោយយោងតាមបញ្ញត្តិនៃមាត្រា១២៥៧ (វិធីនៃការយល់ព្រមដោយកម្រិត) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១៤ ការទទួលពាក្យសុំបោះបង់សន្តតិកម្ម ដោយយោងតាមបញ្ញត្តិនៃមាត្រា១២៦០ (ការបោះបង់សន្តតិកម្ម) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១៥ ការជ្រើសតាំងអ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១២៦៤ (អ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១៦ ការចាត់ចែងដែលទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និងកថាខណ្ឌទី ៣ មាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយកថាខណ្ឌទី ៣ មាត្រា ១២៦៤ (អ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១៧ ការបែងចែកមត៌ក ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា ១២៧០ (ការបែងចែកដោយតុលាការ) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១៨ ការជ្រើសតាំងអ្នកវាយតម្លៃ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា១២៨៤ (ការសងកាតព្វកិច្ច ជាអាទិ៍ នៅមុនពេលកំណត់) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១៩ ការជ្រើសតាំងអ្នកវាយតម្លៃ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា១២៨៦ (ការប្តូរមត៌កជាប្រាក់) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ២០ ការជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១២៨៩ (ករណីដែលមានសន្តតិជនច្រើននាក់) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ២១ ការជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១២៩១ (ការជ្រើសតាំងអ្នកគ្រប់គ្រង) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ២២ ការអនុញ្ញាតឱ្យចាត់ចែងទាក់ទងនឹងការគ្រប់គ្រងមត៌ក ដោយយោងតាមបញ្ញត្តិនៃមាត្រា១២៩២ (សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកគ្រប់គ្រង) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ២៣ ការផ្តល់កម្រៃចំពោះអ្នកគ្រប់គ្រងមត៌ក ដោយយោងតាមបញ្ញត្តិនៃមាត្រា១២៩៣ (កម្រៃសម្រាប់អ្នកគ្រប់គ្រង) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |

ROYAUME DU CAMBODGE ★ ROYAL ★ MINISTRE DU PALAIS

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៥ | ២៤ ការជ្រើសតាំងអ្នកវាយតម្លៃ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១២៨៤ (ការសងកាតព្វកិច្ច ជាអាទិ៍ នៅមុនពេលកំណត់) ឬកថាខណ្ឌទី១ មាត្រា១២៨៦ (ការប្តូរមត៌កជាប្រាក់) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយកថាខណ្ឌទី២ មាត្រា ១២៩៦ (ការជូនដំណឹងជាសាធារណៈ និងការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ២៥ ការចាត់ចែងទាក់ទងនឹងការគ្រប់គ្រងមត៌ក ដោយយោងតាមបញ្ញត្តិនៃមាត្រា ១២៩៧ (ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ២៦ ការចាត់ចែងមត៌ក ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា ១២៩៩ (ការចែកមត៌កឱ្យទៅជនដែលមាននិស្ស័យពិសេស) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |

# ឧបសម្ព័ន្ធទី៣

# ព្រះរាជក្រមលេខ១៩១០ ន.ស

ចំពោះច្បាប់
បណ្ណសារដ្ឋានជាតិ



# ព្រះរាជក្រមលេខ ១៩១០ ន.ស.

បានទទួលយល់ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រ ។

បានទទួលយល់ ពិធីសារប្រគល់សមត្ថកិច្ចតុលាការ ចុះថ្ងៃទី ២៩ សីហា គ.ស. ១៩៥៣ ។

បានទទួលយល់ អនុសញ្ញាតុលាការ ចុះថ្ងៃទី ៩ កញ្ញា គ.ស. ១៩៥៣

បានទទួលយល់ ព្រះរាជក្រឹត្យលេខ ៥២១ ន.ស. ចុះថ្ងៃទី ២៦ សីហា គ.ស. ១៩៥៤ ស្ដីពីតាំងគណៈរដ្ឋមន្ត្រី ។

បានទទួលយល់ យោបល់នៃក្រុមប្រឹក្សាជាតិ ។

គណៈរដ្ឋមន្ត្រី បានយល់ព្រមផង ។

## ត្រាស់បង្គាប់ ដូចមានខាងក្រោម:

## ១— បទបញ្ញត្តទូទៅ

មាត្រា ១ – សារៈការីជាមន្ត្រីសាធារណៈ ដែលតាំងឡើងតាមព្រះរាជក្រឹត្យនៃរដ្ឋាភិបាល ដោយមានតំបំណង:

១– ទទួល និងធ្វើតាមត្រូវការ នូវលិខិតឬកិច្ចសន្យាទាំងឡាយដែលគូសញ្ញាត្រូវធ្វើឲ្យមាន ឬចូលចិត្តឲ្យមានចារឹកជាពេញលក្ខណៈតាមផ្លូវច្បាប់ ដែលតែងតែមានដល់លិខិតរបស់រាជការគាន់អំណាចសាធារណៈ ។

២– ធ្វើបញ្ជាក់កាលបរិច្ឆេទនៃលិខិតនេះ ទទួលរក្សាលិខិតនេះ ទុកនឹងចេញឲ្យសេចក្ដីដើម ឬសេចក្ដីចំឡងលិខិតនេះ ។

ករណីយកិច្ចជាដើមរបស់សារៈការី គឺត្រូវបំភ្លឺ, ឲ្យដំណឹងនឹងទូន្មានគូសញ្ញាអំពីលិខិត ដែលអ្នកនេះបានធ្វើ ឬមានបំណងនឹងធ្វើ ហើយដោយខ្លួនជាមន្ត្រីសាធារណៈ

ត្រូវពិនិត្យឲ្យដឹងថា សេចក្តីកត់ចុះក្នុងលិខិតទាំងនោះត្រឹមត្រូវតាមការពិត ។ ក្នុងករណីណាក៏ដោយមន្ត្រីនេះមិនអាចបំរាស់ពីការខុសត្រូវ ដោយថាខ្លួនគ្រាន់តែទទួលកត់តាមសេចក្តី ឬកត់តាមលិខិតរបស់គូសញ្ញាដោយឥតល្អៀងដើម្បីឲ្យពេញតាមលក្ខណៈច្បាប់ទេ ។

មាត្រា ២.— ព្រះរាជក្រមនេះ មិនធ្វើឲ្យខូចសិទ្ធិគូសញ្ញាណាដែលសុខចិត្តឲ្យអ្នករាជការ បញ្ជាក់លិខិតតាមទម្រង់ការដែលមានបញ្ញត្តនៅមាត្រា ៩៤៤ និងមាត្រាតទៅទៀតនៃច្បាប់ក្រមរដ្ឋប្បវេណី ព្រមទាំងគ្មានធ្វើឲ្យខូចផលនៃការបញ្ជាក់លិខិតនេះនោះឡើយ ។

មាត្រា ៣— ប៉ុន្តែតទៅមុខទៀត មានតែសារៈការីទេ ដែលអាចបញ្ជាក់តាមទម្រង់ការមុខក្រសួងខ្លួន នូវលិខិតគ្រប់ប្រភេទបើកាលណាលិខិតនេះ មានចុះទឹកប្រាក់ចំនួនស្មើនឹងលើសពី ២០០.០០០ រៀល ។

ពី ៥០,០០០ ទៅ ២០០ ០០០ រៀល ចៅហ្វាយស្រុកដែលមានសមត្ថកិច្ចតាមនាទី គឺស្រុកដែលជាទីកន្លែងអសង្ហារិមៈ ឬជាទីលំនៅគូសញ្ញាណាមួយអាចធ្វើសេចក្តីបញ្ជាក់បាន ។

ចុះពី ៥០.០០០ រៀលមក ការបញ្ជាក់ធ្វើបានតាមកិច្ចស្ម័គ្រគូសញ្ញា គឺមេឃុំ ឬចៅហ្វាយស្រុកតាមបញ្ញត្តិវគ្គទី ១ និងទី ២ នៃមាត្រា ៩៤៥ ក្រមរដ្ឋប្បវេណីក៏បាន ឬសារៈការីក៏បាន ។

បទបញ្ញត្តខាងដើមនៃមាត្រា ៣ នេះ ត្រូវបង្កើតទៅជាវគ្គទី ៣-៤-និង ៥ នៃមាត្រា ៩៤៥ ក្រមរដ្ឋប្បវេណី មួយទៀតពាក្យជាលំដាប់ខាងក្រោយនេះ ត្រូវបន្ថែមតពីសេចក្តីបញ្ចប់វគ្គទី ១ នៃមាត្រា ៩៤៥ :

"តែត្រូវទុកសិទ្ធិ ឬការផ្តាច់មុខ ដែលមានសំដែងក្នុងមាត្រានេះដើម្បីជាប្រយោជន៍ឲ្យមន្ត្រីសាធារណៈឯទៀត" ។

ពាក្យដូចខាងក្រោយនេះ ត្រូវបន្ថែមនៅខាងមុខវគ្គទី ២ នៃមាត្រា ៩៤៩ :

"ប៉ុន្តែកុំបីឲ្យសៅហ្មងដល់សិទ្ធិនឹងការផ្តាច់មុខ ដែលសារៈការីមានសមត្ថកិច្ចត្រូវមានផង (កាតនៅសល់គ្មានកែប្រែ) ។

មាត្រា ៤.— តទៅមុខ ច្បាប់អាចដាក់កំហិតឲ្យចុះបញ្ជាក់ចំពោះមុខសារៈការីតាមការតព្វកិច្ច នូវកិច្ចសន្យាណាដែលច្បាប់បានកាយឈ្មោះតាមកំរិត ។ ចំណែកកិច្ចសន្យាស្តីពីបញ្ចាំដាក់អសង្ហារិមៈជាធានា ដែលមាត្រា ១៣៦៥ នៃក្រមរដ្ឋប្បវេណីបញ្ញត្តថា ឲ្យចុះសេចក្តីបញ្ជាក់តាមលក្ខណៈច្បាប់បាក់ង ត្រូវបញ្ជាក់នៅចំពោះមុខសារៈការីដែរ បើពុំនោះទេកិច្ចសន្យានេះគ្មានតំលៃត្រូវនឹងផ្លូវច្បាប់ ។

មួយទៀត ការមិនត្រូវធ្វើឲ្យខូចសិទ្ធិដែលមានមកហើយជារៀបរយ ទាំងសិទ្ធិដែលព្រមបើកឲ្យភ្នាក់ងារកុងស៊ុល ឬភ្នាក់ងារទូតដែលតាំងនៅអមព្រះរាជរដ្ឋាភិបាលឲ្យប្រតិបត្តិការជាសារៈការី ក្នុងព្រំដែនច្បាប់អន្តរជាតិ ឬក្នុងព្រំដែនអនុសញ្ញាទូតដែលរដ្ឋាភិបាលនៃភ្នាក់ងារនេះបានធ្វើជាមួយនឹងព្រះរាជរដ្ឋាភិបាល ។

ព្រះរាជរដ្ឋាភិបាល អាចប្រគល់អំណាចឲ្យទូត ឬកុងស៊ុលប្រទេសខ្មែរនៅបរទេសឲ្យកាន់ការជាសារៈការី តាមទម្រង់ការដែលមានបញ្ញត្តក្នុងច្បាប់ខ្មែរ ចំពោះកិច្ចសន្យាទាំងអស់ ដែលមានខ្មែរជាគូសញ្ញា ។ ប៉ុន្តែការសុំឲ្យភ្នាក់ងារបញ្ជាក់លិខិតនោះ មិនមែនត្រូវបង្ខំទៅលើជនខ្មែរទេ ជនខ្មែរនេះអាចមានសេរីភាព នឹងឲ្យរាជការកាន់អំណាចមានសមត្ថកិច្ចនៃប្រទេសដែលខ្លួននៅ ធ្វើលិខិតបេញច្បាប់ឲ្យខ្លួនបាន ។

មាត្រា ៥.— ដោយអនុវត្តន៍តាមបទបញ្ញត្តខាងលើ មាត្រា ៩៦១ នៃក្រមរដ្ឋប្បវេណីត្រូវទុកជាមោឃៈ ហើយត្រូវយកសេចក្តីដូចតទៅនេះជំនួសវិញ ៖

"មាត្រា ៩៦១.— ត្រូវទុកដូចជាលិខិតដែលត្រូវបញ្ជាក់ ក្រៅពីលិខិតដែលមានបញ្ញត្តនៅមាត្រា ៩៤៤ នឹងមាត្រាតទៅទៀត :

ថតចម្លង
បណ្ណសារដ្ឋានជាតិ



មាត្រា ៧.- បេក្ខជនដែលសុំកាន់តំណែងជាសារៈការី ត្រូវមានសញ្ជាតិជាខ្មែរ មានសិទ្ធិជាពលរដ្ឋនិងនយោបាយ, មានអាយុ ៣០ ឆ្នាំយ៉ាងតិច និងមានសញ្ញាបត្រដែលមានសំដែងនៅវគ្គទី ២ និងទី ៣ នៃមាត្រានេះ ។

បេក្ខជនដែលមានបរិញ្ញាបត្រច្បាប់ ឬថ្នាក់បណ្ឌិត្យច្បាប់ ត្រូវបានហាត់ធ្វើការពីរឆ្នាំនៅក្នុងមន្ទីរសារៈការី ដែលតាំងនៅប្រទេសខ្មែរ ឬក្នុងប្រទេសណាមួយ ក្នុងសហភាពបារាំង ។

រយៈពេលហាត់ធ្វើការនេះ ត្រូវឡើងដល់ទៅបួនឆ្នាំ ចំពោះបេក្ខជនដែលមានសមត្ថភាពច្បាប់ ឬមានសញ្ញាបត្រស្មើនឹងនេះ ព្រមទាំងបេក្ខជនដែលមានសញ្ញាបត្រវិជ្ជាយុត្តិធម្មសាស្ត្រនិងសេដ្ឋសាស្ត្ររបស់ជាតិ ។

មាត្រា ៨.— ប៉ុន្តែជាអន្តរៈបញ្ញត្តិ

១ ១.— ហើយក្នុងកំឡុងពេលមិនលើសពីបីឆ្នាំ គិតពីថ្ងៃប្រកាសឲ្យប្រើនូវព្រះរាជក្រមនេះ ដោយឥតគិតអំពីលក្ខណៈហាត់ធ្វើការ រដ្ឋាភិបាលអាចតាំងឲ្យកាន់តំណែងជាសារៈការី ទាល់តែបេក្ខជនណាដែលបំពេញលក្ខណៈ, អាយុ, សញ្ជាតិ, និងសីលធម៌ពេញបរិបូណ៌តាមមាត្រា ៧— ហើយបើបេក្ខជននេះមានបរិញ្ញាបត្រច្បាប់ផង ។

១ ២ — បេក្ខជនណា ដែលមានត្រឹមតែសញ្ញាបត្រសមត្ថភាពច្បាប់ ឬមានសញ្ញាបត្រស្មើនឹងនេះ អាចតាំងក្នុងតំណែងសារៈការី ក្នុងកំណត់ពេលបួនឆ្នាំ បើប្រសិនជាបេក្ខជននេះ បំពេញលក្ខណៈ អាយុ, សញ្ជាតិ សីលធម៌ពេញបរិបូណ៌តាមធម្មតា លុះផុតរយៈពេលបួនឆ្នាំហើយ បេក្ខជននេះ ទុកជាបានបំពេញកាតព្វកិច្ចហាត់ធ្វើការហើយ ត្រូវតាំងបេក្ខជននេះអស់មួយជីវិត ។

១៣.— បេក្ខជនណាដែលគ្មានសញ្ញាបត្រ តែបានបញ្ជាក់ថាបានធ្វើវិជ្ជាជីវៈ ជាប់ប្រាំឆ្នាំក្នុងក្របខណ្ឌជាន់ខ្ពស់ ក្នុងរដ្ឋាភិបាលព្រះរាជាណាចក្រ អាចតាំងជាសារៈការីក្នុងរយៈពេលប្រាំឆ្នាំ ហើយបើតាំងជាថ្មីវិញបាន បើប្រសិនជាបេក្ខជននោះបានបំពេញ លក្ខណៈអាយុសញ្ជាតិ, និងសីលធម៌បរិបូណ៌ ។

បេក្ខជនអាចតាំងអស់ជីវិតបាន បើប្រសិនជាខ្លួនបានសញ្ញាបត្រសមត្ថភាពច្បាប់ ឬសញ្ញាបត្រស្មើនឹងនេះ ក្នុងរយៈពេលប្រាំឆ្នាំដែលបានតាំងខ្លួនជាបណ្តោះអាសន្ន ។ ការតាំងអស់មួយជីវិត មិនអាចធ្វើបាន បើសាមីខ្លួនមិនទាន់ធ្វើជាមេមន្ទីរសារៈការី បានប្រាំឆ្នាំទេ ។

មាត្រា៩.— ព្រះរាជក្រឹត្យតាំងសារៈការី ដែលធ្វើតាមសេចក្តីស្នើសុំនៃរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវកំរិតប្រាក់ធានា ដែលសាមីខ្លួនត្រូវបង់មុនទទួលសម្បថសច្ចា ។

ប្រាក់ធានានេះ ត្រូវកំរិតដូចខាងក្រោម ចំពោះអ្នកកាន់កាប់ទី ១ នៅមន្ទីរសារៈការី ដែលបង្កើតតាមវគ្គទី ១ មាត្រា ៦ នៃព្រះរាជក្រមនេះ ។

១.— ដាក់ប្រាក់ធានា ៥០០.០០០រៀល ក្នុងគណនីឃ្លាំងធនាគារ ឬគ្រឹះស្ថានបង្ការប្រាក់ ដែលរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុបានអនុញ្ញាត ។

២.— បញ្ជាក់ថាខ្លួនមានអសង្ហារិមៈ នៅប្រទេសខ្មែរផុតពាក់ព័ន្ធការធានាបញ្ចាំ ឬការបញ្ចាំទាំងអស់ អាចបញ្ចាំជាដំឡៃតិចតាមច្បាប់ ប្រហាក់ប្រហែលយ៉ាងតិច ១.០០០.០០០រៀល ។ មុននឹងទទួលសម្បថសច្ចា សាមីខ្លួនត្រូវដាក់បញ្ចាំអសង្ហារិមៈនេះ ជាប្រយោជន៍ឃ្លាំងជាដំឡៃ ១.០០០.០០០រៀល ។ កិច្ចសន្យាបញ្ចាំត្រូវធ្វើតាមបញ្ញត្តមាត្រា ១០ នៃព្រះរាជក្រមនេះ ។

១៣.- បេក្ខជនណាដែលគ្មានសញ្ញាបត្រ តែបានបញ្ជាក់ថាបានធ្វើវិជ្ជាជីវៈជាប់ប្រាំឆ្នាំក្នុងក្របខណ្ឌជាន់ខ្ពស់ ក្នុងរដ្ឋាភិបាលព្រះរាជអាណាចក្រ អាចតាំងជាសារៈការីក្នុងរយៈពេលប្រាំឆ្នាំ ហើយបើតាំងជាថ្មីវិញបាន បើប្រសិនជាបេក្ខជននោះបានបំពេញ លក្ខណៈអាយុសញ្ជាតិ, និងសីលធម៌បរិបូណ៌ ។

បេក្ខជនអាចតាំងអស់ជីវិតបាន បើប្រសិនជាខ្លួនបានសញ្ញាបត្រសមត្ថភាពច្បាប់ ឬសញ្ញាបត្រស្មើនឹងនេះ ក្នុងរយៈពេលប្រាំឆ្នាំដែលបានតាំងខ្លួនជាបណ្ដោះអាសន្ន ។ ការតាំងអស់មួយជីវិត មិនអាចធ្វើបាន បើសាមីខ្លួនមិនទាន់ធ្វើជាមេមន្ទីរសារៈការីបានប្រាំឆ្នាំទេ ។

មាត្រា៩.- ព្រះរាជក្រឹត្យតាំងសារៈការី ដែលធ្វើតាមសេចក្ដីស្នើសុំនៃរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវកំរិតប្រាក់ធានា ដែលសាមីខ្លួនត្រូវបង់មុនទទួលសម្បថសច្ចា ។

ប្រាក់ធានានេះ ត្រូវកំរិតដូចខាងក្រោម ចំពោះអ្នកកាន់កាប់ទី ១ នៅមន្ទីរសារៈការី ដែលបង្កើតតាមវគ្គទី ១ មាត្រា ៦ នៃព្រះរាជក្រមនេះ ។

១.- ដាក់ប្រាក់ធានា ៥០០.០០០ រៀល ក្នុងគណនីឃ្លាំងធនាគារ ឬគ្រឹះស្ថានបង់ការប្រាក់ ដែលរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុបានអនុញ្ញាត ។

២.- បញ្ជាក់ថាខ្លួនមានអសង្ហារិមៈ នៅប្រទេសខ្មែរផុតបាតពីការធានាបញ្ចាំ និងការបញ្ចាំទាំងអស់ អាចបញ្ចាំជាដំឡៃគិតតាមក្បួន ប្រថាប់ត្រាបានយ៉ាងតិច ១.០០០.០០០ រៀល ។ មុននឹងទទួលសម្បថសច្ចា សាមីខ្លួនត្រូវដាក់បញ្ចាំអសង្ហារិមៈនេះ ជាប្រយោជន៍ឃ្លាំងជាដំឡៃ ១.០០០.០០០ រៀល ។ កិច្ចសន្យាបញ្ចាំត្រូវធ្វើតាមបញ្ញត្តមាត្រា ១០ នៃព្រះរាជក្រមនេះ ។

## ៣.— កាតព្វកិច្ច សិទ្ធិសារៈការី

មាត្រា ១០.— សារៈការី គ្មានសមត្ថកិច្ចនឹងទទួលលិខិត ដែលខ្លួន បងប្អូនខ្លួន, ញាតិពន្ធុត្រង់ ឬសាខាញាតិរហូតដល់ថ្នាក់មានកម្រិតទាំងថ្នាក់នេះផង ត្រូវធ្វើជាគូសញ្ញា ឬលិខិតដែលមានបញ្ញត្ត ថាត្រូវឲ្យផលប្រយោជន៍ដល់ខ្លួន ឬបងប្អូននេះទេ ។

ជនដែលមានសំដែងនៅវគ្គខាងលើ ត្រូវតាំងហ្មាងសាលាជំរះក្តីបើកអនុញ្ញាតឲ្យទៅពឹងរកសារៈការីឯទៀត ដែលគ្មានសមត្ថកិច្ចតាមនាទីទេ ។

បើមានសារៈការីតែមួយនៅប្រទេសខ្មែរ ឬក្នុងករណីដែលសារៈការីទាំងអស់ នៅក្នុងទុកទេបញ្ញត្តវគ្គខាងលើនៃមាត្រានេះ តាំងហ្មាងផ្នែករដ្ឋប្បវេណីសាលាជំរះក្តីនៅភ្នំពេញ ត្រូវតាំងចៅហ្វាយស្រុកដែលយល់ឃើញថាគួរតាមសាលក្រមដែលធ្វើឡើងតាមពាក្យសុំ ដែលបញ្ជូនមកពីមន្ត្រីស្តីការនៃរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ អ្នកធ្វើការនេះប្រតិបត្តិការដូចជាសារៈការីតាមទម្រង់ការដូចគ្នា ហើយមានអំណាចនឹងបានប្រាក់បំណាច់ដូចសារៈការីដែរ ។

មាត្រា ១១.— ក្នុងលិខិតទាំងឡាយ ដែលគូសញ្ញាទាំងអស់ឬតែមួយមិនអាចចុះហត្ថលេខាបាននោះ ត្រូវយកសាក្សីពីរនាក់ពេញនីតិភាពនឹងពេញសិទ្ធិឲ្យចុះហត្ថលេខាបាន ។

មាត្រា ១២.— ក្នុងលិខិតទាំងឡាយណា ដែលមានគូសញ្ញាមួយនាក់ឬច្រើននាក់ មានសញ្ជាតិជាជនបរទេស សារៈការីត្រូវមានអ្នកប្រែភាសាជាជំនួយ មានភាសាបរទេសប៉ុន្មាន ត្រូវមានអ្នកប្រែភាសាប៉ុណ្ណោះ ។

មាត្រា ១៣.— មុននឹងចូលកាន់មុខក្រសួង សារៈការីត្រូវទទួលសម្បថសច្ចានៅចំពោះមុខអស់ក្រុមជំនុំនៃសាលាឧទ្ធរណ៍ ។ រូបមន្ត ពាក្យសម្បថមានដូចតទៅនេះ

" ខ្ញុំសូមសច្ចាប្រណិធានថា រាល់តែឱកាស ខ្ញុំប្រព្រឹត្តជាមន្ត្រីសាធារណៈមួយល្អ និងគោរពច្បាប់ និងលាក់បំបិទបំបាំងនូវការសម្ងាត់ នៃរឿងដែលខ្ញុំទទួលជាដរាប បើទុកជាខ្ញុំឈប់លែងធ្វើការទៅក៏ដោយ" ។

មាត្រា ១៤.— សារៈការីត្រូវនៅក្រោមរបៀបគ្រប់គ្រងច្បាប់វិន័យនៃសមាជិកក្រុមមេធាវី ។ ក្នុងករណីដែលមានធុរៈ ឬមានជម្ងឺ, មន្ត្រីនេះត្រូវចាត់ឱ្យធ្វើការមុខក្រសួងក្នុងមន្ទីរខ្លួន ដោយខ្លួនទទួលខុសត្រូវ ។ ក្នុងករណីមរណៈភាព, លាឈប់, បញ្ឈប់ ឬបណ្តេញពីមុខក្រសួង, រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវតាំងអ្នកកាន់កាប់បណ្តោះអាសន្ន ឲ្យកាន់កាប់មន្ទីរសារៈការីនេះ អ្នកកាន់កាប់នេះ ត្រូវទទួលសម្បថសច្ចាដែលមានបញ្ញត្តនៅមាត្រា ១៣ មុននឹងចូលដំណែង ។ អ្នកកាន់កាប់នេះ ត្រូវបំពេញលក្ខណៈតាមបញ្ញត្តដើម្បីតាំងជាសារៈការី លើកលែងតែប្រាក់ធានាចេញ ។

មាត្រា ១៥.— សារៈការីត្រូវតែទទួលការ កាលណាបើមានគេមកសុំ លើកលែងតែករណីដែលមានសំដែងនៅមាត្រា ១០ ឬកាលណាបើគូសញ្ញាទាំងអស់ ឬមួយណាជាជនវិកលលក្ខណៈគ្មាននីតិសម្បទា, បើកាលណាលិខិតមិនត្រឹមត្រូវតាមគន្លងច្បាប់ បើកាលណាគូសញ្ញាមិនបានបង់ប្រាក់ថ្លៃប្រថាប់ត្រា និងថ្លៃឈ្នួល បើមន្ត្រីនេះ មិនស្គាល់គូសញ្ញា ហើយគូសញ្ញានេះមិនអាចបង្ហាញនូវអត្តសញ្ញាណប័ណ្ណខ្លួនដោយសំបុត្រស្នាម ឬដោយយកសាក្សីពីរនាក់បាន ឬជាអវិសាន បើកាលណាសារៈការី មិនអាចនឹងទទួលរកបាន ដោយមានហេតុជៀសវាងមិនរួច ។

មាត្រា ១៦ — ប្រាក់បំណាច់ជាប្រយោជន៍សារៈការី ដែលបានមកអំពីប្រាក់ថ្លៃឈ្នួល ត្រូវនៅក្នុងរបៀបគ្រប់គ្រងបទបញ្ញត្ត ដែលមានប្រើមកត្រឹមថ្ងៃទី ២៩ សីហា គ.ស. ១៩៥៣ លើកលែងតែមានព្រះរាជក្រឹត្យកែប្រែដែលធ្វើឡើងដោយការជំនុំនៃគណៈរដ្ឋមន្ត្រី ។

មាត្រា ១៧.– បើមានចេញព្រះរាជក្រឹត្យមួយទៅថ្ងៃក្រោយ ដើម្បីនឹងបញ្ញត្ត ពីបែបបទ ដែលត្រូវត្រួតត្រាលើសារៈការី ។

មាត្រា ១៨.– រហូតដល់ពេលប្រកាសឲ្យប្រើអត្ថបទជាតិ ដែលរដ្ឋាភិបាលអាចតាំងឡើងតាមព្រះរាជក្រឹត្យ មុខក្រសួងសារៈការី ត្រូវគោរពតាមបទបញ្ញត្តនៃដេក្រេ ចុះថ្ងៃទី ២៤ សីហា គ.ស. ១៩២១ និងអត្ថបទបារាំងទាំងអស់ ដែលមិនផ្ទុយនឹងព្រះរាជក្រមនេះ ហើយដែលបានប្រកាសឲ្យប្រើជាត្រឹមត្រូវនៅកម្ពុជា ត្រឹមថ្ងៃទី ២៩ សីហា គ.ស. ១៩៥៣ ។

មានការប្រែប្រួលរក់សារដែលនៃសារៈការីជាដើម និងទម្រង់លិខិតការទុកដាក់ និងការរៀបចំណាំនិងលិខិតដើម ការកាន់សៀវភៅនិងបញ្ជី ។

ប៉ុន្តែសារៈការី គ្មានអំណាចនឹងសុំឲ្យរដ្ឋាភិបាលតាំងអ្នកជំនួសទេ តាមព្រំដែននៃព្រះរាជក្រមនេះ រដ្ឋាភិបាលមានឥស្សរភាពនឹងតាំងជនណាដែលយល់ថាគួរ ។

ធ្វើនៅព្រះបរមរាជវាំងក្រុងភ្នំពេញ, នៅថ្ងៃ ៥ ១២ ឆ្នាំមមីសក័ ព.ស. ២៤៩៧ ត្រូវនឹងថ្ងៃទី ៤ វិច្ឆិកា គ.ស. ១៩៥៤ ។

ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង
ទ្រង់ឡាយព្រះហស្តលេខាហើយៈ
ណ. សីហនុ

---

ព្រះរាជក្រមលេខ ៩២២–ន.ស.

បានទ្រង់យល់ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រ ។

បានទ្រង់យល់ ព្រះរាជក្រមលេខ ១៧១-ន ស. ចុះថ្ងៃទី ១៥ មេសា គ.ស. ១៩៤៦ ស្ដីពីមុខក្រសួងនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីទាំងឡាយ ។

# ឧបសម្ព័ន្ធទី៤
# ច្បាប់ស្តីពីបណ្ណសារ

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងកំណត់ការគ្រប់គ្រងនិងការថែរក្សាបណ្ណសារដែលជាឯកសារប្រវត្តិសាស្ត្រ និងបញ្ជាក់សិទ្ធិរបស់រូបវន្តបុគ្គល ឬ នីតិបុគ្គលនៃនីតិសាធារណៈ ឬ នីតិឯកជន សម្រាប់បម្រើការស្រាវជ្រាវសំដៅជំរុញការអភិវឌ្ឍន៍ជាតិ ។

**មាត្រា ២.-**

វាក្យសព្ទដែលប្រើក្នុងច្បាប់នេះមាននិយមន័យដូចតទៅ :

១-បណ្ណសារ សំដៅឯកសារទាំងឡាយទោះបីស្ថិតក្នុងកាលបរិច្ឆេទក្នុងទម្រង់ ឬ ប្រភេទបែបណាក៏ដោយ ដែលរូបវន្តបុគ្គល ឬ នីតិបុគ្គលនៃនីតិសាធារណៈ ឬ នីតិឯកជនបានបង្កើតឡើង ឬ បានទទួលក្នុងការបំពេញសកម្មភាពរបស់ខ្លួន ។

២-បណ្ណសារសាធារណៈ សំដៅបណ្ណសាររដ្ឋបាលដែលក្នុងនោះមានបណ្ណសារចរន្ត អន្តរបណ្ណសារ និងបណ្ណសារស្ថាពរ ។

៣-បណ្ណសារដ្ឋានជាតិនៃកម្ពុជា សំដៅមជ្ឈមណ្ឌលតម្កល់បណ្ណសារដែលស្ថិតនៅក្រោមឱវាទទីស្តីការគណៈរដ្ឋមន្ត្រី ។

៤-បណ្ណសារឯកជន សំដៅឯកសារទាំងឡាយដែលបានបង្កើតឡើង ឬបានទទួលដោយរូបវន្តបុគ្គល ឬ នីតិបុគ្គលនៃនីតិឯកជន ។

៥-ហ្វុង សំដៅបណ្តុំបណ្ណសារដែលក្រសួង ស្ថាប័ន ខេត្ត ក្រុង គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ រូបវន្តបុគ្គល ឬ នីតិបុគ្គលណាមួយបានបង្កើតឡើង ឬ បានទទួល ។

៦-ដែនហ្វុង សំដៅផ្នែកមួយនៃហ្វុង ដែលអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន ខេត្ត ក្រុង គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ រូបវន្តបុគ្គល ឬ នីតិបុគ្គលណាមួយបានបង្កើតឡើង ឬ បានទទួល ។

**មាត្រា ៣.-**

បណ្ណសារដែលត្រូវរក្សាទុកជាស្ថាពរនៅបណ្ណសារដ្ឋានជាតិនៃកម្ពុជា ត្រូវបានចាត់ទុកជាបេតិកភណ្ឌជាតិ ។

## ជំពូកទី ២

## លក្ខណៈនៃបណ្ណសារសាធារណៈ

**មាត្រា ៤.-**

បណ្ណសារសាធារណៈមិនត្រូវបានរឹបអូស ផ្ទេរ ឬ ជួញដូរ និងគ្មានអាជ្ញាយុកាល ។

ក្នុងករណីដែលបណ្ណសារសាធារណៈ ស្ថិតក្នុងដៃរូបវន្តបុគ្គល ឬ នីតិបុគ្គលនៃនីតិឯកជនណាមួយ រដ្ឋអាចទាមទារយកឯកសារទាំងនោះមកវិញបានគ្រប់ពេលវេលា ។

## ជំពូកទី ៣

## ការរៀបចំ និងការថែរក្សាបណ្ណសារសាធារណៈ

**មាត្រា ៥.-**

ការរៀបចំ និងការថែរក្សាបណ្ណសារសាធារណៈស្ថិតក្រោមនិវាទទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានបណ្ណសារដ្ឋានជាតិនៃកម្ពុជា ជាអ្នកទទួលបន្ទុក ។

ក្រៅពីតួនាទីប្រមូល ទទួល គ្រប់គ្រង ថែរក្សា សិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយ បណ្ណសារសាធារណៈ បណ្ណសារដ្ឋានជាតិនៃកម្ពុជាមានភារកិច្ចត្រួតពិនិត្យនិងធ្វើការណែនាំការងារតម្កល់បណ្ណសារសាធារណៈនៅតាមក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈ ។

**មាត្រា ៦.-**

ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិមានភារកិច្ចប្រមូល រៀបចំ ថែរក្សាបណ្ណសារសាធារណៈរបស់ខ្លួនផ្ទាល់និងបណ្ណសារសាធារណៈនៅតាមបណ្តាអង្គភាពក្រោមនិវាទ ។

ɤ



5/12

**មាត្រា ៧.-**

ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ត្រូវប្រមូល រៀបចំ ថែរក្សា និង បម្រើឱ្យការស្រាវជ្រាវបណ្ណសារសាធារណៈរបស់ខ្លួន ។

## ជំពូកទី ៤

## ការគ្រប់គ្រងបណ្ណសាររដ្ឋបាល

**មាត្រា ៨.-**

បណ្ណសារចរន្ត ជាឯកសារដែលក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ ឬគ្រឹះស្ថានឯកជន សហគ្រាសឯកជន ដែលទទួលបន្ទុកបម្រើសេវាសាធារណៈបានបង្កើត ឬ បានទទួលនិងដែលកំពុងប្រើប្រាស់ក្នុងសកម្មភាពការងារនៅឡើយ ។

បណ្ណសារចរន្តត្រូវបានគ្រប់គ្រង និងថែរក្សាដោយក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ នីតិបុគ្គលនៃនីតិសាធារណៈ ឬ នីតិបុគ្គលនៃនីតិឯកជនដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ។

**មាត្រា ៩.-**

អន្តរបណ្ណសារ ជាឯកសារដែលលែងចាត់ទុកថាជាបណ្ណសារចរន្តត្រូវបានគ្រប់គ្រងនិងថែរក្សាដោយបណ្ណសារដ្ឋានរបស់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ ឬគ្រឹះស្ថានឯកជន សហគ្រាសឯកជនដែលទទួលបន្ទុកបម្រើសេវាសាធារណៈ ។

**មាត្រា ១០.-**

បណ្ណសារស្ថាពរ ជាឯកសារដែលបានឆ្លងកាត់ការវាយតម្លៃ និងចាត់ទុកថាជាឯកសារប្រវត្តិសាស្ត្រសម្រាប់បម្រើផលប្រយោជន៍សាធារណៈត្រូវបានថែរក្សាទុកនៅបណ្ណសារដ្ឋានជាតិនៃកម្ពុជា ដោយមិនកំណត់រយៈពេល ។

**មាត្រា ១១.-**

ការជ្រើសរើស និងការបំផ្លាញចោលអន្តរបណ្ណសារនៅតាមក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ ឬ គ្រឹះស្ថានឯកជន សហគ្រាសឯកជន ដែលទទួលបន្ទុកបម្រើសេវាសាធារណៈ និងការប្រគល់បណ្ណសារសាធារណៈត្រូវអនុវត្តតាមការណែនាំរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ១២.-**

ការចំណាយក្នុងការរៀបចំ ការគ្រប់គ្រង និងការថែរក្សាបណ្ណសារ ជាបន្ទុកថវិការបស់ក្រសួង ស្ថាប័នជាអាណាព្យាបាល និងជាបន្ទុកថវិការបស់គ្រឹះស្ថានសាធារណៈ ឬសហគ្រាសសាធារណៈ ។

## ជំពូកទី ៥

## ការស្រាវជ្រាវបណ្ណសារសាធារណៈ

**មាត្រា ១៣.-**

បណ្ណសារសាធារណៈ ដែលជាប្រភេទឯកសារផ្សព្វផ្សាយត្រូវបានអនុញ្ញាតឱ្យសាធារណជនស្រាវជ្រាវ និងពិគ្រោះដើម្បីជាព័ត៌មានដោយគ្មានការហាមឃាត់ ។

ចំពោះបណ្ណសារសាធារណៈផ្សេងទៀត ត្រូវបានអនុញ្ញាតឱ្យស្រាវជ្រាវដោយសេរីក្រោយរយៈពេល ២០(ម្ភៃ)ឆ្នាំ គិតចាប់តាំងពីកាលបរិច្ឆេទនៃឯកសារ ឬគិតចាប់ពីថ្ងៃបញ្ចប់សំណុំរឿង ឬក្នុងករណីពិសេស ក្នុងរយៈពេលកំណត់ដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ ។

**មាត្រា ១៤.-**

ដើម្បីធានាការការពារអធិបតេយ្យជាតិ ការការពារសន្តិសុខជាតិ និងការការពារសិទ្ធិនៃការរស់នៅរបស់បុគ្គលម្នាក់ៗ បណ្ណសារសាធារណៈត្រូវអនុញ្ញាតឱ្យស្រាវជ្រាវបានក្រោយ

រយៈពេលកំណត់ដូចខាងក្រោម ៖

-៤០(សែសិប)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃឯកសារ ឬគិតចាប់ពីថ្ងៃបញ្ចប់សំណុំរឿង ចំពោះឯកសារដែលប៉ះពាល់ដល់វិស័យការពារជាតិ សន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងសៀវភៅអត្រានុកូលដ្ឋាន លិខិតសារការី និងសំណុំរឿងក្តី ។

ចំពោះឯកសារដែលប៉ះពាល់ដល់វិស័យការពារជាតិ សន្តិសុខជាតិ និង សណ្តាប់ធ្នាប់សាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យ ។

-១២០(មួយរយម្ភៃ)ឆ្នាំ គិតចាប់តាំងពីថ្ងៃកំណើត ចំពោះសំណុំឯកសារផ្ទាល់ខ្លួន និង សំណុំឯកសារផ្នែកវេជ្ជសាស្ត្ររបស់បុគ្គលម្នាក់ៗ ។

**មាត្រា ១៥.-**

ដើម្បីបម្រើឱ្យផលប្រយោជន៍សាធារណៈ រាជរដ្ឋាភិបាលអាចសម្រេចកាត់បន្ថយរយៈពេលកំណត់ ដើម្បីអនុញ្ញាតឱ្យធ្វើការស្រាវជ្រាវចំពោះហ្វុង ឬ ផែនហ្វុងនៃហ្វុងណាមួយ ។

ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីសាមី ក្រសួង ស្ថាប័ន ដែលជាអ្នកបង្កើតបណ្ណសារសាធារណៈ បណ្ណសារដ្ឋានជាតិនៃកម្ពុជាអាចអនុញ្ញាតឱ្យស្រាវជ្រាវបណ្ណសារសាធារណៈ មុនរយៈពេលកំណត់ដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់នេះ ។

## ជំពូកទី ៦

## បណ្ណសារឯកជន

**មាត្រា ១៦.-**

បណ្ណសារដ្ឋានជាតិនៃកម្ពុជាអាចទិញ ទទួលជាអំណោយ ឬទទួលជាបញ្ញើនូវបណ្ណសារឯកជនដែលមានតម្លៃជាប្រវត្តិសាស្ត្រ ឬ ជាបេតិកភណ្ឌជាតិ ។

បណ្ណសារដ្ឋានជាតិនៃកម្ពុជាធានាការគ្រប់គ្រង និងការថែរក្សា ព្រមទាំងបម្រើឱ្យការស្រាវជ្រាវបណ្ណសារឯកជននានាបាន ដោយគោរពតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ។



8/12

**មាត្រា ១៧.-**

រូបវន្តបុគ្គល ឬ នីតិបុគ្គលនៃនីតិឯកជនត្រូវផ្តល់ឯកសារ ឬ សំណុំឯកសារមានតម្លៃជាប្រវត្តិសាស្ត្រ ឬ ជាបេតិកភណ្ឌជាតិចំនួនមួយច្បាប់ ដល់បណ្ណសារដ្ឋានជាតិនៃកម្ពុជាក្នុងពេលអនុវត្តសកម្មភាពរបស់ខ្លួននៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

ឯកសារ ឬ សំណុំឯកសារដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ៧

## ក្រុមប្រឹក្សាបណ្ណសារ

**មាត្រា ១៨.-**

ត្រូវបង្កើតឡើងនូវក្រុមប្រឹក្សាបណ្ណសារដែលមានភារកិច្ច :

-ធ្វើសំណើអំពីគោលនយោបាយក្នុងការគ្រប់គ្រងបណ្ណសារ

-កំណត់គោលការណ៍ និងនីតិវិធីក្នុងការជ្រើសរើស ការវាយតម្លៃ ការបំផ្លាញបោលអន្តរបណ្ណសារ ការរក្សាទុកបណ្ណសារស្ថាពរ និងអំពីរយៈពេលកំណត់ ក្នុងការប្រគល់នូវបណ្ណសារសាធារណៈ

-ផ្តល់យោបល់ទាក់ទងនឹងបណ្ណសារឯកជនដែលមានតម្លៃជាប្រវត្តិសាស្ត្រ ឬ ជាបេតិកភណ្ឌជាតិ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៨

## ទោសប្បញ្ញត្តិ

**មាត្រា ១៩.-**

មន្ត្រី ឬ បុគ្គលិករដ្ឋបាលទទួលបន្ទុកថែរក្សាបណ្ណសារសាធារណៈ ដែលបានផ្តល់ព័ត៌មានរំលោភលើបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់

ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ៤.០០០.០០០(បួនលាន)រៀល និងផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ទៅ ១(មួយ)ឆ្នាំ ពីបទរំលោភលើការសម្ងាត់វិជ្ជាជីវៈ ។

មន្ត្រី ឬបុគ្គលិករដ្ឋបាលទទួលបន្ទុកថែរក្សាបណ្ណសារសាធារណៈ ដែលបានផ្តល់ព័ត៌មានរំលោភលើបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ លើកលែងតែបណ្ណសារសាធារណៈដែលទាក់ទងនឹងវិស័យការពារជាតិ សន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៤.០០០.០០០(បួនលាន)រៀល ទៅ ៨.០០០.០០០ (ប្រាំបីលាន)រៀល និងផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ទៅ ៣(បី)ឆ្នាំ ពីបទរំលោភលើការសម្ងាត់វិជ្ជាជីវៈ ។

ក្នុងករណីបទល្មើសខាងលើដែលទាក់ទងនឹងវិស័យការពារជាតិ សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន)រៀល ទៅ២៥.០០០.០០០ (ម្ភៃប្រាំលាន)រៀល និងផ្តន្ទាទោសដាក់ពន្ធនាគារពី ៧(ប្រាំពីរ)ឆ្នាំ ទៅ ១៥ (ដប់ប្រាំ)ឆ្នាំ ។

ការសមគំនិត ឬ ការប៉ុនប៉ងក្នុងការប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រានេះ ត្រូវផ្តន្ទាទោសដូចគ្នា ។

**មាត្រា ២០.-**

មន្ត្រី ឬ បុគ្គលិករដ្ឋបាលដែលបានធ្វើឱ្យខូចគុណភាព តែបំបាត់ ជួញដូរ ឬ នាំចេញទៅបរទេសនូវបណ្ណសារសាធារណៈ ដោយរំលោភលើបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន)រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន)រៀល និងផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ទៅ ៣(បី) ឆ្នាំ ។

មន្ត្រី ឬ បុគ្គលិករដ្ឋបាលដែលបានធ្វើឱ្យខូចគុណភាព តែបំបាត់ ជួញដូរ ឬនាំចេញទៅបរទេសនូវបណ្ណសារសាធារណៈ ដោយរំលោភលើបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ លើកលែងតែបណ្ណសារសាធារណៈដែលទាក់ទងនឹងវិស័យការពារជាតិ សន្តិសុខជាតិ ឬ សណ្តាប់ធ្នាប់សាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន)រៀល ទៅ១០.០០០.០០០(ដប់លាន)រៀលនិងផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំ ។

ក្នុងករណីបទល្មើសខាងលើ ដែលទាក់ទងនឹងវិស័យការពារជាតិ សន្តិសុខជាតិ



10/18

ឬសណ្តាប់ធ្នាប់សាធារណៈត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១០.០០០.០០០(ដប់លាន)រៀល ទៅ ៥០.០០០.០០០(ហាសិបលាន)រៀល និងផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥(ដប់ប្រាំ)ឆ្នាំ ទៅ ៣០(សាមសិប)ឆ្នាំ ។

ការសមគំនិត ឬ ការប៉ុនប៉ងក្នុងការប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រានេះ ត្រូវផ្តន្ទាទោសដូចគ្នា ។

**មាត្រា ២១.-**

ជនណាដែលបានធ្វើឱ្យខូចគុណភាព បំផ្លាញ កែបំបាត់ ជួញដូរ ឬ នាំចេញទៅបរទេស នូវបណ្ណសារសាធារណៈ ដែលរក្សាទុកនៅក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បណ្ណសារដ្ឋានជាតិនៃកម្ពុជា គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ ឬ គ្រឹះស្ថានឯកជន សហគ្រាសឯកជនដែលទទួលបន្ទុកបម្រើសេវាសាធារណៈ ដោយរំលោភលើបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន)រៀល និងផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ទៅ ៣(បី)ឆ្នាំ ។

ជនណាដែលបានធ្វើឱ្យខូចគុណភាព បំផ្លាញ កែបំបាត់ ជួញដូរ ឬ នាំចេញទៅបរទេស នូវបណ្ណសារសាធារណៈ ដោយរំលោភលើបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ លើកលែងតែបណ្ណសារសាធារណៈ ដែលទាក់ទងនឹងវិស័យការពារជាតិ សន្តិសុខជាតិ ឬ សណ្តាប់ធ្នាប់សាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ ។

ក្នុងករណីបទល្មើសខាងលើ ដែលទាក់ទងនឹងវិស័យការពារជាតិ សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០(ហាសិបលាន)រៀល និងផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥(ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

ការសមគំនិត ឬ ការប៉ុនប៉ងក្នុងការប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រានេះ ត្រូវផ្តន្ទាទោសដូចគ្នា ។

**មាត្រា ២២.-**

មន្ត្រី បុគ្គលិករដ្ឋបាល ឬ ជនណាដែលបានធ្វើឱ្យខូចគុណភាព បំផ្លាញ គៃបំបាត់ ដូរជួរ ឬ នាំចេញទៅបរទេសនូវបណ្ណសារឯកជនដែលគ្រប់គ្រងដោយបណ្ណសារដ្ឋានជាតិនៃកម្ពុជា ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន) រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល និងផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ទៅ ៨ (ប្រាំបី)ឆ្នាំ ។

ការសមគំនិត ឬ ការប៉ុនប៉ងក្នុងការប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រានេះ ត្រូវផ្តន្ទាទោសដូចគ្នា ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ២៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៥

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

ពរល.០៥១០.៤៥២ នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា

សុខ អាន

លេខ: ៣៧៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវ តាន់

# ឧបសម្ព័ន្ធទី៥

# គំរូមតកសាសន៍ដោយលិខិតយថាភូត

(គំរូលិខិតមតកសាសន៍)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# លិខិតមតកសាសន៍

## ម្ចាស់បណ្តាំ

- នាម-គោត្តនាម ៖..............................ភេទ៖.....................ជនជាតិ៖ ......................................
- ថ្ងៃខែឆ្នាំកំណើត៖.........................................មុខរបរ៖.......................................................
- ទីកន្លែងកំណើត៖.............................................................................................................
- ឪពុកឈ្មោះ៖...........................................ម្តាយឈ្មោះ .......................................................
- ស្ថានភាពគ្រួសារ៖ ..........................................................................................................
- អត្តសញ្ញាណប័ណ្ណលេខ៖ ..................................................................................................
- សៀវភៅគ្រួសារលេខ៖ .....................................................................................................
- ទីលំនៅនច្ចុប្បន្ន៖ផ្ទះលេខ.........ផ្លូវ...............ភូមិ..............សង្កាត់..............ខណ្ឌ ...................រាជធានី/ខេត្ត.................។

## អច្ច័យលាភី

- នាម-គោត្តនាម ៖..............................ភេទ៖.....................ជនជាតិ៖ ......................................
- ថ្ងៃខែឆ្នាំកំណើត៖.........................................មុខរបរ៖.......................................................
- ទីកន្លែងកំណើត៖.............................................................................................................
- ឪពុកឈ្មោះ៖...........................................ម្តាយឈ្មោះ .......................................................
- ស្ថានភាពគ្រួសារ៖ ..........................................................................................................

- អត្តសញ្ញាណប័ណ្ណលេខ៖
  ............................................................................................................
- សៀវភៅគ្រួសារលេខ៖
  .................................................................................................................
- ទីលំនៅបច្ចុប្បន្ន៖ផ្ទះលេខ..........ផ្លូវ................ភូមិ...............សង្កាត់...............ខណ្ឌ
  ....................រាជធានី/ខេត្ត..................។

**សាក្សីទី១៖**

- នាម-គោត្តនាម ៖.................................ភេទ៖......................ជនជាតិ៖
  .......................................
- ថ្ងៃខែឆ្នាំកំណើត៖...........................................មុខរបរ៖..........................................................
- ទីកន្លែងកំណើត៖...................................................................................................................
- ឪពុកឈ្មោះ៖.............................................ម្តាយឈ្មោះ
  ...........................................................
- ស្ថានភាពគ្រួសារ៖
  ......................................................................................................................
- អត្តសញ្ញាណប័ណ្ណលេខ៖
  ............................................................................................................
- សៀវភៅគ្រួសារលេខ៖
  .................................................................................................................
- ទីលំនៅបច្ចុប្បន្ន៖ផ្ទះលេខ..........ផ្លូវ................ភូមិ...............សង្កាត់...............ខណ្ឌ
  ....................រាជធានី/ខេត្ត..................។

**សាក្សីទី២៖**

- នាម-គោត្តនាម ៖.................................ភេទ៖......................ជនជាតិ៖
  .......................................
- ថ្ងៃខែឆ្នាំកំណើត៖...........................................មុខរបរ៖..........................................................
- ទីកន្លែងកំណើត៖...................................................................................................................
- ឪពុកឈ្មោះ៖.............................................ម្តាយឈ្មោះ
  ...........................................................
- ស្ថានភាពគ្រួសារ៖
  ......................................................................................................................

- អត្តសញ្ញាណប័ណ្ណលេខៈ
  ...............................................................................................
- សៀវភៅគ្រួសារលេខៈ
  ...................................................................................................
- ទីលំនៅនាបច្ចុប្បន្នះផ្ទះលេខ..........ផ្លូវ................ភូមិ...............សង្កាត់...............ខណ្ឌ
  ....................រាជធានី/ខេត្ត..................។

សាក្សីបានអះអាងថាមិនមែនជាញាតិលោហិតខ្សែផ្ទាល់របស់ម្ចាស់បណ្តាំ។

**សារការីផ្តល់លិខិតយថាតួតលើលិខិតមតកសាសន៍**

ឈ្មោះ.....................ជាសារកី និងជា....(សមាសភាព និងនាករណ៍ស្ថាប័ន).........មានអាស័យដ្ឋាន នៅផ្ទះលេខ..........ផ្លូវ................ភូមិ...............សង្កាត់...............ខណ្ឌ....................រាជធានី/ខេត្ត ..................។

**I-អត្តន័យនៃបណ្តាំ**

..............................................................................................................................
..............................................................................................................................
..............................................................................................................................
......................

**II-សេចក្តីអះអាងរបស់សាក្សី**

..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................

III-អ្នកទទួលអច្ច័យទាន (ករណីដែលមានការចូលរួមពីសំណាក់អច្ច័យលាភី)

..............................................................................................................................
..............................................................................................................................
..............................................................................................................................
......................

IV-ការរៀបចំ និងការផ្តិតមេដៃលើលិខិតមតកសាសន៍

..................................................................................................................................................................................................................................................................................................................................................................................................................................

ហត្ថលេខាម្ចាស់បណ្តាំ                    ស្នាមមេដៃស្តាំអច្ច័យលាភី

..................................                    ..................................

ស្នាមមេដៃស្តាំសាក្សីទី១                    ស្នាមមេដៃស្តាំសាក្សីទី២

..................................                    ..................................

**លិខិតមតកសាសន៍នេះ ត្រូវបានពិនិត្យ និងធ្វើការបញ្ជាក់**
**ជាលិខិតយថាភូតដោយចុះបញ្ជី**

**លេខ.................................................**
**នៅមន្ទីសារការី....................................**
**ក្រោមការទទួលខុសត្រូវរបស់**
**សារការី...............................................**

**មានខ្លឹមសារបញ្ជាក់ដូចតទៅ ៖**

**១.សារការីបានពិនិត្យឯកសារច្បាប់ដើម្បមាន៖**

..................................................................................................................................................................................................................................................................................................................................................................................................................................

**២.សារការីបានធ្វើការកត់សម្គាល់បញ្ជាក់ឆន្ទៈរបស់ភាគីពាក់ព័ន្ធថា៖**

..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
......................

**៣.អត្ថបទច្បាប់**

..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
......................

**៤.មន្ទីសារការី.....................ទទួលលិខិតមតកសាសន៍នេះ តាមសំណើររបស់ម្ចាស់បណ្តាំតាមនីតិវិធីច្បាប់។**

លិខិតមតកសាសន៍នេះមានសុពលភាពអនុវត្ត
ចាប់ពីថ្ងៃ..........ខែ........ឆ្នាំ..........សំរិទ្ធិស័ក ព.ស.............
ត្រូវនឹងថ្ងៃទី............ខែ..........ឆ្នាំ................

(ហត្ថលេខា និងត្រា)
(ឈ្មោះសារការី)

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### លិខិតមរតកសាសន៍
### និងការប្រគល់សិទ្ធិឲ្យចាត់ចែងទ្រព្យបណ្ដោះអាសន្ន

**ម្ចាស់បណ្ណាំ និងជាអ្នកប្រគល់សិទ្ធិ**

- នាម-គោត្តនាម ៖ **ម្ចាស់បណ្ណាំ** ភេទ៖ប្រុស ជនជាតិ៖ ខ្មែរ
- ថ្ងៃខែឆ្នាំកំណើត ៖ ០៧-០៥-១៩៣៧ មុខរបរ៖ ពា
- ទីកន្លែងកំណើត ៖ សង្កាត់ លេខ៥ ក្រុងភ្នំពេញ
- ឪពុកឈ្មោះ ៖ **អៀ ឡាំ** ម្ដាយឈ្មោះ៖ **ឡាំ**
- ស្ថានភាពគ្រួសារ ៖ ពោះម៉ាយពីខ្មោចនាង **តាំង ស៊ីមទៀង** និងមានកូន០៧នាក់
- អត្តសញ្ញាណប័ណ្ណលេខ៖ ០១០៤២៦៨៨៣ (០១)
- សៀវភៅគ្រួសារលេខ៖០១.០២៥១៨២ ចុះថ្ងៃទី១៥-១០-២០១០
- ទីលំនៅបច្ចុប្បន្ន ៖ ផ្ទះលេខ១៦៩ ផ្លូវម៉ៅសេទុង ភូមិ០៥ សង្កាត់ទួលស្វាយ ព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**អ្នកទទួលអច្ច័យទាន និងជាអ្នកទទួលសិទ្ធិ**

- នាម-គោត្តនាម ៖ **សន្តិជន** ភេទ៖ប្រុស ជនជាតិ៖ខ្មែរ
- ថ្ងៃខែឆ្នាំកំណើត ៖ ០១-០៦-១៩៦២ មុខរបរ៖ពាណិជ្ជករ
- ទីកន្លែងកំណើត ៖ សង្កាត់លេខ៥ ក្រុងភ្នំពេញ
- ឪពុកឈ្មោះ ៖ **ម្ចាស់បណ្ណាំ** ម្ដាយឈ្មោះ៖ **តាំង ស៊ីមទៀង(ស្លាប់)**
- ស្ថានភាពគ្រួសារ ៖ ប្រពន្ធឈ្មោះ **ជាសារី** កូន៣នាក់
- កំរិតវប្បធម៌៖ ថ្នាក់ទីបញ្ចប់
- កាន់អត្តសញ្ញាណប័ណ្ណ០១០៧១៨៧២៦(០១)
- ទីលំនៅបច្ចុប្បន្ន ៖ ផ្ទះលេខ១៦៩ ផ្លូវម៉ៅសេទុង ភូមិ០៥ សង្កាត់ទួលស្វាយ ព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**សាក្សីទី១៖**

- នាម-គោត្តនាម ៖ **ជា ស៊ីថា** ភេទ៖ប្រុស ជនជាតិ៖ខ្មែរ
- ថ្ងៃខែឆ្នាំកំណើត ៖ ០៧-១០-១៩៥២ មុខរបរ៖ ពាណិជ្ជករ
- ទីកន្លែងកំណើត ៖ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល
- ឪពុកឈ្មោះ ៖ **ជា លី** ម្ដាយឈ្មោះ ៖ **ខូវ**
- ស្ថានភាពគ្រួសារ ៖ ពោះម៉ាយ កំរិតវប្បធម៌៖ ថ្នា
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ៖ ០១០១៤៨០៤៨(០១)

- ទីលំនៅបច្ចុប្បន្ន ៖ ផ្ទះលេខ២២៦អឺ០ ផ្លូវ៣៥៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**សាក្សីទី២៖**

- នាម-គោត្តនាម ៖ **លាង ស្រីទូច** ភេទ៖ស្រី ជនជាតិ៖ខ្មែរ
- ថ្ងៃខែឆ្នាំកំណើត ៖ ១០/០៣/១៩៨១ មុខរបរ៖ពាណិជ្ជករ
- ទីកន្លែងកំណើត ៖ សង្កាត់លេខ៥ ក្រុងភ្នំពេញ
- ឪពុកឈ្មោះ ៖ **លាង វ៉ាន់ថុន** ម្តាយឈ្មោះ ៖ **ឈឿង យ៉ុង**
- ស្ថានភាពគ្រួសារ ៖ មានគ្រួសារ កំរិតវប្បធម៌ ៖ បរិញ្ញាប័ត្រ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ៖ ០១០៦៧៥២០៣(០១)
- ទីលំនៅបច្ចុប្បន្ន ៖ ផ្ទះលេខ២២៨ ផ្លូវលេខ៣៥៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

សាក្សីបានអះអាងថាមិនមែនជាញាតិលោហិតខ្សែផ្ទាល់របស់ម្ចាស់បណ្តាំ ។

**សារការីផ្តល់យថាភូតលើលិខិតមតកសាសន៍**

បណ្ឌិត **ជាសារការី** និងជា**ប្រធានមន្ទីរសារការី** មានអាសយដ្ឋាននៅ ផ្ទះលេខ ១៣៥ CD ផ្លូវ១៩៩ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ។
ទូរស័ព្ទការិយាល័យ អ៊ីម៉ែល៖

**I-អត្ថន័យនៃបណ្តាំ និងការប្រគល់សិទ្ធិ**

ម្ចាស់បណ្តាំ និងជាអ្នកប្រគល់សិទ្ធិឲ្យគ្រប់គ្រងចាត់ចែងបណ្តោះអាសន្នរួមទាំងបំណុល និងពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរបស់ខ្លួន បានប្រកាសជាឱឡារិកជម្រាបជូន **សារការី** នូវទ្រព្យសម្បត្តិដែល ជាកម្មវត្ថុនៃបណ្តាំ និងការប្រគល់សិទ្ធិរបស់ខ្លួនរួមមាន៖

**ទ្រព្យសម្បត្តិផ្ទាល់ខ្លួន**

១ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ** ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ ទទួលស្គាល់ដោយម.រ.ដ.ន.ស **រាជធានីភ្នំពេញ**

២ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ** ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ទទួលស្គាល់ដោយម.រ.ដ.ន.ស **រាជធានីភ្នំពេញ**

៣ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ** ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ទទួលស្គាល់ដោយម.រ.ដ.ន.ស **រាជធានីភ្នំពេញ**

៤ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ** ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ទទួលស្គាល់ដោយម.រ.ដ.ន.ស **រាជធានីភ្នំពេញ**

៥ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ**

ទទួលស្គាល់ដោយម.រ.ដ.ន.ស **រាជធានីភ្នំពេញ**

៦ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ**

ទទួលស្គាល់ដោយម.រ.ដ.ន.ស **រាជធានីភ្នំពេញ**

៧ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ**

ទទួលស្គាល់ដោយម.រ.ដ.ន.ស **រាជធានីភ្នំពេញ**

៨ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ**

ទទួលស្គាល់ដោយម.រ.ដ.ន.ស **រាជធានីភ្នំពេញ**

៩ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ**

ទទួលស្គាល់ដោយម.រ.ដ.ន.ស **រាជធានីភ្នំពេញ**

១០- **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ**

ទទួលស្គាល់ដោយម.រ.ដ.ន.ស **រាជធានីភ្នំពេញ**

១១- ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ

ដោយម.រ.ដ.ន.ស **ខេត្តស្វាយរៀង**

១២- ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ

ទទួលស្គាល់ដោយម.រ.ដ.ន.ស **ខេត្តកណ្តាល**

១៣- លិខិតផ្ទេរសិទ្ធិកាន់កាប់ដី/ផ្ទះ របស់ឈ្មោះ ចុះ

ទទួលស្គាល់ដោយ

១៤- លិខិតផ្ទេរសិទ្ធិកាន់កាប់ដី/ផ្ទះ របស់ឈ្មោះ ចុះ

ទទួលស្គាល់ដោយ

១៥- លិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ របស់ឈ្មោះ ចុះថ្ងៃទី

ទទួលស្គាល់ដោយ

១៦- លិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ របស់ឈ្មោះ

ចុះថ្ងៃទី ទទួលស្គាល់ដោយ

## ទ្រព្យសម្បត្តិសហកម្មសិទ្ធិ

១ - ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ចុះថ្ងៃទី

ទទួលស្គាល់ដោយ

២ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី

ទទួលស្គាល់ដោយ

៣ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ
៤ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ
៥ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ
៦ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ
៧ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ
៨ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ
៩ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ
១០- វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

**ទ្រព្យសម្បត្តិជាក្រុមហ៊ុន**

**អាជីវកម្ម ក្រុមហ៊ុន**

ម្ចាស់បណ្តាំ បានបង្ហាញឆន្ទៈជាចុងក្រោយនៅចំពោះមុខសារការីមានខ្លឹមសារ ច្បាស់លាស់ថា"ម្ចាស់បណ្តាំបានសម្រេចចិត្តធ្វើអច្ច័យទាននូវទ្រព្យសម្បត្តិជាកម្មសិទ្ធិ និងសហកម្មសិទ្ធិរបស់ខ្លួនដែលមានទំហំ ទីតាំង និងមានឯកសារសម្គាល់ដូចបានបញ្ជាក់ខាងលើនេះ ឲ្យទៅអ្នកទទួលអច្ច័យទានដូចមានអត្តសញ្ញាណខាងលើ ធ្វើជាម្ចាស់កម្មសិទ្ធិ កាន់កាប់ទ្រព្យរបស់ខ្លួនបន្តបន្ទាប់ពីម្ចាស់បណ្តាំទទួលមរណភាព ។ ដោយឡែកចំពោះស្ថានភាពបច្ចុប្បន្នម្ចាស់បណ្តាំស្ថិតនៅក្នុងស្ថានភាពសុខភាពពុំល្អ ហេតុនេះបានសម្រេចចិត្តប្រគល់សិទ្ធិឲ្យអ្នកទទួលអច្ច័យទាន មានសិទ្ធិគ្រប់គ្រងលើអាជីវកម្មក្រុមហ៊ុន ដោះស្រាយបំណុលរបស់ក្រុមហ៊ុន និងចាត់ចែងលើទ្រព្យសម្បត្តិដើម្បីឲ្យក្រុមហ៊ុនដំណើរការបានល្អ ។ ក្រៅពីនេះម្ចាស់បណ្តាំបានអះអាងថាខ្លួនមានកូនចំនួន ដែលតាមច្បាប់មានសិទ្ធិទទួលមរតកពីខ្លួន ក៏ប៉ុន្តែខ្លួនបានសម្រេចចិត្តមិនធ្វើការបែងចែកបណ្តាំតាមច្បាប់ទេ គឺបែងចែកបណ្តាំតាមឆន្ទៈរបស់ខ្លួនដោយមានមូលហេតុថា កូនទាំង ផ្សេងទៀតមិនព្រមមកជួយការងាររបស់ម្ចាស់បណ្តាំនៅក្នុងប្រទេសកម្ពុជា ហើយរាល់ការងាររបស់ខ្លួនមានតែអ្នកទទួលអច្ច័យទានម្នាក់នេះប៉ុណ្ណោះ ដែលបានបំពេញការងារ ជួយដល់ម្ចាស់បណ្តាំ លើគ្រប់កិច្ចការទាំងអស់ ។

៣ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៤ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៥ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៦ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៧ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៨ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៩ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

១០- វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

**ទ្រព្យសម្បត្តិជាក្រុមហ៊ុន**

**អាជីវកម្ម ក្រុមហ៊ុន**

ម្ចាស់បណ្តាំ បានបង្ហាញឆន្ទៈជាចុងក្រោយនៅចំពោះមុខសារការីមានខ្លឹមសារ ច្បាស់លាស់ថា"ម្ចាស់បណ្តាំបានសម្រេចចិត្តធ្វើអច្ច័យទាននូវទ្រព្យសម្បត្តិជាកម្មសិទ្ធិ និងសហកម្មសិទ្ធិរបស់ខ្លួនដែលមានទំហំ ទីតាំង និងមានឯកសារសម្គាល់ដូចបានបញ្ជាក់ខាងលើនេះ ឲ្យទៅអ្នកទទួលអច្ច័យទានដូចមានអត្តសញ្ញាណខាងលើ ធ្វើជាម្ចាស់កម្មសិទ្ធិ កាន់កាប់ទ្រព្យរបស់ខ្លួនបន្តបន្ទាប់ពីម្ចាស់បណ្តាំទទួលមរណភាព ។ ដោយឡែកចំពោះស្ថានភាពបច្ចុប្បន្នម្ចាស់បណ្តាំស្ថិតនៅក្នុងស្ថានភាពសុខភាពពុំល្អ ហេតុនេះបានសម្រេចចិត្តប្រគល់សិទ្ធិឲ្យអ្នកទទួលអច្ច័យទាន មានសិទ្ធិគ្រប់គ្រងលើអាជីវកម្មក្រុមហ៊ុន ដោះស្រាយបំណុលរបស់ក្រុមហ៊ុន និងចាត់ចែងលើទ្រព្យសម្បត្តិដើម្បីឲ្យក្រុមហ៊ុនដំណើរការបានល្អ ។ ក្រៅពីនេះម្ចាស់បណ្តាំបានអះអាងថាខ្លួនមានកូនចំនួន៧នាក់ ដែលតាមច្បាប់មានសិទ្ធិទទួលមរតកពីខ្លួន ក៏ប៉ុន្តែខ្លួនបានសម្រេចចិត្តមិនធ្វើការបែងចែកបណ្តាំតាមច្បាប់ទេ គឺបែងចែកបណ្តាំតាមឆន្ទៈរបស់ខ្លួនដោយមានមូលហេតុថា កូន នាក់ផ្សេងទៀតមិនព្រមមកជួយការងាររបស់ម្ចាស់បណ្តាំនៅក្នុងប្រទេសកម្ពុជា ហើយរាល់ការងាររបស់ខ្លួនមានតែអ្នកទទួលអច្ច័យទានម្នាក់នេះប៉ុណ្ណោះ ដែលបានបំពេញការងារ ជួយដល់ម្ចាស់បណ្តាំ លើគ្រប់កិច្ចការទាំងអស់ ។





ការអនុវត្តលិខិតមតកសាសន៍នេះ នឹងត្រូវធ្វើឡើងដោយ **មន្ទីរសារការី** តាមនីតិវិធីច្បាប់ ដើម្បីឲ្យអច្ច័យទានទាំងអស់តាមម្ចាស់បណ្តាំទៅអ្នកទទួលអច្ច័យទាន ដោយពេញលេញ និងស្របតាមច្បាប់ ។

ម្ចាស់បណ្តាំបានយល់ព្រមផ្តិតមេដៃលើលិខិតមតកសាសន៍នេះ ទុកជាភស្តុតាងតាមច្បាប់ នៅចំពោះមុខសារការី ។

**II-សេចក្តីអះអាងរបស់សាក្សី**

សាក្សីទាំងពីររូបមានអត្តសញ្ញាណដូចខាងលើ ដែលបានយល់ព្រមធ្វើជាសាក្សីក្នុងលិខិតមតកសាសន៍ បានអះអាងដោយប្រាកដថា សាក្សីមិនមានជាប់ពាក់ព័ន្ធជាញាតិលោហិតខ្សែផ្ទាល់ជាមួយនឹងម្ចាស់បណ្តាំឡើយ ហើយយល់ព្រមផ្តល់ចម្លើយជាសាក្សីជូនសមត្ថកិច្ចពាក់ព័ន្ធនៅពេលដែលអនុវត្តខ្លឹមសារ នៃលិខិតមតកសាសន៍នេះថាម្ចាស់បណ្តាំពិតជាបានធ្វើបណ្តាំដោយស្ម័គ្រចិត្ត ដោយមានសមត្ថភាពពេញបរិបូរណ៍ ដោយមានសាក្សីដែលជារូបខ្លួនបានចូលរួមដឹងឮដោយផ្ទាល់ប្រាកដមែន។

**III-អ្នកទទួលអច្ច័យទាន**

អ្នកទទួលអច្ច័យទានដែលត្រូវជាកូនបង្កើតជាមួយម្ចាស់បណ្តាំ បានចូលរួម ការធ្វើបណ្តាំនេះនៅចំពោះមុខសារការី ហើយក៏បានយល់ព្រមផ្តិតមេដៃ នឹងទទួលយកនូវអច្ច័យទានជាអចលនទ្រព្យខាងលើ រួមទាំងទទួលសិទ្ធិដោះស្រាយ និងចាត់ចែងអាជីវកម្មក្រុមហ៊ុន និងដោះស្រាយបញ្ហាបំណុល រួមទាំងការចាត់ចែងលើទ្រព្យជាបណ្តោះអាសន្នក្នុងពេលបច្ចុប្បន្នតាមខ្លឹមសារ នៃលិខិតមតកសាសន៍នេះដោយពេញចិត្តពីម្ចាស់បណ្តាំ ។

**IV-ការរៀបចំ និងការផ្តិតមេដៃលើលិខិតមតកសាសន៍**

លិខិតមតកសាសន៍នេះ ត្រូវបានរៀបចំឡើងដោយ**មន្ទីរសារការី** ក្រោមការទទួលខុសត្រូវរបស់ លោក ជាសារការី អមដោយលោក ជាលេខាធិការកត់ត្រា និងវាយអក្សរ នៃបណ្តាំនេះ ។ លិខិតនេះ មានចំនួន ០៣ច្បាប់ ជាច្បាប់ដើម ធ្វើឡើងជាភាសាខ្មែរ និងត្រូវបានផ្តល់ជូនម្ចាស់បណ្តាំ ចំនួន ០១ច្បាប់ អ្នកទទួលអច្ច័យទានចំនួន ០១ច្បាប់ និងរក្សាទុកនៅ មន្ទីរសារការី លុច ស៊ីអេចឌី ចំនួន ០១ច្បាប់ សម្រាប់ប្រើប្រាស់តាមច្បាប់តទៅ ។

លិខិតមតកសាសន៍នេះ បន្ទាប់ពីរៀបចំ និងកែសម្រួលខ្លឹមសារច្បាស់លាស់រួច សារការីបានអានឲ្យម្ចាស់បណ្តាំ អ្នកទទួលអច្ច័យទាន និងសាក្សី ស្តាប់ និងអ្នកទាំង អស់គ្នាបានឆ្លើយតបមកវិញ នៅចំពោះមុខសារការីថា ខ្លឹមសារនៃលិខិតមតកសាសន៍ នេះពិតជាត្រឹមត្រូវតាមឆន្ទៈរបស់ខ្លួនទាំងស្រុង ហើយយល់ព្រមផ្តិតមេដៃលើលិខិតមតកសាសន៍នេះ នៅចំពោះមុខសារការី និងបានសរសេរឈ្មោះរបស់ខ្លួន រៀងខ្លួនៗ នៅលើលិខិតមតកសាសន៍នេះ ដោយសារការីបានចុះថ្ងៃខែឆ្នាំចំណាំតទៅ ។

ស្នាមមេដៃស្តាំអ្នកធ្វើបណ្តាំ



**ឈ្មោះ មាស់បណាំ**

ស្នាមមេដៃស្តាំអ្នកទទួលអច្ច័យទាន



**អច្ច័យលាភី**

ស្នាមមេដៃស្តាំសាក្សីទី ១



ស្នាមមេដៃស្តាំសាក្សីទី២



លិខិតមរតកសាសន៍នេះ ត្រូវបានពិនិត្យ និងធ្វើការបញ្ជាក់
ជាលិខិតយថាភូតដោយចុះបញ្ជី

**លេខ**
**នៅមន្ទីរសារការី**
ក្រោមការទទួលខុសត្រូវរបស់
**សារការី**

មានខ្លឹមសារបញ្ជាក់ដូចតទៅ ៖

១. សារការីបានពិនិត្យឯកសារច្បាប់ដើមរួមមាន៖

- អត្តសញ្ញាណប័ណ្ណឈ្មោះ ម្ចាស់បណ្តាំ
- អត្តសញ្ញាណប័ណ្ណឈ្មោះ អច្ច័យលាភី
- អត្តសញ្ញាណប័ណ្ណឈ្មោះ សាក្សីទី១
- អត្តសញ្ញាណប័ណ្ណឈ្មោះ សាក្សីទី២
- សៀវភៅស្នាក់នៅរបស់ឈ្មោះ ម្ចាស់បណ្តាំ
  ប័ណ្ណកម្មសិទ្ធិជាកម្មវត្ថុ នៃមរតកសាសន៍នេះ

២. សារការីធ្វើការកត់សម្គាល់បញ្ជាក់ឆន្ទៈរបស់ភាគីពាក់ព័ន្ធថា៖

ម្ចាស់បណ្តាំឈ្មោះ ម្ចាស់បណ្តាំ និងអ្នកទទួលអច្ច័យទានឈ្មោះ អច្ច័យលាភី រួមទាំងសាក្សីទាំងពីរនាក់ពិតជាបានយល់ព្រមដោយស្ម័គ្រចិត្តផ្តិតមេដៃលើលិខិតមរតកសាសន៍នេះ ទុកជាចំណាំតាមច្បាប់ តាមឆន្ទៈរៀងខ្លួន នៅចំពោះ មុខសារការី។

៣. **អត្ថបទច្បាប់**

សារការីបានបង្កើតលិខិតមរតកសាសន៍នេះ ដោយផ្អែកតាមមាត្រា ១១៦៩ មាត្រា ១១៧០ មាត្រា ១១៧១ មាត្រា១១៧២ មាត្រា ១១៧៣ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

៤. **មន្ទីរសារការី** ទទួលអនុវត្តលិខិតមតកសាសន៍នេះ តាមសំណើរបស់ ម្ចាស់បណ្តាំ និងរបស់អ្នកទទួលអច្ច័យទាន តាមនីតិវិធី និងច្បាប់ ។

៥. ការបង្កើតលិខិតមរតកសាសន៍នេះ អនុឡោមតាមអនុក្រឹត្យលេខ **(អនុក្រឹត ទទួលស្គាល់មន្ទីសារក** របស់រាជរដ្ឋាភិបាលកម្ពុជា ។

លិខិតមតកសាសន៍នេះមានសុពលភាពអនុវត្ត

ចាប់ពីថ្ងៃ ខែ ឆ្នាំ សំរឹទ្ធិស័ក ព.ស ២៥៦២

ត្រូវនឹងថ្ងៃទី ខែ ឆ្នាំ

**មន្ទីសារការី** (នាមករណ៍)

**សា រ កា រី**

(ហត្ថលេខា និងត្រា)

(ឈ្មោះ សារការី)

# ឧបសម្ព័ន្ធទី៦

# គំរូពាក្យស្នើសុំរូបមន្តអនុវត្ត

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំរូបមន្តអនុវត្ត

ខ្ញុំបាទឈ្មោះ ភេទប្រុស កើតឆ្នាំ១៩៦២ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ផ្លូវម៉ៅសេងទុង ភូមិ៥ មានទីលំនៅផ្ទះលេខ១៦៩ (០១)សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**សូមគោរពជូន**

**លោកបណ្ឌិត ឡូត លុច សារការីនៃមន្ទីរសារការី លុច ស៊ីអេចឌី**

**កម្មវត្ថុ ៖** ស្នើសុំរូបមន្តអនុវត្តនៃលិខិតមតកសាសន៍ លេខ០១៨/១៩ ចុះថ្ងៃទី២២-០២-២០១៩ របស់**មន្ទីរសារការី** ។

**យោង ៖** - លិខិតមតកសាសន៍ លេខ០១៨/១៩ ចុះថ្ងៃទី២២-០២-២០១៩ របស់**មន្ទីរសារការី**

- សំបុត្របញ្ជាក់មរណភាពលេខ.......... ចុះថ្ងៃទី............. របស់ឈ្មោះ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាប **លោកបណ្ឌិតសារការី** មេត្តាជ្រាបថា ឪពុកខ្ញុំបាទឈ្មោះ បានទទួលមរណភាពកាលពីថ្ងៃទី............ វេលាម៉ោង ........ ស្ថិតនៅ.... ។ ដោយហេតុថា ឪពុករបស់ខ្ញុំបាទឈ្មោះ បានធ្វើលិខិតមរតកសាសន៍មានខ្លឹមសារប្រគល់នូវទ្រព្យសម្បត្តិដូចមានចែងនៅក្នុងលិខិតមរតកសាសន៍ លេខ០១៨/១៩ ចុះថ្ងៃទី២២-០២-២០១៩ របស់**មន្ទីរសារការី** នេះស្រាប់ ។

ដូច្នេះ ខ្ញុំបាទស្នើសុំ **លោកបណ្ឌិតសារការី** មេត្តាផ្តល់ជូននូវរូបមន្តអនុវត្តដល់ខ្ញុំបាទ ដើម្បីយកទៅប្រើប្រាស់តាមនីតិវិធីច្បាប់ ។

សូម **លោកបណ្ឌិតសារការី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ ។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ពុទ្ធស័ករាជ ២៥៦៤

ត្រូវនឹងថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០

**ស្នាមមេដៃស្តាំ**

# ឧបសម្ព័ន្ធទី៧

# គំរូរូបមន្តអនុវត្ត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# រូបមន្តអនុវត្ត

**យើង បណ្ឌិត** **សារការីនៃមន្ទីរសារការី**

-**បានឃើញ** មាត្រា ៣៥០, មាត្រា៣៥៤, មាត្រា៣៥៥, និងមាត្រា៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី

-**បានឃើញ** អនុក្រឹត្យលេខ ចុះថ្ងៃទី០២-០២-២០១៦ របស់រាជរដ្ឋាភិបាលកម្ពុជា

-**បានឃើញ** សំបុត្រមរណភាព លេខ..... ចុះថ្ងៃទី..... របស់សាលាសង្កាត់....... បញ្ជាក់អំពីមរណភាព ឈ្មោះ

-**បានឃើញ** លិខិតមតកសាសន៍ លេខ០១៨/១៩ ចុះថ្ងៃទី២២-០២-២០១៩ របស់ **មន្ទីរសារការី**

-**បានឃើញ** ពាក្យសុំ ចុះថ្ងៃទី២៦-១១-២០២០ របស់ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ ស្នើសុំរូបមន្តអនុវត្តលិខិតមតកសាសន៍ លេខ០១៨/១៩ ចុះថ្ងៃទី២២-០២-២០១៩ របស់ **មន្ទីរសារការី**

**សូមបញ្ជាក់អំពីខ្លឹមសារនៃការអនុវត្តដូចខាងក្រោម ៖**

**ម្ចាស់បំណុលនៃការអនុវត្ត** ឈ្មោះ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ១៦៩ ផ្លូវម៉ៅសេទុង ភូមិ៥ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**អាចអនុវត្តដោយបង្ខំ** តាមលិខិតមតកសាសន៍ លេខ០១៨/១៩ ចុះថ្ងៃទី២២-០២-២០១៩ របស់ **មន្ទីរសារការី** ។

ពី **កូនបំណុលនៃការអនុវត្ត** ឈ្មោះ

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ត្រាស់បង្គាប់មកស្ថាប័នអនុវត្តដោយបង្ខំ ឱ្យអនុវត្តតាមលិខិតអនុវត្តនេះ និងឱ្យអាជ្ញាធរសាធារណៈជួយអនុវត្តឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។**

ថ្ងៃសុក្រ ៤រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ពុទ្ធស័ករាជ ២៥៦៤
ត្រូវនឹងថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០
**មន្ទីរសារការី**

**សារការី បណ្ឌិត**